


# ស្រលាញ់ខ្មែរ

សួស្តី

បើប្អូនៗគាំទ្រនិងស្រលាញ់*ស្រលាញ់ខ្មែរ*

សូមកុំយករឿងទៅផុសនៅកន្លែងផ្សេងៗ

បើមានមិត្តភ័ក្រ្តចង់បានអាចប្រាប់ពួកគេ

ChatមកLovekhmerពួកយើងនឹងផ្តល់អោយៗ

អរគុណ

Lovekhmer_Teams

www.SrolanhKhmer.com

www.srolanhkhmer.com

## ១
## ជីវិតតួឯកស្រីរបស់ ស្លឹកតើយ

"ស្អីគេ ម៉ាក់និយាយថាម៉េច?"

សំឡេងក្តែងៗនោះធ្វើឲ្យម៉ាក់របស់ខ្ញុំ ឬអ្នកស្រី ឈើរី សម្លក់សម្លឹងខ្ញុំ ដែលសុខៗក៏ទម្លាក់សមស្លាបព្រាលើតុលាន់ក្រេង និងស្រែកសួរគាត់ខ្លាំងៗ ។

"ស្លឹកតើយ! ធ្វើឫកឲ្យវាសមរម្យ ឲ្យវាសុភាពរៀបរយគួរឲ្យស្រឡាញ់ សមជាបវរកញ្ញាមហាវិទ្យាល័យ កូនស្រីអតីតបវរកញ្ញាមហាវិទ្យាល័យកាលពីជាង៣០ឆ្នាំមុន និងជាប្អូនស្រីរបស់អតីតបវរកញ្ញាមហាវិទ្យាល័យកាលពី៤ឆ្នាំមុនបន្តិចទៅ"

"ម៉ាក់ ខ្ញុំរៀនចប់ហើយ ជិតធ្វើការហើយ មិនមែនបវរកញ្ញាមហាវិទ្យាល័យ ឬចក្រវាលស្អីទេ"

ខ្ញុំប្រាប់ហើយក៏ដកដង្ហើមចូលឲ្យជ្រៅៗ មើលមុខដែលនៅតែរក្សាសម្រស់បានស្អាត ទាំងដែលអាយុរបស់ម៉ាក់៤០ជាងទៅហើយ ។ ការពិតទៅគាត់មិនបានញុំាបន្លែ ហាត់ប្រាណ ឬលេងយ៉ូហ្គាដេកផ្កាប់មុខស្អីនោះទេ ផ្ទុយទៅវិញ ម៉ាក់របស់ខ្ញុំស្អប់ការញុំាបន្លែគ្រប់ប្រភេទ មិនចូលចិត្តហាត់ប្រាណ ចាស់ដល់ថ្នាក់លុតជំមិនកើតទៅហើយ និងចូលចិត្តទៅចូលរួមកម្មវិធីសង្គមរាល់យប់ គ្រាន់តែថាម៉ាក់ចូលចិត្តទៅមន្ទីរពេទ្យជាប្រចាំ ហើយមន្ទីរពេទ្យដែលគាត់ចូលចិត្តទៅគឺកែសម្ផស្ស ដូច្នេះហើយទើបស្បែកមុខរបស់ម៉ាក់តឹងផ្ទឹះ ស្បែកសដូចពងមាន់បក និងបបូរមាត់ក្រមប់ពណ៌ផ្កាឈូកហាក់ដូចស្រីវ័យជំទង់ ច្រមុះស្រួចរលែម ចង្កាក៏ធ្វើតាមសម័យនិយមដោយពេទ្យថ្មីដែលល្អ ។

"ហើយខ្ញុំក៏ធំលើសពីការរៀបការដោយការចាប់ផ្ដើមនោះដែរ"

ខ្ញុំសង្កត់សំឡេង មែន ចាប់ផ្ដឹម!

"និយាយស្អី ចាប់ផ្ដឹមស្អី ម៉ាក់គ្រាន់តែចង់ឲ្យឯងរៀបការជាមួយកូនប្រុសមិត្តភក្តិ មិនមែនចាប់ផ្ដឹមអីបន្តិចទេ"

"ហ្នឹងហើយ ចាប់ផ្ដឹមច្បាស់ណាស់ ម៉ាក់...ខ្ញុំអាយុ២១ឆ្នាំ ទើបតែរៀនចប់ នៅមិនទាន់បានធ្វើការផង ជីវិតរបស់ខ្ញុំត្រូវជួបនឹងរឿងច្រើនគរគោកទៀត ហើយសំខាន់ ខ្ញុំគ្មានថ្ងៃរៀបការជាមួយមនុស្សប្រុសដែលខ្ញុំមិនបានស្រឡាញ់នោះទេ" ខ្ញុំរៀបរាប់យ៉ាងវែងអន្លាយ ។

"តែគេជាមនុស្សល្អ ផ្ទួហ្វាល់កាលីប មុខសង្ហា ហើយក៏...ស្រឡាញ់សត្វស្រឡាញ់ធម្មជាតិ ហើយមុខមាត់ក៏អូប៉ាណាស់ដែរ"

"ម៉ាក់..." ខ្ញុំបង្អូសសំឡេង គិតនៅក្នុងចិត្តថាត្រូវតែលួចយករឿងភាគកូរ៉េទាំងអស់ដែលម៉ាក់ចូលចិត្តមើលទៅបោះចោលមែនទែនហើយ ។

"ខ្ញុំនិយាយមែន"

"..."

ម៉ាក់ឈប់ញញឹម ហើយដកដង្ហើមធំ ចិញ្ចើមគាត់ក៏ជ្រួញជាប់គ្នា មុននឹងលូកដៃយកកែវទឹកមកក្រេប និងធ្វើភ្នែកឡេមឡាម ។

"ម៉ាក់ជំពាក់បំណុលម៉ាក់របស់គេ ហើយគេនឹងប្ដឹងយើង ក្រៅពីឯងរៀបការជាមួយកូនប្រុសគេ"

"ម៉ាក់!" លើកនេះខ្ញុំស្រែកខ្លាំងជាងមុនទៅទៀត ដំបូងវាគឺជាការចាប់ផ្ដឹម តែពេលនេះវាជាមង្គលការដោះបំណុលច្បាស់ណាស់ ខ្ញុំគួរតែទៅពិនិត្យក់ប៉េះគូទនៅមុខកញ្ចក់ហើយមែនទេ ក្រែងលោមានឆ្នូតរូបបេះដូងជាប់នៅត្រង់នោះ ហេតុអីក៏ជីវិតរបស់ខ្ញុំដូចកុនល្ខោនអីយ៉ាងនេះ!



"ម៉ាក់និយាយលេងមែនទេ?"

"និយាយមែន"

ខ្ញុំចំហមាត់ឆ្ពង នេះជារឿងស្អីទៅ ថ្ងៃនេះម៉ាក់ហៅខ្ញុំពីខុនដូដែលគាត់ទិញឲ្យកាលរៀនមហាវិទ្យាល័យ ដើម្បីងាយស្រួលក្នុងការធ្វើដំណើរ ។ ផ្ទះរបស់ខ្ញុំមិនមែនជាអ្នកមានអីនោះទេ ប៉ាខែកហានយូរហើយ ទុកលុយបានាក៉ាប់រងមួយចំនួនឲ្យ និងផ្ទះដីស្អិមស្មៃនៅលើដីធំទូលាយនៅតំបន់ដែលអ្នកមានរស់នៅ ។

បងស្រីរបស់ខ្ញុំ ផ្កាឈូក រៀបការទៅនៅបរទេសជាមួយស្វាមីជនជាតិអាល្លឺម៉ង់ នៅសល់តែខ្ញុំនិងម៉ាក់ដែលរស់នៅកូរ៉េ ។ រយៈពេល៤ឆ្នាំដែលរៀននៅមហាវិទ្យាល័យ ខ្ញុំមិនធ្លាប់មានបញ្ហារឿងប្រាក់កាស ព្រោះម៉ាក់វេរប្រាក់ឲ្យរាល់ខែ គឺប្រាក់ធានារ៉ាប់រងរបស់ប៉ាដែលមានក្នុងធនាគារនោះឯង ។ រហូតដល់កាលពីពីរឆ្នាំមុន ម៉ាក់របស់ខ្ញុំដែលស្រឡាញ់សម្រស់ ស្រឡាញ់សោភ័ណភាពជាងអាជីព គាត់ក៏ចូលមន្ទីរពេទ្យកែសម្ផស្ស ដើម្បីរក្សានិងអភិវឌ្ឍសម្រស់របស់គាត់តាមការនិយម ខ្ញុំមិនហាម ព្រោះនោះជាសេចក្ដីសុខរបស់ម៉ាក់ តែ...ម៉ាក់ទៅជំពាក់បំណុលអ្នកណានៅពេលណាខ្ញុំមិនដឹងពិតមែន ។

"ម៉ាក់ខ្ចីប្រាក់ពីអ្នកណាទៅវះកាត់ឬ?"

"មិនមែនទេ!"

អ្នកស្រី ឈើរី សម្លក់សម្លឹងខ្ញុំ ។

"ចុះបំណុលដែលថានេះវាមកពីណា?"

"..."

លើកនេះអ្នកនៅចំពោះមុខស្ងាត់មួយដង្ហើម មុននឹងតបខ្លីៗ៖

"ហ៊ុន"

"ហ៊ុន?"

"មែន...ជួនអីម៉ាក់លេងហ៊ុន គឺ...លេងបីឆ្នាំហើយ តាំងពីឯង

រៀនមិនទាន់ចប់ ពេលនេះហ៊ុនក៏ស្រុតចុះ...លុយទាំងអស់ក្នុងបញ្ជីដែលមានក៏អស់តាមដែរ ទើបម៉ាក់ទៅខ្ចីលុយគេមកចាយវាយ និងបង់ថ្លៃសាលាឲ្យឯង និងប្រើចាយវាយក្នុងផ្ទះដែរ"

"!!"

ខ្ញុំបើកភ្នែកធំៗ ចុះហេតុអីក៏ខ្ញុំមិនធ្លាប់ដឹងរឿងនេះ ផ្ទះយើងឡុងចុងព្រោះហ៊ុនអស់ប្រាក់ ម៉ាក់ខ្ចីបំណុលគេ អូ...ងាប់ហើយខ្ញុំ!

"ម៉ាក់មិនបានឆខ្ញុំលេងទេដឹង នេះមិនមែនជាថ្ងៃ April fool day"

"ម៉ាក់មិនបានឆ មិនជឿអញ្ជើញមើលកិច្ចសន្យានេះ"

ម៉ាក់របស់ខ្ញុំបើកកាបូបឯកសារដែលដាក់នៅក្បែរខ្លួន (តាំងពីអង្កាល់!!) ហើយយកក្រដាសពណ៌ត្នោតខ្ចីមកហុចឲ្យ ។

ខ្ញុំហែសយកមកអាន អានទាល់តែអស់តួអក្សរ ហើយក៏មានអារម្មណ៍ថាបេះដូងលោតកាន់តែញាប់ ។ ខ្ញុំមើលឈ្មោះម្ចាស់បំណុល...លី ធីហ្វានី ឈ្មោះប្រហែលៗ តែនោះមិនមែនជាអ្វីដែលខ្ញុំផ្ចង់អារម្មណ៍បំផុត ខ្ញុំសម្លឹងមើលតួលេខ លេខ 1...និងលេខ 0 មានប៉ុន្មានតួ? មួយ ពីរ បី បួន...អឹម...ប្រាំ ប្រាំមួយ ប្រាំពីរ...ប្រាំបី លេខ 0 ប្រាំបីខ្ទង់!

"ម៉ាក់...100លានឬម៉ាក់?"

នេះជាសំឡេងរបស់ខ្ញុំ តែសឹងតែចាំមិនបាន ព្រោះបាភទាំង ស្លុកទាំងញ័រ ។

"អឹម...ហ្នឹងឯង តួលេខអារ៉ាប់នេះហើយ ហត្ថលេខាម៉ាក់" ខ្ញុំមើលមុខដ៏ស្រស់ស្អាតក្មេងជាងវ័យរបស់ម៉ាក់ មុននឹងដកដង្ហើមចូលឲ្យជ្រៅៗ ហើយសួរម្តងទៀត ។

ព្យាយាមមិនឲ្យខ្លួនឯងនិយាយខ្លាំងៗដល់ថ្នាក់ជាការគំហក ព្រោះយ៉ាងណាក៏ខ្ញុំស្រឡាញ់ម៉ាក់ខ្លាំង ទោះពេលនេះចង់គាំង

ខ្លួនជាលោកយាយ ហើយចាប់ម៉ាក់វាយកំប៉េះគូទក៏ដោយ ។

"លុយឡើងគរគោក អាចឲ្យមនុស្ស១០នាក់រៀនចប់មហាវិទ្យាល័យបាន ម៉ាក់ខ្ចីគេធ្វើអីច្រើនដល់ម្លឹង"

"គឺបងថ្លៃឯងហ្នឹង មុខជំនួញនៅអាល្លឺម៉ង់មានបញ្ហា ទើបម៉ាក់ផ្ញើលុយទៅជួយ"

"ប៉ុន្មាន?" ខ្ញុំសួរដោយសំឡេងស្រាលស្ងើក ។

"៥០លាន" ម៉ាក់ក៏តបដោយសំឡេងស្រាលស្ងើកដូចគ្នា ។

"ចុះ...បងស្រីថាម៉េច រឿងបំណុលនោះ?"

"គេមិនទាន់សងទេ ហើយការកំណត់ភតិ..."

មែន ពេលម៉ាក់និយាយដល់ត្រង់នេះ ខ្ញុំក៏សម្លឹងរកមើលសេចក្តីលម្អិតភ្លាម ហើយក៏ចំហមាត់ធ្លុងនិងស្រែកខ្លាំងៗជាងមុនទៅទៀត ។

"ស្អែក!"

ទន់ជង្គង់ សំណាងល្អដែលអង្គុយលើកៅអី ហើយហាក់ដូចពុទ្ធោ ស្រីបម្រើដែលជួលឲ្យមកធ្វើការផ្ទះនិងនៅកំដរម៉ាក់ដឹងតួនាទីល្អ រត់ទៅយកប្រេងខ្យល់មកហុចឲ្យតាំងពីពេលណាក៏មិនដឹង ខ្ញុំក៏យកមកហិតចូលឲ្យពេញសួត បេះដូងលោតញាប់ដោយសារបំណុលមហាសាលដែលទើបតែដឹងថាមាន ។

"១០០លាន...ខ្ញុំទៅយកមកពីណាសងគេនេះ"

ចង់យំក៏យំមិនចេញ មានអារម្មណ៍ដល់ភាពជាតួឯកស្រីក្នុង រឿងកុន ទើបតែដឹងថាជីវិតពិតវាសាហាវជាងប្រលោមលោកទៅ ទៀត ។

"គឺមិនបាច់សងហ្នឹងអី គឺគ្រាន់តែឯងរៀបការជាមួយកូនប្រុ មីង ធីហ្វានី មិត្តម៉ាក់ គេក៏លុបចោលបំណុលយើងទៅហើយ"

ម៉ាក់និយាយដោយទឹកមុខស្រស់ស្រាយ ។

"ម៉ាក់..."

"កូនប្រុសគេមុខមាត់សង្ហា ស្រីៗចោមរោម ជា..."

ខ្ញុំលើកដៃហាមម៉ាក់ ពេលនេះខួរក្បាលវិលខ្លាំង ថែមទាំងមានសំឡេងដីងៗនៅក្នុងត្រចៀក មិនទាន់ចង់ស្តាប់គុណសម្បត្តិរបស់កូនប្រុសម្ចាស់បំណុលរបស់ម៉ាក់ ។

"សុខទៅរៀបការ ?" ម៉ាក់សួរដោយមានសង្ឃឹម ។

"មិនរៀប ម៉ាក់តេទៅប្រាប់បងស្រីឲ្យលែងលះប្តី ហើយត្រឡប់មកកូរើញរៀបការជំនួសខ្ញុំទៅ"

"ហ៎...ឯងនិយាយមែនក៏អី!"

ក្លាមខ្មៅ ស្រែកសួរខ្លាំងៗ ព្រមទាំងដាក់ទូរសព្ទដៃដែលទើបតែយកមកថតរូបអែស៍គ្រីមនៅលើតុចប់ មើលមុខខ្ញុំដោយការភ្ញាក់ផ្អើល ចំណែកខ្ញុំក៏ងក់ក្បាលដោយទឹកមុខនឿយណាយ ។

បន្ទាប់ពីនិយាយជាមួយម៉ាក់ហើយ ខ្ញុំក៏ដាក់មេធាយចេញពីផ្ទះ មុនពេលម៉ាក់ចាប់ទាន់ ។ ខ្ញុំបើកឡានសំណព្វចិត្តចេញមក ហើយតេរកមិត្តជិតស្និទ្ធនៅក្នុងក្រុម ណាត់ជួបគ្នានៅហាងការ៉េមល្បីឈ្មោះក្នុងហាងទំនិញ ដើម្បីរិះរកផ្លូវចេញពីការដែលត្រូវមានប្តីបែបមិនទាន់បានត្រៀមខ្លួន ។

"មែន"

ក្លាមខ្មៅ កូនស្រីម្ចាស់ហាងលក់មាសធំនៅតំបន់ X ធ្វើមុខដូចត្រូវខ្មោចលង ចំណែកស្រីតូចមុខគួរឲ្យស្រឡាញ់ម្នាក់ទៀតដែលអង្គុយបៀមអែស៍គ្រីមខេក ក៏ដកដង្ហើមធំ ។

"ខ្ញុំយល់ពីឯង ស្លឹកតើយ ប្រហែលជាស្លុត"

គ្រាប់ត្នោត មិត្តម្នាក់ទៀតនិយាយដោយក្តីអាណិត តែដៃនៅតែដួសការ៉េមដាក់មាត់ ។

"ដូចឯងអាណិតខ្ញុំមិនពិតអីចឹង គ្រាប់ត្នោត នៅតែញ៉ាំបន្តបានទៀត"

"អា៎...គឺខ្ញុំឃ្លានហ្នឹងណា៎ នេះម៉ោងពីររសៀលទៅហើយ មិនទាន់បានអីចូលពោះតាំងពីព្រឹក"

"ចុះម៉ាក់ឯងថាយ៉ាងម៉េច ដែលឯងប្រាប់ឲ្យបងស្រីលែងប្តីហើយមកការជំនួស ?"

ក្លាមខ្មៅ សួរបន្ត ខ្ញុំក៏ធ្វើភ្នែកឡេមឡាម គឺលើរត់ចេញមកមិនទាន់ មានសង្ឃឹមថានឹងត្រូវវាយជាលើកដំបូងនៅក្នុងជីវិត ហើយ... ខ្ញុំក៏គ្មានចេតនាដូចដែលនិយាយដែរ អ្នកណាទៅឲ្យបងស្រីលែងលះស្វាមីដែលមានកូនក្មេងវ័យគួរឲ្យស្រឡាញ់ ហើយមករៀបការដោះបំណុលទៅ ។ តែបើថាទៅ វាអត់មិនបានដែលបងស្រីបានឡុយឆាយនៅបរទេស ហើយបណ្តោយឲ្យកម្មធ្លាក់មកលើខ្ញុំ ត្រូវរៀបការដោះបំណុលជំនួសម៉ាក់ ទាំងដែលប្រាក់អស់នោះយកបានតែពាក់កណ្តាល ។

"គឺស្រែក!"

"ម៉ាក់ឯងស្រែក មិនខ្លាចមុខតឹងនោះទៅជាជ្រីវជ្រួញទេឬ ?"

មិត្តភក្តិសួរ ព្រោះដឹងច្បាស់ពីរឿងឆ្កួតសម្រស់ ឆ្កួតស្អាតរបស់ម៉ាក់ខ្ញុំ ។

ពួកយើងសេពគប់គ្នាតាំងពីរៀនថ្នាក់មធ្យមម្លេះ ហើយក៏ប្រឡងចូលជាប់មហាវិទ្យាល័យតែមួយទៀត មានភាពស្និទ្ធស្នាលដល់ថ្នាក់ដឹងរាក់ដឹងជ្រៅរបស់គ្នាច្បាស់ ច្បាស់ដល់ថ្នាក់ដែលដឹងថាខ្ញុំជាពពែខ្មៅប្រចាំផ្ទះ...ម៉ាក់និងបងស្រីដែលស្រឡាញ់សម្រស់ស្រឡាញ់ស្អាត ចូលចិត្តទៅស្ប៉ាមើលថែខ្លួនឯង ខណៈដែលខ្ញុំចូលចិត្តបោះជំរំតាមព្រៃតាមផ្សៃជាមួយសាលា ហើយក៏រត់ទាត់បាល់នៅតារាងបាល់ជាមួយសិស្សប្អូន ដែលមានបាល់ទាត់ស្រី

ថែមទាំងមានកម្លាំងខ្លាំង អាចដើរទៅដាល់មាត់មនុស្សប្រុសផ្នែកវិស្វកម្មដែលចូលចិត្តបង្អាប់ទៀតផង ។

"ចុះឯងគិតយ៉ាងម៉េច ស្លឹកតើយ បំណុលដល់ទៅ១០០លាន?" គ្រាប់ត្នោត សួរ ។

"ឯងទាំងពីរមានឲ្យខ្ចីដែរទេ?" ខ្ញុំចេះតែសួរវាទៅ ហើយក៏បានការសម្លក់សម្លឹងមកវិញ ទើបញាក់ស្មា ។

បើរក៥-៦សែន ប្រហែលជាខ្ចីពីស្រីពីរនាក់នេះបាន តែដុំចាលុយច្រើនដល់ម្លឹង ទោះមិត្តភក្តិព្រមទៅសុំអ្នកផ្ទះឲ្យខ្ចី ក៏ខ្ញុំមិនហ៊ានយកដែរ ។

"ខ្ញុំក៏មិនដឹងថាធ្វើយ៉ាងណាដែរ ឲ្យរៀបការដោះបំណុល...វាបុរាណពេកហើយ ហើយអនាគតស្វាមីរបស់ខ្ញុំជាអ្នកណាក៏មិនទាន់ដឹង"

"អាំ" មិត្តភក្តិទាំងពីរធ្វើភ្នែកឡេមឡាម ។

"ហើយឯងគិតយ៉ាងម៉េច?"

"ប្រហែលជាប្រឹងត្រដរសិន លក់ឡាន លក់ខុនដូ ហើយយកប្រាក់ទៅដោះបំណុល ប្រហែលជាបានមិនដល់មួយចំណែក ខ្វល់ចិត្តដល់ហើយ"

ទោះជាលក់ទ្រព្យសម្បត្តិគ្រប់យ៉ាង ក៏ខ្ញុំគ្មានលទ្ធភាពរកប្រាក់ច្រើនដល់ថ្នាក់នោះទៅសងគេដែរ ហើយធ្វើយ៉ាងម៉េចទៅ? ឬថាបណ្តោយឲ្យគេប្តឹងរឹបអូសគ្រប់យ៉ាង ហើយនាំអ្នកស្រី ឈើរី មេបញ្ហាមកនៅខុនដូជាមួយ?

ខ្ញុំទើបតែរៀនចប់ ការងារក៏រកមិនទាន់បានធ្វើ តែប្រាក់សន្សំអាចមានខ្លះ បើរកការងារធ្វើបានគួរតែមានប្រាក់ចិញ្ចឹមម៉ាក់ម្នាក់បាន ។

"ចុះម្ចាស់បំណុល ម៉ាក់របស់ប្រុសម្នាក់នោះឈ្មោះអី?"

ភ្លាមខ្មៅ សួរ ។

"..." ខ្ញុំគិតមុននឹងតប "ឈ្មោះ លី ធីហ្វានី"

មិត្តភក្តិងក់ក្បាលផ្ទួនៗ មុននឹងជ្រួញចិញ្ចើម ។

"ចាំទៅរកទិន្នន័យរបស់គេឲ្យ"

"អឺម"

អង្គុយនិយាយគ្នាបន្តមួយស្លែតទៀត ខ្ញុំក៏លាមិត្តភក្តិហើយបើកឡានទៅខុនដូ ចិត្តក្រៀមស្រពោនដល់ថ្នាក់មិនអាចនិយាយលេង អង្គុយលេង ឬឲ្យមិត្តភក្តិជួយរកវិធីដោះស្រាយបាន ។

ពេលនេះរឿងតែមួយគត់ដែលខ្ញុំត្រូវការបំផុតគឺងូតទឹកក្តៅឧណ្ហៗ រកថ្នាំចាក់មួយគ្រាប់ពីរលេបហើយឡើងគ្រែដេក ។

ជិតពីរម៉ោងទម្រាំតែបើកឡានមកដល់ខុនដូ ខ្ញុំទាំងហត់នឿយទាំងឈឺក្បាល លូកហោប៉ៅយកឃីយ៍កាតហើយក៏បើកទ្វារចូលបន្ទប់ដែលដាក់វិលផេបពើរ៍ពណ៌ផ្ទៃមេឃស្រស់ ដោះស្បែកជើងទុក ដាក់កាបូបលើតុពណ៌ស មុននឹងដើរអូសសង្ខារទៅបន្ទប់ដេក ដែលមានបន្ទប់ទឹកនៅខាងក្នុង ។

ខុនដូនេះអ្នកស្រី ឈើរី ម៉ាក់របស់ខ្ញុំទិញឲ្យតាំងពីនៅរៀន អត់គិតមិនបានថានេះគឺយកលុយបំណុលមកទិញដែរ បើដឹង...ខ្ញុំសុខចិត្តជួលបន្ទប់តូចចង្អៀតនៅជាមួយមិត្តភក្តិពីរនាក់ល្អជាង ។

ខ្ញុំដើរចូលបន្ទប់ដោយមិនទាន់បានមើលជុំវិញខ្លួន ដោះរ៉ូបសាច់ឃឹតដែលមានសម្រុងដល់ក្បាលជង្គង់ចេញតាមក្បាល បោះចូលកន្ត្រកទុកសម្រាប់បោក ហើយក៏យកឥង្កៀបធំមកចងសក់អង្កាដីពណ៌ត្នោតវែងប៉ប្រះស្មាឲ្យមានរបៀប ។

ទឹកក្តៅឧណ្ហៗ...ពេលនេះខ្ញុំចង់ត្រាំតែទឹកក្តៅឧណ្ហៗប៉ុណ្ណោះ កំពុងតែលូកដៃប្រឡេះតម្លក់អាវក្នុងពីក្រោយ ពេលដែលទើបតែនឹកឃើញក៏ងាកទៅមើលគ្រែពណ៌ផ្ទៃមេឃរូបផ្ការបស់ខ្ញុំ ដែលរ

រញ៉េរញ៉ៃ និងមានភួយមួយគំនរនៅកណ្តាលគ្រែ ។

អេ់...កាលពីព្រឹកពេលទទួលទូរសព្ទពីម៉ាក់លើគ្រែដេក ចាំបានថាទោះបើកភ្នែកមិនទាន់ស្រឡះ តែក៏រត់ទៅងូតទឹក តែងខ្លួនទៅរកម៉ាក់នៅផ្ទះព្រោះពាក្យថា **អាសន្នបន្ទាន់** ដែលម៉ាក់ប្រាប់ ខ្ញុំថា...ខ្ញុំរៀបចំគ្រែខ្នល់ខ្នើយរួចហើយ ។

"..."

ឬភ្លេច ? ខ្ញុំញាក់ស្មា ហើយដើរទៅទាញភួយដើម្បីបត់ ប៉ុន្តែអ្វីដែលនៅលើគ្រែ វាមិនមែនមានតែខ្នើយឱបនិងតុក្កតានោះទេ តែនៅមានមនុស្សប្រុសម្នាក់ទៀតដែរ ។

"អាំយយយ!"

[Intouch`s Talk]

ខ្ញុំភ្ញាក់ពីដំណេកថ្ងៃត្រង់ មុននឹងប្រត់កែងដៃនឹងពូក យកបាតដៃទ្រក្បាល...សំឡេងស្រែកស្រួចរលែមរបស់មនុស្សស្រីដែលឈរបើកភ្នែកធំៗដូចមនុស្សឡប់សតិ មិនបានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល គឺអាចដៅបានស្រាប់ទៅហើយថានាងច្បាស់ជាស្រែក បើបើកទ្វារបន្ទប់ដេកមកឃើញមនុស្សប្លែកមុខនៅលើគ្រែ ថែមជាមនុស្សប្លែកមុខដែលសង្ហាបំផុត និងស្លៀកតែខោបុកស័រដូចជាខ្ញុំពេលនេះ ។

តែដែលមិនបានគិតទុកជាមុននោះ គឺម្ចាស់សំឡេងស្រែកនោះនៅក្នុងឈុតក្នុងពណ៌ផ្ទៃមេឃ មានតែស្លែងលើនិងស្លែងក្រោមប៉ុណ្ណោះ ។

"..."

ខ្ញុំចំហមាត់ ព្រឹមភ្នែកមើលដើមទ្រូងទំហំ៣៤ដែលគ្មានផ្លូវដៅខុស ក្តោបដោយសាច់កំណាត់ពណ៌ផ្ទៃមេឃ ហើយក៏អត់មិនបាននឹងថ្ងូចថ្ងូរ ។

"អឹហ៊ុ...សម្លេះ"

"ឯង...ឯងជាអ្នកណា ? ចោរ ពួកទុច្ចរិត មនុស្សឆ្កួតកាម អាំយយយ!"

អ្នកដែលភ្លេចទៅហើយថាខ្លួនឯងកំពុងតែស៊ិចស៊ីចង្រុលមុខខ្ញុំ ដែលថាភ្លេចនោះ ព្រោះនាងតន្ត្រំជើងអមដោយពាក្យសម្តី ធ្វើឲ្យជុំសាវលាយពណ៌ផ្កាឈូកនោះករញ្ជ្រាលគួរឲ្យចង់បឺត អឹម!...គួរឲ្យចង់មើល ។

"ស្រែកធ្វើអី មកវិញហើយឬ ល្អហើយអីចឹង ព្រោះឃ្លានល្មមធ្វើអីឲ្យញ៉ាំបន្តិច"

ខ្ញុំប្រាប់ ទាំងដែលពេលនេះអ្វីដែលចង់ញ៉ាំមិនមែនអាហារ តែជាដោះគោ អឹម! ជាស្រីនៅចំពោះមុខ ។

ខ្ញុំងើបអង្គុយ ហើយលើកដៃច្រងងសក់ មុននឹងពត់ខ្លួនពត់ប្រាណ ហើយចុះពីគ្រែ ។

ម្ចាស់រូបរាងសមសួនជាងពីស្រីបង្ហាញម៉ូដ ឬតារាថតឈុតហែលទឹកថយក្រោយក្រាក ភ្នែកក៏សម្លក់ខ្ញុំថ្មែដោយការភ័យខ្លាច និងភ្ញាក់ផ្អើល ប៉ុន្តែ...នាងភ្លេចសភាពខ្លួនឯងដែលថាស៊ិចស៊ីប៉ុណ្ណា ។

"ចេញពីបន្ទប់ខ្ញុំ មិនអីចឹងខ្ញុំនឹងប្តឹងប៉ូលិស"

"អ្នកណាទៅហាម ខ្ញុំចាំនាងឡើងយូរ ជូនអីយប់មិញដេកតិចពេក ងងុយទើបចូលមកដេកចាំ"

"ចេញភ្លាម!"

នាងហាមាត់ដេញភ្លែងៗ បបូរមាត់ក្រមប់កំញ័រ ។

"មិនចេញ"

"ឯងជាអ្នកណា ? ចេញទៅ!"

អ្នកដែលពាក់តែឈុតក្នុង នាងមិនសូម្បីតែលើកដៃបិទបាំង

ភាពទ្រលុកទ្រលន់នៅល្វែងលើ ឬសូម្បីតែ...ខ្ញុំដេញខ្សែភ្នែកតាំងពីដើមទ្រូងស ចុះមកពោះរាបស្មើនិងរន្ធផ្ចិត មុននឹងបញ្ឈប់ខ្សែភ្នែកត្រឹមសាច់កំណាត់បីជ្រុងពណ៌ផ្ទៃមេឃ តុបតែងដោយបូតូចៗដែលរាងទុលបន្តិច...ជួយមិនបានទេដែលវាធ្វើឲ្យខ្ញុំខះក ហើយក៏ចង់ដឹងថាបើខ្ញុំឱនទៅថើបត្រង់នោះ វានឹង...

"វ៉ាយយយ!"

អ្នកដែលសម្លក់ខ្ញុំថ្មៃឱនមើលតាមខ្សែភ្នែករបស់ខ្ញុំ ដឹងខ្លួនថាខ្លួនឯងឈរស្រាតគួរឲ្យចង់ស៊ី វាទាក់ទាញកិលេសតណ្ហាខ្ញុំប៉ុណ្ណា នាងរត់ទៅស្រវាយកភួយដែលធ្លាក់នៅក្បែរគ្រែមកបិទបាំងរាងកាយរបស់ខ្លួនឯងដោយការភ័យខ្លាច និងញាប់ញ័រខ្លួនទទ្រើត មុខស្រស់ស្អាតដែលមានដីក្រេដាបវរកញ្ញាមហាវិទ្យាល័យល្បី និងជា Drum Meyer របស់កីឡាបាល់រាងមហាវិទ្យាល័យចំណាស់ដែលរៀបចំឡើងរាល់ឆ្នាំតាមទិន្នន័យដែលខ្ញុំដឹងនៅពេលនេះ ម្ដងក្រហមម្ដងបៃតងដូចកាទូនបេះបិទ ។

"ឯង! ចេញទៅ មិនអីចឹងខ្ញុំនឹងហៅប៉ូលិសឲ្យមកចាប់"

និយាយហើយរាងតូចប្រឡឹងក៏ស្ទុះទៅស្រវាយកទូរសព្ទលើតុចុចលេខញាប់ដៃស្មេក ។

"អញ្ចើញ"

ខ្ញុំញញឹម និងជ្រិមភ្នែកមើលស្រីស្អាតសំឡេងល្អដែលគិតតែស្រែកព្រៃតៗមិនឈប់ ទម្លាក់ខ្លួនអង្គុយលើគ្រែ ហើយកន្ទែកជើងដោយមានចេតនា ។ ជឿជាក់ថាអាកូនប្រុសដែល ត្ងាត់ ស្វាងចែសហើយនោះ កំពុងតែសាងការភ័យខ្លាចឲ្យមនុស្សស្រីលស់ព្រលឹងនៅចំពោះមុខបានខ្លាំងប៉ុណ្ណា នេះថ្នាក់នៅមានខោបុកស័របិទបាំងផង ។

"គេហៅម៉ោ ឲ្យវាដឹងទៅថានាងប្តឹងប៉ូលិសចាប់អនាគតប្តី!"

ស្លីកតើយ អនាគតកូនក្រមុំរបស់ខ្ញុំងាកមកបើកភ្នែកធំៗមើលខ្ញុំ ដៃដែលចាប់ទូរសព្ទនោះក៏ទម្លាក់ចុះ ហាក់ដូចប្រយោគដែលនិយាយនោះធ្វើឲ្យនាងស្រឡាំងកាំង បបូរមាត់ស៊ិចស៊ីនោះចំហហើយបិទ បិទហើយចំហ ដូចត្រីដរ៉ា ។

"អនាគតប្តី?"

"មែន"

"ប្តីខ្ញុំ?"

"ប្តីនាងហ្នឹងហើយ"

ខ្ញុំសប្បាយដែលបានឃើញទឹកមុខមានអារម្មណ៍ជាច្រើនរបស់នាងក្រមុំ ដែលមានភួយរុំខ្លួន ។

"មិនពិត ខ្ញុំមិនទាន់..."

"ខ្ញុំឈ្មោះ អ៊ីនថាច់...លី អ៊ីនថាច់ ឈ្មោះនេះធ្លាប់ឮដែរទេ?"

"លី អ៊ីនថាច់..."

អ្នកដែលខ្ទាំភួយជាប់នោះរំឭក មុននឹងបើប្រិចភ្នែក ហើយក៏ស្រែកខ្លាំងៗ ។

"លី ធីហ្វានី!"

"មែន នោះម៉ាក់ខ្ញុំ ពេលនេះដឹងហើយនៅថាខ្ញុំជាអនាគតប្តីរបស់នាងមែន ស្លីកតើយ"

ស្លីកតើយ មើលខ្ញុំដោយខ្សែភ្នែកស្រឡាំងកាំង និងដៅថាខួរក្បាលតូចរបស់នាងប្រហែលជាវិលខ្វាល់ក្នុងការប្រមូលទិន្នន័យថាវាកំពុងតែមានអ្វីកើតឡើង ហើយខ្ញុំជាអ្នកណា...តែនាទីបន្ទាប់មកមនុស្សស្រីដែលធ្វើឫកដូចខ្លាចខ្ញុំក៏ប្ដូរអាកប្បកិរិយា នាងពើងទ្រូងនិងខ្ចិបមាត់ មុននិងនិយាយដោយសំឡេងដូចគ្មានអ្វីកើតឡើង ។

"អំ...រីករាយដែលបានជួបលោកម្ចាស់បំណុល តាមពិតខ្ញុំកំពុងគិតថាទៅសុំជួបលោកល្មម ទាស់ត្រង់ថាមិនដឹងថាលោកនៅ

ឯណា យើងមានរឿងត្រូវនិយាយគ្នាច្រើន ខ្ញុំនឹងអរគុណច្រើនបើលោកចេញទៅចាំនៅខាងក្រៅឲ្យខ្ញុំតុបតែងខ្លួនសិន"

អឺម...ឆ្លាតគួរសម ព្យាយាមដោះស្រាយស្ថានការណ៍ចាញ់ប្រៀបបានល្អ ខ្ញុំមើលរូបភាពគួរឲ្យចាប់អារម្មណ៍នៅចំពោះមុខដោយពន្លឺភ្នែកផ្លេកៗ មុននឹងញាក់ស្មា ។

“ខ្ញុំមិនជាអីទេបើនាងតែងខ្លួនត្រង់នេះនៅចំពោះមុខខ្ញុំ ដើម្បីឲ្យខ្ញុំមើលទំនិញឲ្យដឹងថាវានៅក្នុងលំដាប់ណា សមាមាត្រនឹងតម្លៃឬក៏អត់" ខ្ញុំនិយាយហើយក៏ញញឹម ពេលឃើញ ស្លឹកតើយ ធ្វើមុខដូចមិនស្មានថានឹងបានឮពាក្យអាសអាភាសបែបនេះពីមាត់ខ្ញុំ ។

នាងក្រមុំដ៏ស្រស់ស្អាតនៅចំពោះមុខពេលនេះមានទឹកមុខស្លេកស្លាំង ខ្ញុំសឹងតែអស់សំណើចនៅក្នុងចិត្ត រង់ចាំមើលស្រីស្អាតនេះស្រែកម្តងទៀត ឬមិនអីចឹងក៏យំព្រោះតែពាក្យកំណាចរបស់ខ្ញុំ តែនាងបែរជាងក់ក្បាល ហើយញាក់ស្មា ថែមទាំងសើចញឹមៗទៀតផង ។

"មែនហ្នឹង ព្រមលុបបំណុលដល់ទៅ១០០លាន ដោះដូរនឹងការបានមនុស្សស្រីធ្វើជាប្រពន្ធ ជាអ្នកមានតែម្យ៉ាងធ្វើមិនបានទេលោក ត្រូវតែល្ងង់ដែរ"

"ស្លឹកតើយ"

ក្លាយជាខ្ញុំទៅវិញដែលខឹង ពេលលូកដៃទៅស្រវាចាប់ ស្រីសម្តីកំណាចនោះក៏លោតចូលបន្ទប់ទឹក ហើយបិទទ្វារលាន់ប៉ុង ខ្ញុំក៏តាមទៅគោះទ្វារបន្ទប់ទឹកខ្លាំងៗ គ្មានចេតនាទម្លុះចូលទៅ តែមានចេតនាគំរាមក្មេងស្រីមុខស្រស់ឲ្យខ្លាច ។

"ចេញពីបន្ទប់ខ្ញុំពេលនេះនៅមានពេល ព្រោះថាខ្ញុំនឹងហៅប៉ូលិសម៉ោ ចង់អាម៉ាស់មុខទូទាំងប្រទេសក៏ស្រេចតែចិត្ត!"

សំឡេងស្រែកមកពីខាងក្នុងបន្ទប់ទឹក ធ្វើឲ្យខ្ញុំសង្កៀតធ្មេញ ឃើញមានមុខស្រស់ស្រទន់បែបនេះ តែនាងប្រមក់ចោះសម្តីហ៎ មិនណយទេ ។

"មិនអីទេ អនាគតប្រពន្ធស្អាត ថ្ងៃនេះប្តីគ្រាន់តែតាំងចិត្តមកណែនាំខ្លួន តែក៏មិននឹកស្មានដូចគ្នាថានាងចិត្តល្អដល់ថ្នាក់ស្រាតឲ្យមើលទំនិញមុននឹងសម្រេចចិត្តទិញ ទោះមិនបានស្រាតទាំងអស់ តែអ្វីដែលឃើញនោះក៏គួរឲ្យចង់ស៊ី ស្អែកគ្រប់ការកំណត់តាមសន្យាហើយ ខ្ញុំនឹងទៅចាំនៅផ្ទះរបស់នាង ស្លឹកតើយ"

ខ្ញុំប្រាប់មុននឹងលូកដៃអង្អែលទ្វារញញឹមយ៉ាងកំណាច ហើយក៏ដើរទៅយកខោអាវរបស់ខ្លួនដែលដោះពាក់នឹងសាឡុង ពេលស្លៀកពាក់រួចរាល់ក៏ឈរមើលទ្វារបន្ទប់ទឹក ហើយហួចជាសំឡេងបទភ្លេងដែលចូលចិត្តចេញមក ។

ខ្ញុំចុះពីឡាន ព្រមទាំងបោះសោឲ្យអ្នកបម្រើយកទៅទុក ហើយក៏ដើរចូលភូមិគ្រឹះ ។ ក្រុមគ្រួសាររបស់ខ្ញុំធ្វើជំនួញអចលនទ្រព្យ ខ្ញុំជាកូនទោល គ្រាន់តែទ្រព្យសម្បត្តិក៏ធ្វើឲ្យស្រីៗអើតកតាមមើលខ្ញុំម៉ក់ៗទៅហើយ តែដូនអីខ្ញុំមានឈាមក្នុងខ្លួនពាក់កណ្តាលកាត់អាមេរិករបស់លោកតា( ខាងប៉ា ) ហើយវាក៏ធ្វើឲ្យខ្ញុំមានទម្រង់មុខបែបកូនកាត់ ច្រមុះស្រួច បបូរមាត់ពណ៌ផ្កាឈូក និងមុខសង្ហាអានេះខ្ញុំមិនបានលង់ខ្លួនឯងទេ វាគឺជាការពិត ។

"យ៉ាងម៉េចដែរ អីនចាច់ ជួបនាងដែរទេ ?"

សំឡេងរបស់ម៉ាក់បន្លឺឡើងសឹងតែភ្លាមៗពេលដែលខ្ញុំដើរចូលភូមិគ្រឹះ គាត់នៅតែស្អាតនៅតែក្មេង នៅក្នុងឈុតប្រ៊ែនដ៍នេមទាំងដែលអាយុជិត៥០ទៅហើយ ។

"ជួបហើយម៉ាក់"

"ហើយយ៉ាងម៉េចដែរ នាងថាម៉េច នាងមានត្អាក់ផ្អើលទេ

ដែលឯងទៅចាំនៅខុនដូ ?"

ម៉ាក់របស់ខ្ញុំ លី ធីហ្វានី អ្នកជំនួញមេម៉ាយស្រស់ស្អាតមានទឹកមុខរំភើបញាប់ញ័រ ។

"គឺ..." សម្រាប់ខ្ញុំជាងពីភ្ញាក់ផ្អើលទៅទៀត រូបភាពដើមទ្រូងមូលក្លំពណ៌សព្រលាំផ្កាឈូក មានសាច់កំណាត់ពណ៌ផ្លែមេយឱបក្រសោបពាក់កណ្តាល វារត់ចូលមកក្នុងការចងចាំដោយជួយមិនបាន អឺយ...ក្តៅខ្លាំងណាស់ ទាំងដែលនៅក្នុងនេះបើកម៉ាស៊ីនត្រជាក់ឡើងត្រជាក់ស្រេង តែខ្ញុំក៏ក្តៅទៅៗឡើងខះកទៅហើយ "សុំផឹកទឹកសិនបានទេម៉ាក់ ហើយខ្ញុំនឹងឲ្យម៉ាក់សួរគ្រប់សំណួរ"

បានផល ម៉ាក់របស់ខ្ញុំម្នីម្នាស្រែកហៅអ្នកបម្រើឲ្យយកទឹកត្រជាក់មកឲ្យ ហើយក៏ដឹកដៃខ្ញុំទៅអង្គុយលើសាឡុងដែលនាំមកពីអ៊ីតាលី រង់ចាំទាល់តែខ្ញុំផឹកទឹកអស់ពីកែវទើបសួរ ។

"ស្ទីកតើយ ចម្លែកចិត្តទេ នាងមានអាកប្បកិរិយាយ៉ាងម៉េចពេលជួបឯង ?"

...ចម្លែក ផឹកទឹកអស់ពីកែវហើយក៏នៅតែខះក...ខ្ញុំដាក់កែវចុះ ហើយក៏ខ្ទឹបបបូរមាត់ នឹកដល់ទឹកមុខភ្ញាក់ផ្អើលបំផុតរបស់ស្ទីកតើយ ហើយក៏ងក់ក្បាល ។

"សទ្រលុកទ្រលន់"

"ហ៊ឹម ?"

កម្មពៀរ...ខ្ញុំធ្វើភ្នែកឡើមឡាម មិនស្មានថាឆ្លោយរបូតមាត់តាមអ្វីដែលគិត ។

"ខ្ញុំមានន័យដល់ គឺ...មើលទៅមិនជ្រើមប៉ុន្មាន"

"ឲ្យជ្រើមបានយ៉ាងម៉េចទៅ ម៉ាក់នាងនិយាយឲ្យស្តាប់ថាស្ទីកតើយ រត់ចេញពីផ្ទះពេលដែលដឹងថាត្រូវរៀបការដោះបំណុល"

ហ៊ឺ!!! ស្រីកំណាច តាំងពីកើតមកមានតែអ្នករត់ដាក់ តែនាងព្រមក់នោះរត់គេចពីការរៀបការជាមួយខ្ញុំ ។

"ប្រាប់នាងឬអត់ថាស្អែកនេះយើងទៅនិយាយគ្នារឿងមង្គលការនៅផ្ទះរបស់នាង ?"

"ប្រាប់ហើយ តែមិនដឹងថា ស្ទីកតើយ ព្រមទៅឬអត់"

"ត្រូវតែទៅ នាងច្បាស់ជាទៅ ម៉ាក់ថាគេទៅកក់សណ្ឋាគារទុកកិច្ច រំភើបដល់ហើយ"

ម៉ាក់របស់ខ្ញុំដើរញញឹមញញែមចេញពីបន្ទប់ទៅហើយ ឬកពាមើលទៅសប្បាយចិត្តសប្បាយភ្លើមដែលបានកូនប្រសាដូចគេដូចឯង បន្ទាប់ពីច្រណែនមិត្តភក្តិដែលកូនរៀបការមានក្រុមគ្រួសារច្រើននាក់ទៅហើយ ។

តាមពិតក៏មិនចង់រៀបការប៉ុន្មានដែរ ជីវិតកំលោះនៅលីវ វាមានសេរីភាពនិងមានសេចក្តីសុខ អ្នកណាទៅចង់យកប្រឡៅកមកពាក់ទៅ តែថា...បើជាប្រឡៅកដែលមានមុខមាត់ឃ្យូតៗ បបូរមាត់តូច ច្រមុះតូចដូចស្រីតូចមិនដឹងខ្យល់អីប៉ុន្តែសម្តីអាក្រក់ដូចនាងព្រមក់ដែលខ្ញុំទៅជួប...ជួនកាលមង្គលការនេះវាអាចមិនអាក្រក់អីណាស់ណាក៏ថាបាន ។

"មែនឬអត់ អ៊ីនថាច់ ដែលថាឯងរៀបការ ?"

គីតេ មិត្តរួមជំនាន់តាំងពីរៀនបរិញ្ញាបត្រ ហើយក៏ជាមិត្តរួមមហាវិទ្យាល័យពេលទៅរៀនអនុបណ្ឌិតនៅបរទេសសួរ មុននឹងលើកកែវស្រាផឹក ។ វាជាកូនប្រុសអ្នកនយោបាយ និងកំពុងតែត្រៀមខ្លួនដើរតាមគន្លងរបស់ឪពុក ។

វាជាមិត្តភក្តិតែម្នាក់ដែលខ្ញុំមាន តាមពិតទោះខ្ញុំសាច់ក្រអូបនៅក្នុងចំណោមស្រីៗ ក្នុងឋានៈជាកូនទោលរបស់មហាសេដ្ឋីម្ចាស់សណ្ឋាគារល្បីនៅក្នុងប្រទេស តែសម្រាប់គេខដូចគ្នា ខ្ញុំគឺជាជន

ព្រោះថ្នាក់និងសេពគប់មិនបាន ។

តាមពិតខ្ញុំមិនបានធ្វើអីនោះទេ គ្រាន់តែជារូបរាងមុខមាត់និងឋានៈ វាធ្វើឲ្យសង្សាររបស់ពួកនោះនាំគ្នាផ្សៀងចិត្តមករកខ្ញុំជាង... តែប៉ុណ្ណឹង ។

"មែន"

"ហេ! មែនក៏អី"

"អឺម ប្លែកកន្លែងណា ?"

"ប្លែកត្រង់កន្លែងហ្នឹង ផ្ទុយពីបងដូចជា អ៊ីនថាច់ រៀបការទាំងអាយុទើបតែ២៦នេះ សួរតាមត្រង់ និយាយលេងឬអត់ ?"

ខ្ញុំញាក់ស្មា និងទាញកែវស្រាមកផឹក ។

បន្ទាប់ពីនិយាយជាមួយម៉ាក់ចប់ គឺតេ មិត្តម្នាក់នេះក៏ទូរសព្ទមកភ្លាម ព្រមទាំងហៅខ្ញុំឲ្យមករកនៅបារដែលតែងតែមក ដែលត្រូវតែជាសមាជិកប៉ុណ្ណោះទើបមានសិទ្ធិចូល ហើយតម្លៃសមាជិកនៅទីនេះក៏ថ្លៃស្មើនឹងប្រាក់ខែអ្នករៀនចប់កម្រិតបរិញ្ញាតែម្ដង ។

"ហើយឯងដឹងបានយ៉ាងម៉េច ?"

"ម៉ាក់ឯងតេមកប្រាប់ ថាឲ្យខ្ញុំត្រៀមខ្លួនធ្វើជាអ្នកកំដរកូនកំលោះ"

ម៉ាក់អើយម៉ាក់...ខ្ញុំដកដង្ហើមធំ រសជាតិល្វីងមុតករបស់វីស្គីធ្វើឲ្យអណ្ដាតស្ពឹកតិចៗ កក្ដៅភាយៗដូចដែលទើបតែលេបភ្លើង... រូបភាពកែវភ្នែករបស់ ស្ទីកតើយ ផុសផ្ដោលនៅក្នុងខួរក្បាលម្ដងទៀតហើយ រហូតដល់ត្រូវបិទភ្នែកដោយការងឿងឆ្ងល់ ។

កម្មមែន...ទាំងដែលមិនមែនជាមាន់សម្ល ដូចទើបតែឃើញមនុស្សស្រីនៅក្នុងឈុតក្នុងលើកដំបូង តែហេតុអី...រលាស់រូបភាពស្រីម្នាក់នោះមិនបានអីចឹង ?

"ចុះបណ្ដាស្រីទាំងឡាយរបស់ឯង ធ្វើយ៉ាងម៉េច ?"

"ស្រីបែបនោះគឺដូចស្ករកៅស៊ូ ងាយរកទិញ តម្លៃមិនថ្លៃ ទំពាមិនប៉ុន្មានក៏រស់ជាតិផ្អែម ត្រូវខ្ជាក់ចោល"

"វាគេះ...ជេរបានឈឺមែន" គឺតេ ត្រវីក្បាលដាក់ពាក្យប្រៀបធៀបរបស់ខ្ញុំ ។

ខ្ញុំញញឹមចុងមាត់ អាចស្ដាប់ទៅទើសត្រចៀក តែខ្ញុំគិតអីចឹងពិតមែន ។

"ហើយអ្នកដែលឯងរៀបការជាមួយនេះជាស្អី ជាស្ករកៅស៊ូទេ ?"

ខ្ញុំងៀងមើលមុខមិត្តជិតស្និទ្ធតែម្នាក់គត់ ហើយក៏យកអណ្ដាតញ្ញាល់មុននឹងត្រវីក្បាល ។

"ឈប់និយាយរឿងនេះទៅ ហៅមកផឹកស្រាគឺផឹកស្រា"

"សួរម្ដងទៀតចុះ អ៊ីនថាច់ ក្នុងឋានៈដែលរាប់អានគ្នាយូរយារ ឯងគិតចង់ប្រើជីវិតជាមួយមនុស្សស្រីដែលមិនធ្លាប់ស្រឡាញ់ មិនធ្លាប់ស្គាល់ រៀបការតាមបញ្ជាម៉ាក់ មួយជីវិតឬ ?"

គឺតេ សួរដោយទឹកមុខប្រាកដប្រជា ខ្ញុំញញឹមនិងបណ្ដោយឲ្យវាធ្វើមុខប្រាកដប្រជាចង់ដឹងបែបនោះបន្ត មិនឆ្លើយតបវា លើកកែវស្រាអោកម្ដងទៀត ។ ហើយជាលើកដំបូង ពេលដែលរសជាតិក្ដៅរបស់វីស្គីរត់តាមក រូបភាពដែលឃើញគឺជារូបរបស់មនុស្សស្រីដែលធ្វើឲ្យខ្ញុំត្រូវឈប់ទំពាស្ករកៅស៊ូម្ដងទៀត...កាលពីថ្ងៃខ្ញុំមានចេតនាទៅធ្វើបាបនាង ដោយការទៅដេកស្រាតលើគ្រែ តែពេលនេះគឺជាខ្ញុំដែលត្រូវមកដេកមិនលក់ពេញមួយយប់ ផឹកស្រាក៏មិនឆ្ងាញ់ ។

"ទៅវិញហើយ"

"អេ៎...ទើបតែម៉ោងតើ"

"ស្អែកមានការសំខាន់ ត្រូវត្រឡប់ទៅវិញហើយ ឯងផឹកហើយ

កត់ក្នុងបញ្ជីទៅ ខ្ញុំចាំ"

ខ្ញុំប្រាប់ ហើយក៏ដើរចេញទៅ ជឿជាក់ថាមិត្តភក្តិគ្មានផ្លូវអផ្សុកឬអង្គុយផឹកស្រាម្នាក់ឯងនោះទេ កំលោះសង្ហាដូច គីតេ មិនយូរប៉ុន្មាននឹងមានស្រីស្អាតមកអង្គុយផឹកស្រាកំដរមិនខាន ។

"មិនទាន់មានប្រពន្ធផង ក៏ក្លាយជាកំលោះអនាម័យចូលដេកពីព្រលប់ទៅហើយអាសម្លាញ់"

គីតេ រអ៊ូរទាំតាមពីក្រោយនិងដកដង្ហើមធំ មុននឹងរកមើលអ្នកណាមកអង្គុយកំដរជំនួស ។ កែវភ្នែកផ្លេកៗបែបព្រាននារីឃើញស្រីស្អាតពាក់ឈុតពណ៌មាសទើបញញឹម ហើយលើកកែវស្រាដាក់ជាការបើកផ្លូវ ហើយក៏ញញឹមញញែមពេលឃើញថាអ្នកម្ខាងទៀតលើកកែវតប មុននឹងដើរទាំងអែនអនមករក ជាការធានាបានថាយប់នេះ គីតេ មិនអផ្សុកនោះទេ ។

[End Intouch's Talk]

www.srolanhkhmer.com

## ២

## ស្វាមីផ្លេកបន្ទោរ និង ស្នាមថើបរន្ទះបាញ់

មិនបានចង់មកទេ មិនបានចង់មក តែត្រូវតែមកដើម្បីបាននិយាយជាមួយអ្នកស្រី លី ឲ្យដឹងរឿង ។ ខ្ញុំដកដង្ហើមធំ មុននឹងដើរចូលទៅក្នុងផ្ទះខ្លួនឯង ដែលទើបតែរត់គេចពីម៉ាក់កាលពីម្សិលបន្ទាប់ពីទុកចោលគ្រាប់បែកមួយគ្រាប់ធំ ដោយការប្រាប់ថាឲ្យបងស្រីលែងលះជាមួយស្វាមីមករៀបការដោះបំណុលជំនួស ។

ឡានទំនើបតម្លៃថ្លៃដែលចតនៅមុខផ្ទះ ប្រាប់ឲ្យដឹងថាម្ចាស់បំណុលមកហើយ ហើយគ្រប់គ្នាក៏អង្គុយនៅក្នុងបន្ទប់ទទួលភ្ញៀវដែរ មានទាំងម៉ាក់ខ្ញុំ ស្រីវ័យកណ្តាលមុខមាត់ស្អាតម្នាក់ ហើយនិង...ខ្ញុំសម្លឹងមើលមុខសង្ហារបស់អ្នកដែលពាក់អាវស៊ឺមីពណ៌ខ្មៅ ខោជើងវែងពណ៌ខៀវចាស់ សក់របស់គេសិតទៅក្រោយ ។

កាលពីម្សិលព្រោះរវល់តែភ័យដែលសុខៗក៏មានមនុស្សប្រុសទៅដេកក្នុងបន្ទប់របស់ខ្លួនឯង ហើយខ្ញុំក៏នៅក្នុងសភាពសិចស៊ីទើបមិនបានជាមើលមុខមាត់គេឲ្យច្បាស់ តែពេលដែលខ្ញុំដើរចូលមកក្នុងបន្ទប់ទទួលភ្ញៀវ អាម្សៀនោះអង្គុយទល់មុខទ្វារ ហើយក៏មើលមកខ្ញុំល្មម ទើបយើងប្រសព្វភ្នែកគ្នា ។

គេសង្ហា...ខ្ញុំព្រមទទួលស្គាល់ តែចរិតអាក្រក់ ចាំបានទេថាកាលពីម្សិលមិញគេថាអីឲ្យខ្ញុំខ្លះ ឆឹះ!

"ស្លឹកតើយ មកល្មម សួស្តីអ្នកមីងទៅកូន"

"សួស្តីអ្នកមីង"

"ហៅមីងធ្វើអី ហៅម៉ាក់ទៅ ឈើ! នេះចំមែន...ស្លឹកតើយ ជិតក្លាយជាកូនប្រសាខ្ញុំហើយ"

"អឺម មែន...ភ្លេចទៅ ស្លឹកតើយ ហៅអ្នកម៉ាក់ទៅ"

នេះ...និយាយខ្លួនឯងស្អីខ្លួនឯង ត្រូវគ្នាបែបនេះផង...ខ្ញុំលើកចិញ្ចើម ហេតុអីបរិយាកាសរវាងម៉ាក់ខ្ញុំនិងម្ចាស់បំណុលរបស់យើងមើលទៅបីតិសោមនស្សរីករាយអីយ៉ាងនេះ ។

"សួស្តីអ្នកមីង"

ពេលដែលក្បាលរឹង ខ្ញុំនេះរឹងមុខមោយ ឱនគំនាប់ហើយក៏ដើរទៅអង្គុយនៅលើសាឡុងក្បែរម៉ាក់ ព្យាយាមមិនក្រឡេកមើលមុខប្រុសឆ្កួតដែលគិតតែសម្លឹងខ្ញុំមិនប៉ព្រិចភ្នែក ។

មនុស្សយើងនេះក៏ប្លែក តាំងពីខ្ញុំធំដឹងក្តីក៏ដឹងថាក្លាយជាមនុស្សមុខមាត់ល្អ ខ្ញុំជាស្រីស្អាត ចំណុចនេះដឹងច្បាស់និងមិនធ្លាប់គិតថាមកអង្គុយជួបខ្លួនបដិសេធដែរ ពេលដែលសិស្សឡុងប្រាប់ឲ្យឡើងវេទិកាប្រកួតបវរកញ្ញា ឬធ្វើជា Drum Meyer ទីមួយរបស់មហាវិទ្យាល័យនៅក្នុងការប្រកួតមិត្តភាព នៅកណ្តាលចំណោមខ្សែភ្នែកមនុស្សរាប់ពាន់ ខ្ញុំមិនឃើញមានអារម្មណ៍អីបន្តិច តែពេលនេះគ្រាន់តែប្រុសភ្នែកមុតដែលអង្គុយមើលខ្ញុំស្ងាត់ៗពីជ្រុងម្ខាងនៃបន្ទប់ ពោះវៀនពោះតាំងរបស់ខ្ញុំក៏ច្របល់ ហើយក៏មានអារម្មណ៍ប្លែកៗ ទាំងខ្មាសផង ទាំងមិនពេញចិត្តផង ។

"គោរពបងផង នេះបង អ៊ីនថាច់ កូនប្រុសអ្នកម៉ាក់ ធីហ្វានី" ម៉ាក់នៅតែព្យាយាមញាត់ញៀតឲ្យខ្ញុំហៅអ្នកមីង ធីហ្វានី ថាម៉ាក់ដដែល...ចង់តែងើបស្រែកប្រាប់ថា ខ្ញុំជាកូនម៉ាក់ មើលយល់ពីអារម្មណ៍គ្នាបន្តិចបានទេ តែដែលធ្វើបានគឺដៀងមើលអាមៀអ៊ីនថាច់ ហើយឱនគំនាប់ ។

"សួស្តី"

"មិនអីទេ យើងសុទ្ធតែជាគ្នាឯង"

សំឡេងរាបស្មើនិងស្នាមញញឹមកក់ក្តៅដែលបញ្ជូនមកឲ្យនោះ ធ្វើឲ្យខ្ញុំជ្រួញចិញ្ចើម មើលមុខសង្ហារបស់ អ៊ីនថាច់ ហើយខ្ទប

បបូរមាត់ អំ...ជាពពួកមុខពីរហ្នឹងឯង ពីម្សិលធ្វើជាអាហាតចិត្តសម្តីអាក្រក់ តែពេលនេះនៅចំពោះមុខមនុស្សចាស់ក្លាយជាកំលោះទន់ភ្លន់ ។

អាហាតចិត្ត...ខ្ញុំបញ្ជូនពាក្យជេរតាមខ្សែភ្នែក ហើយគេក៏សើចញឹមៗដាក់ មាត់នេះញញឹមកក់ក្តៅ តែភ្នែកដែលមើលមកខ្ញុំដូចខ្សែភ្នែកឃាតក ហ៊ឺ! មើលខ្សែភ្នែកខ្ញុំនឹងហើយហ្នឹង!

"ក្នុងពេលដែលមកគ្រប់គ្នាហើយ អីចឹងយើងនិយាយគ្នារឿងមង្គលការទៅ ធីហ្វានី" ម៉ាក់ងាកទៅញញឹមញញែមដាក់ ។

"អត់ទេ ខ្ញុំមកទីនេះមិនបានមកនិយាយរឿងមង្គលការ ខ្ញុំមកនិយាយជាមួយអ្នកមីងរឿងបំណុល"

ខ្ញុំរហ័សជំទាស់ ធ្វើជាមើលមិនឃើញខ្សែភ្នែករបស់ម៉ាក់ដែលសម្លក់សម្លឹងមក ចំណែកអ្នកស្រី ធីហ្វានី ក៏ញញឹម មិនបានមានឫកពាខឹងខ្ញុំអីបន្តិច មុខស្អាតតាមវ័យបែបស្រីចិត្តល្អ នាងលូកដៃមកប៉ះដៃខ្ញុំ ហើយញញឹមស្រស់ដាក់ ។

"និយាយម៉ោ ស្លឹកតើយ"

ទេពធីតា ទេពធីតាច្បាស់ណាស់ (តែហេតុអីកូនប្រុសក្លាយជាបិសាច) ខ្ញុំញញឹម ធូរចិត្តច្រើនណាស់ បែបនេះឱកាសមិនបាច់រៀបការដោះបំណុលក៏មានច្រើនដែរ រួចខ្លួនហើយ ស្លឹកតើយ!

"ខ្ញុំចង់សូមអង្វរអ្នកមីង ចង់សុំពេលវេលាអ្នកមីងបន្តិច ខ្ញុំសុំបង់ការប្រាក់សិន ខ្ញុំមានប្រាក់សន្សំនិងខុនដូ ខ្ញុំនឹងប្រកាសលក់ខុនដូ អាចបានមិនច្រើន ហើយខ្ញុំនឹងលក់ឡានដែរ ខ្ញុំនឹងដោះបំណុលអ្នកមីង តែប្រហែលជាត្រូវសុំបង់រំលស់ ខ្ញុំនឹងឆាប់រកការងារធ្វើឲ្យបាន ហើយផ្ញើប្រាក់ទៅឲ្យអ្នកមីងរាល់ខែ ផ្ទះមួយនេះខ្ញុំនឹងសុំឲ្យម៉ាក់លក់ ហើយយកប្រាក់ឲ្យអ្នកមីងដែរ អ្នកមីងជួយបន្ធូរបន្ថយឲ្យខ្ញុំបានទេ ?"

ម៉ាក់ប្រាប់ថាអ្នកមីងម្នាក់នេះជាមិត្តភក្តិរបស់គាត់ អ្នកមីងត្រូវតែយល់ អាណិត និងព្រមមិនខាន ។

ខ្ញុំញញឹមស្រស់ និងធ្វើភ្នែកស្រទន់ឲ្យមើលទៅគួរឲ្យអាណិតបន្តិចទៀត ។

"ព្រះអើយ...នាង...មិនចង់រៀបការជាមួយកូនប្រុសម៉ាក់ឬ"

"មិនចង់ទេ..." តបវាងលឿនបន្តិច ខ្លាចតាត្រូវស្អប់ខ្ពើមនិងពាលមិនបន្ធូរបន្ថយបំណុលឲ្យ ។

ខ្ញុំញញឹមខ្មោះដាក់ ។

"ខ្ញុំគិតថាមង្គលការវាត្រូវតែកើតឡើងដោយក្តីស្រឡាញ់ ខ្ញុំមិនបានស្រឡាញ់...បង គីនថាច់"

ប្រឹងលេបពាក្យថា **អា** ចូលបំពង់កមួយម៉ាត់ទៀត ។

"ខ្ញុំចង់ធ្វើការ ហើយការរៀបការដោះបំណុលបែបនេះ ខ្ញុំថាវាមិន..."

"ស្លឹកតើយ ប្រហែលជាលំបាកចិត្តហើយម៉ាក់ យើងមិនស្គាល់គ្នា ទាំងនាងទាំងខ្ញុំដូចមនុស្សប្លែកមុខ សុខៗឲ្យមករៀបការ នាងប្រហែលជាមានអារម្មណ៍មិនល្អ"

អ៎...អាមៀនេះចេះនិយាយស្តីពីរោះដែរតើ ឬប្តូរចិត្តហើយ?

"មែន បង គីនថាច់ និយាយត្រូវ" ខ្ញុំនិយាយនិងញញឹមញញែម ផ្ទូរស់ឡើងដល់៦០ភាគរយហើយ ។

"ការរៀបការមិនមែនជារឿងលេងសើច អ្នកដែលត្រូវរៀបការជាមួយគ្នាត្រូវតែស្គាល់គ្នាឲ្យបានច្រើន ហើយត្រូវសិក្សាស្វែងយល់និងស្រឡាញ់គ្នាដែរ" សំឡេងរបស់អាមៀបិសាចនោះបន្លឺឡើងម្តងទៀត ម៉ាក់យើងទាំងពីរមើលមុខគ្នា ម៉ាក់ខ្ញុំក៏ភ្ញាក់ដែលអនាគតកូនប្រសាររបស់គាត់និយាយបែបនេះ ។

"មែន បង គីនថាច់ និយាយត្រូវ"

ខ្ញុំបន្ទរ ផ្ទូរស់ឡើងទៅដល់៨០ភាគរយ ។

"ដូច្នេះហើយខ្ញុំជាអ្នកចាត់ការរឿងនេះ ខ្ញុំនឹងបង្កើតទំនាក់ទំនងរវាងខ្ញុំ និង ស្លឹកតើយ ហើយប្រើពេលវេលាជិតខ្លីឲ្យយើងទាំងពីរបានសិក្សាពីគ្នាឲ្យឆាប់បំផុត"

"មែន បង គីនថាច់ និយាយត្រូ...អា...មិញនេះនិយាយស្អីគេ?"

ខ្ញុំងាកទៅមើលមុខគេ ហើយក៏បានឃើញស្នាមញញឹមរបស់បុរសដែលងើបឈរ គេខ្ពស់ណាស់ ដល់ថ្នាក់ខ្ញុំត្រូវងើយមើល មុខមាត់សង្ហានោះមានស្នាមញញឹមក្រញាក់ តែបែរជាធ្វើឲ្យខ្ញុំព្រឺសម្បុរយ៉ាងចម្លែក ។

"ភយយយ!"

ខ្ញុំស្រែក ពេលសុខៗអ្នកដែលងើបនោះក៏ដើរមកលើកបីខ្ញុំបានយ៉ាងងាយ ធ្វើឲ្យខ្ញុំទៅនៅក្នុងរង្វង់ដៃរបស់គេដោយមិនទាន់បានពង្រឹងជំហរ ទើបត្រូវស្រវាឱបករបស់គេជាប់ ។

"លោកធ្វើស្អីហ្នឹង!"

ខ្ញុំញេញធ្មេញដាក់ដោយភ្លេចរក្សាមារយាទ ។

"គឺនាំនាងទៅស្វែងយល់ពីគ្នាហ្នឹងអី"

"ស្វែងយល់ឆ្កួតស្អី ដាក់ខ្ញុំចុះ ម៉ាក់!"

ខ្ញុំងាកទៅស្រែកហៅម៉ាក់ដើម្បីសុំជំនួយ តែម៉ាក់ក៏ធ្វើត្រឹមតែបើកភ្នែកធំៗមើលប៉ុណ្ណោះ ពេលងាកទៅសុំជំនួយពីម៉ាក់របស់អាមៀនោះ អ្នកស្រី ជីហ្វានី ក៏ធ្វើមុខមិនខុសពីគ្នាអីបន្តិច ។

"អូហ៍ បែបនេះដូច..."

ម៉ាក់ជួចជួរ និងញញឹមញញែមរំភើបចិត្តបំផុត ។

ហេ៎! នេះមិនមែនជាឈុតឆាកនៅក្នុងល្ខោនទេ!

"ម៉ាក់! ជួយខ្ញុំផង"

"ម៉ាក់ ម៉ាក់ក្មេក" អាមៀប៊ិសាចនៅក្រោមក្បាំងមុខទេវបុត្រនោះងាកទៅនិយាយយ៉ាងស្រទន់ "ខ្ញុំសុំអនុញ្ញាតខ្ចី ស្លឹកតើយមួយរយៈ ការពិតដូចដែលប្រាប់ យើងមិនស្គាល់គ្នា ខ្ញុំនឹងនាំនាងទៅដើរលេង និងឲ្យនាងបានស្វែងយល់ បានសម្របខ្លួន ហើយខ្ញុំនឹងនាំនាងមកឲ្យវិញ យើងនឹងបានត្រៀមមង្គលការជាមួយគ្នា មិនមែនទេ...ខណៈនេះ អ្នកម៉ាក់ទាំងពីរត្រៀមមង្គលការចាំបានហើយ"

ហាស! គេនិយាយថាម៉េច?

"អត់ទេ មិនព្រម ដាក់ខ្ញុំចុះ អាជាតចិត្ត ដាក់ចុះ ម៉ាក់!"

ខ្ញុំទាំងរើបម្រះទាំងស្រែកហៅម៉ាក់ឲ្យជួយ ប៉ុន្តែធ្វើបានត្រឹមប៉ុណ្ណឹង អីនចាច់ គេរឹងមាំណាស់ ហើយក៏បីខ្ញុំដើរចេញពីបន្ទប់ដោយមានខ្សែភ្នែកស៊ីអារម្មណ៍របស់ម៉ាក់ទាំងពីរតាមមើល ។

"ម៉ាក់! អ្នកម៉ីង!" ខ្ញុំស្រែកខ្លាំងៗ ។

[Intouch's Talk]

ខ្ញុំបីអ្នកដែលរើបម្រះចេញពីផ្ទះរបស់ម៉ាក់នាង ហើយក៏ដាក់ឲ្យឈរ ដោយនៅតែឱបចង្កេះរបស់នាងជាប់ និងទាញកូនសោមកបើកឡានបានដោយមិនលំបាកអី ។ ទោះ ស្លឹកតើយ ទាំងរើបម្រះទាំងស្រែកសុំជំនួយ តែមានល្បិតប៉ុណ្ណឹង កម្លាំងដូចស្រមោច ត្រឹមមួយភ្លែតខ្ញុំក៏ចាប់ញាត់ឲ្យអង្គុយក្នុងឡានក្បែរអ្នកបើក ហើយក៏ចុចសោបិទ មុននឹងម្ញីម្ញាដើរទៅបើកទ្វារម្ខាងទៀត ហើយឡើងឡានភ្លាម ស្រីមានល្បិតប្រុងគេច តែខ្ញុំចាក់សោឡានម្តងទៀត ហើយក៏បញ្ឆេះឡានភ្លាម ។

"បើកទ្វារភ្លាម!"

ពេលគេចមិនបានក៏ងាក...

ឆ្មាដែលព្យាយាមតំរាមដាក់ ។

គួរឲ្យស្រឡាញ់ គួរឲ្យភ្ញាក់អីយ៉ាងនេះ!

"ដាក់ខ្សែក្រវាត់"

"មិនដាក់ បើកទ្វារឡានឲ្យខ្ញុំភ្លាម"

"ដាក់ខ្សែក្រវាត់ទៅ"

"មិនដាក់!" នាងស្រែកដាក់ ធ្វើឲ្យក្រដាសត្រចៀករបស់ខ្ញុំញ័រ ហើយខ្ញុំក៏ញាក់ស្មា ។

"តាមចិត្ត"

"វ៉ាយ!"

មនុស្សស្រីនៅក្បែរស្រែកម្តងទៀត លើកនេះព្រោះតែការភ្ញាក់ផ្អើលដោយសារខ្ញុំបើកឡានចេញទៅយ៉ាងលឿន ប្រភេទដែលនាងសឹងតែផ្កាប់មុខ ដៃតូចនោះរហ័សស្រវាយកខ្សែក្រវាត់ដោយការភិតភ័យ ខ្លាចភាពឆ្កួតរបស់ខ្ញុំ ហើយក៏លើកដៃបិទមុខដោយការភ័យខ្លាចយ៉ាងខ្លាំងពេលដែលខ្ញុំបន្ថែមល្បឿនលឿន ។

"ឆ្កួតឬ លោកចង់ទៅណា បើកលឿនដល់ម្ល៉ឹង វ៉ាយយយ!"

"ខ្លាចឬ?"

ខ្ញុំសួរ ខ្សែភ្នែកមិនព្រមដកចេញពីថ្នល់ដែលនៅខាងមុខ ខ្ញុំមិនបានឆ្កួតដល់ថ្នាក់បើកទៅបុកអ្នកណា ជើងដែលជាន់ហ្វ្រាំក៏បន្ថយ តែអ្នកដែលនៅក្បែរខ្លួនគិតតែយកដៃបិទមុខដោយការភិតភ័យ ទើបមិនដឹងថាខ្ញុំបើកយឺតវហើយ ។

"ខ្លាចហើយ ខ្ញុំស្លាប់មិនទាន់បាន មិនទាន់បានធ្វើស្ត្រីឡើងគរគោក ហ៊ឹ"

"..." ខ្ញុំងៀងភ្នែកមើលអ្នកដែលគិតតែថ្ងូចថ្ងូរ ហើយក៏អស់សំណើច ។

"ស៊ើចស្អីលោក?"

"ឈប់ហៅថាលោកថាឯងទៅ ចាប់ពីពេលនេះទៅនាងត្រូវហៅខ្ញុំថាបង អ៊ីនថាច់ គ្រប់ពេល"

"ហេតុអី!"

"អីចឹង...១៥០គម/១ម៉ោង យ៉ាងម៉េចដែរ"

"វ៉ៃយៗ កុំ ព្រមហើយៗ បង អ៊ីនថាច់"

ចាប់បានហើយថាប៊ិនខ្លាច បែបនេះរាងគំរាម អឺយ! រាងនិយាយគ្នាងាយបន្តិច ។

ខ្ញុំញញឹមពេញចិត្ត ហើយបើកឡានឡើងផ្លូវហាយវេយ៍ភ្លាម ប៉ុន្តែភ្នែកនៅតែសម្លឹងមើលអ្នកអង្គុយក្បែរ ដែលយកទូរសព្ទដៃពីហោប៉ៅសំពត់មកចុចលេខ១៩១ នាងព្រមក់នេះចង់ប្ដឹងប៉ូលិស។

"ធ្វើស្អី!" ខ្ញុំសួរខ្លាំងៗ ហើយក៏លែងដៃពីចង្កូតទៅដណ្ដើមយកទូរសព្ទពីនាង ។

ស្លឹកតើយ ចង់តេប្ដឹងប៉ូលិស លើកដំបូងនៅក្នុងជីវិតហើយនេះ ដែលមនុស្សដូច លី អ៊ីនថាច់ ត្រូវស្រីតេប្ដឹងប៉ូលិសឲ្យចាប់ ។

"ស្លឹកតើយ នាងហ៊ានដល់ថ្នាក់ហៅប៉ូលិសមកចាប់ខ្ញុំឬយ៉ាងម៉េច"

"..."

នាងសម្លក់សម្លឹងមុខខ្ញុំ ហើយមើលទៅដូចជាមានពន្លឺភ័យខ្លាចនៅក្នុងនោះដែរ ខ្ញុំប្រហែលជាធ្វើអីតាមអំពើចិត្តខ្លួនឯងបន្តិចហើយ ។

"ណ្ហើយចុះ មិនចាំបាច់ដល់ថ្នាក់ហៅប៉ូលិសមកទេ ខ្ញុំមិនបានយកទៅសម្លាប់ចោលឯណា"

"ប្រាកដហើយ ?" នាងសួរដោយមិនទុកចិត្ត ខ្ញុំក៏ញញឹមដាក់ ហើយក៏ឃើញមុខនាងក្រហមមិនប៉ុន្មានវិនាទី មុននឹងនាងធ្វើមុខធម្មតាវិញ ។

"ប្រាកដហើយ"

"សន្យាម៉ោ"

"សន្យាជាមួយក៏បាន!"

ខ្ញុំនិយាយដោយសំឡេងម៉ាំ មុននឹងក្លឹកមើលមុខអ្នកដែលដកដង្ហើមធូរទ្រូង ក្រៅពីគួរឲ្យស្រឡាញ់គួរឲ្យភ្ញាក់ មាត់កំណាចចូលចិត្តប្រកែក និងរាងវៃឆ្លាតហើយ អនាគតកូនក្រមុំរបស់ខ្ញុំនៅងាយស្ដាប់បង្គាប់ទៀតផង ហ៊ឺៗ!

ពីដូចដែលប្រាប់ ខ្ញុំប្រាប់ថាមិននាំទៅសម្លាប់ តែមិនបានមានន័យថាមិននាំទៅរំលោភឯណា ។

ខ្ញុំចតឡានពេលដល់គោលដៅ ហើយងាកទៅមើលអ្នកដែលមិនបានពេញចិត្តមកជាមួយខ្ញុំអីបន្តិច ។

មនុស្សស្រីដែលមានអាយុតិចជាងខ្ញុំច្រើនឆ្នាំម្នាក់នេះ កំពុងតែដេកលក់ ផ្អែកក្បាលនឹងបង្អួចឡាន លើកដៃឱបទ្រូងជាប់ ។

មែនហើយ ខ្ញុំបីនាងមកដោយ ស្លឹកតើយ គ្មានអ្វីមកជាប់ខ្លួនសូម្បីតែកាបូប ប្រាក់ ទ្រព្យសម្បត្តិតែមួយគត់គឺទូរសព្ទដៃដែលត្រូវខ្ញុំរឹបអូសទៅហើយ ។

"ស្លឹកតើយ ដល់ហើយ"

អ្នកដែលដេកលក់មិនព្រមភ្ញាក់មើលទៅសម្ដីគួរសម ខ្ញុំដោះខ្សែក្រវាត់ការពារ ពន្លត់ម៉ាស៊ីនឡាន ហើយងាកទៅមើលនាងឲ្យពេញភ្នែក ស្លឹកតើយ មានស្បែកសម៉ដ្ឋខៃព្រលាំផ្កាឈូកពេញមួយតួខ្លួន ( អានេះខ្ញុំបានពិសោធនៅថ្ងៃដែលលួចទៅដេកនៅក្នុងខុនដូនាង ) ចិញ្ចើមក្រាស់តាមធម្មជាតិ មិនបានសាក់ឲ្យមើលទៅកំប្លែងដូចស្រីខ្លះដែលចូលចិត្តធ្វើ ច្រមុះរបស់នាងស្រួច និងចុងរាងងខើចប្រាប់ឲ្យដឹងថានាងជាមនុស្សក្បាលរឹង និងមាត់...

"ចង់ធ្វើអី ?"

សំឡេងស្រែកដោយការភ្ញាក់ផ្អើល ដំណាលគ្នានឹងដៃដែលក្រអូបប្រហើររុញមុខខ្ញុំចេញ ។

នេះ...ខ្ញុំល្ងោកមុខទៅរកបបូរមាត់ស្រស់នោះតាំងពីពេលណា?

"គឺហៅប៉ុន្មានដងហើយក៏មិនភ្ញាក់ ថែមទាំងទឹកមាត់ក៏ហូរដូចកូនក្មេង ទើបចូលឲ្យជិត...យ៉ាងម៉េច គិតថាខ្ញុំចង់ថើបឬ?"

"ខ្ញុំ..." នាងហាមាត់ប្រុងប្រកែក តែពេលឃើញខ្ញុំធ្វើភ្នែកធំៗក៏និយាយម្តងទៀត "ខ្ញុំមិនបានហូរទឹកមាត់ទេ តែ...បងទៅវិញទេដែលហូរទឹកមាត់ពេលនេះ"

ហ៊ឹម...ខ្ញុំរហ័សលើកមេដៃប៉ះតែមមាត់ មុននឹងញាក់ស្មាញញឹមដាក់ស្រីស្រស់នៅចំពោះមុខ ។

"គឺនាងគួរឲ្យចង់ស៊ីធ្វើស្អី ចុះពីឡានទៅ បើសិនអង្គុយនៅតរតេក្ទឹមបែបនេះ ពិតត្រូវចាប់ថើបដូចដែលចង់"

ហើយក៏បានផល កញ្ញា ស្លឹកតើយ រហ័សចុះពីឡានភ្លាម ខ្ញុំក៏ចុះតាមដោយចិត្តត្រជាក់ មិនខ្លាចថានាងរត់គេចទៅណា ព្រោះទោះចង់រត់គេក៏បើកឡានតាមទាន់ ។

"នេះជាកន្លែងណា?"

"ផ្ទះល្វែងរបស់ខ្ញុំ នាងចូលចិត្តសមុទ្រហ្នឹងណា៎"

"ម៉េចក៏ដឹងថាខ្ញុំចូលចិត្តសមុទ្រ?" នាងងាកមកសួរខ្ញុំ ។

"ជូនអីថ្ងៃនេះមនុស្សគ្មានមារយាទមកតាមការណាត់យឺត ទើបខ្ញុំនិងម៉ាក់អង្គុយនិយាយគ្នាជាមួយនឹងម៉ាក់របស់នាង គាត់និយាយរឿងឲ្យស្តាប់ជាច្រើន"

មនុស្សស្រីដែលឈរក្បែរឡានខ្ញុំធ្វើមុខដូចលេបថ្នាំល្វីង និងងាកទៅមើលផ្ទៃខ្សាច់ដែលក្តៅហែង ព្រោះនេះម៉ោងពីររសៀល ។

"ខ្ញុំដឹងហើយថាទីនេះសមុទ្រ តែវានៅខាងណាដែរ?"



"គូសាន"

ខ្ញុំតប ហើយក៏ដើរនាំមុខចូលទៅក្នុងផ្ទះឈើពណ៌សពីរជាន់ខាងក្រោមសង្កត់ធ្ងន់ទៅលើការតុបតែងបែបកញ្ចក់ ធ្វើឲ្យមើលឃើញខាងក្នុង និងស័ក្តិសមចំពោះបរិយាកាសឆ្នេរខ្សាច់ ។

"ចូលអេម៉ា ចង់ឈរហាលថ្ងៃឲ្យខ្យល់គរឬយ៉ាងម៉េច"

អោ...នៅតែឈរធ្វើឫកដូចមិនបានឮទៀត នាងក្រមុំអតីតបរកញ្ញាមហាវិទ្យាល័យក្បាលរឹង!

"ឬចង់ឲ្យបី តែសុំថ្លៃបីជាការថើប"

ខ្ញុំសួរហើយក៏មូរដៃអាវ ដើរញញឹម ព្យាយាមមិនឲ្យឫកពាមើលទៅដូចសប្បាយចិត្តខ្លាំងដែលបានបីរាងតូចទន់ល្មៀយក្រអូបនោះទៀត ។

"មិនបាច់ទេ មិនបាច់"

ស្រីក្បាលរឹងរហ័សប្រាប់ ហើយក៏រត់នាំមុខខ្ញុំចូលក្នុងផ្ទះ ។

"គេចឲ្យបានរហូតទៅ"

ខ្ញុំអត់មិនបាននឹងស្រែកដាក់ ហើយដើរតាមអនាគតកូនក្រមុំដែលដាក់មេប្រូចចូលក្នុងផ្ទះ ។

នាងឈរចាំនៅមុខទ្វាររបង ខ្ញុំក៏ទាញកូនសោមកចាក់បើក ធ្វើដៃជើងដោយអាកប្បកិរិយាលេងសើច ហើយក៏បានផល មុខស្រស់ស្រទន់នោះក៏ក្រញូវភ្លាម ហើយក៏ដើរតន្រ្តំជើងចូលទៅខាងក្នុង ។

"ចូលចិត្តទេ?"

"..." ស្លឹកតើយ សម្លឹងមើលផ្ទះដែលខ្ញុំជាអ្នកចេញម៉ូដដោយខ្លួនឯង និងមើលការខុសត្រូវរៀងសាងសង់ទាល់តែរួចរាល់ ហើយងាកមកសរសើរ "ផ្ទះស្អាត អូខេ...អរគុណដែលនាំមកដើរលេង យើងត្រឡប់ទៅវិញបានហើយ"

"ឈប់សិន"

ខ្ញុំចាប់ដៃរបស់អ្នកដែលដើរញាប់ជើងស្ទុះសំដៅទ្វារ ហើយ

ឱនមុខទៅរក ។

ស្រីម្នាក់នេះមិនបានខ្ពស់ដូចតារាបង្ហាញម៉ូដដែលធ្លាប់បណ្ដើរ តែក៏មិនបានទាបផ្លុលពេក ពេលដែលនាងងើយមុខហើយខ្ញុំក៏ឱន ទៅរក រាសីក្តិសមគ្នាល្អម គួរឲ្យចម្លែកចិត្ត ។

"ស្លឹកតើយ មើលទៅនាងដូចមិនទាន់យល់ពីអ្វីដែលខ្ញុំប្រាប់ អ្នកម៉ាក់យើងទាំងពីរ ខ្ញុំចង់ឲ្យយើងទាំងពីរសិក្សាស្វែងយល់ពីគ្នា ហើយស្និទ្ធស្នាលគ្នា ខ្ញុំចង់មានន័យតាមនោះពិតមែន ព្រោះដូច្នេះ ហើយ នាងត្រូវនៅទីនេះជាមួយខ្ញុំទាល់តែដល់ថ្ងៃរៀបការ"

"រៀបការ!!"

"មែន រៀបការ"

"អ្នកណាប្រាប់ថាខ្ញុំរៀបការជាមួយ...ជាមួយបង យើងមិនបានស្គាល់គ្នាផង ខ្ញុំធ្លាប់ឃើញមុខបងមិនដល់២៤ម៉ោងផង"

អ្នកដែលមានមាឌល្អិតស្រែកប្រាប់ខ្លាំងៗ ។

ខ្ញុំញញឹមចុងមាត់ដាក់នាង ជាស្នាមញញឹមដែល គីតេ មិត្តខ្ញុំប្រាប់ថាជាស្នាមញញឹមដ៏កំណាច ។

"មិនអីទេ យើងមានពេលរាប់រយរាប់ម៉ឺនម៉ោងទៀត ដែលនាងត្រូវឃើញមុខខ្ញុំមួយជីវិតហ្នឹងណា៎"

"កាន់តែឆ្កួតហើយ គ្មានសមត្ថភាពរកកូនក្រមុំទេឬ ឬថាកូនបំណុលផ្សេងគ្មាន ម៉េចចាំបាច់ជាខ្ញុំ ?"

ខ្ញុំទាញដៃនាងមកជិត ហើយឱនមុខទៅរកបន្តិចទៀត ។

"ដោះគោ" ខ្ញុំនិយាយតែមួយម៉ាត់ ។

"ដោះគោ ?" ស្លឹកតើយ នៅតែតាមគំនិតរបស់ខ្ញុំមិនទាន់ដដែល ចិញ្ចើមក្រាស់របស់នាងជ្រួញជាប់គ្នា ។

"មែន វាជាកំហុសរបស់នាងដែលបង្អួតដោះគោឲ្យខ្ញុំមើលថ្ងៃនោះ តាមពិតខ្ញុំមិនពេញចិត្ត ឬយល់ស្របនឹងមង្គលការដោះបំណុលរបស់ម៉ាក់ ពេលម៉ាក់យកឃើយកាតរបស់នាងមកឲ្យ បញ្ជាឲ្យខ្ញុំទៅរកនាង ទើបខ្ញុំមានចេតនាដោះខោអាវ ហើយដេកចាំនាងលើគ្រែ មានចេតនាធ្វើឲ្យនាងភ័យ ហើយលុបចោលមង្គលការនេះ តែ...នាងបែរជាយកដោះគោមកបង្អួត ហើយខ្ញុំក៏..."

ខ្ញុំខាំបបូរមាត់ក្រោម ជ្រិមភ្នែកមើលនាង ដោយដកដង្ហើមចុះឡើងៗ ហើយក៏ឱនមើលដើមទ្រូងរបស់នាងដែរ ។

ណាមក!

"ព្រមទទួលស្គាល់ ខ្លាំងទៀតផង"

"អី" ស្លឹកតើយ ក្រាញគេច តែខ្ញុំចាប់ដៃជាប់ ទើបពេលនេះគឺជាការប្រទាញប្រទង់គ្នា ។

"១០០លាន ដោះដូរនឹងការបានដេកជាមួយនាងមួយជីវិត កន្លែងណា ពេលណា ប៉ុន្មានដងក្នុងមួយយប់ក៏បាន សមាមាត្រសឹងអី"

ផាប់!

វាកើតឡើងលឿនខ្លាំងណាស់ មុខខ្ញុំស្ពឹកតែម្ដង ហើយក៏ឈឺព្រោះតែកម្លាំងទះពីដៃតូចតែធ្ងន់របស់ ស្លឹកតើយ ។

សម្ដីអម្បាញ់មិញប្រហែលជាធ្វើឲ្យនាងខឹង តែជាពេលនេះការទះកំផ្លៀងដែលទទួលបាន វាធ្វើឲ្យខ្ញុំខឹង ។

ទះកំផ្លៀងអីចឹងឬ...ខ្ញុំលៀនអណ្ដាតមកលិឍបបូរមាត់ មុននឹងមើលនាងដោយខ្សែភ្នែកដែលប្រាប់ឲ្យដឹងថាខ្ញុំឡប់ស្រឡាំងជាសងសឹក ។ ស្រីជើងល្អឈានថយក្រោយ តែថាគេចមិនផុត ខ្ញុំស្រវាចាប់កញ្ចឹងករបស់នាងទាញមកជិត ដៃម្ខាងទៀតក៏ច្របាច់ថ្ពាល់ម៉ដ្ឋខៃ មុននឹងឱនទៅថើបបបូរមាត់ពណ៌ស្រស់របស់ ស្លឹកតើយ

ខាំសាច់ទន់ល្មើយនោះ ហើយត្រវាសអណ្តាតលិឍ រសជាតិរបស់នាងផ្អែម តែនាងបែរជាមិនព្រមឲ្យខ្ញុំភ្លក្សតាមសម្រួល ដៃទាំងពីរក្តាប់តក់ស្មា និងទាញសក់ខ្ញុំខ្លាំងៗ...

ឈប់ហើយ! ឈឺ ប៉ុន្តែវាសមាមាត្រនឹងការបានថើប កាន់តែនាងទាញសក់របស់ខ្ញុំខ្លាំងប៉ុណ្ណា ខ្ញុំក៏កាន់តែសង្កត់បបូរមាត់ថើបជញ្ជក់ខ្លាំងប៉ុណ្ណោះ និងហាមាត់ខាំបបូរមាត់ក្រោមរបស់ ស្លឹកតើយ មុននឹងបឺតជញ្ជក់ខ្លាំងៗ រហូតដល់នាងស្រែកតវ៉ា ។

ស្រេចមិនខាន! ហាមាត់បែបនេះ...

[End Intouch's Talk]

៣

## មនុស្សប្រុសដូច អ៊ីនថាច់ ចង់បាន...គឺត្រូវតែបាន

ខ្ញុំឈឺ...ឈឺថ្ពាល់ដែលត្រូវគេច្របាច់ និងឈឺបបូរមាត់ដែលត្រូវ អ៊ីនថាច់ ថើបជញ្ជក់ ។

ខ្ញុំមិនធ្លាប់ថើបជាមួយអ្នកណាបែបនេះ តែក៏មិនមែនមិនដឹងឡល់អីដល់ថ្នាក់មិនដឹងថាគេមានចេតនាធ្វើឲ្យភពពីនោះទេ ។

គេមានចេតនាធ្វើបាបរាងកាយខ្ញុំដោយមាត់របស់គេ បន្ទាប់ពីធ្វើបាបចិត្តរបស់ខ្ញុំដោយពាក្យសម្តីរបស់គេរួចរាល់ ។

*“១០០លានដោះដូរនឹងការបានដេកជាមួយនាងមួយជីវិត កន្លែងណា ពេលណា ប៉ុន្មានដងក្នុងមួយយប់ក៏បាន សមាមាត្រសឹងអី”*

សម្តីដែលបុរសម្នាក់នេះនិយាយ វាមិនខុសអីពីការបោះពាក្យជាសោភិនីដាក់មុខខ្ញុំច្បាស់ណាស់ ។ ដៃខ្ញុំញ័រទទ្រើត ហើយពេលដឹងខ្លួនម្តងទៀតខ្ញុំក៏ទះគេទៅហើយ ភ្នែករបស់គេជះពន្លឺខឹងសម្បា ហើយមុខសង្ហាមាំខុសពីបុរសក្មេងទូទៅក៏រឹងកំព្រឹសភ្លាម ។

ពេលនេះខ្ញុំដឹងថាត្រូវតែរត់គេច ត្រូវតែទៅឲ្យឆ្ងាយពី អ៊ីនថាច់ ប៉ុន្តែមិនទាន់បានឈានជើងផងក៏ត្រូវគេស្រវាចាប់ក ហើយឱនមកថើប ថើបជញ្ជក់ទាល់តែបបូរមាត់របស់ខ្ញុំឈឺ ពេលខ្ញុំរើបម្រះគេក៏ច្របាច់ថ្ពាល់ ធ្វើឲ្យខ្ញុំព្យាយាមទាញសក់របស់គេចេញ ។

“អ៊ូយ...”

គេកាន់តែថើបបបូរមាត់ក្រោមរបស់ខ្ញុំខ្លាំងៗ ដល់ថ្នាក់ឈឺនិងត្រូវតែមាន វាធ្វើឲ្យ អ៊ីនថាច់ អាចធ្វើបាបខ្ញុំបានកាន់តែខ្លាំង ដោយការជ្រែកអណ្តាតក្តៅសើមរបស់គេចូលមក ។

អឺម...បេះដូងវាលោតញាប់ លោតញាប់ខ្លាំងណាស់ ខ្លាំងដល់ថ្នាក់សឹងតែធ្លាយចេញពីទ្រូង អណ្ដាតរបស់គេក្ដៅឧណ្ហៗ ហើយក៏មិនព្រមនៅស្ងៀម ត្រាវស្គង់ប្រអប់មាត់របស់ខ្ញុំ ធ្វើឲ្យចប់ផ្ដើម ប៉ុន្តែ...វាហាក់ដូចមានថ្នាំស្ពឹកដែរ ព្រោះមិនថាគេកម្រើកចុងអណ្ដាតទៅខាងណា ខ្ញុំក៏មានអារម្មណ៍ថាស្ពឹកពេញខ្លួន...ចាប់ផ្ដើមពីមាត់វាលទៅដល់មុខ មុននឹងរត់ទៅរកបេះដូង ហើយរត់កាន់តែទាបទៅរកពោះ ខ្ញុំ...កើតអី?

"អឺម...ផ្អែមដូចដែលគិត"

គេសរសើរខ្ញុំឬ? ខ្ញុំត្រូវអរគុណមែនទេ ពេលដែលមានអ្នកសរសើរ? ខួរក្បាលរបស់ខ្ញុំដូចត្រូវបិទដល់ថ្នាក់គិតអីមិនចេញ មិនទាំងដឹងផងថាឈរឲ្យគេអូសបបូរមាត់ថើបតាំងពីចង្កានិងថ្ពាល់ ដៃរបស់ អីនថាច់ ឬពីការចាប់ប្រាថ់ថ្ពាល់របស់ខ្ញុំជាការងើយចង្កា ហើយអូសបបូរមាត់មករកក...មាត់របស់គេក្ដៅដូចភ្លើង ភ្លើងដែលបន្សល់ទុកកម្ដៅលើខ្លួនខ្ញុំ ។

អីនថាច់ ក្រសោបថ្ពាល់របស់ខ្ញុំ ហើយពេលនោះឯងដែលគេប្រសព្វភ្នែកជាមួយខ្ញុំ ។

ភ្នែកគេ...វាមិនមែនជាពណ៌ត្នោតចាស់ តែដូចពណ៌ប្រផេះពិចៗ ក្រឡេកមើលត្រួសៗឃើញថាច្រមុះគេស្រួចខ្លាំងណាស់ ។

"ធ្វើមុខបែបនេះមានន័យថាចូលចិត្តឲ្យខ្ញុំថើប លើកក្រោយចង់ឲ្យថើបក៏ប្រាប់តាមសម្រួលមក មិនចាំបាច់ដើរតួជាតួឯកស្រីទះតប់ស្ងួចនោះទេ"

គេនិយាយថាម៉េច?

ខ្ញុំប៉ប្រិចភ្នែក មុននឹងដឹងខ្លួនថាឈរផ្អឹងដូចគ្មានស្មារតីអស់ជាច្រើននាទី ទើបរហ័សរុញដើមទ្រូងគេចេញ ហើយលើកខ្នងដៃជូតបបូរមាត់ខ្លាំងៗ ។

"ខ្ញុំ...ខ្ញុំមិនបានត្រូវការឲ្យលោកថើប..."

"ប្រាប់ឲ្យហៅថាបង មិនអីចឹងនឹងថើបឲ្យឈឺមាត់ ឲ្យនិយាយមិនកើតយូរថ្ងៃ" គេប្រាប់ដោយសំឡេងមាំ មិនបានគំរាមលេងនោះទេ តែគេនឹងធ្វើមែន ។

"ខ្ញុំមិនត្រូវការឲ្យបងថើប ហើយក៏មិនធ្លាប់ស្នើខ្លួនរៀបការដោះបំណុលជាសោភិនីជាច់ថ្លៃឲ្យអ្នកណាដែរ ខ្ញុំនឹងរកប្រាក់សងឲ្យគ្រប់ចំនួន"

"មិនយក"

"អ៎!"

ប្រុសរាងខ្ពស់ស្រឡះញញឹម គេលើកដៃប្រុងសក់ដែលសើងម៉ើងព្រោះត្រូវខ្ញុំទាញអម្បាញ់មិញទៅក្រោយ តែមាត់ក៏មានស្នាមញញឹម មុខសង្ហាហាក់ដូចទេវបុត្រ តែហេតុអីពេលញញឹមបែបនេះវាមើលទៅគួរឲ្យខ្លាចម្ល៉េះ ។

"មិនចង់បានប្រាក់ ចង់បាននាង"

"មនុស្សស្រីមានរាប់លាននាក់ ម៉េចក៏មិនទៅរក មករវើរវល់នឹងខ្ញុំធ្វើអី"

"ចូលចិត្ត...ឈប់ធ្វើសំឡេងស្រួចរលែមទៅ ពេញចិត្តឬមិនពេញចិត្តក៏ម៉ាក់របស់នាងយកនាងដោះបំណុលទៅហើយ លុយប៉ុណ្ណឹងហើយដែលខ្ញុំឲ្យហេនៈជាប្រពន្ធ ពេលនេះខ្ញុំឃ្លានហើយ ទៅរកបាយញ៉ាំ"

"តែខ្ញុំមិនឃ្លាន"

ខ្ញុំទប់ទឹកភ្នែកយ៉ាងលំបាក មើលអ្នកដែលមានរៀបគ្រប់យ៉ាងដោយខ្សែភ្នែកទិតៀន ។

តវ៉ាគេច្រើនក៏មិនបាន ព្រោះថាប្រុសម្នាក់នេះនឹងតបតដោយវិធីដែលធ្វើឲ្យបេះដូងសឹងតែឈប់ដើរដូចអម្បាញ់មិញទៀត ។

"តែខ្ញុំឃ្លានហើយ បើមិនបានញ៉ាំអាហារ ខ្ញុំនឹងស៊ីនាង"

អាហារដំបូងរបស់ខ្ញុំ និង អ៊ីនចាច់ គេនាំខ្ញុំទៅហាងមួយដែលជាបារ៍ផង ជាភោជនីយដ្ឋានផង ទាំងដែលទើបតែម៉ោង២រសៀលប៉ុណ្ណោះ ថែមទាំងហាងនេះក៏មិនទាន់បើកបម្រើដែរ ។

អ្នកដែលប្លន់ស្នាមថើបដំបូងរបស់ខ្ញុំចុះពីឡាន ក៏ស្រវាចាប់ដៃខ្ញុំបង្ខាប់ឲ្យដើរចូលទៅជាមួយ ដែលខាងក្នុងតុបតែងដោយរូបគំនូរពីតុល័រទៀន មើលទៅគេដូចជាស្គាល់ទីនេះច្បាស់ដល់ហើយ ។

"អាំ បង អ៊ីនចាច់ មកពីអង្កាល់ហ្នឹង"

ស្រីតូចមុខមាត់មាំទុកសក់វែងដល់ត្រគាក ដើរចេញពីខាងក្នុងពេលទ្វារហាងត្រូវបានអ្នកខាងក្រៅបើកចូលទៅ ដោយមានស្លាកព្យួរនឹងប្រដាប់បិទបើកទ្វារថា Closed ។

"ស្មានថាភាពណាមកហាងទេតើ"

"និយាយស្ដីពីរោះដូចគេឯងក៏ចេះដែរ វ៉ាមី"

"ហើយ...នេះ?" មនុស្សស្រីដែល អ៊ីនចាច់ ហៅថា វ៉ាមី មើលមុខខ្ញុំដោយការងឿងឆ្ងល់ មុននឹងធ្វើមុខដូចទើបតែត្រូវខ្មោចលង ពេលមើលដៃរបស់ខ្ញុំដែលត្រូវ អ៊ីនចាច់ ចាប់ ។

"នេះអនាគតកូនក្រមុំរបស់ខ្ញុំ"

"មិនមែនទេ" ខ្ញុំរហ័សប្រាប់ ងាកទៅញញឹមដាក់ស្រីមុខមាំដែលគួរតែមានអាយុស្របាលគ្នា "ខ្ញុំឈ្មោះ ស្លឹកតើយ ជាកូនបំណុល..."

"ជាអនាគតកូនក្រមុំ" សំឡេងត្រជាក់ចេញពីមាត់អ្នកដែលរឹតកដៃរបស់ខ្ញុំកាន់តែណែនបន្តិចឡើង ។

ខ្ញុំខ្ទឹបមាត់ងើយមើលមុខគេ នៅតាមផ្លូវក្នុងឡានយើងមិនបាននិយាយរកគ្នា ខ្ញុំទាំងខឹងទាំងញាប់ញ័រចំពោះស្នាមថើបដែល



បាត់បង់ ។

សាកប្រកែកមើលច្បាស់ជាត្រូវថើបមិនខាន!

ខ្ញុំមើលខ្សែភ្នែករបស់គេឃើញបែបនោះមែន កាន់តែគេក្រឹមភ្នែកមើលមាត់របស់ខ្ញុំ ធានាថាកាត់ន័យយល់បានបែបនេះ ។

"មែនឬនេះ ល្អដល់ហើយ"

មាត់ប្រាប់ថាល្អ តែខ្សែភ្នែកនេះឲ្យស្រពោន...ខ្ញុំញញឹមដាក់ស្រីមុខមាំដែលមើល អ៊ីនចាច់ ដូចសោកស្ដាយនិងខូចចិត្ត ។

ចង់បាននិងយកទៅដាក់ជើងពាន ថ្វាយឲ្យឥឡូវនេះយកទេ!

"ខ្ញុំចង់នាំ ស្លឹកតើយ មកញ៉ាំអាហារដែលឆ្ងាញ់បំផុតនៅក្បែរខាងត្បូង ទើបមកហាងរបស់នាង ដឹងថាហាងមិនទាន់បើក តែខ្ញុំនិង ស្លឹកតើយ ឃ្លានខ្លាំង"

"ចាំ បាន ខ្ញុំធ្លាប់ប្រាប់ហើយតើ ថាហាងនេះស្វាគមន៍បងគ្រប់ពេលវេលា"

នោះអ៊ីស្លាន ម៉េចក៏មិនឡើងទៅ មករញ៉េរញ៉ៃនឹងខ្ញុំធ្វើអី ក្នុងពេលដែលខ្លួនឯងក៏មានស្រីៗចាំងល្មើមយកតំណែងដែលខ្ញុំមិនចង់បាន...មើលតាមរយៈស្រីតូច វ៉ាមី នេះទៅ ស្មានដែលរង់ចាំឲ្យ អ៊ីនចាច់ ដើរឆ្លងប្រហែលជាអោយដោយស្រទាប់កុលាប ។

"អរគុណច្រើន"

អ្នកដែលប្រណិប័តន៍ចំពោះខ្ញុំយ៉ាងគ្រោតគ្រាត លាមក ឆ្កួតអំណាចដែលយើងទើបតែស្គាល់គ្នាប្រាប់ដោយសំឡេងដ៏ស្រទន់ ហើយលូកដៃទៅញីសក់ក្បាល វ៉ាមី ដោយកាយវិការអាណិតស្រឡាញ់ ដល់ថ្នាក់ធ្វើឲ្យខ្ញុំអត់ពេបមាត់មិនបាន ។

មិនបានប្រណែនទេ គ្រាន់តែជ្រេញមនុស្សមុខពីរ នៅចំពោះមុខអ្នកដទៃក៏ធ្វើឫកពាជាសុភាពបុរស (សាកញីសក់ខ្ញុំឲ្យខូចម៉ូដមើល៍ ម៉ែនឹងទះឲ្យផ្កាប់មុខមិនខាន សាកមើលទៅ) ។

"មកខាងនេះ ស្វីកតើយ"

ព្រោះតែរវល់តែនិន្នាគេនៅក្នុងចិត្ត ទើបមិនបានឮអ្វីដែល វិនជាច់ ប្រាប់ ខ្ញុំងាកទៅមើលគេ ហើយលើកចិញ្ចើម ទើបកែវភ្នែកមុតស្រួចពណ៌ត្នោតមួយគូនោះមើលមកដូចចង់ស្តីឲ្យទៀត ។

"ស្តីគេ ?"

"រវល់តែភ្លឹកអី ខ្ញុំប្រាប់ថាឲ្យមកខាងនេះពីរបីដងហើយ ពេលនៅជាមួយខ្ញុំ ហាមយកចិត្តទុកដាក់ឬចាប់អារម្មណ៍អ្នកផ្សេង"

អីយ៉ាស់! ខ្ញុំធ្វើភ្នែកឡេមឡាម តែក៏ឃើញមុខស្រពោនរបស់ភិមី កុំធ្វើភ្នែកស្រពោនមើលខ្ញុំព្រោះច្រណែនបែបនោះអី ចង់បានអាត្មតនេះមែនទេ យកខ្លួនមកដោះបំណុលជំនួសខ្ញុំទៅ ខ្ញុំព្រម!

"ឲ្យឆាប់ឡើង"

ដៃធំក្រាស់នោះចាប់ដៃរបស់ខ្ញុំ ហើយក៏អូសម្តងទៀតពេលដែលខ្ញុំធ្វើអែនអន គឺក្នុងពេលដែលមិនអាចរឹងទទឹង ឬយកឈ្នះគេបាន ជាតុកម្មដោយការដើរយឺតៗក៏ល្អ ។

តុដែលគេនាំមកអង្គុយ គឺតុដែលនៅកែនហាលលយចេញទៅក្រៅ អាចមើលឃើញសមុទ្របានច្បាស់ ហាងនេះនៅមិនឆ្ងាយពីផ្ទះល្វែងរបស់គេ ហើយផ្លូវខ្សាច់នៅទីនេះក៏ស្អាត និងគ្មានមនុស្សដើរញ៉េរញ៉ៃដូចផ្លូវផ្សេង ។

"ទីនេះទេសភាពស្អាតបំផុត ហើយអាហារក៏ឆ្ងាញ់ តាមពិតមានតន្ត្រីករមកលេងហ្គីតាដែរ ប៉ុន្តែយើងមកពេលដែលហាងមិនទាន់បើក ទើបអត់បានមើល"

"..."

ខ្ញុំធ្វើជាមិនបានឮ ធ្វើជាមើលទៅផ្លូវខ្សាច់ពណ៌សនៅខាងក្រៅ ហើយក៏ត្រូវភ្ញាក់ព្រើតពេលដៃធំក្រាស់របស់ វិនជាច់ លូកមកចាប់សក់ដែលប៉ើងតាមខ្យល់សៀតនឹងត្រចៀកឲ្យ ។

"ខ្យល់ខ្លាំង"

ហឿក...ម៉េចក៏បេះដូងលោតញាប់ដល់ថ្នាក់នេះ!

"មីនុយ"

ភិមី ដើរមកវាក ព្រមទាំងហុចក្រដាសដែលជាមីនុយពណ៌សគួរអក្សរពណ៌ផ្ទៃមេឃចាស់ និងតុបតែងគួរឲ្យស្រឡាញ់ដោយផ្កាម្លៀម ។

"ខ្ញុំសុំឆាខ្ញីមាន់ ស៊ុប បង្កាបំពង ពងមាន់ចៀនក្តាម អ៊ំ...ទឹកដូងក្រឡុកថែមទឹកដោះគោស្រស់បន្តិចសម្រាប់ ស្វីកតើយ ខ្ញុំសុំទឹកសុទ្ធ"

ខ្ញុំលើកចិញ្ចើមដោយការចម្លែកចិត្តម្តងទៀត នោះជាម្ហូបដែលខ្ញុំចូលចិត្ត ហើយម៉ាក់ក៏មិនធ្លាប់ដឹងដែរថាខ្ញុំចូលចិត្តទឹកដូងក្រឡុកដែលត្រូវបន្ថែមទឹកដោះគោ...ចុះម៉េចក៏គេដឹង ?

"គ្រប់ទេ តិចពេកឬអត់ ?"

"គ្រប់ តែថាម៉េចក៏បង..."

"បើជារឿងរបស់នាង ខ្ញុំដឹងទាំងអស់"

មនុស្សប្រុសភ្នែកស្អាតនិងមុខសង្ហានៅចំពោះមុខញញឹម សក់របស់គេត្រូវខ្យល់ផាត់ដូចគ្នា តែបែរជាធ្វើឲ្យមើលទៅល្អខ្លាំងណាស់...លី វិនជាច់ គឺជាមនុស្សដែលធ្វើឲ្យបេះដូងរបស់ខ្ញុំលោតបានញឹកញាប់ជាងប្រុសគ្រប់គ្នានៅក្នុងលោកប្រមូលផ្តុំគ្នាទៅទៀត អឹម...អត់ព្រមទទួលស្គាល់មិនបានទេថា បើយើងទាំងពីរជួបគ្នានៅក្នុងស្ថានការណ៍ផ្សេង អាចជាខ្ញុំដែលរត់ដេញតាមចែចង់គេក៏ថាបាន ។

"អ៊ី..." ខ្ញុំប្រុងសួរបន្តថាម៉េចក៏ដឹង ។

"ដើមទ្រូងទំហំ៣៤ ចូលចិត្តពាក់ឈុតក្នុងពណ៌ផ្ទៃមេឃ ចង្កេះ២៣ ត្រគាក៣៥ កម្ពស់១,៦៥ ទម្ងន់៤៨គីឡូក្រាម"

*អាំ...ហេ!*

"ឈប់និយាយ!"

ខ្ញុំហើសហាម ចង់យកចង្កឹះនៅលើតុចាក់គ្រាប់ភ្នែកគេ មិនគួរណាភ្លើតភ្លើនឈ្លក់វង្វេងនឹងគេសោះ ស្លឹកតើយ អើយ ស្លឹកតើយ!

"មិនចង់ដឹងទេឬថាខ្ញុំដឹងរាងរៅរបស់នាងដោយរបៀបណា"

"ប្រាប់ហើយថាឈប់និយាយ"

"ហ៊ឺ"

គេសើច ភ្នែកមានពន្លឺផ្លេកៗ ថែមទាំងមើលខ្ញុំដោយខ្សែភ្នែកដែលបើសិនខ្ញុំជាអៃស៍គ្រីម មានសង្ឃឹមថាត្រូវកម្តៅរបស់ខ្សែភ្នែកគេរលាយមិនខាន ។

ខ្ញុំងាកមុខចេញ នេះថ្នាក់កណ្តាលថ្ងៃចែសកាលពីមួយសន្ទុះធំមុនគេថើបខ្ញុំឡើងឈឺមាត់ នេះថ្នាក់នៅក្នុងហាងអាហារ គេនៅល្បួយដាក់ខ្ញុំបានទៀត មើលភ្នែកក៏ដឹងថាគេកំពុងតែគិតមិនស្មោះត្រង់ ហើយយប់នេះខ្ញុំអាចយករួចខ្លួនពីប្រុសម្នាក់នេះបានដែរទេ?

"អាហារមកដល់ហើយ" សំឡេងរបស់ រ៉ាមី បន្លឺឡើង ស្របពេលដែលនាងលើកចានអាហារមកដាក់ ហើយក៏ថយចេញទៅ សង្ឃឹមថាប្រហែលជាមិនបានទៅលួចយំ ។

"ញ៉ាំទៅ ញ៉ាំឲ្យច្រើន នាងនៅធំបានទៀត"

"..."

ខ្ញុំមើលរបស់ដែលចូលចិត្តទាំងឡាយ ជ្រើសរើសជូសពងមាន់ចៀនភ្លាមមកដាក់ក្នុងចាន ហើយក៏ភ្លក្សមួយម៉ាត់ដំបូង រសជាតិឆ្ងាញ់សមនឹងការឃោសនារបស់ អ៊ីនថាច់ តែមិនទាន់បានលេបចូលកស្រួលបួលផងក៏ឈ្លក់សឹងស្លាប់ ពេលមនុស្សប្រុសដែលជូសអាហារមកដាក់ឲ្យនោះនិយាយបន្ត ។

"ពេលនេះ៣៤ បើញ៉ាំឲ្យច្រើន ជូនកាលទម្រាំបានរៀបការចូលបន្ទប់ផ្សំដំណេកអាចឡើង៣៥ឬ៣៦ ចាប់បានពេញដៃបន្តិច"

[Intouch's Talk]

ខ្ញុំមើលអ្នកដែលអង្គុយលើសាឡុងហើយគឺអត់បង្អាប់មិនបាន បន្ទាប់ពីអាហារដំបូងរបស់យើងបញ្ចប់ ខ្ញុំគឺនាំ ស្លឹកតើយ មកផ្ទះលម្ហែភ្លាម មិនបាននាំទៅឯណាទៀត នោះមកពីមិនទុកចិត្តថានាងបញ្ចេញឫទ្ធិទៀតឬអត់ បើថាទៅ ស្លឹកតើយ ក៏ទប់ទល់នឹងរឿងត្រូវបង្អាប់បង្ខំបានល្អតែម្តង ព្រោះនាងឈប់ឡូឡា ( តាមពិតខ្ញុំសោកស្តាយតិចតួច ព្រោះតាំងចិត្តថាបើនាងជេរពេលណា នឹងថើបឲ្យហាមាត់មិនបានយូរទៀត ) ហើយគឺអង្គុយរៀបរយនៅកន្លែងដើម។

"នាងចង់ទៅដើរលេងនៅឆ្នេរខ្សាច់ទេ ?"

"មិនចង់" នាងបដិសេធខ្ញុំដោយសំឡេងរាបស្មើ ។

"ឬចង់មើលព្រះអាទិត្យលិច ?"

"មិនចង់"

"ស្អីក៏មិនចង់ ចង់ធ្វើអីជាពិសេសឬអត់ ?"

យល់ដល់ភាពគួរឲ្យស្រឡាញ់ធ្វើខ្លួនស្តាប់បង្គាប់ ទើបខ្ញុំចង់តាមចិត្តនាងបានម្តង ។

"ចង់ទៅផ្ទះវិញ ជូនទៅបានទេ ?"

"មិនបាន...អំ ហើយកុំចង់ប្រើល្បិចលួចកូនសោឡានបើកខ្លួនឯង ធានាថាខ្ញុំនឹងប្តឹងប៉ូលិសពីបទលួចទ្រព្យសម្បត្តិមិនខាន" ខ្ញុំគំរាមទុកមុន ។

"ហើយមិនខ្លាចត្រូវគំរាមពីបទចាប់ពង្រត់ឃុំឃាំងទេឬ ?"

ហ្នឹងអី សរសើរថ្មីៗ លេងត្បូកជាន់កែងខ្ញុំទៀតហើយ តែដូចដែលថាហ្នឹង នេះជាអ្វីដែលធ្វើឲ្យ ស្លឹកតើយ ខុសពីមនុស្សស្រីដទៃទៀតនៅក្នុងខ្សែភ្នែករបស់ខ្ញុំ ។

រយៈពេលកន្លងមក មនុស្សស្រីគ្រប់គ្នាដែលចូលមកក្នុងជីវិត ដែលគ្រាន់តែប្រើដើម្បីកាត់បន្ថយស្ត្រេសមួយគ្រា សុទ្ធតែមិនធ្លាប់មានអ្នកណាតតាំង ឬហ៊ានជំទាស់ចិត្តខ្ញុំសូម្បីតែម្នាក់ គ្រប់គ្នាប្រឹងតុបតែងខ្លួនដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់ខ្ញុំឲ្យបានយូរបំផុត យកចិត្តយកថ្លើម ផ្គាប់ផ្គុន...ស្រីៗទាំងនោះស្រឡាញ់ប្រាក់របស់ខ្ញុំ តែ ស្លឹកតើយ មិនមែនបែបនោះ នាងមានតែរត់គេចពីខ្ញុំ... បើរៀបការដោះបំណុល នឹងបានរស់នៅដូចព្រះនាងក្នុងឋានៈជាកូនក្រមុំរបស់ទាយាទមហាសេដ្ឋីដូចជាខ្ញុំ គឺមានតែបាន និងមានក្តីសុខ តែនាងបែរជាមិនព្រម វាទាំងគួរឲ្យឈឺចិត្តដែល ស្លឹកតើយ ធ្វើដូចខ្ញុំជារបស់ដ៏គួរឲ្យខ្ពើមរអើម ។

"មិនគិតចង់ងូតទឹកផ្លាស់ខោអាវទេឬ?"

នោះអី ពេលខ្ញុំនិយាយដល់រឿងនេះនាងក៏រឹងខ្លួន ធ្វើដូចមិនបានឮយ៉ាងអីចឹង ។

"ឈុតនោះពាក់ពេញមួយថ្ងៃហើយ មិនស្អិតខ្លួនចង់ងូតទឹកផ្លាស់ខោអាវទេឬយ៉ាងម៉េច"

"មិនចង់ ខ្ញុំមិនស្អិតខ្លួន មិនចង់ងូតទឹក"

"ស្មោគគ្រោក"

"ព្រមទទួលស្គាល់"

ខ្ញុំគ្រឹមភ្នែកមើលមនុស្សស្រីដែលប្រកែកមួយម៉ាត់មិនធ្លាក់ដល់ដី ហើយក៏ញាក់ស្មា មុននឹងដើរទៅលើកបីមនុស្សក្បាលរឹងស្លឹកតើយ ក៏ស្រែកឡូឡានិងរើបម្រះ ។

"បើធ្លាក់បាក់ក មិនទទួលខុសត្រូវទេ" ខ្ញុំគំរាម ។

"ចង់ធ្វើស្អីទៀត ដាក់ខ្ញុំចុះទៅ"

"នាំទៅងូតទឹក នាងអាចសុខចិត្តនៅស្មោគគ្រោកបែបនេះ តែខ្ញុំមិនចូលចិត្តមនុស្សស្រីខ្លួនស្អុយ"

ខ្ញុំប្រាប់ ហើយក៏ឡើងជណ្តើរទៅបន្ទប់ ស្រីតូចក្នុងដៃក៏រើសស្រែកប្រាប់ ។

"ខ្ញុំមិនស្អុយទេ មិនបាច់ងូតក៏បាន"

ខ្ញុំទប់ជើងពេលកំពុងតែឡើងជណ្តើរកាំទីមួយ និងឈ្ងោកមើលមុខស្រស់ស្រទន់របស់មនុស្សស្រីដែលដកដង្ហើមហត់តយូសប្រហែលទាំងខ្លាចទាំងញ័រ...ពន្លឺភ្នែករបស់នាងប្រាប់បែបហ្នឹង ។

"អីចឹងឲ្យខ្ញុំហិតសិនមើលថាស្អុយឬអត់"

"កុំយ!"

ខ្ញុំឱនទៅរកថ្ពាល់ម៉ដ្ឋខៃ ដែលមានសរសៃឈាមពណ៌ផ្កាឈូកឲ្យរោម នាងក៏គេចសព្វគ្រប់ ដៃនៅតែរុញចង្កាខ្ញុំ តែទោះបុងច្រមុះមិនបានសង្កត់លើថ្ពាល់ម៉ដ្ឋខៃនោះដើម្បីបោសអង្អែល ក៏ក្លិនក្រអូបប្រហើរគ្មានសារធាតុគីមីឆ្អួលដូចទឹកអប់ទូទៅ នៅតែចូលមកក្នុងច្រមុះដដែល ក្រអូបមែនទែន...ចង់ស៊ីមែនទែន ខ្ញុំភ្ញាក់ណាស់ ។

"កុំ"

"សុំថើបមួយខ្សឹតក៏មិនបាន កំណាញ់"

ខ្ញុំព្រមបញ្ឈប់ ហើយធ្វើជាដកដង្ហើមធំ តែពេលនាងដាក់ដៃចុះព្រោះគិតថាមានសុវត្ថិភាពហើយ ខ្ញុំក៏អាស្រ័យពេលដែលនាងភ្លេចខ្លួនឱនទៅថើបថ្ពាល់នោះឮឡឹត ។

វាទាំងទន់ល្មើយ ទាំងក្រអូប ខ្ញុំមិនត្រឹមតែថើបធម្មតាៗនោះទេ នៅមានចេតនាសង្កត់បបូរមាត់និងច្រមុះខ្លាំងៗលើថ្ពាល់របស់នាងទៀតផង ។

"ត្រជាក់ចិត្ត...អឹម មិនស្អុយមែន"

"..."

អ្នកដែលភ្ញាក់ស្មៀតធ្វើអីមិនបានក្រៅពីធ្វើមុខមោយៗ និង

សម្លក់សម្លឹងខ្ញុំស៊ីងតែញៀនគ្រាប់ភ្នែក ហើយពេលដែលខ្ញុំឡើងជណ្ដើរបន្ត នាងក៏រហ័សស្រែកប្រាប់ ។

"ខ្លួនខ្ញុំមិនស្អុយហើយដាក់ខ្ញុំចុះទៅ មិនចាំបាច់ងូតទឹកទេ"

ខ្ញុំញាក់ចិញ្ចើមដាក់ មុននឹងញញឹមចុងមាត់ ហើយក៏ឡើងបន្តជារៀងៗ វង្វង់ដៃក៏រឹតរាងតូចទន់ល្មៀយបន្តិចទៀតពេលដែលតបតសម្ដីរបស់នាង ។

"ថ្ពាល់ហ្នឹងពិសោធជាមិនស្អុយ តែកន្លែងផ្សេងមិនទាន់បានថើបទើបមិនដឹង អាចស្អុយក៏ថាបាន ដូច្នេះហើយនាងត្រូវតែងូតទឹក ឬមិនអីចឹងឲ្យខ្ញុំថើបសព្វសាច់ បើក្រអូបដូចថ្ពាល់មែន នាងមិនចាំបាច់ងូតទឹកទេ"

"អីនចាច់!"

ស្រីតូចរបស់ខ្ញុំស្រែកឡូឡាដោយទឹកមុខស្រឡាំងកាំង...ជួយមិនបានទេ ចង់ធ្វើឫកគួរឲ្យចង់ញ៉េះធ្វើស្អី!

[End Intouch's Talk]

"អេ៎...ល្ងើរនេះទៅហើយម៉េចក៏ ស្លឹកតើយ មិនទាន់ឲ្យដំណឹងទៀត"

គ្រាប់ត្នោត រអ៊ូរទាំ ព្រមទាំងដើរទៅបើកទូរទស្សន៍មើល ចំណែក ក្ដាមខ្មៅ មិត្តម្នាក់ទៀតកំពុងតែអង្គុយលេងហ្គេមនៅក្នុងទូរសព្ទដៃ ។

"បន្តិចទៀតប្រហែលមកវិញហើយ"

ពួកគេទាំងពីរនៅក្នុងខុនដូរបស់ ស្លឹកតើយ នោះឯង ព្រោះជា...យប់មិញ ស្លឹកតើយ ប្រាប់រឿងដែលថ្ងៃនេះទៅចរចាជាមួយម្ចាស់...ណ្ឌលរបស់ម្ដាយ ទើបពួកនាងមកខុនដូនេះ ។

គ្រាប់ត្នោត ដែលមកដេកជាមួយមិត្តស្រស់ស្អាតរអ៊ូរទាំប្រាប់ ក្ដាមខ្មៅ ដែលមានឃីយ៍កាតសោរដែល ស្លឹកតើយ ទុកឲ្យ ។

"តែនេះម៉ោង៧ហើយ" គ្រាប់ត្នោត ខ្វល់ខ្វាយ ។

"សាកតេទៅរកម៉ាក់នាងមើល៍ ជួនកាលយប់នេះនាងអាចដេកនៅផ្ទះក៏ថាបាន បែបថាខ្ជិលបើកឡានទៅមកស្អីបែបនោះ"

"ខ្ញុំតេចូលទូរសព្ទដៃ ស្លឹកតើយ ហើយ តែនាងបិទទូរសព្ទ"

"អីចឹងតេចូលលេខផ្ទះទៅ"

"មែនហើយ..." គ្រាប់ត្នោត ដើរទៅយកទូរសព្ទដៃតេទៅលេខផ្ទះរបស់មិត្តភក្ដិភ្លាម បើដឹងថា ស្លឹកតើយ នៅផ្ទះនឹងអស់បារម្ភ ហើយបើមិត្តភក្ដិមិនមកដេកនៅខុនដូ នាងនឹងបានទៅផ្ទះវិញ មិនបាច់រង់ចាំ "សួស្ដីអ្នកមីង...ខ្ញុំ គ្រាប់ត្នោត មិត្តភក្ដិរបស់ ស្លឹកតើយ ...ចាំ ស្លឹកតើយ មិននៅផ្ទះមែនទេ ជួនអីខ្ញុំនៅខុនដូរបស់នាង"

គ្រាប់ត្នោត នៅស្ងៀមមួយស្របក់ មុននឹងបើកភ្នែកធំ ។

"ស្អីគេ ស្លឹកតើយ ទៅដើរលេងជាមួយគូដណ្ដឹង!"

ក្ដាមខ្មៅ ដាក់ទូរសព្ទក្នុងដៃចុះភ្លាម និងងាកខ្ទាប់ទៅមើលដោយការចាប់អារម្មណ៍ ។

"អឺ...ចាំ គ្មានអីទេ ហេះៗ អីចឹងអរគុណច្រើន ជម្រាបលាអ្នកមីង"

"យ៉ាងម៉េច?" ក្ដាមខ្មៅ សួរភ្លាម គ្រាប់ត្នោត ក៏ធ្វើមាត់ស្រួច។

"មានយ៉ាងម៉េច គឺ ស្លឹកតើយ ហ្នឹង មាត់ប្រាប់ថាមិនរៀបការ មិនចង់ធ្វើជាប្រពន្ធដោះបំណុល...តែមានពីអង្គាល់" គ្រាប់ត្នោត បង្អួសសំឡេងយ៉ាងវែង "នាងទៅដើរលេងជាមួយគូដណ្ដឹង និងប្រហែលមិនមកដេកខុនដូមួយរយៈ អីយ៉ា...ល្អណាស់ហ្ន៎ សមហាន់នីមូន"

៤

# រាត្រីទី១

[Intouch's Talk]

ខ្ញុំបីស្រីក្បាលរឹងមកមុខបន្ទប់ មុននឹងលើកដាក់លើស្មា ទាល់តែម្យ៉ាងគឺនាងរើបម្រះ ធ្វើឲ្យខ្ញុំបើកទ្វារបន្ទប់មិនកើត ។

"អីនចាច់! ធ្វើបែបនេះមិនបានទេ"

ធ្លាស់ផ្ញើមដូចជា ស្លឹកតើយ មានឬដែលព្រម នាងទាំងរើបម្រះ នៅមិនស្ងៀម ធ្វើឲ្យខ្ញុំត្រូវលើកដៃវាយកំភេះគូទរបស់នាងមិនឮមកខ្លាំងមួយដៃ ។

"ឈឺ អីនចាច់!"

នាងស្រែកចាច ហើយក៏គក់ខ្នងគក់ស្មាខ្ញុំមិនឈប់ តែខ្ញុំមិនញាប់ញ័រ មនុស្សប្រុសកម្ពស់១,៧៩ ម៉ែត្រ ថែមទាំងមានសាច់ដុំព្រោះឧស្សាហ៍ហាត់ប្រាណ មិនញាប់ញ័រនឹងកម្លាំងដូចស្រមោចរបស់ស្រីតូចទន់ល្មើយដូចជា ស្លឹកតើយ នោះទេ ។

ខ្ញុំសើចចូលចិត្ត ហើយវាដូចជាយកសាំងទៅជះលើភ្លើង ព្រោះថានាងកាន់តែរើបម្រះ និងទាត់ជើងដោយកំហឹង ។

"អូយ!"

នាងឧទានពេលដែលខ្ញុំដាក់ឲ្យឈរមុខបន្ទប់ទឹក ហើយក៏ថយក្រោយ និងមើលមុខខ្ញុំដោយការមិនទុកចិត្ត ។

"ចង់ចាប់រំលោភឬ?"

"ចុះព្រមទេ? កុំឲ្យពិបាកចាប់"

"មិនព្រម!"

"អីចឹងចាប់" ខ្ញុំប្រាប់ងាយៗ ។

"អា!!!"

នាងហែកមាត់ស្រែកកម្រិត១០០០ដេស៊ីប៊ែល ធ្វើឲ្យខ្ញុំស្ទុះទៅសង្រួបបិទមាត់ហើយស្តីឲ្យ ។

"ស្រែកធ្វើអី មិនធ្វើទេ"

យ៉ាងហោចណាស់ក៏មិនមែនពេលនេះ...ខ្ញុំបន្តនៅក្នុងចិត្ត ។

ស្លឹកតើយ មើលមកខ្ញុំយ៉ាងប្រុងប្រយ័ត្ន ចំណែកដៃរបស់ខ្ញុំបិទមាត់នាងជាប់...ជាប់ហើយ! ធ្លាក់ត្រឹមប៉ះត្រូវបបូរមាត់ទន់ល្មើយរបស់នាង ខ្ញុំនៅមានអារម្មណ៍ប្លែកៗ វាល្អប៉ុណ្ណាទៅហ្ន៎បើបបូរមាត់ទន់ល្មើយរបស់ ស្លឹកតើយ បពោសអង្អែលរាងកាយខ្ញុំកន្លែងផ្សេងទៀត ដូចជា...

"គ្រាន់តែនាំមកងូតទឹកធម្មតាៗ ខ្ញុំចុះទៅចាំនៅខាងក្រោម... ខោអាវរៀបចំទុកឲ្យហើយ ខោអាវខ្ញុំហ្នឹង នាងគួរតែពាក់បាន ងូតទឹកហើយចុះទៅខាងក្រោម សន្យាថាមិនរំលោភទេ"

"អឺមៗ" អ្នកដែលត្រូវបិទមាត់ងក់ក្បាលញាប់ស្អេក ទើបខ្ញុំដកដៃចេញពីមាត់របស់នាងទាំងសោកស្ដាយ និងអត់មិនបានពិតមែនដែលយកដៃនោះមកថើបមកហិត ។

"ក្រអូប"

ហើយក៏បានផល...ស្លឹកតើយ សម្លក់សម្លឹងខ្ញុំ ហើយក៏រត់ចូលបន្ទប់ទឹកភ្លាម សំឡេងចុចសោពន្លឹកក៏បន្លឺឡើង ។

ពេលនេះស្រីតូចរបស់ខ្ញុំប្រហែលជាឈរញ័រពេះដូង ព្រោះខ្លាចក្រែងខ្ញុំសម្រុកចូលទៅរំលោភក្នុងបន្ទប់ទឹកមិនខាន ។

"ស្លឹកតើយ...ងូតទឹកឲ្យលឿន បើយឺតយ៉ាវខ្ញុំនឹងចូលទៅតាមជួនអីខ្ញុំមានកូនសោ"

"ឆ្កួត!"

សំឡេងស្រែកតបនោះធ្វើឲ្យខ្ញុំញញឹមញញែម ហើយដើរមកវិញ ចេញពីបន្ទប់នោះដោយអារម្មណ៍រីករាយ ។ នេះបើ គឺតែ មក

ឃើញ ប្រហែលជាចាប់ខ្ញុំបញ្ជូនទៅមន្ទីរពេទ្យឆ្កួតមិនខាន ត្រូវតែ
ត្រូវស្តី តែបែរជាមានក្តីសុខនេះ!

[End Intouch's Talk]

ខ្ញុំងូតទឹកយ៉ាងលឿន ព្រោះខ្លាចអ្នកដែលគំរាមធ្វើដូចដែលគេប្រាប់មែន ។ គឺនេះជាផ្ទះរបស់គេ គេច្បាស់ជាមានកូនសោស្រាប់ទៅហើយ ។

ពេលងូតទឹករួច និងរុំកន្សែងពោះគោ ក៏មិនហ៊ានចេញពីបន្ទប់ទឹក ត្រូវបើកទ្វារហើយអើតមុខទៅមើលសិន ពេលគ្មានប្រុសមាឌធំរាងខ្ពស់នៅក្នុងបន្ទប់ដេក ខ្ញុំក៏រត់យ៉ាងលឿនទៅចាក់សោទ្វារបន្ទប់ដេក ហើយមកឈរដកដង្ហើមធំនៅក្បែរគ្រែ ។

"..."

ភ្នែកក្រឡេកមើលអាវយឺតពណ៌ស និងខោជំណេកពណ៌ផ្ទៃមេឃដែលបត់ទុកយ៉ាងមានរបៀបនៅលើគ្រែ ។

ខ្ញុំសម្រេចចិត្តពាក់អាវក្នុងដដែល ចំណែកខ្សែងក្រោម...វា... ហ៊ឺយ មិនដឹងថាស្អែកនេះអាឆ្កួតនោះព្រមនាំខ្ញុំទៅផ្ទះវិញឬអត់ បើចង់គេចចេញពីទីនេះដោយគ្មានប្រាក់គ្មានទូរសព្ទដៃ និងក្នុងពេលវេលាបែបនេះ គឺដូចមានចេតនាចេញទៅបញ្ឆោតពួកទុច្ចរិត ឬពោរឆ្កួតកាមច្បាស់ណាស់ ខ្ញុំមិនល្ងង់ធ្វើនោះទេ ។

"ល្ហើយចុះ ត្រឹមមួយយប់នេះ ស្អែកចាំរកវិធីយកទូរសព្ទដៃគេទៅប្រាប់ ភ្លាមខ្មៅ ឬ គ្រាប់ត្នោត ឲ្យមកយក"

ខ្ញុំលួងលោមខ្លួនឯង ហើយរហ័សស្លៀកពាក់ឲ្យរួចរាល់ ដើរចេញពីបន្ទប់ដេកចុះទៅជាន់ក្រោម បើយឺតយ៉ាវមានសង្ស័យថាត្រូវអាម្សៀនោះតាមមិនខាន ហើយវាមិនល្អនោះទេបើនៅក្នុងបន្ទប់ជាមួយ អ៊ិនថាច់ តែពីរនាក់បែបនេះ ។



ខ្ញុំចុះជណ្តើរមកខាងក្រោម ឃើញ អ៊ិនថាច់ អង្គុយនៅលើសាឡុង លើភ្លៅមានចានឆីរ៉ និង...

ហៀក!

"ងូតទឹករួចហើយឬ"

អ៊ិនថាច់ សួរ ព្រមទាំងងាកមកមើល គេមិនបានពាក់អាវ ស្លៀកតែខោជំណេកជើងវែង បង្ហាញសាច់ដុំពោះនិងចុងដោះពណ៌ផ្កាឈូក...អ៊ើយ...ទើបតែដឹងថាក្បាលដោះរបស់មនុស្សប្រុសក៏ធ្វើឲ្យយើងមានអារម្មណ៍ថាគេសិចស៊ីបានដែរ ( តាមពិតខ្ញុំក៏មិនធ្លាប់ឃើញក្បាលដោះអ្នកណាក្រៅពីខ្លួនឯងដែរ ) ថ្ងៃមុនពេលនៅខុនដូ គេក៏ខនលតក តែជាពេលនោះខ្ញុំមិនបានសម្លក់សម្លឹងដូចថ្ងៃនេះ ព្រោះរវល់តែភ័យ ។

"មកអង្គុយត្រង់នេះម៉ោ...មើលបាល់ទេ ?"

ទូរទស្សន៍ទំហំ៥០អ៊ីញបង្ហាញឲ្យឃើញរូបភាពបាល់ទាត់ ។

"ខ្ញុំមិនចូលចិត្តមើលបាល់"

ខ្ញុំកុហក ទាំងដែលពេលនេះដកខ្សែភ្នែកចេញពីអេក្រង់មិនបាន នោះជា...ក្រុមដែលខ្ញុំគាំទ្រ ។

"អ៊ីចឹងមើលរឿង"

បុរសសង្ហានិយាយ ហើយក៏ទាញតេឡេប្តូរប៉ុស្តិ៍ ពេលនោះកីឡាករកំពូលសង្ហាភ្នែកមុតដែលខ្ញុំគ្រឹត ឈ្លក់វង្វេងនឹងសមត្ថភាពរួមទាំងភាពសង្ហាដែលត្រូវកាមេរ៉ាចាប់យកមុខ គេកំពុងតែយារជើងទាត់បាល់ល្មម ។

"កុំ!"

ខ្ញុំស្រែកហាមអស់សំឡេង និងស្ទុះទៅអង្គុយនៅលើសាឡុងយ៉ាងលឿន ដណ្តើមតេឡេពីគេបានហើយក៏ឱបជាប់ដោយការហួងហែង ផ្ទង់សមាធិមើលកីឡាក្នុងដួងចិត្តយ៉ាងយកចិត្តទុកដាក់

ព្រោះដូច្នេះហើយទើបមិនឃើញស្នាមញញឹមរបស់មនុស្សកំហុងដែលអង្គុយនៅក្បែរខ្លួន ។

"អាមុខគ្រូង! ម៉េចក៏ទាញអាវប្ដីខ្ញុំ អឺ..."

"វ៉ាវៗ បន្តិចទៀត ហ្នឹងហើយៗ ញាក់ដាច់ហើយ ឃើញទេៗ"

"អាំ! ពូកែមែនទែន"

ខ្ញុំស្រែកពេលប្ដីក្នុងក្ដីស្រមៃទាត់បាល់ចូលទីបាន សំឡេងហ៊ោបន្លឺឮពេញកីឡដ្ឋាន ខ្ញុំក៏ជ្រួលណាស់ដែរ...អ្នកនៅក្បែរខ្លួនក៏អង្គុយមើលជាមួយ យើងមើលយ៉ាងភ្លើតភ្លើន...តាមពិតខ្ញុំម្នាក់ឯងដែលភ្លើតភ្លើន ចំណែក អ៊ីនថាច់ គេញ៉ាំបណ្ដើរមើលបណ្ដើរ ។

ពេលក្រុមដែលខ្ញុំគាំទ្រនាំមុខពីរទល់នឹងមួយ ខ្ញុំក៏ដកដង្ហើមធំធូរទ្រូង ហើយងាកទៅមើលអ្នកអង្គុយក្បែរ...កែវភ្នែកមុតស្រួចនោះសម្លឹងមើលខ្ញុំមុនរួចទៅហើយ ។

"អឺ..."

"ទឹកក្រូចទេ?" អ៊ីនថាច់ សួរ មើលទៅដូចដឹងថាខ្ញុំកំពុងតែអាម៉ាស់ដែលបង្ហាញអាកប្បកិរិយាជ្រួលជ្រើមនឹងបាល់ទាត់ខ្លាំងពេក ។

"ក៏ល្អ"

គេដើរទៅយកទឹកក្រូចកំប៉ុងមកហុចឲ្យ វាត្រជាក់ស្រេង ខ្ញុំគាស់ហើយក៏លើកផឹកក្លឹកៗភ្លាម រួចក៏លើកខ្នងដៃជូតបបូរមាត់ ។

"ញ៉ាំទេ?"

អ្នកដែលឧស្សាហ៍បម្រើពន់ពេកហុចបានឆីរមកឲ្យ ខ្ញុំមើលផ្លែឈើដែលចូលចិត្តមួយមុខទៀត ហើយក៏ជ្រួញចិញ្ចើម ពេលនៅក្នុងហាងគេក៏កុម្ម៉ង់តែអាហារដែលខ្ញុំចូលចិត្ត វាចៃដន្យពេកដែរទេ!

"នេះបើបងនិយាយជាមួយម៉ាក់ខ្ញុំយូរជាងនេះពីរម៉ោងទៀតប្រហែលជាដឹងហើយ

"..."

គេញញឹមទៀតហើយ បេះដូងខ្ញុំលោតញាប់ដូចគ្នា បើសិនគេឧស្សាហ៍ញញឹមបែបនេះញឹកញាប់ ជំនួសការនិយាយស្ដីបេះបួយ និងធ្វើឫកមុខចង់លោតសង្គ្រុបខ្ញុំគ្រប់ពេលនោះ...ខ្ញុំប្រហែល...

ប្រហែលស្លុង! នេះខ្ញុំកើតអី ត្រឹមមួយថ្ងៃដែលនៅជាមួយនឹងអាម្សៀនេះ ហេតុអីចិត្តងាយដល់ថ្នាក់នេះ?

"បាល់ម៉ោហើយ"

ខ្ញុំរហ័សងាកទៅចាប់អារម្មណ៍កីឡានៅក្នុងទូរទស្សន៍ម្ដងទៀត និងព្យាយាមមិនងាកទៅមើលគេ ចូលដល់តង់ទីពីរក្រុមសំណព្វចិត្តរបស់ខ្ញុំជាអ្នកចាញ់ប្រៀប ហើយក៏ត្រូវខាងគេតាមទាន់ដោយលទ្ធផលពីរទល់នឹងពីរ ។

ខ្ញុំអង្គុយសម្លឹងអេក្រង់ទូរទស្សន៍មិនប៉ប្រិចភ្នែក មិនប៉ុន្មាននាទីទៀតនឹងចប់ហើយ កីឡាករសង្ហាខាងព្រលឹងដែលខ្ញុំឈ្លក់វង្វេងគ្រប់គ្រងបាល់ម្ដងទៀត គេក៏បោះជើង ហើយក៏...ប៉ិប! ទាត់ចូលទីឆាសដៃអ្នកចាំទីទាំងប្រផុតប្រផើយ ។

"អាំ!"

"អាំ!"

ខ្ញុំស្រែកបាច និងងាកទៅឱបអ្នកដែលស្រែកដោយការពេញចិត្តដូចគ្នាដោយការសប្បាយចិត្ត ហើយយើងក៏ឱបគ្នាអង្រួនខ្លួនឡើងញ័រទទ្រើត ។

"ឈ្នះហើយ ឈ្នះហើយ អាំ...គឺ...អឺ"

ងាប់ហើយ! នេះខ្ញុំធ្វើស្អីហ្នឹង?

ខ្ញុំចំហមាត់ធ្លុង ងើយមុខចេញពីទ្រូងរបស់មនុស្សប្រុសដែលមិនបានពាក់អាវដែលខ្លួនឯងផ្ទប់មុខនិងស្រែកដោយការសប្បាយចិត្តឃើតៗ ចំណែកដៃទាំងពីររបស់ខ្ញុំឱបរាងកាយដែលតឹងណែន

ទៅដោយសាច់ដុំ ។

ខ្ញុំងើយមុខយឺតៗមើលអ្នកដែលដូចជាដឹងខ្លួនដូចគ្នា ។

អ៊ីនថាច់ ក៏ឱនមកមើលខ្ញុំ ថ្ពាល់របស់គេក្រហម...

គេអៀន ? ព្រះជាម្ចាស់! មនុស្សប្រុសដូច អ៊ីនថាច់ ចេះអៀនដែរ អាបិសាចព្រេតកាមដែលខ្ញុំត្រូវគេចដើម្បីយករួចខ្លួនតាំងពីរសៀលមកដល់ពេលនេះក៏ចេះអៀនដែរ ។

"អឺ...បើនាងនៅតែឱបខ្ញុំណែនបែបនេះ យក៣៤មកបៀតខ្ញុំបែបនេះ...វាមិនល្អទេ"

"វ៉ាយ! អឺ..."

ខ្ញុំងើបពីសាឡុងភ្លាម មុខក៏ក្ដៅភាយៗ និងលើកដៃអង្អែលទ្រូងលួងលោមចិត្តខ្លួនឯង...ព្រលឹងប្អូនដប់ចូលមកវិញភ្លាម!

"បាល់ចប់ហើយ យប់ជ្រៅហើយទៅដេកទៅ"

ខ្ញុំងាកឡាប់ទៅមើលនាឡិកា នេះវាជាស្អី ពេលវេលាកន្លងផុតទៅលឿនដល់ថ្នាក់នេះឬ ព្រោះតែបាល់ទាត់ទើបធ្វើឲ្យខ្ញុំសប្បាយដល់ភ្លេចការភ័យខ្លាច និងភ្លេចថាខ្លួនឯងត្រូវបឺមកទាំងមិនបានពេញចិត្តអីបន្តិច ។

"ទៅដេកទៅ"

អ៊ីនថាច់ ងើបឈរពត់ខ្លួនពត់ប្រាណ ហើយក៏ហាមាត់ស្ងាប... នោះ...ជាការធ្វើពុតច្បាស់ណាស់ គេមិនបានស្ងាបមែនទែនទេ មុខសង្ហារបស់បុរសសក់ស៊ើងម៉ើងដល់ថ្នាក់មើលមិនដឹងថាជាអ្នកជំនួញពោរពេញដោយសមត្ថភាព ឈឺ អ៊ីនថាច់ ញញឹមដាក់ខ្ញុំ មុននឹងដើរមករក ។

"ទៅដេកទៅ"

ហ៊ឹម ?

"អឺ មិនទាន់ងងុយទេ នេះអឺ មានបាល់មួយគូទៀត ខ្ញុំសុំមើលទៀត"

ខ្ញុំក្រឡេកមើលទូរទស្សន៍ ហើយក៏រហ័សដើរទៅអង្គុយ លើកនេះស្រវាយកខ្នើយផ្អែកមកឱប ហើយក៏អង្គុយក្រញ៉ុំខ្លួន ភ្នែកសម្លឹងមើលទៅខាងមុខតែម្យ៉ាង ទាំងដែលបេះដូងលោតផុកផាក់ ។

"អីចឹងខ្ញុំមើលក៏ដែរ"

អ៊ីនថាច់ ទម្លាក់ខ្លួនអង្គុយតាម ខ្ញុំក៏ងក់ក្បាល ហើយខិតចេញឲ្យឆ្ងាយពីគេម្ដងបន្តិចៗ ។

[Intouch's Talk]

ខ្ញុំក្រឡេកមើលអ្នកដែលអង្គុយបត់កនៅក្បែរ នៅពីមុខទូរទស្សន៍ដែលនៅតែចាក់ផ្សាយការប្រកួតបាល់ទាត់ តែអ្នកដែលប្រាប់ថានឹងមើលបាល់បន្តបែរជាលង់លក់ទៅវិញ ថែមទាំងអង្គុយទន់ខ្លួនទៀតផង ។

ប្រឹងទ្រាំងងុយដល់ថ្នាក់ទ្រាំលែងបានហើយ ស្លឹកតើយ!

ខ្ញុំគ្រវីក្បាល នេះនាងប្រហែលជាខ្លាចការដេកនៅក្នុងបន្ទប់ជាមួយខ្ញុំខ្លាំង ដែលតាមពិតមានបន្ទប់ដេកពីរ ហើយខ្ញុំក៏មានចេតនាទៅដេកនៅបន្ទប់ផ្សេងដែរ តែដែលមិនបានប្រាប់ព្រោះចង់បោកឲ្យខ្លាចលេង ។

"ស្លឹកតើយ...ស្លឹកតើយ ទៅដេកក្នុងបន្ទប់"

ខ្ញុំប្រាប់ពេលរាងតូចស្ទើងទោរទន់ទៅមក រហូតដល់ជ្រប់នឹងសាឡុង ហើយរើលខ្លួនដេកយ៉ាងមានសេចក្ដីសុខ បបូរមាត់ផ្អែមនោះក៏ធ្វើមួបៗ ។

"ស្លឹកតើយ"

"..."

គ្មានការតបទទួល ម្យ៉ាងទៀតដែលខ្ញុំទើបតែដឹងពាក់ព័ន្ធនឹង

ស្លឹកតើយ គឺនាងជាមនុស្សដេកទ្រមក់យ៉ាងកំណាច ។ ខ្ញុំងើបឈរ លើកជើងនាងដាក់លើសាឡុង សំណាងល្អដែលនាងមិនបានខ្ពស់ពេក សាឡុងនេះក៏ធំនិងទន់ល្មើយណាស់ដែរ បន្ទាប់មកខ្ញុំក៏ដើរទៅជាន់លើដើម្បីយកភួយពណ៌សមកដណ្ដប់ឲ្យ អត់គិតអាក្រក់បន្តិចមិនបានពេលដែលទាញភួយដណ្ដប់ដល់ទ្រូងឲ្យនាង ។

"រំលោភល្អទេ ដេកលក់ដូចងាប់បែបនេះ ភ្ញាក់ឡើងម្ដងទៀតមានប្ដីពេញរូបពេញរាង"

អ្នកដែលដេកលក់នៅតែដកដង្ហើមថេរមិនដឹងរឿង ខ្ញុំញញឹមដាក់មនុស្សស្រីនៅចំពោះមុខ ហើយបិទភ្លើងដើរទៅមុខសាឡុងព្រំស្បែកខ្លានោះក្រាស់ទន់ល្មើយគួរសម ទើបខ្ញុំយកខ្នើយផ្អែកមកតើយ ហើយដេកបែរមុខទៅរកសាឡុង មុននឹងលូកដៃទៅស្រាវយកតេឡេមកបិទទូរទស្សន៍ ។

ព្រមទទួលស្គាល់ថាដេកដោយមានក្លិនក្រអូបនិងសំឡេងដកដង្ហើមរបស់មនុស្សស្រីឈ្មោះ ស្លឹកតើយ នៅជិតៗបែបនេះវាពិបាកនឹងដេកលក់ខ្លាំងណាស់ ។

ភ្លុក!

"!!"

ខ្ញុំភ្ញាក់ព្រើតភ្លាមទាំងដែលទើបតែដេកលក់រលីវៗ មានអ្វីម្យ៉ាងធ្លាក់មកលើខ្លួនខ្ញុំ...រាងតូចស្ដើងទន់ល្មើយនិងក្រអូប ថែមទាំងធ្លាក់ពីសាឡុងមកនៅលើដើមទ្រូងរបស់ខ្ញុំល្មម ។

"កញ្ញា! ដេកដល់ថ្នាក់ធ្លាក់ហើយ នៅមិនដឹងខ្លួនទៀត"

ខ្ញុំថ្ងូចថ្ងូរ មុននឹងលូកដៃប្រែខ្លួនអ្នកដែលដេកសង្កត់ខ្លួនឯងទាំងមូល សូមបញ្ជាក់...គឺទាំងមូល! ឲ្យមកដេកក្បែរ ឲ្យនាងកើយដៃរបស់ខ្ញុំជំនួស ។

ខ្ញុំដេកផ្អៀងមើលមុខនៅក្រោមពន្លឺភ្លើងព្រាលៗ ចំមែន...ខ្ញុំ

គិតដោយចិត្តភ្ញាក់ភ្ញាញ់ មើលចុះ ធ្វើឫកតើយខ្លាចប្រុងប្រយ័ត្នពេញបន្ទុក តែខ្លួនឯងបែរជាដេកលក់មិនដឹងរឿង ថ្នាក់ធ្លាក់មកសង្កត់ខ្ញុំហើយ នៅមិនភ្ញាក់ទៀត អឺម...

"..."

ខ្ញុំយកច្រមុះទៅផល់នឹងច្រមុះស្រួចខើចរបស់ ស្លឹកតើយ និងព្រមុសតិចៗ ពេលដែលកម្រើកខ្លួនទាញនាងមកឱបបន្តិចទៀតក៏មិនភ្ញាក់ ល្អ...ខ្ញុំញញឹមដាក់ខ្លួនឯង មុននឹងលោមុខទៅជិតបន្តិចទៀត សង្កត់ច្រមុះលើថ្ពាល់របស់នាង ហើយក៏ស្រូបយកក្លិនចូលឲ្យពេញសួត ។

"..."

បន្តិចទៀតទៅចុះ...ខ្ញុំគិតហើយក៏លោមុខទៅរកក ក្លិនខ្លួនមនុស្សស្រីធ្វើឲ្យបេះដូងខ្ញុំលោតញាប់ ព្រមទាំងក្ដៅដោយអារម្មណ៍ធម្មជាតិទាមទាររបស់មនុស្សប្រុស ខុសគ្នាត្រង់ពេលនេះវាក្ដៅជាងរាល់ដងនៅក្នុងជីវិតវ័យកំលោះ វាលុកលុយខ្ញុំយ៉ាងខ្លាំង...ខ្ញុំសង្កត់បបូរមាត់នឹងចង្កាតូច មិនមែនមិនចង់ថើបបបូរមាត់ផ្អែមនោះទេ តែបើថើបហើយចំណីភ្ញាក់ដឹងខ្លួន...ខ្ញុំមុខជាអត់ ។

ខ្ញុំរំកិលមកថើបចុងចង្កាតូច ត្រង់ថ្ពាល់ ត្រង់ថ្ពាម និងសង្កត់ច្រមុះនិងប្រឡោះកក្រអូបនោះយូរជាងកន្លែងផ្សេង ។

បើសួរថាចង់ទេ...ប្រាប់បានថាចង់ខ្លាំងណាស់!

បើសួរថាត្រូវការទេ...សុំប្រាប់ថាត្រូវការខ្លាំងបំផុត!

ជាលើកដំបូងនៅក្នុងជីវិត ដែលចង់សាករំលោភមនុស្សស្រីដែលមិនព្រមសហការមើលបានម្ដង ។

"អ៊ឺម"

សំឡេងថ្ងូចថ្ងូរពុតិចៗ អាចធុញទ្រាន់ដែលខ្ញុំញៀវញៀវនឹងខ្លួនប្រាណរបស់នាង ប៉ុន្តែ ស្លឹកតើយ នៅតែមិនភ្ញាក់...

អឹម...ខ្ញុំហាមាត់ខាំសាច់ត្រង់កនោះ ហើយក៏បឺតជញ្ជក់ខ្លាំងៗ មុននឹងលែង ហើយសម្លក់សម្លឹងស្នាមនោះដោយការពេញចិត្ត ។

ត្រង់ចំបូងដែលខ្ញុំកក់...

"..."

មនុស្សសម្លឹកងាកខ្លួនបន្តិច ដៃស្រឡូនក៏លើកមកឱបចង្កេះខ្ញុំ ស្លឹកតើយ កម្រើកខ្លួននៅមិនសុខ ជ្រប់មុខនឹងដើមទ្រូងរបស់ខ្ញុំ ធ្វើហាក់ដូចធុញទ្រាន់ចំពោះការរំខាន ។

ប៉ុណ្ណឹងសិនក៏បាន អាណិត...ថ្ងៃនេះជួបនឹងរឿងជាច្រើនហើយ ។ ខ្ញុំលូកដៃទៅទាញភួយពណ៌សចេញពីសាឡុង ហើយយកមកដណ្តប់ឲ្យពួកយើងទាំងពីរ មុននឹងបិទភ្នែកបន្ទាប់ពីសង្កត់ច្រមុះនឹងសក់ក្បាលរបស់នាងម្តងទៀត ។

"អាំ!"

សំឡេងមនុស្សស្រីដែលបន្លឺឡើងនៅក្បែរត្រចៀក ធ្វើឲ្យខ្ញុំភ្ញាក់ពីយល់សប្តិដ៏ផ្អែមល្ហែមភ្លាម ។

"ស្អីគេ?"

ការភ្ញាក់ផ្អើលធ្វើឲ្យខ្ញុំស្រែកសួរ ហើយក៏ដកដង្ហើមធំ ពេលឃើញថាវាគ្មានស្អីគ្រោះថ្នាក់កើតឡើងចំពោះអ្នកដែលដេកក្បែរ ។

ស្លឹកតើយ ភ្ញាក់ហើយក៏ឆ្លេឆ្លាងើបទៅអង្គុយនៅជិតជញ្ជាំងបន្ទប់តែម្តង ។

"ម៉េចក៏យើងមកដេកឱបគ្នាបែបនេះ!" នាងស្រែកសួរដោយសំឡេងញ័រតែម្តង ។

"គឺនាងចុះមកក្រោមដោយខ្លួនឯង ដំបូងនាងដេកនៅលើនោះ" ខ្ញុំចង្អុលសាឡុងនៅក្បែរ ។

"មិនពិត"

"ពិតបំផុត នាងជាអ្នកចុះមករកខ្ញុំ ថែមទាំងឱបខ្ញុំណែនដៃ

នេះស្នាមអង្អែលខ្លួនប្រាណខ្ញុំ ដល់ថ្នាក់ខ្ញុំ...គិតហើយក៏ព្រឺសម្បុរ"

ស្លឹកតើយ បើកភ្នែកធំៗ មុននឹងមើលខ្លួនប្រាណរបស់ខ្ញុំដោយកែវភ្នែកមូលក្លំរបស់នាង ។

"ថែមទាំងថើបថ្ពាល់ខ្ញុំទៀតផង រីះតែថើបមាត់ខ្ញុំទៅហើយ សំណាងដែលខ្ញុំងាកមុខចេញទាន់" ខ្ញុំកុហកបន្ត តែមើលទៅនាងដូចមិនជឿប៉ុន្មាន ។

នាងមើលខ្ញុំដោយការសង្ស័យបំផុត យើងមើលគ្នាបែបនោះអស់ជាច្រើននាទី ពេលនោះឯងដែលខ្ញុំទើបតែឃើញថា ស្លឹកតើយមិនបានត្រឹមតែស្អាតគួរឲ្យស្រឡាញ់តែម្យ៉ាងនោះទេ នាងនៅសិចស៊ីខ្លាំងទៀតផង ។ ជាការពិតដែលខ្ញុំធ្លាប់ឃើញនាងនៅក្នុងសភាពមានតែឈុតក្នុងបិទបាំងខ្លួនប្រាណ ប៉ុន្តែធៀបនឹងពេលនេះ ភាពសិចស៊ីរបស់នាង វាចំជា..មុខពងក្រពើដែលមានសរសៃសក់សើមម៉ឺងក្រសោប កែវភ្នែកដែលមើលមុខខ្ញុំដោយមិនជឿ និងបបូរមាត់ផ្អែមដែលចំហឃើញអណ្តាតពណ៌ផ្កាឈូកនៅខាងក្នុង...អាវរបស់ខ្ញុំដែលនាងពាក់ វាធំជាងខ្លួននាងឆ្ងាយណាស់ ចំណែកកអាវមូលដែលធ្លាក់ពីស្មាម្ខាង បង្ហួតសាច់សត្រង់តល់ទ្រូងនិងស្មាបន្តិច ។

កបស់នាងមានស្នាមថើបរបស់ខ្ញុំ ធ្វើឲ្យខ្ញុំក្តៅពេញមុខ និងវាលមកដល់ក មុននឹងចុះទៅខាងក្រោមជាបឿយៗ ទៅរកប្រឡោះជើងរបស់ខ្ញុំ...អាវរបស់ដែលពេលព្រឹកវាភ្ញាក់ដឹងខ្លួនតាមធម្មជាតិ ពេលនេះដូចជាចង់ផ្ទុះឲ្យបាន ពេលបានឃើញ ស្លឹកតើយ ដែលហាក់ដូចងុតហឿហៀមុនដោកខ្លួន ។

"ណាមក!"

សុខៗនាងក៏ស្រែក ហើយលើកដៃបិទភ្នែក ធ្វើឲ្យខ្ញុំជ្រួញចិញ្ចើមឈ្ងោកមើល **អាណាមក** ដែលបះឆ្កិតបង្ហួតប្រវែងរបស់វានៅក្នុងខោជំណោកដ៏រលុង...វាបង្ហាញខ្លួនយ៉ាងសង្ហា ។

"វាជួយមិនបានទេ ភជា..."

"ឆ្កួតមែន!"

ស្លឹកតើយ ប្រាប់ហើយក៏ស្ទុះលោតឡើងជណ្តើរទៅជាន់លើ។ ខ្ញុំមិនបានតាម តែផ្តួលខ្លួនដេកកើយដៃ បិទភ្នែកនិងខាំធ្មេញទប់អារម្មណ៍ ។ ដែលខ្ញុំមិនរត់តាម មិនមែនជាខ្ញុំមិនចង់តាមទាន់ជាមួយនាងនោះទេ តែខ្ញុំដឹងថាបើខ្ញុំតាមទៅដល់បន្ទប់ ខ្លាចបារមិនចប់ត្រឹមតែការប្រកែក ពេលមានគ្រែ និង ស្លឹកតើយ នៅជាមួយគ្នាហើយ វាមានន័យដល់...កម្មពៀរ!

ខ្ញុំខទានមុននឹងខាំមាត់ ទប់អារម្មណ៍ត្រេកកាមដែលក្រាស់ក្រាល់នេះឲ្យស្ងប់...ពេលឈ្ងោកមើលខ្លួនឯងឃើញអាបះផ្អើតនោះ ហើយក៏...ងូតទឹកត្រជាក់ពេលព្រឹកអាចជួយបាន ទើបខ្ញុំដើរទៅបន្ទប់ទឹកដែលមាននៅជាន់ក្រោម ហើយក៏ងូតទឹក ។

បន្ទាប់ពីនោះក៏ជូតខ្លួន រុំកន្សែងពោះគោ ហើយក៏ដើរចេញមកពេលបាត់ត្រេកកាមហើយ ។ ចំណែកពោះក៏ឃ្លាន ទើបធ្វើអាហារពេលព្រឹកសាមញ្ញៗទុកឲ្យនាងប្រមក់ដែរ ។

ខ្ញុំឆ្អើរចរាល់ល្មម ហើយក៏កំពុងតែចាក់ទឹកក្រូចប្រអប់ដាក់កែវ ពេលដែល ស្លឹកតើយ ដើរចុះជណ្តើរពីជាន់លើក្នុងឈុតដេកកាលពីព្រឹកដដែល ប៉ុន្តែមុខពងក្រពើនោះស្រស់ស្រាយ គិតថានាងប្រហែលទៅងូតទឹកដូចខ្ញុំដែរ តែជាហេតុផលតែមួយឬអត់នោះ អានេះខ្ញុំមិនដឹង!

"ឃ្លានទេ ញ៉ាំអាហារពេលព្រឹកសិន"

"ពេលណាទើបយើងត្រឡប់ទៅវិញ ?"

"ត្រឡប់ ?...ត្រឡប់ទៅណា ?"

ស្លឹកតើយ ដើរមកឈរនៅជ្រុងម្ខាងទៀតនៃតុដែលខ្ញុំដាក់ចានអាហារពេលព្រឹក ។ ប្រាប់បានថាពេលព្រឹកការត្រូវពន្លត់កម្តៅនៅក្នុងបន្ទប់ទឹក វាធ្វើឲ្យមួម៉ៅតិចតួច ហើយក៏មកជួបនឹងសំណួរបែបនេះ ទើបជួយមិនបានដែលត្រូវខឹងតិចតួច ។

"ទៅសេអូលវិញ ខ្ញុំមានការងារត្រូវធ្វើ"

"ទើបតែរៀនចប់មិនអីចឹង ? រកការងារមិនទាន់បានធ្វើឯណា"

"លី អ៊ីនថាប់ យើងនិយាយគ្នាឲ្យស្រួលបួលទៅ យើងទាំងពីរមិនស្គាល់គ្នា ខ្ញុំទើបតែដឹងថាមានលោកជាម្ចាស់បំណុលរបស់ម៉ាក់ ហើយម៉ាក់ក៏ចង់ឲ្យខ្ញុំរៀបការដោះបំណុល ឬគិតសរុបតាំងពីពេលនោះមកដល់ពេលនេះ យើងទាំងពីរឃើញមុខគ្នាមិនទាន់ដល់៧២ម៉ោងផង ខ្ញុំមិនដឹងអីពាក់ព័ន្ធនឹងលោក ខ្ញុំនឹងដោះបំណុលឲ្យម៉ាក់ ព្រោះជាភតីជាអ្វីដែលកូនស្រីដូចជាខ្ញុំត្រូវធ្វើ តែរឿងមង្គលការវាមិនមែន...នោះ លោកធ្វើអី ?"

ស្លឹកតើយ ដែលគិតតែនិយាយ ក៏ស្ទួរនៅចុងប្រយោគពេលសង្កេតឃើញថាខ្ញុំរុំតែកន្សែងពោះគោ ព្រោះថាតុវាបិទបាំងអ្វីម្យ៉ាងខាងក្រោម ដូច្នេះហើយពេលដែលខ្ញុំដាក់កែវទឹកក្រូចលើតុ និងដើរទៅរកនាង នាងក៏បើកភ្នែកធំៗនិងឈានថយក្រោយ ។

"អម្បាញ់មិញទើបតែដាក់កែវទឹកក្រូច" ខ្ញុំតបដោយសំឡេងហត់នឿយ តែកែវភ្នែកមានពន្លឺផ្លេកៗ ។

"ខ្ញុំចង់មានន័យដល់ពេលនេះ! លោកចង់ធ្វើអី ?"

"អ៎...ពេលនេះឬ រំលោភនាងហ្នឹងអី" ខ្ញុំតបដោយសំឡេងរាបស្មើ មុននឹងញញឹមដាក់ ។

ស្លឹកតើយ ប្រហែលដឹងហើយថាខ្ញុំមិននិយាយលេង ទើបបែរខ្នងប្រុងរត់សំដៅទ្វារ តែដូចដែលប្រាប់ រាងកាយរបស់នាងនិងខ្ញុំខុសគ្នា គ្រាន់តែខ្ញុំឈានជើងពីរជំហានក៏ស្រវាចាប់នាងបានទៅហើយ ។

"អា៎!"

"ចេះស្រែកទៅកើត មិនឈឺកទេឬយ៉ាងម៉េច ទុកសំឡេងឲ្យ វិញទៅ"

"ឆ្គួតឬ លែង លែង!"

ស្លឹកតើយ ស្រែកពេលដែលត្រូវខ្ញុំបីដើរឡើងជណ្ដើរ អាហារពេលព្រឹកដែលមើលហើយឃ្លាននោះក៏អស់អារម្មណ៍ចង់ ពេលនេះសូមប្រាប់ថាមានតែអារម្មណ៍ត្រេកកាម!

[End Intouch's Talk]

## ៥

## ការស្ដាំដែលធ្វើឲ្យរបះដូងលោត... ពេលកាយជិតគ្នា

ខ្ញុំពិបម្រះយ៉ាងខ្លាំង តែក៏មិនអាចរបូតពីរង្វង់ដៃរបស់គេបាន អ៊ិនថាច់ កំពុងខឹង គេបីខ្ញុំឡើងជណ្ដើរ ហើយបើកទ្វារពេញកម្លាំង ធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលព្រួតពេលដឹងថាគេកំពុងតែធ្វើអី ។

"លែង!"

ខ្ញុំរើបម្រះទៀត ហើយក៏ប្រើក្រចកខ្វៀរគេខ្លាំងៗ ។

"ប្រឹងរើទៅ កន្សែងជូតខ្លួនរបូតមិនដឹងទេ" អ៊ិនថាច់ គំរាម ។

មែនហើយ! គេតែងខ្លួនគ្រោះថ្នាក់ដល់ថ្នាក់នេះ...តែបើមិនពិបម្រះ មានសង្ឃឹមថាខ្ញុំនេះជួបគ្រោះថ្នាក់មិនខាន ។

ខ្ញុំប្រមូលកម្លាំងកំហែងដើម្បីពិបម្រះម្ដងទៀត តែលែងទាន់ទៅហើយ ព្រោះជាពេលដល់គ្រែ អ៊ិនថាច់ ក៏ទម្លាក់ខ្លួនទាំងដែលបីខ្ញុំបែបនេះ ។

ភាធ្វើឲ្យខ្ញុំអស់ឱកាសក្រឡាស់ខ្លួនប្រវេប្រវាគេចបាន ព្រោះថាស្រូវខ្លួនប្រាណរបស់គេឃុំឃាំង និងសង្កត់ខ្ញុំស៊ឹងតែកប់នឹងពូក ។

យ៉ាប់ហើយ!

"ព្រាងសន្យាហើយថាមិនធ្វើអីនោះ!" ខ្ញុំរហ័សទាមទារសន្យាភ្លាមពេលឃើញថាភគ្រោះថ្នាក់ពេញបន្ទុកហើយ ។

"ដូចដែលនាងធ្លាប់សន្យាជាមួយខ្ញុំហ្នឹងអីថាហៅបង តែនាងគិតតែហៅខ្ញុំថាលោក អ៊ិនថាច់...លី អ៊ិនថាច់ ស្អីបែបនោះ"

ខ្ញុំបើកភ្នែកធំៗភ្លាម ។

"បង អ៊ិនថាច់ លែងខ្ញុំទៅ ខ្ញុំធ្ងន់"

"លែងទាន់ហើយ"

គេអស់សំណើច តែសំឡេងដូចតំរាមច្រើនជាង ។

គីនថាច់ ស្រាក់ម្រាមដៃទាំងសងខាងរបស់ខ្ញុំ ហើយទាញវា ទៅលើ ខ្លួនប្រាណរបស់គេធំនិងសុទ្ធតែសាច់ដុំ ខណៈដែលមិន មានតែអាវយឺតដែលខ្ញុំពាក់ប៉ុណ្ណោះឃាំងខណ្ឌកណ្ដាល ។

"កុំ!"

ខ្ញុំស្រែកហាមពេលដែលគេលោមុខមកជិត ខ្យល់ដង្ហើមក្ដៅ របស់ គីនថាច់ ស្រោចលើមុខខ្ញុំ ខ្យល់ដង្ហើមរបស់គេមានក្លិនជិ អង្កាម ច្រមុះស្រួចរបស់គេក៏ប៉ះនឹងចុងច្រមុះរបស់ខ្ញុំ តែភ្នែកពណ៌ ត្នោតដែលប្រលាំប្រផេះតិចៗនោះក៏មើលខ្ញុំមិនប៉ប្រិចភ្នែក ។

"នាង...ហៅខ្ញុំថាលោកប៉ុន្មានម៉ាត់ ?"គេសួរ ចំណែកសំឡេង ក៏ស្អកតិចៗ ។

គីនថាច់ មើលខ្ញុំមិនដាក់ភ្នែកដូចរង់ចាំចម្លើយ សក់របស់គេ ដែលសើមធ្លាក់ចុះមក ចុងសក់ក៏ប៉ះថ្ពាល់របស់ខ្ញុំ វាត្រជាក់...ប៉ុន្តែ បែរជាធ្វើឲ្យខ្ញុំមានអារម្មណ៍ក្ដៅស្រៀវស្រាញពេញមុខ ។

ខ្លួនរបស់គេក៏សង្កត់ខ្លួនខ្ញុំ គេដាក់ជើងធ្ងន់ៗនោះលើភ្លៅរបស់ ខ្ញុំ ធ្វើឲ្យខ្ញុំរើបម្រះចេញពីក្រោមរាងកាយរបស់គេមិនបាន ។

"ចាំ...ចាំមិនបាន"

"គិតឲ្យស្រួលបួលទៅ ព្រោះថាខ្ញុំនឹងថើបតាមចំនួនដែលនាង ហៅ"

ហាស...គេថាម៉េច ? មិនលេងចូល! មិនលេងចូលទេ!

"មួយម៉ាត់"

ខ្ញុំហើសគេបយក្សចខ្លួន ។

មាត់របស់គេស្អាតដល់ហើយ...មិនមែនទេ ស្លឹកតើយ នាង ត្រូវតែមានស្មារតី ប៉ុន្តែ...ភ្នែករបស់គេក៏ស្អាតដែរ វ៉ាយ! ខ្ញុំកំពុងតែ ត្រូវអាម្យៀនេះលុកលាន់ដោយ...

មានស្មារតីឡើង ស្លឹកតើយ!

"កុហក...តិតើយគុណនឹងពីរ"

គេញញឹមយ៉ាងកំណាចនៅចុងមាត់ មុននឹងឱនមុខមករក ខ្ញុំ ក៏របាសបិទភ្នែកហើយងាកមុខចេញ ធ្វើឲ្យច្រមុះស្រួចរបស់ គីន ថាច់ សង្កត់លើថ្ពាល់ ហើយមាត់របស់គេក៏ថើបពីចុងចង្កា រុញទៅ ដល់គុម្ពត្រចៀក តែជំនួសដែលគេឈប់ គីនថាច់ បែរជាធ្វើនូវអ្វី ដែលធ្វើឲ្យខ្ញុំញាក់ព្រើតបើកភ្នែកធ្លាម ហើយក៏ស្រែក ។

"អាំ!"

អណ្ដាត...អណ្ដាតរបស់គេត្រាវសត្រង់ស្លឹកត្រចៀកខ្ញុំតិចៗ មុននឹងជញ្ជក់ ហើយក៏ដកចេញវិញ ។

អារម្មណ៍ស្រៀវស្រើបណាយឡើងរសើប រត់កាត់ត្រចៀករបស់ខ្ញុំ មករកដើមទ្រូង ហើយក៏ធ្វើឲ្យខ្ញុំញាប់ញ័រ ។

"កុំ"

ខ្ញុំហាម និងព្យាយាមរុញកពេល គីនថាច់ រុសមាត់មករកក របស់ខ្ញុំ ហើយខាំសាច់ត្រង់នោះ និងបឺតដល់ធ្លាក់ឮសំឡេង ។

ពោះរបស់ខ្ញុំប្រហោង ខួរក្បាលក៏វិលខ្លាល់ ចំណែកចុងជើង របស់ខ្ញុំក៏រឹង ហើយគេក៏វិលមកថើបចុងចង្កា ។

ទើបតែដឹងថាមាត់របស់មនុស្សប្រុសទន់ល្មៀយ ទន់...អាំ...កុំ អាលជ្រួលជ្រើម...ស្លឹកតើយ កុំជ្រួលជ្រើម! ការពិតទៅគេគឺជា មនុស្សប្លែកមុខ ។

"លែងខ្ញុំ មិនអីចឹង..."

"មិនអីចឹងយ៉ាងម៉េច ?" សំណួររបស់គេធ្វើឲ្យបេះដូងរបស់ខ្ញុំ លោតញាប់ សំឡេងស្អកដែលប្រាប់ឲ្យដឹងថាមានអារម្មណ៍ ។

"នឹង..."

ខ្ញុំរកពាក្យមកតំរាម តំរាមថាម៉េចល្អ ? ទើបធ្វើឲ្យបុរសមាឌធំ

កំពុងថើបខ្ញុំនេះព្រមបញ្ឈប់ ។

"អ៊ឺម!"

ព្រោះរាល់តែគិតរកពាក្យតំរាម ទើបត្រូវ អ៊ីនថាច់ ថើប មាត់របស់គេភក្ដៅនិងទន់ល្មើយ ។ អ៊ីនថាច់ មិនត្រឹមតែថើប ទេ មាត់របស់គេនៅរំកិលទៅមក ហើយក៏ជញ្ជក់មាត់របស់ខ្ញុំដែរ ហាក់ដូចត្រូវជេញ ចំណែកចុងអណ្ដាតសើមរបស់ អ៊ីនថាច់ ប្រដេញលើបបូរមាត់របស់ខ្ញុំទាំងលើទាំងក្រោម ។

"..."

ខ្ញុំភ្ញាក់ផ្អើលក្អក វាហាក់ដូចយើងកំពុងតែនៅលើទីខ្ពស់ ហើយ ធ្លាក់ចុះមក ។ ខ្ញុំព្យាយាមងាកមុខចេញ តែមិនបានងាកទៅខាងណា ក៏មាត់ក្ដៅគគុកនោះតាមទៅបឺតជញ្ជក់ខ្លាំងលើសដើម ។

ខ្លួនប្រាណរបស់គេដែលសង្កត់លើខ្លួនប្រាណរបស់ខ្ញុំក៏ប្រាកដ សាច់របស់ខ្ញុំដែរ រហូតដល់...ខ្ញុំទទួលដឹងថាមានអ្វីម្យ៉ាងដែលរឹង និងក្ដៅឆ្អិបត្រង់ពោះ ។

កន្សែងពោះគោរបស់គេរបូតបាត់ទៅហើយ ។

"..."

អ៊ីនថាច់ ថើបខ្ញុំយ៉ាងពុះកញ្ជ្រោល ធ្វើឲ្យខ្ញុំដកដង្ហើមមិនចេញ ខ្លួនប្រាណភាស្រាល ហើយក៏ធូរនៅក្នុងពេលតែមួយ។ ខ្យល់ដង្ហើមរបស់យើងសុទ្ធតែដង្ហក់និងញ័រ ហើយគេក៏ជ្រែកអណ្ដាតចូលមកក្នុងមាត់របស់ខ្ញុំ ចុងអណ្ដាតក៏ត្រាសនៅមិនសុខ ។

អា...ហេតុអីបានជាខ្ញុំមិនខ្ពើមរអើម ?

គេថើបខ្ញុំកាន់តែខ្លាំង ខ្ញុំមិនដឹងទេថា អ៊ីនថាច់ លែងដៃរបស់ខ្ញុំដែលសង្កត់នោះតាំងពីពេលណា និងមិនដឹងដូចគ្នាថាខ្ញុំរំកិលទៅឱបស្មារបស់គេពេលណា ។ ខ្យល់ដង្ហើមរបស់យើងកាន់តែញាប់និងកាន់តែញ័រ ហើយខ្ញុំក៏ងាកមុខមកទទួលយកការថើប

របស់គេដោយការពេញចិត្ត ។ ដៃរបស់គេក៏រំកិលមកចាប់ចង្កេះរបស់ខ្ញុំ និងលូកចូលទៅក្នុងអាវធំរលុង មុននឹងរំកិលមកក្ដោបដើមទ្រូងរបស់ខ្ញុំ ហើយក៏ខ្ទាំវា ។

"អ៊ឺម"

ខ្ញុំបើកភ្នែកធំៗពេលដែលត្រូវវាយលុយយ៉ាងខ្លាំង ដៃដែលសង្កត់ស្មាក៏ទៅជាច្រញច្រាន ប៉ុន្តែ អ៊ីនថាច់ មិនព្រម គេទាញអាវក្រៅរបស់ខ្ញុំមកដាក់លើគល់ទ្រូង ព្រមទាំងលូកក្រោមដៃទាញអាវក្នុងរបស់ខ្ញុំឡើងទៅលើ ។ ហើយមុនពេលដែលខ្ញុំបានធ្វើអី គេក៏ឈប់ថើបខ្ញុំ ហើយក៏រំកិលខ្លួនកាន់តែទាប មុននឹងហាមាត់គ្របគ្រងដើមទ្រូងរបស់ខ្ញុំយ៉ាងលឿន ។

"កុំ...បង អ៊ីនថាច់ អ្ហា...កុំ អ៊ឺម...កុំ"

នោះសំឡេងរបស់ខ្ញុំមែនទេ ? ខ្ញុំកំពុងតែហាមគេ តែហេតុអីបានជាញ័របែបនេះ ?

គេមិនព្រមឈប់ តែបែរជាត្រាសអណ្ដាតលើទ្រូងរបស់ខ្ញុំ ទាល់តែខ្លួនរបស់ខ្ញុំម្ដងក្ដៅម្ដងរងា កាន់តែពេលគេបឺតជញ្ជក់វា ព្រមទាំងប្រើដៃម្ខាងទៀតអង្អែលដើមទ្រូងម្ខាងទៀតរបស់ខ្ញុំដែរ ។

ល្បិចនេះ នេះគឺជាអារម្មណ៍ស្អី ? ស្រៀវស្រើបពេញខ្លួន ដល់ថ្នាក់សូម្បីតែសំឡេងក៏រកមិនឃើញ ។

ខ្ញុំតើងដើមទ្រូងទៅរក អ៊ីនថាច់ កាន់តែខ្លាំង ដៃទាំងពីរដែលធ្លាប់តែច្រញច្រានគេ ក៏ខ្ទាំសក់ទន់ល្មើយរបស់គេទៅវិញ ។

"អ្ហា...ឈឺ"

ខ្ញុំតវ៉ាពេលដែលត្រូវគេបឺតជញ្ជក់ចុងទ្រូងខ្លាំងៗ ពេលនោះឯងដែលមានអារម្មណ៍ថាដៃរបស់គេរំកិលទៅរកចង្កេះខោ មុននឹងរំកិលទៅកាន់តែជ្រៅ ហើយដាក់វាលើ...

កុំ!

ខ្ញុំធ្លាក់ក្រញាង និងខាំបបូរមាត់ខ្លាំងៗដល់ថ្នាក់ឈាមជើមឡើង ស្មារតី ហើយក៏ប្រើដៃចាប់ទាញសក់របស់គេចេញពីភាពការពារ ខ្លួនឯងមួយទំហឹង បានឮសំឡេងរបស់គេឧទាន ហើយក៏បើ ញ្ញគេចេញខ្លាំងៗ មុននឹងប្រមៀលខ្លួនចុះពីគ្រែ ចំណែកដៃក៏ទាញ ភួយមកដែរ ។

"ស្លឹកតើយ" គេហៅខ្ញុំ តែថា...

"កុំ បើបងធ្វើ ខ្ញុំនឹងស្អប់បងមួយជីវិត"

ភាសាដែលធ្លាប់ឮក្នុងកុនល្ខោន និងអានប្រលោមលោក តែមិនធ្លាប់គិតថាយកមកនិយាយដោយខ្លួនឯងសូម្បីតែម្ដង ។

ខ្ញុំសម្លក់មុខអ្នកដែលតាមមកស្រវាចាប់ទាញថ្មី (ប្រុសស្ទើរ មុខ ព្រោះថាគេគ្មានអីជាប់ខ្លួននៅពេលនេះ!) ។

"..."

"..."

ហាក់ដូចយើងទាំងពីរមើលគ្នាយូរយារ ទាំងដែលវាមិនប៉ុន្មាន វិនាទីផង ។

គីនថាន់ ខ្ទឹបបបូរមាត់ ផ្ទឹមភ្នែកមើលខ្ញុំ មុននឹងងើបឈរពីគ្រែ គ្រែ អើយ! គេមិនបានស្លៀកពាក់អី ទើបខ្ញុំរហ័សងាកមុខចេញ ។

រូបភាពដែលទើបតែឃើញរបស់ពិតលើកដំបូង វាក៏ធ្វើឲ្យនេះ ស្ទុងលោតញាប់ ។

"ទៅតែងខ្លួន...ចុះទៅចាំនៅតុអាហារ បើខ្ញុំងូតទឹកតែងខ្លួន ហើយចុះទៅមិនឃើញ ច្បាស់ជាត្រូវរំលោភមិនខាន ហើយលើក នេះនឹងមិនបញ្ឈប់ ទាល់តែបានញាត់ចូលទៅក្នុងខ្លួននាង...យល់ ទេ!" គីនថាន់ ប្រាប់ដោយសំឡេងកាច ។

ខ្ញុំក៏បិទភ្នែកបិទត្រចៀក និងងក់ក្បាលញាប់ស្អេក សំឡេង របស់គេដើរតាំងៗចេញទៅឆ្ងាយ ធ្វើឲ្យខ្ញុំបើកភ្នែកព្រឹមៗមើល

ហើយក៏ឃើញកំប៉េះគូទរបស់គេដែលចេញពីបន្ទប់ បន្ទាប់ពីនោះខ្ញុំ ក៏រហ័សស្ទុះទៅចាក់សោទ្វារទាំងដៃញ័រទទ្រើត ។

វិះទៅហើយ ស្លឹកតើយ អើយ! វិះទៅហើយ!

ខ្ញុំរាសសក់ទៅស្មៀតត្រចៀកដោយដៃញ័រទទ្រើត ។

គីនថាន់...គេធ្វើឲ្យខ្ញុំទើបតែដឹងថា បើគេត្រូវការខ្លួនខ្ញុំ វាមិន ចាំបាច់ប្រើកម្លាំងឬប្រើពាក្យបង្គាប់បញ្ជា ក្នុងពេលដែលគ្រាន់តែគេ ប៉ះពាល់ ប៉ុណ្ណឹងខ្ញុំក៏វិះតែ...

ពីរ គីនថាន់ ប្រុសគ្រោះថ្នាក់!

[Intouch's Talk]

ខ្ញុំងូតទឹកម្តងទៀតឲ្យទាល់តែបាននៅក្នុងព្រឹកថ្ងៃដដែល ។

ស្លឹកតើយ ជាមនុស្សស្រីដំបូងដែលធ្វើឲ្យខ្ញុំបាត់បង់ភាពម្ចាស់ ការដល់ថ្នាក់នេះ...នាងផ្អែមនិងក្រអូបសមនឹងឈ្មោះ ។

ខ្ញុំងូតទឹកនៅក្នុងបន្ទប់ទឹកមួយទៀត ហើយតែងខ្លួនឲ្យមាន របៀប មុននឹងមានចិត្តយកអាវយឺតពណ៌ខ្មៅ និងខោចងចង្កេះ ពណ៌ខ្មៅ ដឹងថា ស្លឹកតើយ គ្មានសម្បត្តិអីជាប់ខ្លួន ទាំងខោអាវនិង ឈុតក្នុង ខ្ញុំនឹងបាត់ការវាថ្ងៃនេះ ។

ខ្ញុំចុះពីបន្ទប់ ហើយក៏ឃើញអ្នកដែលអង្គុយអស់ឫទ្ធិនៅតុ អាហារ...មិនមែនទេ មនុស្សស្រីដូច ស្លឹកតើយ មិនបានរៀបរយ សុភាពរាបសាដូចសម្បកក្រៅ ខ្ញុំដឹងថានៅក្រោមមុខមាត់ស្រស់ ស្អាតទន់ភ្លន់របស់នាងលាក់ភាពឆ្លាសឆ្លើម ក្បាលរឹង មិនអីចឹង ប្រហែលជាព្រមរៀបការជាមួយខ្ញុំងាយៗ ដោយការសប្បាយចិត្ត ដែលបានធ្វើជាកូនប្រសាស្រីរបស់មហាសេដ្ឋីនៅក្បែរទៅហើយ ។

"នំប៉័ងត្រជាក់អស់ហើយ"

ខ្ញុំប្រាប់ពេលឃើញ ស្លឹកតើយ មើលនំប៉័ងដែលខ្ញុំធ្វើទុកឲ្យ

អាហារពេលព្រឹកងាយៗ គ្រាន់តែគោះពងមាន់ក្រឡុក ហើយ ចូលម៉ៃក្រូវេវ ពេលឆ្អិនក៏យកចេញមកលាយម្រេចនិងស្រោច ត្រលក់ ។ ខ្ញុំយកចិត្តយកថ្លើមដល់ថ្នាក់នេះហើយ នៅចេះតែ ចង់ក្រឡប់ទៅសេអ៊ីលវិញទៀត គិតហើយក៏ខឹង ។

"ចាំធ្វើឲ្យថ្មី"

"មិនបាច់ទេ ខ្ញុំញ៉ាំបាន" នាងប្រាប់ ហើយក៏កាត់នំប៉័ង មាត់ទំពា ។

"..."

ខ្ញុំចូលអង្គុយទល់មុខ មើលអ្នកដែលដូចជាព្យាយាមយកចិត្ត ទុកដាក់ចំពោះអាហារនៅពីមុខ ហើយក៏ដកដង្ហើមធំ ។

"ស្លឹកតើយ ម៉េចក៏មិនចង់រៀបការជាមួយខ្ញុំ ?"

"..."

នាងនៅស្ងៀម ហើយក៏លើកកែវទឹកក្រូចផឹក ។

"ឆ្លើយម៉ោ"

"បើឆ្លើយមិនត្រូវចិត្ត បងនឹងអូសខ្ញុំឡើងគ្រែទៀតឬអត់ ?"

អឺម...តាមពិតទោះមិនឆ្លើយ អង្គុយមើលមុខគ្នាធម្មតាៗ ក៏ខ្ញុំ ចង់អូសនាងឡើងគ្រែពេញ២៤ម៉ោងទៅហើយ ប៉ុន្តែលើកនេះខ្ញុំ គ្រវីក្បាល ទើបនាងខ្ទឹបមាត់មុននឹងតប ៖

"យើងមិនបានស្រឡាញ់គ្នា ហើយវាក៏ជាមង្គលការដោះ បំណុល ខ្ញុំមិនចង់រស់នៅជាមួយអ្នកដែលមិនស្រឡាញ់គ្នា ដោយ សារតែចំនួនទឹកប្រាក់ដ៏ច្រើនបែបនេះ"

"ចុះបើគ្មានរឿងបំណុល នាងនៅតែមិនចង់រៀបការជាមួយខ្ញុំ ទៀតមែនទេ ?"

លើកនេះ ស្លឹកតើយ មើលមកខ្ញុំដោយការងឿងឆ្ងល់ នាង ផ្អៀងចិញ្ចើមនៅស្ងៀមមួយភ្លែត មុននឹងគ្រវីក្បាល ។

"ទោះគ្មានរឿងបំណុល ហើយម៉ាក់របស់បងនិងម៉ាក់ខ្ញុំចង់ឲ្យ យើងរៀបការជាមួយគ្នា ក៏វាជាការចាប់ផ្ដើមដដែល ខ្ញុំមិនចង់រៀប ការព្រោះហេតុផលនេះទេ"

"ស្នេហា...សរុបទៅនាងជាមនុស្សស្រីបូជាស្នេហា...មែនទេ"

"..." មនុស្សស្រីនៅចំពោះមុខខ្ញុំដកដង្ហើមធំ ហើយក៏និយាយ ដោយសំឡេងរាបស្មើ "ខ្ញុំគ្រាន់តែចង់រៀបការជាមួយអ្នកដែលខ្ញុំ ស្រឡាញ់និងស្រឡាញ់ខ្ញុំវិញ មង្គលការគឺមានតែម្ដងនៅក្នុងជីវិត"

ខ្ញុំញញឹម ហើយក៏លោមុខទៅជិតនាងបន្តិចទៀត ។

"ហើយអ្នកណាប្រាប់ថាបើរៀបការជាមួយខ្ញុំហើយ នៅមាន ឱកាសទៅរៀបការលើកទីពីរជាមួយអ្នកដទៃទៀត ?"

"ចុះបើខ្ញុំសួរវិញថា ហេតុអីបានជាបងចង់រៀបការជាមួយខ្ញុំ ម្ល៉េះ ? ក្នុងពេលដែលយើងទើបតែជួបគ្នា"

ស្លឹកតើយ លេងមួយក្បាច់បែបមិនឲ្យត្រៀមចិត្តត្រៀមកាយ ធ្វើឲ្យខ្ញុំគាំង តែនោះវាមានតែមួយភ្លែតប៉ុណ្ណោះ មុននឹងខ្ញុំញញឹម ចុងមាត់ ។

"នាងស្អាត ស ទ្រលុកទ្រលន់បែបនេះ បើបានរស់នៅជាមួយ ប្រហែលជាមិនគួរឲ្យធុញ ម្យ៉ាងទៀតខ្ញុំជាប្រភេទកូនតាមចិត្តម្ដាយ ប្រកាន់គំនិតដើរតាមគន្លងមនុស្សចាស់ មរតកវាមិនធ្លាក់ទៅណា ទេ ម្យ៉ាងទៀតមិនរៀបការជាមួយនាង ម៉ាក់របស់ខ្ញុំគង់តែរកអ្នកថ្មី ឲ្យដដែល ហើយបានស្អាតដូចនាងដែរឬអត់ក៏មិនដឹង ស៊ីស្រវា យកនាងមិនល្អជាងឬ ?"

នាងធ្វើមុខដូចមិនចង់ឮអ្វីដែលខ្ញុំនិយាយ កែវភ្នែកមូលក្លំនោះ បើកធំៗ មុននឹងមើលខ្ញុំដោយការខ្ពើមរអើមបែបមិនបិទបាំង តែ អ្នកណាទៅចាប់អារម្មណ៍ទៅ ។

"នាងក៏ដូចគ្នា មិនថាយ៉ាងណាក៏គេចពីមង្គលការនេះមិន

បាន មើលក៏មិនធ្វើឲ្យរាងកាយទៅ ម៉ាក់ខ្ញុំអាចស្រឡាញ់មិត្តភក្តិ...
ជាម៉ាក់នាង តែជឿចុះថារឿងបំណុលមាសប្រាក់ មិត្តភាពក៏...
នៅក្បែរ អាបង់វិលសំនោះប្រាប់ទៅថាមិនអូខេ មិនចង់រៀបការ...
ទៅរកប្រាក់១០០លានមកដាក់ពីមុខនៅថ្ងៃស្អែក ហើយខ្ញុំនឹង...
ចោលមង្គលការរបស់យើង"

ស្លឹកតើយ ធ្វើមុខដូចលេបថ្នាំល្វីង ប៉ុន្តែត្រឹមមួយភ្លែតប៉ុណ្ណោះ
នាងក៏តើងខ្លួន ។

"ចុះបើខ្ញុំមិនរៀបការ តែរត់គេច ?"

"រត់...រត់ទៅជាមួយអ្នកណា ?" ខ្ញុំសួរដោយសំឡេងខ្សឹបៗ ។

"គឺ...អាចជាសង្សារខ្ញុំក៏ថាបាន"

"សង្សារ...មនុស្សប្រុស...អញ្ចើញ...បើពិតជាខ្ញុំព្រមឲ្យនាង
ទៅនៅជាមួយប្រុសផ្សេងក៏សាកមើលទៅ បើមិនងាប់ក៏ពិការមិន
ខាន"

ខ្ញុំប្រាប់ដោយសំឡេងរាបស្មើ តែពេលនេះបេះដូងរលោះ
ផុតដាក់ ទាំងដែលដឹងថាមនុស្សស្រីនៅចំពោះមុខ កុហក ។

នាងគ្មានសង្សារ មិនធ្លាប់មានអ្នកណាតាំងពីរៀនវិទ្យាល័យ
ម្ល៉េះ តែពេលបានឮពាក្យបែបនេះ អារម្មណ៍នៃភាពជាម្ចាស់វាក៏រត់
ប្រាស់ប្រាល់ពេញរាងកាយ ។

ខ្ញុំធ្លាប់ប្រាប់នាងហើយនៅ ជាចរិតអន់ដែលមានជាប់ខ្លួនតាំង
ពីកំណើត គឺការប៉ុនហ្វូងហែងបែបព្រៃផ្សៃ ហើយមានអានុភាព
កម្ទេចអ្នកដែលមកដណ្តើមបានគួរឲ្យខ្លាច ។

"បងចង់ធ្វើអី ?"

"សម្លាប់មនុស្សប្រុសចោល"

"បងធ្វើមិនបានទេ!" នាងនិយាយដោយការភ្ញាក់ផ្អើល ។
ខ្ញុំក៏ញញឹម ញញឹមស្រស់ តែជាទឹកមុខមិនរួសរាយដូចស្នា...

ញញឹម ព្រោះ ស្លឹកតើយ ធ្វើមុខភ័យខ្លាចពេលដែលខ្ញុំតប មុននឹង
ទាញកែវទឹកក្រូចផឹកដូចយើងមិនបាននិយាយរឿងគួរឲ្យខ្លាច ។

"ចុយទៅវិញ នឹងពន្លះសាច់មនុស្សប្រុសដែលនាំនាងរត់គេច
ពីខ្ញុំម្តងមួយកាំបិតៗ"

ខ្ញុំញញឹមដាក់នាងទៀត ។

"..."

ស្លឹកតើយ ចំហមាត់ធ្លុង មុននឹងធ្វើមុខក្រិនទ្រូត ប្រហែលជា
គិតរូបភាពតាមខ្ញុំនិយាយ ។

"ញ៉ាំទៅ បន្តិចទៀតនាំទៅទិញខោអាវ"

"ទិញខោអាវ ? យើងនៅទីនេះប៉ុន្មានថ្ងៃទៀត ?"

មនុស្សស្រីនៅចំពោះមុខសួរខ្ញុំ ។

"ពីរបីថ្ងៃ ទាល់តែនាងធ្វើខ្លួនគួរឲ្យស្រឡាញ់ ហើយយើង
ស្និទ្ធស្នាលគ្នាជាងនេះ ទើបខ្ញុំនាំនាងទៅវិញ"

"តែខ្ញុំត្រូវធ្វើការ!"

"រកការងារធ្វើមិនទាន់បាន មិនអីចឹង ?"

ខ្ញុំឡក ហើយក៏ធ្វើឲ្យនាងធ្វើមុខជូរ អារម្មណ៍មួម៉ៅរលាយបាត់
អស់ស៊ិងពាក់កណ្តាលពេលបានឃើញទឹកមុខរបស់ ស្លឹកតើយ
ស្រីតូចរបស់ខ្ញុំមុខបានគួរឲ្យស្រឡាញ់បំផុត ។

"ខ្ញុំប្រាប់ឲ្យដឹងទៅថាគ្មានខោអាវឲ្យនាងពាក់ទៀតទេ បើមិន
ទៅទិញ ពីរបីថ្ងៃក្រោយនេះអាចគ្មានស្អីពាក់ ខ្ញុំមិនថាអីទេបើនាង
ស្លៀកខ្យល់ដណ្តប់មេឃ ព្រោះពេលនាងមិនស្លៀកពាក់ខោអាវ
ហើយ គឺ...ស្អាតខ្លាំងណាស់"

មុខរបស់ ស្លឹកតើយ ក្រហមពេលដែលខ្ញុំនិយាយដល់ហេតុ
ការណ៍ដែលកើតឡើងកាលពីព្រឹក ។

នាងធ្វើជាសម្លក់សម្លឹងខ្ញុំ ហើយក៏ញ៉ាំអាហារពេលព្រឹកបន្ត

ប៉ុន្តែថ្ពាល់នេះឡើងពណ៌ផ្កាឈូកតែម្តង វាគួរឲ្យស្រឡាញ់ដល់ថ្នាក់ ទប់ចិត្តមិនបានដែលត្រូវឱនទៅផ្ទាក់ថើបយ៉ាងលឿន ។

"បង អ៊ីនជាច់!"

ដូចដែលប្រាប់...ខ្ញុំអាចនៅជាមួយមនុស្សស្រីម្នាក់នេះបាន មួយជីវិត ដោយគ្មានថ្ងៃធុញទ្រាន់ពិតមែន!

ខ្ញុំនាំ ស្លឹកតើយ មកហាងទំនិញនៅក្នុងខេត្ត ហើយក៏ដើរ... មនុស្សស្រីដែលពាក់អាវយឺត ស្លៀកខោចង្កេះធំរលុង ប៉ុន្តែនាង នៅតែពាក់បានយ៉ាងឡូយនិងគួរឲ្យស្រឡាញ់ គួរឲ្យស្រឡាញ់ដល់ ថ្នាក់មនុស្សជាច្រើនដែលដើរកាត់ងាកមកមើល...មនុស្សស្រីមិន ប៉ុន្មាន ប៉ុន្តែយូរៗទៅអាពួកមនុស្សប្រុសនេះក៏មើលដែរ មើលរហូត ចង់លេបត្របាក់ ។ ពេលពួកនោះមើលមក ឃើញខ្ញុំដែលដើរ... នាង និងបាញ់ខ្សែភ្នែកពិឃាតបែបមនុស្សហ្វូងហែងដាក់ ពួកគេក៏ នាំគ្នាងាកមុខចេញ ។

"រើសបានហើយនៅ?"

"បានហើយ ម៉េចក៏មិនចាំនៅឡាន?"

"បណ្តោយឲ្យនាងលួចរត់ទៅសេអ៊ូលវិញឬ គ្មានផ្លូវទេ"

ស្លឹកតើយ ធ្វើមុខដូចសោកស្តាយដែលខ្ញុំដេញដើងទាន់ នាង រើសអាវពណ៌ស្រស់ពីរបី និងសំពត់ខោមួយមុខមួយប៉ុណ្ណោះ នេះ ប្រហែលគិតថានៅទីនេះតែពីរថ្ងៃហើយ ។

"ឈុតក្នុងយកទេ ពាក់ដដែលៗមិនល្អចំពោះសុខភាព"

"បង អ៊ីនជាច់!"

"នោះអីហាង ទៅទិញទៅ"

មនុស្សស្រីក្បាលរឹងទៅជាមុខក្រហម ពេលនាងអៀនគួរឲ្យ ស្រឡាញ់ជាងពេលខឹងទៅទៀត ទើបខ្ញុំដើរដឹកដៃនាងចូលហាង

ឈុតក្នុងម៉ាកល្បី ហើយក៏ទាញទៅស្តូដែលមានអាវក្នុងស្អាតៗ ។

"ចាំខ្ញុំរើសឲ្យ"

"មិនបាច់ទេ! ចេញទៅចាំនៅខាងក្រៅទៅ ខ្ញុំរើសខ្លួនឯង"

"មិនទៅ"

"ហ៎?"

លើកនេះ ស្លឹកតើយ និយាយខ្លាំងៗ និងសម្លក់សម្លឹងខ្ញុំ ប្រហែលបានចិត្តថាយើងនៅក្នុងហាងមានមនុស្សច្រើន គិតថាខ្ញុំ មិនហ៊ានធ្វើអី ទើបបញ្ចេញឫទ្ធិបានបែបនេះ...*ស្គាល់ លី អ៊ីនជាច់ ស្មើងពេកហើយអូនស្រី*...ទើបខ្ញុំលើកដៃឱបស្មារបស់នាង ហើយ ទាញមកជិត ធ្វើឲ្យនាងភ្ញាក់ផ្អើល តែបុគ្គលិកផ្នែកលក់ក៏មកដល់ ល្មម ហើយក៏ញញឹមញញែមសួរ ។

"សួស្តី រកមើលឈុតក្នុងបែបណាដែរ?"

"ចង់បានបែបសិចស៊ី"

"បង អ៊ីនជាច់!"

ស្លឹកតើយ ស្រែកម្តងទៀត សំឡេងឮដល់ថ្នាក់ខ្ញុំងាកមក បញ្ចក់មាត់ដាក់ ។

"ឲ្យឡាធ្វើអីប្រពន្ធសម្លាញ់ ចាំប្តីរើសឲ្យ"

"បង អ៊ីនជាច់!"

ស្លឹកតើយ គិតតែហៅឈ្មោះខ្ញុំ ទើបខ្ញុំងាកទៅញញឹមដាក់ បុគ្គលិក ។ ស្នាមញញឹមរបស់ លី អ៊ីនជាច់ កំលោះសង្ហាដូចជាខ្ញុំ ធ្វើឲ្យបុគ្គលិកស្លុងអារម្មណ៍ភ្លាម ឃើញទេ! មានតែស្រីៗផ្តួល ផ្តើមទាំងអស់ តែមនុស្សម្នាក់ដែលចង់ឲ្យផ្តើមបែរជាព្យាយាមរើ បម្រះចេញពីរង្វង់ដៃរបស់ខ្ញុំ ។

"ខ្ញុំមិនយកបែបសិចស៊ី ខ្ញុំរើសខ្លួនឯង"

"មិនបាន ខ្ញុំតែម្នាក់គត់ដែលឃើញឈុតក្នុងរបស់នាង ចាំខ្ញុំ

ពីសឲ្យ"

"!!!"

មុខក្រហមរបស់ ស្លឹកតើយ ទៅជាខ្មៅប៉ៃ នាងខឹងនិងខ្មាស

បុគ្គលិកដែលធ្វើមុខព្រងើយ ។

"អូនេ តាមចិត្ត យ៉ាងណាក៏ស្រេចតែចិត្ត អញ្ជើញបង្ហាប់បញ្ចេ

ឲ្យពេញទំហឹងទៅ"

ចូលក្រឡាល្មម!

ខ្ញុំញញឹមដាក់ ស្លឹកតើយ ហើយប្រឆាំចង្កានាងតិចៗ ។

"គួរឲ្យស្រឡាញ់បំផុត ប្រពន្ធសម្លាញ់...អ្នកនាង សុំមើលខ្ញុំ

ដែលសិចស៊ីបំផុត ទំហំ៣៤ ចំណែកស្លៀងក្រោមសុំបែបជីវ្ហ៊ុង

( G-string ) ផង កំប៉េះគូទប្រពន្ធខ្ញុំស្អាតណាស់ស់ស់"

ខ្ញុំបង្អួសសំឡេងយ៉ាងវែង ។

[End Intouch's Talk]

ខ្ញុំចង់ទាញសក់គេ ក្តិចគេ ខ្ទៅគេ ខាំគេ ហើយក៏ស្រែកដាក់

មុខគេ ប្រុសឆ្កួត ប្រុសផ្តាច់ការ ប្រុសអន់ចរិត មាត់បង្គន់ លាមក

ត្រកកាម...

ហ៊ឺយ! ខ្ញុំដកដង្ហើមហត់តយូស ពាក្យជេរទាំងអស់បានដែ

ស្រែកនៅក្នុងចិត្តប៉ុណ្ណោះ ព្រោះថាបើធ្វើមែននោះ មើលតាមចាំ

របស់ អ៊ិនថាច់ ទៅ គេច្បាស់ជាខ្ទាំខ្ញុំនៅកណ្តាលហាងមិនខាន

អាម្សៀនេះទុកចិត្តបានពីអង្កាល់ ។

"បានរបស់គ្រប់ហើយ"

គេប្រាប់ ព្រមទាំងលើកថង់ទាំងឡាយឲ្យខ្ញុំមើល ទឹកមុខនោះ

មើលទៅស្លូបស្លល់បំផុត ។

"..."

"ថ្ងៃត្រង់ហើយ ឃ្លានទេ រកអីទាញញ៉ាំទេ ?"

"..."

"ឬថាចុកជើង រកសណ្ឋាគារដេកបំបាត់ចុកឈ្នញទេ ?"

"មិនរក!"

សរុបទៅ ការធ្វើជាស្ងប់ស្ងាត់ មិននិយាយមិនស្តីដាក់គេ វា

គ្មានបានផល ទើបបានតែសម្លក់សម្លឹងនិងជេរគេក្នុងចិត្តប៉ុណ្ណោះ។

អ៊ិនថាច់ ញញឹម គេលូកដៃម្ខាងដែលទំនេរមកចាប់ដៃរបស់ខ្ញុំ

នាំចូលហាងគុយទាវដែលនៅក្នុងហាងទំនើបជាន់នេះ ។

ខ្ញុំដកដង្ហើមធំនិងដើរតាម មុននឹងលើកចិញ្ចើមពេលសង្កេត

ឃើញថាស្រីៗដែលដើរកាត់ហាងងាកមកមើល អ៊ិនថាច់ ដោយ

ខ្សែភ្នែកសរសើរ ឬមិនអីចឹងក៏ធ្វើភ្នែកម៉ត់ៗ...

អេ៎ ? កុំមើលមកខ្ញុំដូចព្រងើយបែបនេះ ចង់បានក៏យកទៅ

ប្រគល់ឲ្យ!

ខ្ញុំសម្លក់សម្លឹងស្រីម្នាក់ដែលធ្វើខ្លួនដូច វ៉ាមី បេះបិទ ។

"ហាងនេះឆ្ងាញ់ ដំបូងគេលក់ខាងក្រៅ តែឥឡូវនេះរីកចម្រើន

ទើបលក់នៅក្នុងហាង"

"ខ្ញុំមិនឃ្លាន"

"អីចឹងអង្គុយញ៉ាំក់ជខ្ញុំទៅ"

គេតបបែបនោះ ទើបខ្ញុំបានតែដកដង្ហើមធំ ។

អ៊ិនថាច់ ហៅអ្នករត់តុមកកុម្ម៉ង់គុយទាវ គេកុម្ម៉ង់ម្តងប្រាំចាន

និងកុម្ម៉ង់គេសផ្ទះដែរ ធ្វើឲ្យខ្ញុំត្រូវងាកមុខមើល ព្រោះមិនស្មានថា

កំលោះសង្ហាអ្នកមានដូចគេចេះញ៉ាំដែរ ។

"កាហ្វេពីរកែវ"

"..."

"មើលស្តី ចាប់ផ្តើមលង់ស្នេហ៍អនាគតស្វាមីហើយហ្នឹង ប្រាប់

តាមត្រង់ចុះជាឲ្យការទៅ ភាសមាមាត្រសឹងអី មិនចាំបាច់
បំណុល បានបណ្ណាការ ហើយក៏បានប្រួសសង្កាដូចជាខ្ញុំទៀត"

ចាំ! តាមសប្បាយ និយាយបែបនេះ គិតបែបនេះហើយ សប្បាយចិត្តក៏អញ្ជើញ ព្រមទទួលពេញទំហឹងតែម្តង ស្រឡះ ហាត់ចិត្តនឹងប្រកែក!

"ញ៉ាំទេ?" អ៊ីនថាច់ សួរម្តងទៀតពេលគុយទាវត្រូវលើកមក ដាក់ពេញតុ ។

ខ្ញុំតាំងចិត្តបដិសេធ តែបាក្លិនឈ្ងុយរបស់វាចំជា...

"មិនញ៉ាំ"

វាត្រូវតែបែបនេះ ស្លឹកតើយ!

"តាមចិត្ត"

អាំ...មេចក៏មិនចែបប្រែបន្តិចទៀតទៅ គឺតាមពិតទៅខ្ញុំឃ្លាន ឃ្លានខ្លាំងទៀតផង តែគ្រាន់តែចង់ធ្វើជា...នែ៎! ខ្ញុំមើលអ្នកដែល ចាប់គុយទាវដាក់ចូលមាត់ ទំពាយ៉ាងឆ្ងាញ់ ហើយក៏ត្រូវលេបទឹក មាត់...អាមៀនេះតាមធម្មតាបង្អាប់បង្ខំ តែពេលនេះមកធ្វើជាតាម ចិត្តខ្ញុំ ។

"ញ៉ាំក៏បាន"

ខ្ញុំឃ្លានពិតមែន មិនល្ងង់ធ្វើបាបក្រពះនោះទេ ទើបខ្ញុំទាញ ចានមកដាក់ពីមុខ ទាញចង្កឹះនិងស្រង់ក្លិនឈ្ងុយរបស់អាហារ ដែលខ្លួនឯងចូលចិត្តទាល់តែពេញចិត្ត ។ តែពេលកៀបវាដាក់ចូល មាត់ក៏ត្រូវលើកចិញ្ចើម មួយចាននេះគ្មានត្រកួន មានតែសណ្ដែក បណ្ដុះ ខ្ញុំជាមនុស្សដែលមិនញ៉ាំត្រកួនតាំងពីណាពីណីមក ម្ដេះ ពេលគេកុម្ម៉ង់ខ្ញុំមិនបានជាស្ដាប់ នេះជារឿងចៃដន្យទៀតឬអ្វី ដែលគេកុម្ម៉ង់បែបនេះ?

"មើលអី ប្រកួតគ្នាញ៉ាំទេ អ្នកណាញ៉ាំអស់មុន"

អន់ខ្លួ...ខ្ញុំធ្វើភ្នែកឡេមឡាម តែមិនហ៊ាននិយាយ (ល្អចរេះ នៅក្នុងចិត្តក៏ជួយកាត់បន្ថយភាពតានតឹងបានល្អដែរ) ។

"អ្នកឈ្នះបញ្ជាស្អីអ្នកចាញ់ក៏បាន មួយថ្ងៃ"

"មែនក៏អី?"

"លើកលែងបញ្ជាឲ្យនាំទៅសេអ៊ុលវិញ ក្រៅពីនោះអូខេ"

ដេញដើងទាន់ទៀត ហ៊ឺយ...ខ្ញុំដកដង្ហើមធំ តែថាយ៉ាងមោច ណាស់ក៏...ខ្ញុំគ្រិមភ្នែកមើលអ្នកដែលញញឹមដាក់ដូចចង់ធ្លាញ់ ឡាល ហើយក៏ងក់ក្បាលយឺតៗ ។

"អូខេ ចាប់ផ្ដើម"

ហ៊ឹះ...មិនស្គាល់ម្ចាស់ពានញ៉ាំលឿនបំផុតប្រចាំផ្នែក អាមៀ លី អ៊ីនថាច់ គួរតែសិក្សាស្វែងយល់ជាមុនថា ក្រៅពីតំណែងជាបវរ កញ្ញាមហាវិទ្យាល័យដែលខ្ញុំទទួលបានហើយ ខ្ញុំក៏បានតំណែង ស្ដេចស៊ីពីមិត្តភក្ដិជិតស្និទ្ធដែរ ព្រោះជាជំនាញអារឿងស៊ីចុកលឿន និងស៊ីច្រើនគ្មានអ្នកដូច លោកស្រេចផស់ខ្ញុំមិនខាន!

"ឆាប់ឡើង ចាប់បន្តិចម៉ោ ចូលក្នុងផ្ទះ ក្ដៅសឹងស្លាប់"

"ចាំ គេជគុណដឹសង្ការនិងមានមន្តស្នេហ៍លើលោករបស់ ទេសករ ស្លឹកតើយ"

ខ្ញុំតបទាំងប្រឹងនាំធ្មេញនិយាយ ដៃក៏យួរអីវ៉ាន់ដែលទិញមកពី ហាងបន្ថែមឡើងចុកដៃចុកជើង ដើរតាម អ៊ីនថាច់ ចូលផ្ទះលំនៅ របស់គេ ។

"ល្អណាស់ទាសករ ហើយទៅយកទឹកក្រូចត្រជាក់ៗមកឲ្យ គេជគុណម្នាក់នេះផង"

អ៊ីនថាច់ ងាកមុខមកញញឹមដាក់ ហើយក៏ដើរទៅអង្គុយគង អន្ទាក់ខ្លានិងគ្រដាងដៃលើសាឡុង ។

មែនហើយ! ខ្ញុំចាញ់ ចាញ់ដាច់ឆ្ងាយទៀតផង ប្រុស... ធ្វើឲ្យខ្ញុំដឹងថា នៅលើ ស្លឹកតើយ ស្តេចស៊ី នៅមានអាថ៌... ម្នាក់ទៀត គេស៊ីលឿនខ្លាំងណាស់ ខ្លាំងដល់ថ្នាក់ខ្ញុំញាក់ឆ្អឹល ។

គេឈ្នះដាច់ ហើយប្រាកដណាស់ថាហ្គេមពីដំណើរការ... តាមការព្រមព្រៀង បញ្ជាដំបូងគឺខ្ញុំត្រូវធ្វើជាទាសករ និង... ដោយសព្វនាមថា **តេជគុណដ៏សង្ហា និងមានមន្តស្នេហ៍លើលោក... របស់ទាសករ ស្លឹកតើយ** យ៉ាងម៉េចដែរ កាលីបទេ?

"..." ខ្ញុំលួចជេរតាមរយៈខ្សែភ្នែកដូចទម្លាប់ ហើយក៏... របស់ទៅទុក ដោយញែកថង់ម្ហូបនិងថង់ខោអាវចេញពីគ្នា ។

"ទាសករ តេជគុណចុកជើង មកម៉ាស្សាឲ្យបន្តិច"

"ចាំ" ខ្ញុំខាំធ្មេញដើរទៅរក ។

"ឯណាទឹកក្រូច?"

"ចាំ"

ខ្ញុំដើរទៅបើកទូទឹកកក និងយកកែវមកចាក់ទឹកក្រូចឲ្យ... ភ្នែកក៏ក្រឡេកឃើញកន្លែងទុកកាំបិតល្មម...សម្លាប់ចោលល្អទេ?

"ដាប់ឡើង ស្រេកទឹក"

សំឡេងស្រែករបស់គេ ធ្វើឲ្យខ្ញុំធ្វើភ្នែកឡេមឡាម ហើយ... កាន់កែវទឹកក្រូចទៅរកគេ ព្រមទាំងញញ៉ឹញដាក់ដែរ ។

"អង្គុយចុះ ចុកជើង ម៉ាស្សាឲ្យបន្តិច"

គីនចាន់ ទទួលយកកែវទឹកក្រូច ហើយក៏ប្រាប់ឲ្យខ្ញុំអង្គុយ... កម្រាល...ហ៊ើយ ទ្រាំទៅ ស្លឹកតើយ ទ្រាំ!

គេលើកជើងដាក់លើតុកញ្ចក់ ដែលត្រូវតុបតែងដោយស... ខ្យងនៅខាងក្នុងយ៉ាងស្រស់ស្អាត ។

"ម៉ាស្សាទៅ"

"..."

ល្មើយចុះ ជួយមិនបានទេ...

ខ្ញុំដាក់ដៃលើជើងរបស់គេ និងបញ្ចេញកម្លាំងច្របាច់ ។

បានឮសំឡេងរបស់គេជញ្ជក់មាត់ ហើយក៏ដាក់ជើងចុះ មុននឹងដាក់កែវទឹកក្រូចលើតុ ហើយងើបឈរ ចំណែកខ្ញុំក៏បានតែមើលគេទាំងមិងមាំង ។

គីនចាន់ ងើបឈរស្រាតខោខូវប៊យបោះទៅលើសាឡុងមួយទៀតយ៉ាងលឿន ។

ហឿក!

គេធ្វើស្អីហ្នឹង?

"ច្របាច់ពីលើខោវាគ្មានអារម្មណ៍ទេ"

"ហាស..."

"អ៎ ម៉ាស្សាបានហើយ ទាសកររបស់តេជគុណ"

ខ្ញុំលេបទឹកមាត់ក្អឹកៗ ។

គេអង្គុយចុះវិញ ហើយក៏ដាក់ជើងលើតុកញ្ចក់នៅពីមុខ ។

ខ្ញុំមើលជើងវែងមាំរបស់គេ ហើយក៏ដាក់ដៃយឺតៗទៅលើស្មងជើង មុននឹងបញ្ចេញកម្លាំងច្របាច់ខ្លាំងៗ ។

កំភួនជើងរបស់គេមានសាច់ដុំឬ អាំ!

"ខ្ពស់បន្តិចទៀត ខ្ពស់ទៀត"

"..."

ខ្ញុំខាំមាត់ រំកិលដៃកាន់តែខ្ពស់ទៅរកជង្គង់របស់គេ ព្យាយាមមិនមើលខ្ពស់ជាងនោះ ព្រោះវា...អាដែលឃើញកាលពីព្រឹកវាកំរត់បុលមកក្នុងខួរក្បាលភ្លាម ។

អ៊ុយ...ហេតុអីបានជាបេះដូងលោតញាប់បែបនេះ!

"ខ្ពស់ទៀត"

សំឡេងបញ្ជាពីបិសាចកំណាចបន្លឺឡើងម្តងទៀត ធ្វើឲ្យខ្ញុំខាំ

មាត់ ហើយរំកិលដៃម៉ាស្សាទៅដល់ភ្លៅរបស់គេ ថ្ងាំ...ថ្ងាំ...
បានហើយ ចង់ឲ្យម៉ាស្សាខ្ពស់ទៅដល់ណាទៀត ?

"ខ្ពស់ទៀត ម្ដាំ..."

ចង់ធ្វើអី!

ខ្ញុំស្រែកក្នុងចិត្ត តែមិនហ៊ាននិយាយចេញមក ខ្លាចចង្រៃ របស់គេមែនទែន ។

ខ្ញុំខិតដៃឡើងខ្ពស់ទៀត និងព្យាយាមប្រាប់ខ្លួនឯងមិនឲ្យ... ដៃគេ...ជើងរបស់គេក្ដៅដល់ហើយ ។

"ម្ដាំ...ដៃទាសករទន់ល្មើយដល់ហើយ ធ្វើឲ្យគេជាប់អារម្មណ៍ អ៊ុំ...ស៊ីត!"

"ធ្វើសំឡេងបែបនេះធ្វើអី ឈប់បានទេ ?"

"ដំឡើងសំឡេងឬ ?"

"គ្រាន់តែ...អង្វរ"

ខ្ញុំហ៊ាស្រាប់ ហើយក៏ច្របាច់យ៉ាងលឿន ។

អ្នកដែលធ្វើសំឡេងគួរឲ្យស្អប់ក៏លើកជើងបញ្ឈរជង្គង់យ៉ាង រហ័ស និងធ្វើឲ្យខ្ញុំគ្រៀមខ្លួនមិនទាន់ ទើបដៃធ្លាក់ដោយមិនបាន ប្រុងប្រយ័ត្នខ្លួន ។

ដៃរបស់ខ្ញុំធ្លាក់ទៅលើ...លើ...

"ម្ដាំ...ភយលុកបែបនេះ ខ្ញុំយ៉ាប់មិនខាន"

"វ៉ាយ!"

ខ្ញុំស្រែកហើយក៏ដកដៃចេញ ព្រមទាំងរត់គេចភ្លាម ចំណែក ត្រចៀកនៅតែបានឮសំឡេងសើចរបស់អាម្សៀបិសាច អ៊ិនថាច់ តាមពីក្រោយ ។

# ៦

## សម្របខ្លួនឲ្យចុះសម្រុងគ្នា (ម្ល)

[Intouch's Talk]

ខ្ញុំមើលអ្នកដែលពាក់អាវដៃវៀលពណ៌ស្រស់ និងស្លៀកខោខ្លី ដើរទាត់ខ្សាច់លេងនៅខាងមុខ ។ កាលពីម្សិល ស្ពឹកតើយ ចាញ់ ល្បែងភ្នាល់ប្រកួតញ៉ាំល្បឿនជាមួយខ្ញុំ ហើយត្រូវបង្ហាប់តិចតួចនាង ក៏រត់គេច ។ ពីម្សិលខ្ញុំប្រហែលជាលេងសើចជាមួយនាងខ្លាំងបន្ដិច ទាំងលុកលាន់នៅពេលព្រឹក ( សារភាពតាមត្រង់ថាចង់លេងបែប នេះទៀត ) ហើយក៏ធ្វើបាបឲ្យនាងធ្វើជាទាសកររហូតដល់មាន រឿង ទើបពេលល្ងាចមិនរញ៉េរញ៉ៃនឹងនាងទៀត ។

ស្ពឹកតើយ ធ្វើអាហារដោយខ្លួនឯង រសជាតិធម្មតា មិនបាន ឆ្ងាញ់ពិសារ តែពេលដែលញ៉ាំវាក៏មានកម្លាំងដោយប្រាប់មិនត្រូវ (គងមាន់និងបាយ) ។

"ស្ពឹកតើយ មិនចង់ហែលទឹកទេឬ ?"

"..."

មនុស្សស្រីដែលដើរទាត់ខ្សាច់ងាកមកមើលមុខខ្ញុំ ថ្ងៃនេះនាង មិនបាននិយាយរឿងត្រឡប់ទៅសេអ៊ូលវិញ អាចមកពីនិយាយ ហើយក៏ដឹងថាខ្ញុំមិនធ្វើតាម...ស្រីតូចរបស់ អ៊ីនថាច់ សម្របខ្លួន បានល្អ ។

"អត់ទេ គ្មានឈុតហែលទឹក"

"ហើយម៉េចក៏ពីម្សិលមិនទិញ ?"

ស្ពឹកតើយ ធ្វើធម្មតា ដើរទាត់ខ្សាច់អាចឲ្យរលកជោរមកប៉ះ ត្រឹមកជើងលេងបន្ដ ។ ខ្ញុំដើរតាមនាង កម្ដៅពេលល្ងាចមិនក្ដៅ ហើយទឹកសមុទ្រក៏កក់ក្ដៅ ព្រោះត្រូវពន្លឺព្រះអាទិត្យពេញមួយថ្ងៃ ។

www.srolanhkhmer.com

"ខ្លាចខ្ញុំឃើញរាងកាយឬ ?"

"..." នាងមិនតប ។

"ខ្ញុំធ្លាប់ឃើញច្រើនដងទៅហើយ ចាំមិនបានឬ ?"

"តែពីរដង"

ខ្ញុំសើច ពេលស្រីតូចចាញ់កលងាកមកប្រកែកជាមួយ ។

"រាប់ដែរឬ ?"

លើកនេះ ស្លឹកតើយ មិននិយាយ នាងដើរត្រឡប់ទៅផ្ទះភ្ញៀវ គួរសមអារម្មណ៍ដើរលេងលើឆ្នេរខ្សាច់តាមដែលខ្ញុំបបួល ។

"ចង់គេចអីចឹងឬ ?" ខ្ញុំសួរ មុននឹងរត់ទៅរក ។

នាងក៏ងាកមក មើលទៅនាងភ្ញាក់ផ្អើល ហើយក៏ស្រែករួចទាំងរត់គេចពីខ្ញុំ តែយឺតពេលទៅហើយ ខ្ញុំស្រវាទាញចង្កេះរបស់នាង ហើយក៏លើកបីនាំទៅសមុទ្រ ។

"វ៉ាយ! ចង់ធ្វើអី កុំ"

នាងស្រែកអស់សំឡេង ប៉ុន្តែខ្ញុំក៏នាំនាងចុះសមុទ្រជារៀងរហូតដល់ទឹកដល់ត្រឹមភ្លៅ ហើយគ្រវែងនាង ។

"អាំយយយ!"

គ្រាំ!

រាងកាយរបស់នាងត្រូវបានគ្រវែងទៅក្នុងទឹក ខ្ញុំឈរមើលអ្នកដែលប្រវេប្រវាដើបឈរ សក់វែងរបស់នាងទទឹកអស់ ស្លឹកតើយ ឈ្លក់ហើយក៏លុបមុខ ចំណែកភ្នែកស្អាតរបស់នាងសម្លក់សម្លឹងខ្ញុំដោយកំហឹង ។

"បង អ៊ីនចាច់!"

"បាទ"

"ងាប់ទៅ!"

នាងស្រែកហើយក៏រត់លុយទឹកមករកខ្ញុំដោយកំហឹង ខ្ញុំ...

ក្រោយគេម្តង ប៉ុន្តែនាងបែរជាលោតមកឱបរឹតកខ្ញុំពីក្រោយ ទម្លាក់ទម្ងន់ទាំងអស់មកលើខ្ញុំ ធ្វើឲ្យខ្ញុំដួលទៅក្នុងទឹក ។

"ហេ៎!"

គ្រាំ!

ទាំងខ្ញុំទាំងនាងដួលទៅក្នុងទឹកសមុទ្រ ទឹកប្រៃៗចូលតាមច្រមុះនិងមាត់ ខ្ញុំក៏ក្រឡាស់ទ្រនាំនាងចុះ តែ ស្លឹកតើយ ដូចជាច្រាល់ឈាមពេញមុខ នាងច្រមក់នេះទៅយកកម្លាំងកំហែងមកពីណាច្រើនម្ល៉េះ ដៃទាំងពីររបស់នាងរឹតកខ្ញុំ មានចេតនាទម្លាក់ទម្ងន់មកលើខ្ញុំទាំងអស់ ។

"ស្លឹកតើយ !" ខ្ញុំហៅឈ្មោះអ្នកដែលកំពុងតែធ្វើដូចចង់សម្លាប់ខ្ញុំមែនទែនយ៉ាងអីចឹង មិនមែនជាការលេងសើចរបស់គូស្នេហ៍តាមការគួរ "ស្លឹកតើយ បានហើយ"

"ងាប់ទៅ" ស្លឹកតើយ ស្រែកដាក់ មុននឹងចាប់សង្កត់ស្មាទាំងពីររបស់ខ្ញុំ ។

ខ្ញុំត្រូវចាប់ជ្រមុជទឹក តែក៏លើកដៃទាំងពីរឱបចង្កេះរបស់នាង ហើយរកវិធីសងសឹកបាន ដោយការ...

"អាំយយយ!"

"ខេះៗ ព្រមហើយនៅ"

"បង អ៊ីនចាច់ លែង!"

"មិនលែង ចាប់បែបនេះហើយទន់ល្អ"

មែន! វាទាំងទន់ ទាំងម៉ដ្ឋ និងអន្ទិលពេញដៃខ្លាំងណាស់ ខ្ញុំកំពុងតែចាប់ដើមទ្រូងទាំងពីររបស់នាង ហាសៗ!

"ព្រមហើយ ឈប់លេងហើយ"

មនុស្សតំណាករហ័សប្រាប់ ហើយវាសដៃខ្ញុំចេញ មុននឹងឱបទ្រូងខ្លួនឯងជាប់ អាវដែលទទឹកក៏មើលឃើញខាងក្នុង នាងពាក់

អាវក្នុងដែលខ្ញុំទិញឲ្យ...បើស្លៀងលើពាក់...ចុះស្លៀងក្រោម?

"កុំធ្វើមុខបែបហ្នឹង ទឹកមាត់ជិតស្រក់ហើយ"

ស្លឹកតើយ ប្រាប់ដោយសំឡេងកាច ហើយក៏ដើរលុយទឹកឡើងឆ្នេរ ។ ខ្ញុំក៏បំប្រិចភ្នែក ហើយហៅស្មារតីមកវិញ មុននឹងប្ដូរមុខ សម្រួលអារម្មណ៍ មុននឹងដើរលុយទឹកតាមនាងឡើងឆ្នេរ ។

ស្លឹកតើយ មានជើងស្អាតនិងស្រឡូន ខ្ញុំធ្លាប់ប៉ះខ្លះហើយពេលដែលបីនាង ភ្លៅរលោងទាំងម៉ដ្ឋនៃ ល្អិតពិតលេងវាត មនុស្សស្រីម្នាក់នេះស៊ីឡេណាបស្បែកជាអាហារឬអត់ ។

"មិនហែលទឹកទេឬ?"

"មិនហែលទេ ខ្ញុំគ្មានឈុតហែលទឹក"

"ពេលនេះក៏ទទឹកហើយតើ ម៉ោះ...ហែលទឹកទៅ"

ខ្ញុំមិនឈប់ដេញដោល មើលរាងតូចច្រឡឹងពីក្រោយ ហើយក៏ចង់តែទៅអុកម៉ាក់ថារៀបចំពិធីដល់ណាហើយ ចង់មានប្រពន្ធហើយ ។

"ស្លឹកតើយ ហែលទឹកជាមួយខ្ញុំទៅ"

"មិនហែល ខ្ញុំផ្ងា"

"តែទឹកកក់ក្ដៅ" ខ្ញុំបបួលបន្ត ដើរតាមនាងមកដល់ឆ្នេរខ្សាច់ ស្លឹកតើយ ក៏ងាកមកមើលខ្ញុំបន្តិច ហើយក៏ងាកមុខចេញ តែក៏គ្រប់គ្រាន់នឹងឲ្យខ្ញុំឃើញមុខក្រហមព្រឿងៗរបស់នាង ។

នាងកំពុងតែអៀនខ្ញុំ គឺគួរតែអៀន មនុស្សស្រីឯណាមកធ្វើមុខសោះអង្គើយដាក់មនុស្សប្រុសដូចជាខ្ញុំបានទៅ ។

"ខ្ញុំឃ្លានហើយ ទៅរកអីញ៉ាំ"

"ហ៊ឺ...ពងមាន់ទៀតហើយឬ"

មែន...រឿងមួយទៀតពាក់ព័ន្ធនឹង ស្លឹកតើយ ដែលខ្ញុំទើបតែដឹង គឺនាងមិនចេះធ្វើម្ហូប មុខម្ហូបដែលស្ទាត់ជំនាញរបស់នាងគឺស្ងោរពងមាន់ជ្រលក់ទឹកស៊ីអ៊ីវ និងចៀនពងមាន់ប៉ុណ្ណោះ ។

"បើធុញញ៉ាំពងមាន់ហើយ នាំខ្ញុំទៅវិញទៅ"

"នាំទៅភោជនីយដ្ឋានមិនលឿនជាងសេអ៊ីលឬ" ខ្ញុំព្យកហើយញាក់ស្មា មុននឹងដើរដឹកដៃនាងញាប់ជើងស្ទេក ។

"ចាំខ្ញុំធ្វើម្ហូប ក្រែងឃ្លាននោះអី ម៉ោះ"

យើងទាំងពីរនាក់មកដល់ផ្ទះ ខ្ញុំឲ្យ ស្លឹកតើយ ទៅងូតទឹកនៅបន្ទប់របស់នាង ចំណែកខ្ញុំក៏ងូតទឹកនៅបន្ទប់មួយទៀត ។

កាលពីយប់មិញពេលដឹងថាខ្ញុំដេកបែកបន្ទប់ ស្លឹកតើយ ក៏មានអារម្មណ៍ធូរស្រាល ដែលវាក៏ល្អ ព្រោះជាធ្វើឲ្យនាងមិនសូវប្រុងប្រយ័ត្នខ្ញុំ ។

ខ្ញុំងូតទឹករួចមុន និងកំពុងតែដាំទឹកដើម្បីស្រុសមី ចំណែកទូរសព្ទដៃដែលខ្ញុំដាក់នៅចតតុក៏រោទ៍ ។

ខ្ញុំលើកចិញ្ចើម ពីម្សិលខ្ញុំបិទទូរសព្ទ និងទើបតែបើកមុនពេលចេញទៅឆ្នេរខ្សាច់ជាមួយ ស្លឹកតើយ ។ ខ្ញុំដើរទៅយកមកមើលលេខ ហើយក៏ចុចទទួល ។

"សួស្ដីម៉ាក់"

[End Intouch's Talk]

ខ្ញុំធុំក្លិនឈ្ងុយរសាត់មកពីចម្ងាយ តែមិនទាន់បានចុះជណ្ដើរកាំចុងក្រោយផងពោះក៏គួរគ្រូកៗភ្លាម ព្រោះថាកាលពីថ្ងៃត្រង់បាយពងមាន់វាណែនកពេញបន្ទុក ។ តាមពិតទៅ អ៊ិនថាច់ ក៏ប្រាប់ថានាំទៅញ៉ាំនៅហាង តែថាខ្ញុំមិនចង់ចេញទៅខ្មាសគេទៀតនៅឯណា ព្រោះ អ៊ិនថាច់ តែងតែធ្វើអីពាលៗឆ្កួតៗរហូត ដូចកាលទៅទិញអីវ៉ាន់អីចឹង គេធ្វើឲ្យខ្ញុំសឹងតែចង់យកជីស្រ្លីងចងកសម្លាប់ខ្លួនព្រោះតែភាពអាម៉ាស់ ។

"មកហើយឬ អង្គុយសិនម៉ោ កំពុងក្ដៅៗ"

ខ្ញុំមើលមុខបុរសដែលពាក់អាវប៊ិតធិក ( Batik ) ពណ៌... ដឹងថា អ៊ីនថាច់ មានអាយុច្រើនជាងខ្ញុំច្រើនគួរសម ប៉ុន្តែ... ដែលគេគុបតែងខ្លួនសាមញ្ញៗ មិនបានធ្វើម៉ូដសក់ បណ្ដា... សក់វែងលុបកញ្ចឹងកនិងថ្ពាស...គេមានមុខក្មេងជាងខ្ញុំច្រើន... ប្រហែលមកពីគេមើលថែខ្លួនឯងបានល្អទេដឹង ?

"មកហើយ មុខម្ហូបពិសេស មីស្រុសញាក់សាច់"

ហ៊ឺម ?

ខ្ញុំឈ្ងោកមើល...អាសរសៃដែលអណ្ដែតត្រាចុងទឹកខាប់ៗ... នេះ...មើលយ៉ាងណាក៏ជាមីកញ្ចប់ តែវាមានពងមាន់ បង្គាធំៗ និង... និងសាច់ជ្រូកចៀន ថែមទាំងមានក្រួចឆ្មារបន្ទះស្ដើងៗទៀត... ហើយដែលសំខាន់ទំហំបាននេះ...

"នេះជាស្អី ?"

"...មីស្រុសញាក់សាច់ហ្នឹងអី"

អ្នកដែលអង្គុយនៅមុខបានមីរបស់គេប្រាប់ ហើយក៏យកចង្កឹះ... រៀបឲ្យមើល ។

"មានន័យដល់កាផន៍ដែលដាក់នេះ"

"បានហ្នឹងអី"

គេជ្រួញចិញ្ចើម ហើយមើលខ្ញុំដូចមនុស្សអន់ខួរដែលស្ដាប់... ល្ងង់ៗ ទើបខ្ញុំបានតែគ្រវីក្បាល ។

"បើវាធំដល់ថ្នាក់នេះ នៅផ្ទះខ្ញុំគេហៅបានដែក!"

"ហើយយ៉ាងម៉េច វាដាក់របស់ញ៉ាំបានទេ ?"

បុរសនៅចំពោះមុខនេះជាអ្នកជំនួញពោរពេញដោយសម... ភាព បុរសសង្ហាក្នុងវ័យហៃសូកូប៉ែខាងត្បូងឬអត់នេះ ហេតុអ្វី... បានជាគេទាំងពូកែបេះបួយឲ្យខឹង និងមាត់ចំដា...

"ញ៉ាំទៅ តិចត្រជាក់លែងឆ្ងាញ់ ប្រាប់ទៅចុះថាមុខម្ហូបនេះរកមិនបាននៅកន្លែងផ្សេងទេ"

"មីស្រុសបំពង់ទឹកក្ដៅនេះ នៅកន្លែងណាក៏រកញ៉ាំបានដែរ"

"ញ៉ាំតាមសម្រួល ឬចង់ឲ្យបញ្ជក ហើយយកអណ្ដាត..."

"ញ៉ាំ!"

ខ្ញុំចាប់ស្លាបព្រាក្រកម្វាយអារម្មណ៍តិចៗ ក្បួរខ្លាំងពេកខ្លាចទឹកខ្ទាត ។ ខ្ញុំមើលអាហារដែលធ្វើញ៉ាំជាប្រចាំកាលនៅរៀន ពេលដែលខ្ជិលខ្លាំងឬអានសៀវភៅយប់ជ្រៅពេក ។

"ឆ្ងាញ់"

មួយម៉ាត់ដំបូងដែលចូលមាត់ ក៏ប្រាប់បានថាឆ្ងាញ់ណាស់ ខ្ញុំងើយមើលមុខអ្នកធ្វើដោយខ្សែភ្នែកចម្លែកចិត្តយ៉ាងខ្លាំង វាមិនដូចដែលខ្ញុំញ៉ាំរយៈពេល២០ជាងហ្នឹងណា ។

"សរសៃទន់ល្មៀយ ទឹកក៏ឆ្ងាញ់ ពងមាន់ក៏ឆ្ងាញ់" ខ្ញុំសរសើរ ហើយក៏ចាប់មីញាត់មាត់ ព្រមទាំងហុតទឹកយ៉ាងឆ្ងាញ់ ។

"ប្រាប់ហើយតើ...ចូលចិត្តទេ ?"

"អឺម ចូលចិត្ត" ខ្ញុំញញឹមដាក់គេ ហើយភ្លាមនោះពេលដែលគេធ្វើមុខរំភើប ទើបខ្ញុំឈ្ងោកមុខញ៉ាំបន្ត ។

ខ្ញុំល្ងោភដែរទេ គ្រាន់តែគេធ្វើរបស់ឆ្ងាញ់ឲ្យញ៉ាំក៏ញញឹមទៅហើយ ។

"បើចូលចិត្ត អីចឹងរៀបការជាមួយខ្ញុំទៅ ហើយខ្ញុំនឹងធ្វើឲ្យញ៉ាំរាល់ថ្ងៃ"

នេះជាសម្ដីរបស់ លី អ៊ីនថាច់ មេបញ្ជាការឬនេះ...ហេតុអីបានជាភ្លើមល្វែម និងរ៉ូមែនទិកម្ល៉េះ!

"ឆ្កួតទេ ?"

"ចា៎"

"នៅឲ្យស្ងៀម"

អ៎…ខ្ញុំជ្រួញចិញ្ចើមមើលអ្នកដែលអង្គុយទល់មុខ គេចង់ឲ្យ

…អ៊ីនថាច់ មើលខ្ញុំហើយលូកដៃមករក ខ្ញុំភ្ញាក់ថយក្រោយ ដើម្បី

ស្ដីឲ្យទៀត ។

"ប្រាប់ថានៅឲ្យស្ងៀម"

ខ្ញុំអង្គុយស្ងៀម គេក៏លូកដៃមករក មុននឹងប្រើចុងម្រាមដៃប៉ះ តែមមាត់របស់ខ្ញុំ ហើយប្រាប់ដោយសំឡេងដ៏ស្រទន់ ។

"ញ៉ាំយ៉ាងម៉េចហ្នឹង ប្រឡាក់អស់ហើយ"និយាយចប់គេក៏យក ម្រាមដៃដែលប្រឡាក់ទឹកស៊ុបពីតែមមាត់របស់ខ្ញុំ ទៅដាក់លើបបូរ ខ្លួនឯង ហើយលៀនអណ្ដាតមកលិឍ ។

ហ្អឹក!

អ្វីដែលគេធ្វើ វាធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលព្រឺក ហាក់ដូចមនុស្សជិះទូក ហើយធ្លាក់ជង្ហុកយ៉ាងទាន់ហន់ ។

អ៊ីនថាច់ ជាមនុស្សប្រុសសិចស៊ី ទោះគេឈរឬអង្គុយស្ងៀម ក៏សិចស៊ីសឹងស្លាប់ទៅហើយ កាន់តែមកធ្វើទឹកមុខបែបនេះ លើក ម្រាមដៃបែបនេះ អូយ…បេះដូងខ្ញុំចង់គាំង!

ភ្លាមនោះ អារម្មណ៍ម្យ៉ាងវាក៏បោលសម្រុកមករកខ្ញុំយ៉ាងខ្លាំង មនុស្សម្នាក់នេះកំពុងក្លាយជាបុរសរបស់ខ្ញុំ អារម្មណ៍មានមោទន ភាពប្លែកៗរត់សព្វសាច់ ធ្វើឲ្យព្រឺសម្បុរពេញខ្លួន ។

"ខ្ញុំ…ខ្ញុំលាងចានឲ្យ"

"…"

គេមិនទាន់បានញ៉ាំផង ទើបខ្ញុំលើកតែចានរបស់ខ្លួនឯងដែល ញ៉ាំអស់លើងទៅតុលាងចាន ហើយបើកទឹកដោយដៃញ័រទ្រើតៗ ហេតុអីដៃញ័របែបនេះ?

ខ្ញុំទើបតែបើកទឹក មិនទាន់បានធ្វើអីនោះទេ គ្រាន់តែចង់គេច

មុខពីគេមកដកដង្ហើមចូលឲ្យពេញសួតប៉ុណ្ណោះ ប៉ុន្តែកម្ដៅចេញពី រាងកាយរបស់អ្នកដែលឈរកៀកក្រោយខ្នង ក៏ធ្វើឲ្យខ្ញុំរឹងខ្លួនដោយ ធ្វើអ្វីមិនត្រូវ ។ អ៊ីនថាច់ លូកដៃមកចាប់តុ មើលដោយប្រយោលគឺ ដូចគេឱបខ្ញុំពីក្រោយ ។

បេះដូងរបស់ខ្ញុំលោតញាប់ ញាប់ដល់ថ្នាក់ខ្លាចថាអ្នកនៅ ក្រោយខ្នងបានឮ ។

"បង អ៊ីនថាច់ ចង់ធ្វើអី?"

"ជួយលាងចានហ្នឹងអី"

"ត្រឹម…ត្រឹមចានមួយ ខ្ញុំធ្វើម្នាក់ឯងបាន មិន…មិនបាច់ទេ បងទៅញ៉ាំអាហារទៅ"

"ខ្ញុំមិនឃ្លាន"

គេតបដោយសំឡេងគ្រលរនៅជិតត្រចៀកខ្ញុំ ។

អូយ…ងាប់មិនខាន ខ្ញុំធ្វើយ៉ាងម៉េចទៅ បេះដូងវាលោតញាប់ ដៃក៏គ្មានកម្លាំងកំហែង ។

កាលពីម្សិលខ្ញុំអាចរើបម្រះ អាចរត់គេចពីគេបាន ហេតុអីថ្ងៃ នេះគ្រាន់តែងាកខ្លួនចេញពីរង្វង់ដៃរបស់ អ៊ីនថាច់ ខ្ញុំធ្វើមិនទាំង បានផង ហើយអារម្មណ៍រំភើបនេះវាជាអ្វី?

"លាងទៅ"

ដៃធំគ្រាស់រំកិលមកចាប់ដៃរបស់ខ្ញុំ មុននឹងអង្អែលកដៃ ហើយក៏នាំដៃរបស់ខ្ញុំលាងចាន ខ្ញុំចាប់ចានធំដែលខ្លួនឯងប្រាប់ថា ដូចភាជន៍ គួរឲ្យប្លែក វាដូចធ្ងន់ជាងមុន១០ដង លើកសឹងមិនរួច ឬ ថាកម្លាំងកំហែងរបស់ខ្ញុំវារលាយបាត់អស់?

"…" ខ្ញុំ ឬហៅឲ្យត្រូវគឺ **យើង** លាងចានមួយនោះ ។

"ជូតឲ្យខ្លាំងៗបន្តិច វាជិតចេញហើយ"

ព្រាវ!

បានធំធ្លាក់ទៅលើកម្រាលបែកភ្លាម សំណាងល្អដែល...
បានបែកមុតជើងអ្នកណា ។

ខ្ញុំខ្ទឹបមាត់ដែលញ័រតិចៗ តើអ្នកណាប្រើឲ្យគេមក...
បបួលឲ្យស្រៀវបែបនោះក្បែរត្រចៀកធ្វើអី ដឹងថាវាមាន...
ដុសយកសំណល់អាហារចេញពីចាន ប៉ុន្តែ...

"តិតស្អីលាមកឬអត់ ?" អ្នកដែលឈរកៀកក្រោយខ្នង...
សួរ ។

ខ្ញុំដកដង្ហើមធំ ហើយក៏លាងដៃ មុននឹងបន្ទន់ខ្លួនអង្គុយ...
ប្រមូលអំបែងចាន ។

"មិនបាច់ទេ តិចមុតដៃ"

"អ៊ុយ!"

អ៊ីនថាច់ លោកមានមាត់ទិព្វមែនទេ!

ពេលដែលនិយាយរឿងមុតដៃភ្លាម ម្រាមដៃរបស់ខ្ញុំក៏មុត...
ប៉ុន្តែអ្នកដែលភ្ញាក់ផ្អើលមិនមែនខ្ញុំ ជាមនុស្សប្រុសដែល...
មកចាប់ដៃរបស់ខ្ញុំមើលទៅវិញទេ ។

"ឃើញទេ ប្រាប់ហើយមិនស្ដាប់ មើល៍ មុតជ្រៅទេ មានឈាម
ចេញដែរ"

ចង់ហៅឲ្យវិញថារបួសឯណាមិនចេញឈាម ប៉ុន្តែទឹកមុខ
ព្រួយបារម្ភរបស់គេក៏ធ្វើឲ្យខ្ញុំនិយាយមិនចេញ ។

"អាំ"

ហើយមុនពេលខ្ញុំបានហាម គេក៏យកម្រាមដៃរបស់ខ្ញុំដាក់
ចូលមាត់ បិតធ្វើព្រងើយ ។

"កុំ" ខ្ញុំហាម តែគេមិនស្ដាប់ គេបិតទាល់តែរបួសលែងចេញ
ឈាមហើយ ទើបព្រមដកម្រាមដៃរបស់ខ្ញុំចេញពីមាត់របស់គេ ។
មុខរបស់ខ្ញុំពេលនេះក្រហមដូចត្រូវទឹកក្ដៅស្រុសមិនខាន

ព្រោះបារកក្ដៅពេញមុខនិងក ។ អ៊ីនថាច់ លែងម្រាមដៃរបស់ខ្ញុំ
ចេញពីមាត់យឺតៗ ហើយនាទីនោះយើងក៏មើលមុខគ្នា ។

មួយនាទី...ពីរនាទី...និងនៅនាទីទីបី ខ្ញុំក៏មិនអាចដកភ្នែក
ចេញពីកែវភ្នែកមុតស្រួចពណ៌ត្នោតនោះបាន ។

អ៊ីនថាច់ ឈោមុខមកជិត ហើយខ្ញុំដែលមិនដឹងខ្លួន ខ្ញុំក៏ឈោ
មុខទៅរកគេដូចគ្នា ។

បបូរមាត់របស់ អ៊ីនថាច់ ក្ដៅឧណ្ហៗ តែបែរជាធ្វើឲ្យបបូរមាត់
របស់ខ្ញុំមានអារម្មណ៍ដូចត្រូវភ្លើងឆេះ...កម្ដៅនិងភាពហឹររបស់
អាហារដែលទើបតែញ៉ាំ វាប្រៀបមិនបាននឹងកម្ដៅរបស់បបូរមាត់
ប្រុសមេផ្ទាប់ការម្នាក់នេះនោះទេ ។

ពេលង្កត់បបូរមាត់ខ្លាំងៗ មុននឹងថើបជញ្ជក់ ហើយនៅនាទី
បន្ទាប់មកគេក៏ក្រសោបមុខខ្ញុំ បង្ខំឲ្យខ្ញុំទទួលយកការថើបពីគេ
ការថើបដ៏រោលរាលដែលកាន់តែក្ដៅគគុកនិងទាមទារ ធ្វើឲ្យខ្ញុំ
បង្អើបបបូរមាត់ទទួលគេ ។

"..."

សំឡេងទឹកដែលបើកចោលនៅតែឮ ប៉ុន្តែនាទីនេះបេះដូង
របស់ខ្ញុំបែរជាលោតញាប់ដល់ថ្នាក់ខ្លាចថា អ៊ីនថាច់ បានឮ ។

[Intouch's Talk]

ខ្ញុំក្រែកអណ្ដាតចូលទៅក្នុងប្រអប់មាត់ សេរើបរបស់ ស្ទីក
តើយ ក្រអូបផ្អែមជាងមុនរាប់រយដង ពេលដែលវាកើតឡើងដោយ
សារពេញចិត្តរបស់នាង ទាំងដែលពីម្សិលស្រីតូចរបស់ខ្ញុំមិនព្រម
ឲ្យថើប ប៉ុន្តែពេលនេះព្រោះអ្វីក៏មិនដឹង នាងបែរជាទន់ភ្លន់ បិទភ្នែក
ក្រឹមៗ ហើយថើបតបខ្ញុំទាំងងេមងាម គ្មានបទពិសោធ...គ្មានបទ
ពិសោធអីចឹងឬ? អឹម មានអារម្មណ៍ល្អខ្លាំងណាស់ដែលបានគិត

បែបនេះ ។

"..."

ខ្ញុំសង្កត់បបូរមាត់ បានឮសំឡេងដកដង្ហើមរបស់នាង ខ្ញុំចង់ថើបនាងច្រើនជាងនេះ ប៉ុន្តែត្រូវតែមិនមែនទីនេះ ព្រោះ ជាផ្ទះបាយ ទើបខ្ញុំលើកបីនាងដោយមិនព្រមដកបបូរមាត់ ព្រោះខ្លាចជាភាពក្រអូបផ្អែមដែលបានទទួលវាលាយបាត់ ពីលើ នាងនឹងខ្លួន ។

ខ្ញុំបីស្រីតូចរបស់ខ្ញុំដើរទៅរកសាឡុង ដែលយើងធ្លាប់អង្គុយ មើលបាល់ជាមួយគ្នា មុននឹងបន្ទាបខ្លួនអង្គុយដោយឲ្យ ស្លឹកតើយ អង្គុយលើភ្លៅរបស់ខ្ញុំ ដៃទាំងពីររបស់នាងឱបករបស់ខ្ញុំ ហើយ តែបើកភ្នែកព្រឺមៗគួរឲ្យស្រឡាញ់ ។

ផ្អែម...ផ្អែមបែបនេះពេញមួយតួខ្លួនដែរទេ ?

"ស្លឹកតើយ..."

ខ្ញុំហៅឈ្មោះនាងពេលត្រដុសច្រមុះនឹងថ្ពាល់ ចំណែកបបូរ មាត់ក៏នៅតែផ្តិតយកភាពផ្អែមល្ហែមរបស់ ស្លឹកតើយ ត្រង់តែមាត់ មិនឈប់ ។

"ហ៊ឹម ?"

"នាងគួរឲ្យស្រឡាញ់"

"អ៊ឺម"

អ្នកដែលត្រូវសរសើរថ្ពុចថ្ពូរនៅដើម.ក ហើយពេលដែលខ្ញុំ ថើបបបូរមាត់ម្តងទៀត ដៃខ្ញុំក៏រំកិលទៅឱបនាង អង្អែលខ្នងរបស់ នាងថ្នមៗ មុននឹងរំកិលដៃមកខាងមុខដាក់លើដើមទ្រូងណែនឡើ ហើយអង្អែលរាគិតចៗ...ដើមទ្រូងរបស់នាងទាំងទន់ល្មៀយ ទាំង តើងមករកដៃរបស់ខ្ញុំ ។

ខ្ញុំជិតផ្ទុះព្រោះតែ ស្លឹកតើយ ហើយ វាឈឺចាប់ត្រង់ប្រឡោះ

ភ្លៅ និងញាក់ដឹងខ្លួនសឹងតែស្ទុះលោតចេញមកក្រៅ ។

"យើងទាំងពីរចុះសម្រុងគ្នាបានល្អមិនខាន នាងយល់អីចឹង ដែរទេ ?"

"..."

នាងមិនឆ្លើយតប អាចមកពីខ្ញុំធ្វើឲ្យនាងគិតអីមិនចេញដោយ មានវេទនា ។

"ចង់ទៅសេអ៊ុលវិញទេ ?"

ខ្ញុំបោះនុយបញ្ឆោតត្រី ហើយត្រីតូចរបស់ខ្ញុំក៏ងាកមកចាប់ អារម្មណ៍នុយភ្លាម ។

"ចង់នាំទៅវិញហើយមែនទេ ?"

"មែន ប៉ុន្តែនាងតាមចិត្តខ្ញុំបានទេ ?"

"តាមចិត្តរឿងអី ?"

នាងសួរទៀត ស្រីឆ្លាសនេះមិនដឹងមែនឬយ៉ាងម៉េច ?

"ខ្ញុំសុំថើបនាង"

"កំពុងថើបហើយតើ"

ខ្ញុំញញឹម មុននឹងឱនថើបបបូរមាត់ប៉ុនតាំនោះថ្នមៗ ហើយក៏ ខ្សឹបតប ចំណែកដៃនៅតែអង្អែលខ្លួនប្រាណរបស់នាងមិនឈប់ ។

"មិនមែនតែមាត់ តែសុំខ្លួនបានទេ ?"

"មិន...មិនឲ្យ"

នាងបដិសេធ ហើយក៏ភ្ញាក់ព្រើតពេលដែលខ្ញុំសង្កត់បបូរមាត់ ថ្នមៗ ហើយក៏ថើបនាងម្តងទៀត វាយលុកដោយអណ្តាត រហូត ដល់អ្នកដែលមិនព្រមទៅជាទន់ខ្លួន ។

"ណក់...មិនលើសពីនេះ"

ខ្ញុំប្រាប់ដោយសំឡេងស្អក ដៃក៏លូកចូលទៅក្នុងអាវរបស់ នាងយឺតៗ ហើយពេលឃើញទឹកមុខរសាប់រសល់របស់ ស្លឹកតើយ

ដែលវាហាក់ដូចនាងកំពុងតែរារែករវាងការចង់ដឹង ចង់សាក...
និងការភ័យខ្លាច ខ្ញុំក៏មិនរង់ចាំយូរ ដឹងចម្លើយដោយស្ទើរ...
គួរធ្វើយ៉ាងណា ដូចដែលថា ភ្លើងនិងសាំង ស្ពៃនិង...
មនុស្សប្រុសកាមនិងស្រីស្អាត...អឹម មិនមែនទេ តែទោះជា...
ដោយ នៅពេលនេះក្នុងបន្ទប់នេះមានតែ ភីនចាច់ និង ស្លឹក...
ហើយពេលដែលខ្ញុំថើបនាងម្តងទៀត ស្លឹកតើយ ក៏ធ្វើត្រឹមតែ...
មុខចេញ ងាកមុខគេចអីចឹងឬ...គេចអីចឹងឬ...គេចមិនផុត...
ភ្ជាប់ថ្ងៃគេចពីខ្ញុំផុតទេ ។

"អ៊ឹម"

ខ្ញុំថើបប្តូរមាត់ក្រោមរបស់នាងយឺតៗ មុននឹងខាំតិចៗ...
ឈឺ ហើយអាស្រ័យពេលដែលនាងខទាន ក៏ជ្រែកអណ្តាតចូល...
អាំ...ខ្ញុំមិនធ្លាប់មានអារម្មណ៍ចង់ឱប ចង់...ធ្វើបែបនេះដាក់...
ណាពីមុនមកទេ ប្រអប់មាត់របស់ខ្ញុំកក់ក្តៅហាង មិនខុសពីពោះ...
និងទាបជាងនោះ វាកំពុងតែរង់ចាំ រង់ចាំយ៉ាងអំភើប និងពេញចិត្ត...
តែកុំអាល ខ្ញុំអត់ធ្មត់...

អត់ធ្មត់...តាមដែលអាចអត់ធ្មត់បាន ។

"..."

ផ្អែមខ្លាំងណាស់...ទន់ខ្លាំងណាស់ ខ្លួននាងធ្វើពីស្ពៃ...ខ្ញុំតិច
ព្រមទាំងរំកិលដៃទៅក្នុងអាវរបស់នាង ដឹងថា ស្លឹកតើយ ព្រឺសម្បុរ
នាងរួញស្មា តែជាគេចមិនផុតពីដៃរបស់ខ្ញុំ ជាពិសេសពេលដែល
នាងអង្គុយលើភ្លៅខ្ញុំបែបនេះ ។

ខ្ញុំរំកិលដៃឡើងខ្ពស់ទាល់តែប៉ះអាវក្នុង...ទើសទែងមែនទែន
...តែបើលូកទៅដោះ...មានសង្ឃឹមថាមនុស្សស្រីដែលកំពុងតែ
ភ្លឺតភ្លើនព្រោះការថើបនេះនឹងដឹងខ្លួនមិនទាន ។

ទើបខ្ញុំលូកដៃចូលទៅក្នុង ទោះលំបាក តែភាពទន់ល្មើយនិង

ភាពយ៉ាប់នៃនោះវាសមាមាត្រ ។

"បង...បង ភីនចាច់ កុំ!"

"ឲ្យខ្ញុំកក់សិនទៅ ស្លឹកតើយ"

"កក់...កក់អី ?"

"កក់ខ្លួននាងហ្នឹងអី ហើយខ្ញុំនឹងនាំទៅសេអ៊ូលវិញ មិនអីចឹង
យើងនឹងនៅទីនេះបន្ត"

"ខ្សែ...ខ្សែលើ"

ខ្ញុំញញឹមជិតថ្ពាល់របស់នាង មុននឹងអូសបបូរមាត់ទៅរកថ្គាម
ព្រមទាំងអូសអណ្តាតលើស្បែកទន់ល្មើយរបស់នាងសំដៅស្លឹក
ត្រចៀក ហើយក៏សង្កត់តិចៗ មុននឹងអូសបបូរមាត់មករកកក្រអូប
ប្រហើរនោះវិញ ។

"កុំ កុំធ្វើបាប"

"មិនធ្វើបាបទេ...គ្រាន់តែកក់ទុក"

ខ្ញុំចាត់ការដើមទ្រូងទំហំសមនឹងបាតដៃធ្មមៗ ហើយក៏អត់មិន
បាននឹងច្របាច់ថ្នមៗ...ចុងទ្រូងរបស់នាងឡើងរឹង តទល់នឹងដៃរបស់ខ្ញុំ
ចុងម្រាមដៃស្ទាបអង្អែលនិងសង្កត់តិចៗ ចង់...ចង់បៀមខ្លាំង
ណាស់ តើវាផ្អែមប៉ុណ្ណាទៅហ្ន៎!

"បង ភីនចាច់!"

ស្លឹកតើយ ភ្ញាក់ព្រើតពេលដែលខ្ញុំទាញអាវរបស់នាងមកដាក់
លើតល់ទ្រូង ហើយឱនទៅថើបជញ្ជក់ ចុងទ្រូងដែលរឹងតទល់នឹង
អណ្តាតនោះត្រូវត្រវាសទៅត្រវាសមករហូតដល់ញ័រទទ្រើត ញ័រ
ដូចសំឡេងរបស់ ស្លឹកតើយ ដែលថ្ងូចថ្ងូរតិចៗ កាន់តែធ្វើឲ្យតម្រូវ
ការរបស់ខ្ញុំច្រាស់ច្រាល់...ឬមិនត្រឹមតែកក់...តែវាយលុកល្អជាង
ទេ ?

ខ្ញុំបឺតហើយបឺតទៀតដូចខ្លួនឯងជាទារក រហូតដល់ដកបបូរ

មាត់ចេញហើយមកចាត់ការម្ខាងទៀត ជាលើកដំបូងដែល...
មាត់ពីរនៅលើមុខ...ខ្ញុំលើកខ្លួនរបស់ ស្លឹកតើយ ចុះពីភ្លៅ...
លើសាឡុងដោយខ្ញុំតាមទៅទ្រោបពីលើ ចំណែកមាត់របស់ខ្ញុំ...
អារម្មណ៍របស់នាង ឯដៃក៏ស្ទាបអង្អែលភ្លៅដែលទន់ល្មៀយ...
ខែរបស់នាង ។

នាងប្រមក់នេះ...ដុតទឹកដោះគោជំនួសទឹកតាំងពីកើត...
ខ្ញុំមានចេតនាធ្វើឲ្យនាងភ្លេចខ្លួន ពេលដែលចាប់ទាញខោខ្លី...
នាងចេញពីជើងស្រឡូនយ៉ាងរហ័ស ។

ស្លឹកតើយ ចង់ស្រែកហាម ប៉ុន្តែពេលខ្ញុំរកិលមុខមកការ...
និងប្រើដៃម្ខាងទៀតស្ទាបអង្អែលកន្លែងដែលនៅទាបជាងចង្កេះ...
នាងក៏ភ្ញាក់ព្រើត ហើយខ្ញុំរង់ចាំយូរដើម្បីអីទៀត!

"កុំ កុំអី!"

ពេលនេះសំឡេងរបស់នាងដូចឮមកពីទីឆ្ងាយសែនឆ្ងាយ...
ត្រចៀករបស់ខ្ញុំហ៊ឹង មិនបានឮអ្វីទាំងអស់ ។

ស្លឹកតើយ ស្លៀកឈុតក្នុងដែលខ្ញុំទិញឲ្យ...ពីស្ទើង ។

"អាកំណាត់តូចនោះ រាំបិទបាំងខ្លួនប្រាណរបស់នាងស្ទើរ...
មិនជិត និងសរសៃតូចៗដែលទាក់ជាប់គ្នា ធ្វើឲ្យដឹងថាបើខ្ញុំកន្ត្រាក...
តិចៗវាក៏នឹងដាច់ ។

"បង គីនថាច់!"

ខ្ញុំមិនចូលចិត្តឲ្យនាងហៅឈ្មោះ យ៉ាងហោចណាស់ក៏ពេល
នេះ ខ្ញុំចង់ឮសំឡេងថ្ងូរចេញពីបបូរមាត់តូចនោះច្រើនជាង ។

"វ៉ាយ! អ៊ឹម"

ស្លឹកតើយ ស្រែក ពេលខ្ញុំសង្កត់ច្រមុះខ្លាំងៗ នេះជាលើកទី
មួយដែលខ្ញុំធ្វើអ្វីបែបនេះទៅលើខ្លួនប្រាណមនុស្សស្រី ។
តាមធម្មតាស្រីៗដែលខ្ញុំដេកជាមួយតែងតែបម្រើខ្ញុំ មិនធ្លាប់

មានស្រីម្នាក់ណាបានទទួលរបស់នេះពីមនុស្សប្រុសឈ្មោះ លី គីន
ថាច់ នោះទេ ។

ម្រាមដៃរបស់ខ្ញុំលូកទៅកន្ត្រៃដែលនៅក្រោមក្រណាត់ ហើយក៏
ទាញកាត់ម្ដាក់...

[End Intouch's Talk]

# ៧

# ស្វាមីរន្លែកមរន្ទោរ

ខ្ញុំចង់ស្រែកដាក់គេថា អំ...ឬមិនអីចឹងក៏រកទិញសំពត់មកខ្ទប់ក្បាលនៅពេលនេះ មិនស្មានទេថាអារឿងអាសអាភាសដែលមិត្តភក្តិស្រីៗនៅក្នុងក្រុមតាំងពីសម័យនៅរៀនយកមកនិយាយលេងមានកម្មវិធីជប់លៀងតូចតាចនោះ វាកើតឡើងចំពោះខ្លួនឯង ។

អឺ...ខ្ញុំព្រមទទួលស្គាល់ថាអាចគ្មានចេតនាធ្វើជាស្រីព្រហ្មចារីរហូតដល់ចាស់ស្លាប់ តែក៏មិនគិតថាត្រូវមនុស្សប្រុសដែលទើបនឹងជួបគ្នាមិនប៉ុន្មានថ្ងៃធ្វើបែបនោះដាក់ ។

អាបែបនោះដែលថាគឺ...

"មើលខ្ញុំហើយមុខក្រហម គិតរឿងណាមកមែនទេ ឬចង់ឲ្យខ្ញុំធ្វើទៀត?" អ្នកដែលកំពុងបើកឡាននិយាយចោល គេពាក់វ៉ែនតាពណ៌ខ្មៅ ធ្វើឲ្យមើលមិនឃើញភ្នែក តែខ្ញុំដឹងថាគេកំពុងតែធ្វើភ្នែកផ្អែកៗ ។

"អត់ទេ"

ខ្ញុំតបហើយក៏ងាកមុខចេញ មើលទៅក្រៅឡាន ។

"កុហក...ចូលចិត្តក៏ប្រាប់មោថាចូលចិត្ត ថ្ងៃក្រោយនឹងធ្វើឲ្យទៀត"

ខ្ញុំងាកទៅមើល អ៊ីនថាច់ ម្តងទៀត ទាំងខ្មាសទាំង...មិនដឹងទេ គេប្រាប់ថានឹងធ្វើឲ្យទៀតឬ?

"មិនបាច់ វានឹងមិនកើតឡើងទៀតទេ"

"ខ្ញុំចាត់ទុកថាវាជាការផ្ញាញ់ផ្ញាល ស្លឹកតើយ"

អ៊ីនថាច់ ប្រាប់ មុននឹងងាកមកមើលមុខខ្ញុំ ហើយខ្ញុំក៏រហ័សងាកមុខចេញភ្លាម ទ្រាំមិនបាន...ទាំងដែលតាំងពីពេញក្រមុំនិង

ស្អាតបែបនេះ កំលោះៗដែលចូលមករកតាំងពីសម័យរៀនមធ្យមសិក្សារហូតដល់វិទ្យាល័យ ខ្ញុំអាចផ្ចាត់ចេញពីជីវិតបានយ៉ាងងាយទាំងសង្ហា ប៉ិនទាម ព្រាននារី ឬទោះបែបណាក៏ខ្ញុំទប់ទល់បានទាំងអស់ តែចំពោះអាម្សៀនេះវាដូចជាចាញ់ប្រាបគេ គ្រាន់តែនិយាយមិនប៉ុន្មានម៉ាត់ខ្ញុំក៏ទ័លច្រកគ្រប់ពេល ឈឺចិត្តណាស់!

"ជិតដល់ផ្ទះហើយ"

គេប្រាប់ មុននឹងបើកឡានចុះពីផ្លូវហាយវេយ៍ យ៉ាងហោចណាស់ក៏គេរក្សាសច្ចៈ គត់ រួចហើយក៏ជូនមកផ្ទះវិញ ។

"ខ្ញុំចង់ទៅខុនដូ ខ្ញុំស្នាក់នៅខុនដូ"

"..."

គេមិនឆ្លើយ និងមិនព្រមប្តូរផ្លូវដែរ ស្អីគេហ្នឹង?

"បង អ៊ីនថាច់ ខ្ញុំចង់ទៅខុនដូ"

"ខ្ញុំជូនទៅផ្ទះ"

"តែថា..."

"ឬចង់ទៅផ្ទះខ្ញុំ?"

ខ្ញុំធ្វើភ្នែកឡើមឡាម និងរហ័សឆ្លើយ ។

"ផ្ទះខ្ញុំ"

ហ៊ឺយ!!! ខ្ញុំក្លាយជាអ្នកនាង ស្លឹកតើយ ដ៏ស្តាប់បង្គាប់តាំងពី
ពេលណានេះ?

"គួរឲ្យស្រឡាញ់ណាស់"

ខ្ញុំលួចមើលគេ ឃើញថាបបូរមាត់ពណ៌ស្រស់នោះមានស្នា
ញញឹម...មាត់គេដែល...ដែល...បេះដូងរបស់ខ្ញុំលោតញាប់ស៊ី
តែខ្ទាតចេញពីទ្រូង ។

កន្លះម៉ោងបន្ទាប់មក យើងក៏មកដល់ផ្ទះរបស់ខ្ញុំ តែហេតុអ៊ី
ហេតុអីឡានច្រើនម្លេះ?

"ចុះម៉េ"

"ឡានច្រើនម្ល៉េះ..."

ខ្ញុំនិយាយខ្សឹបៗដោយការឆ្ងល់ ហើយចុះពីឡាន... នេះមានឡានច្រើនគ្រឿងចតត្រៀបត្រាពេញមុខផ្ទះ ខ្ញុំ... ដានពត៌មានអីឬអត់ ?

"នោះ...មានការប្រជុំអីឬអត់ ?" ខ្ញុំសួរដោយការសង្ស័យ... ដែលកំពុងពន្លត់ម៉ាស៊ីនឡានក៏ងាកមកញញឹមដាក់ខ្ញុំ ។

"គ្មានប្រជុំអីទេ គ្រាន់តែមកចុះសំបុត្រអាពាហ៍ពិពាហ៍"

"សំបុត្រ...សំបុត្រអី ?"

គេនិយាយថាម៉េច ?

ជំនួសការឆ្លើយ អ៊ីនថាច់ បែរជាដឹកដៃខ្ញុំចូលទៅក្នុងផ្ទះ ខ្ញុំដើរតាមគេដោយមិនបានតាំងជំហរ ។

ក្នុងផ្ទះរបស់ខ្ញុំត្រង់បន្ទប់ទទួលភ្ញៀវពេលនេះ សុទ្ធតែមនុស្ស ទាំងម៉ាក់របស់គេគឺអ្នកស្រី ធីហ្វានី និងចាស់ទុំដែលខ្ញុំមិនស្គាល់ តែប្រហែលមុខប្រហែលមាត់ ព្រោះថាធ្លាប់ឃើញពួកគេខ្លះដែរ... នោះលោករដ្ឋមន្ត្រីដែលចេញតាមទូរទស្សន៍ញឹកញាប់ទេតើ!

"អី"

"មកដល់ល្មម ល្អិតល្អៃ អ៊ីនថាច់"

ម៉ាក់របស់ អ៊ីនថាច់ ដែលញញឹមញញែម មិនមែនទេ...គ្រប់គ្នានៅក្នុងនេះសុទ្ធតែញញឹមញញែមស្រស់ស្រាយ លើកលែងតែខ្ញុំម្នាក់ នេះមានរឿងអី ?

"មកដល់ហើយ ទាន់ពេលល្មម"

ម៉ាក់របស់ខ្ញុំប្រាប់ ថែមទាំងគុបតែងខ្លួនដោយឈុតហាន់ប៊ុក គុបតែងមុខជាងកូនស្រីដូចជាខ្ញុំទៅទៀត គឺពេលនេះខ្ញុំពាក់តែអាវយឺតនិងស្លៀកខោខ្លី ។



"នេះមានរឿងអីហ្នឹង ?"

"អ៎...អ៊ីនថាច់ មិនបានប្រាប់ឯងទេឬថាយើងនឹងឲ្យពួកឯងចុះសំបុត្រអាពាហ៍ពិពាហ៍សិន ហើយចាំរៀបចំពិធីមង្គលការនៅពេលក្រោយ ព្រោះថាថ្ងៃនេះជាពេលល្អ គឺម៉ាក់ជាអ្នកគេទៅប្រាប់អ៊ីនថាច់"

ខ្ញុំងាកទៅមើលអ្នកនៅក្បែរខ្លួន គេមិនបានប្រាប់ មិនធ្លាប់ប្រាប់ នេះវាមានន័យថាម៉េច អ៊ីនថាច់ ដឹងហើយថាថ្ងៃនេះត្រូវនាំខ្ញុំមកវិញ តែគេក៏...បោកខ្ញុំ ។

"ម៉េចក៏ធ្វើមុខអីចឹង...អ៎ សប្បាយចិត្ត!"

មនុស្សកំហូចនៅតែញញឹមញញែម គេដោះវ៉ែនតាការពារចេញ ទើបខ្ញុំឃើញទឹកមុខរបស់គេបានច្បាស់ វាបង្ហាញឲ្យឃើញភាពជាអ្នកឈ្នះពេញបន្ទុក ។

"គ្មានមារយាទ គោរពចាស់ទុំទៅ..."

ម៉ាក់ខ្ញុំជាអ្នកដាស់តឿន ខ្ញុំក៏ប៉ប្រិចភ្នែកញាប់ស្ដេក ងាកទៅមើលលោករដ្ឋមន្ត្រីដែលអង្គុយ និងមើលមកខ្ញុំម៉ក់ៗ ដូចស្មានមិនដល់ថាមនុស្សស្រីដែលខ្លួនឯងមកធ្វើជាសាក្សីក្នុងពិធីមង្គលនេះ អនាគតកូនប្រសាមហាសេដ្ឋីពាក់អាវយឺតនិងស្លៀកខោខ្លីដូចខ្ញុំ ។

"សួស្ដី"

ខ្ញុំឱនគំនាប់ទាំងមិងមាំង មុននឹងងាកទៅមើលម៉ាក់ដោយខ្សែភ្នែកដែលគាត់ធ្វើពុតជាមើលមិនឃើញ ។

"នេះមន្ត្រីអត្រានុកូលដ្ឋាន" ម៉ាក់ខ្ញុំណែនាំ ខ្ញុំក៏ឱនគំនាប់ទៀត ហើយពេលឃើញរបស់ដែលដាក់លើតុ គ្របពណ៌ក្រហមកាំម្លីពីរនោះ ច្បាស់ជាសំបុត្រអាពាហ៍ពិពាហ៍របស់ខ្ញុំមិនខាន អឺយ សំបុត្រអាពាហ៍ពិពាហ៍របស់ពួកយើង មិនមែនទេ ខ្ញុំមិន...

"ម៉ោះ កុំឲ្យខាតពេល តិចអស់ពេលា"

អ្នកស្រី ធីហ្វានី ញញឹមញញែមហើយបបួល អ៊ីនថាច់ ... ដៃខ្ញុំទៅអង្គុយនៅសាឡុង ខ្ញុំក្រាញ ប៉ុន្តែកម្លាំងប្រចាំប្រុស... ធ្វើឲ្យខ្ញុំជ្រួញចិញ្ចើម ពេលមើលភ្នែកគេហើយ ហាក់ដូចមាន... ដាស់តឿននៅក្នុងនោះ ។

"ស៊ុំញៀទៅ"

ម៉ាក់របស់ខ្ញុំប្រាប់ ខ្ញុំមិនដឹងខ្លួនទេថាវាមកនៅក្នុងដៃរបស់... តាំងពីពេលណា និងមិនដូចគ្នាថាខ្ញុំសរសេរឈ្មោះខ្លួនឯងនៅ... ក្រដាសនោះតាំងពីអង្កាល់ តែថា...

"រួចរាល់ហើយ ពេលនេះកូនក្រមុំឱនគំនាប់កូនកំលោះទៅ"

សំឡេងលោករដ្ឋមន្ត្រីប្រាប់ ធ្វើឲ្យខ្ញុំប៉ប្រិចភ្នែក ងាកទៅមើល ម៉ាក់ដែលញញឹមញញែមឡើងទឹកភ្នែករលីងរលោង ហើយក៏ងាក... មុខអ្នកស្រី ធីហ្វានី ដែលកាន់កន្សែងជូតទឹកភ្នែក មុននឹងងាកមក មើលមុខសង្ហារបស់ អ៊ីនថាច់...ស្វាមីរបស់ខ្ញុំ ។

"ឱនគំនាប់ប្ដីទៅកូន"

ខ្ញុំប្រឹងលេបទឹកមាត់ដែលស្ទិតចូលបំពង់ក ឱនក្បាលគំនាប់ គេ តែថា...

"..."

អ៊ីនថាច់ លូកដៃមកស្រវាចាប់ដៃរបស់ខ្ញុំ ហើយទាញឲ្យខ្ញុំ ចូលទៅជិតគេ មុននឹងគេឱនមកថើបថ្ពាល់ខ្ញុំមួយខ្សឹត ។

ខ្ញុំបានឮសំឡេងម៉ាក់របស់ខ្ញុំនិងម៉ាក់របស់គេដកដង្ហើមយ៉ាង វែង ប្រាប់ឲ្យដឹងថាមានសេចក្ដីសុខដំណាលគ្នា ។

បន្ទាប់ពីនោះ ខ្ញុំក៏បានតែអង្គុយមើលហេតុការណ៍ក្នុងបន្ទប់ ទទួលភ្ញៀវទាំងមិនយំ មានសំបុត្រអាពាហ៍ពិពាហ៍របស់ខ្ញុំនៅ ចំពោះមុខ ។ លោករដ្ឋមន្ត្រីនិងមន្ត្រីអញ្ជើញកុលដ្ឋានត្រឡប់ទៅវិញ ហើយ ដោយម៉ាក់ទាំងពីរជាអ្នកជូនដំណើរ សំឡេងអរគុណ



សំឡេងនិយាយគ្នាក៏បន្លឺឡើង ។

"ស្លឹកតើយ"

ខ្ញុំងាកទៅតាមសំឡេងហៅឈ្មោះនោះ ។

ត្រង់នោះ...ត្រង់ទ្វារបន្ទប់ទទួលភ្ញៀវ អ៊ីនថាច់ ឈរនៅត្រង់ នោះ កែវភ្នែកពណ៌ស្វាតរបស់គេមើលមកខ្ញុំ ចំណែកមាត់ដែលតែ តែនិយាយស្ដីធ្វើឲ្យបេះដូងលោតញាប់ និងខឹងដល់ថ្នាក់សឹងតែ សម្រួបអារម្មណ៍មិនទាន់ កំពុងញញឹមដាក់ខ្ញុំ ។

"..."

"សូមស្វាគមន៍ការចូលមកក្នុងជីវិតរបស់បង ស្លឹកតើយ ថ្ងៃ នេះអូនជាប្រពន្ធរបស់បងតាមនីតិន័យហើយ ចំណែកយប់នេះអូន នឹងក្លាយជាប្រពន្ធតាមព្រឹត្តិន័យ"

( ស្លឹកតើយ កុំប្រាប់ណាំ ថាដែលឯងបាត់មុខពីរបីថ្ងៃនេះ ត្រឡប់មកវិញក៏មានប្ដី...អ៊ី ស្វាមីហើយ )

សំឡេងគឹងសរសៃករបស់មិត្តភក្ដិ ធ្វើឲ្យខ្ញុំដកដង្ហើមធំដោយ ការធុញថប់ ។ ខ្ញុំបានទទួលទូរសព្ទកាលពីយប់ ពេលដែលត្រឡប់ មកដល់ផ្ទះ ហើយពេលនេះខ្ញុំកំពុងតែអង្គុយក្នុងបន្ទប់ដេករបស់ ខ្លួនឯង ទោះមកនៅខុនដូតាំងពីនៅរៀន តែរាល់ថ្ងៃឈប់សម្រាក ខ្ញុំតែងតែត្រឡប់ទៅផ្ទះ ។

"អឺ"

( ងាប់ហើយ សម្លាញ់យើង ហើយឯងធ្វើយ៉ាងម៉េចហ្នឹង ឯង ត្រូវដូរសព្ទនាមនាំមុខទៅជាអ្នកស្រីឬអត់ ? ) សំណួររបស់ គ្រាប់ ត្នោត បន្លឺឡើង ។

( អត់ទេ សម័យនេះគេឲ្យជ្រើសរើសបាន ) ក្ដាមខ្មៅ និយាយ កាត់ មែន...ខ្ញុំកំពុងតែពិភាក្សាជាមួយពួកនាង ។

"ខ្ញុំចង់ឲ្យពួកឯងទាំងពីរជួយគិតបែបណាទៅវិញទេ ដែល
ឲ្យមកប្រកែកគ្នារឿងសិទ្ធិសព្វនាមនាំមុខ"

(អឺម...ហើយឯងចង់ឲ្យជួយរឿងអី ?)

(ហ្នឹងហើយ)

ខ្ញុំធ្វើភ្នែកឡេមឡាម ឈប់រាប់អានល្អទេនេះ មិត្តពិតត្រូវ

"គឺរឿងយប់នេះខ្ញុំអាចគេចពីក្រញាំដៃបង អីនជាប់ ម៉េច
ម៉េច"

(អឺហ៎...ទៅសមហាន់នឹមុនមិនប៉ុន្មានថ្ងៃ ហៅបង អីនទេ
ហើយឬ ?)

សំឡេងបង្គាប់របស់ គ្រាប់ត្នោត បន្លឺឡើង ដំណាលគ្នានឹង
សំឡេងស្រែកចូលចិត្តរបស់មិត្តម្នាក់ទៀត ។

(ស្លូតបូត្រង់...ឯងខ្លាចយប់នេះធ្វើអី ក្នុងពេលដែលឯងនឹង
គេនៅជាមួយគ្នាច្រើនយប់ទៅហើយ និយាយតាមត្រង់ចុះ ឯង
ក្រហមរបស់ឯងត្រូវគេបោះបែកអស់ទៅហើយ ខ្ញុំថាអីចឹង)

"ក្តាមខ្វេរ!"

ខ្ញុំស្រែកហៅឈ្មោះមិត្តដោយកំហឹង ខ្មាសឡើងក្រហមមុខ
ម៉ាង សប្បាយចិត្តដែលត្រូវនិយាយខ្ញុំសព្វបែបធម្មតា មិនបានរ
រយៈពីកមុខរបស់ខ្ញុំនៅពេលនេះបានជាមិនទាន់ពីរឿងមុខជាប់ពីរឿងការ

"ខ្ញុំមិនទាន់ត្រូវគេបោះពងក្រហមឡើទាំងអស់ សូមយល់ជាថ្មី
ផង"

ខ្ញុំមិនបានកុហក...យ៉ាងច្រើនគេគ្រាន់តែ...អី លូកលាន់តិច
តួចប៉ុណ្ណោះ ។

(អ៎...អីចឹងឬ អ្នកណាទៅនឹង គិតឃើញថាគ្រឡប់មកវិញ
ប្រញាប់ប្រញាល់ចុះសំបុត្រអាពាហ៍ពិពាហ៍ ស្ពានបាឯងត្រូវស៊ីបាត់

ទៅហើយ)

"នៅទេ!"

(ហ៊ើយ!!! ស្លឹកតើយ ខ្ញុំប្រាប់តាមត្រង់ទៅចុះ អនាគតស្វាមី
មិនមែនទេ ស្វាមីរបស់ឯងម្នាក់នេះគឺមិនបានអាក្រក់អីទេ គេជា
អ្នកជំនួញជំនាន់ថ្មីពោរពេញដោយសមត្ថភាព មកជំនួសម៉ាក់របស់
គេ ឯងដឹងទេថាតារាស្រីៗតាមគេឲ្យប្រវាត់)

គ្រាប់ត្នោត ជាអ្នកប្រាប់ដោយសំឡេងប្រាកដប្រជា ។

(ហើយឯងក៏គ្មានលទ្ធភាពរកប្រាក់ដោះបំណុលម្តាយរបស់
គេដែរ យកខ្លួនទៅប្រើការជំនួសទៅ ប្រាប់ទៅចុះ បើកូនប្រុសមិត្ត
ភក្តិជាម៉ាក់ខ្ញុំមានផ្លូវហ្វាល់ដូច អីនជាប់ វិញ ខ្ញុំនឹងបង្គាប់ឲ្យទៅខ្ចី
ប្រាក់ ហើយយកខ្លួនទៅដោះជំនួសបំណុល ព្រហ្មចារីនេះប្រគល់
ឲ្យគេទៅហើយ)

(មែនហ្នឹង គេល្អសឹងអី ស្លឹកតើយ) ក្តាមខ្វេរ គាំទ្រ ។

"ខ្ញុំចង់រៀបការជាមួយអ្នកដែលខ្ញុំស្រឡាញ់ហ្នឹងណា៎"

(អុំយ...តិចទៀតឯងគង់តែស្រឡាញ់គេទេ ពីរបីថ្ងៃមកនេះ
មានអីកើតឡើងខ្លះ គេនិងឯងចុះសម្រុងគ្នាទេ)

ស្ថានការណ៍ពីរបីថ្ងៃនៅផ្ទះលម្ហែមាត់សមុទ្រ រត់ចូលមកក្នុង
ខួរក្បាលរបស់ខ្ញុំ ទើបខ្ញុំរហ័សរលាស់វាចេញភ្លាម ។

"ខ្ញុំឈប់និយាយហើយ សរុបទៅមិត្តទាំងពីរជួយអីមិនបាន"

ខ្ញុំប្រុងដាក់ទូរសព្ទចុះ តែសំឡេងរបស់ពួកនាងក៏ពុជដំណាល
គ្នាភ្លាម ។

(ឈប់សិន!)

(ឈប់សិនៗ)

"មានការអី ?"

(ហើយឯងរៀបចំមង្គលការផ្លេកបន្ទោរថ្ងៃណា ខ្ញុំទាំងពីរនឹង

បានទៅកាត់ឈុត...)

ខ្ញុំដាក់ទូរសព្ទចុះភ្លាម នឹងថាពីរនាក់នេះពិងពាក់មិន... នេះប្រហែលជានាំគ្នាត្រឹតស្រែករកឈុតស្អាតៗ... មង្គលការរបស់ខ្ញុំទៅហើយ គិតយ៉ាងម៉េចទៅ...ខ្ញុំចាំប្រាប់... គិតមិនចេញ ។

"សូមស្វាគមន៍ការចូលមកក្នុងជីវិតរបស់បង ស្ទីកតើយ... នេះអូនជាប្រពន្ធបងតាមនីតិន័យហើយ ចំណែកយប់នេះអូន... ក្លាយជាប្រពន្ធរបស់បងតាមក្រឹត្តិន័យ"

សម្តីមុនពេលដែលខ្ញុំរត់ឡើងបន្ទប់ វានៅតែឮកងរំពង... មិនបាន ស្ទីកតើយ ងាប់មិនបាន!

គុកៗ!

សំឡេងគោះទ្វារបន្ទប់ឡើង ធ្វើឲ្យខ្ញុំងាកទៅមើលភ្លាមដោយ... ការភ្ញាក់ផ្អើល នេះ...នេះមិនទាន់ងងឹតផង ។

"ស្ទីកតើយ នេះម៉ាក់ បើកទ្វារឲ្យបន្តិច"

ម៉ាក់...ខ្ញុំដកដង្ហើមធូរទ្រូងនិងស្តាយ អេ៎...ស្តាយអី?

"ចាំ" ខ្ញុំដើរទៅបើកទ្វារឲ្យម៉ាក់ ដែលញញឹមញញែមដើរចូល មកក្នុងបន្ទប់ដេក ។

"ម៉េចក៏គេចពីអ្នកមីង ធីហ្វានី និងបង អ៊ីនថាច់ បែបនេះ មិនគួរឲ្យស្រឡាញ់ទេ" ម៉ាក់ស្តីឲ្យ ហើយក៏ធ្វើមុខដូចទើបតែនឹកឃើញ "អូ៎! មិនមែនទេ ត្រូវហៅថាម៉ាក់ ធីហ្វានី និងលោកប្តី ហេះៗ"

"ម៉ាក់...នេះម៉ាក់ជាម៉ាក់របស់ខ្ញុំឬអត់?"

ខ្ញុំសួរដោយអត់មិនបាន ម៉េចក៏ម៉ាក់មើលទៅសប្បាយចិត្ត បែបនេះ ។

"ល្ងង់អើយ ស្ទីកតើយ...អ៊ីនថាច់ គេឥតខ្ចោះយ៉ាងនេះ ហើយក៏មិនត្រូវបានប្តឹងដែរ ធ្លាឈុក ក៏មិនចាំបាច់មានបញ្ហា ថែមទាំងឯង



ក៏បានប្តីល្អ ម៉ាក់ក្មេកល្អ ម៉ាក់ជឿថាមិត្តសម្លាញ់របស់ម៉ាក់ច្បាស់ជាមើលថែឯងបានល្អ"

តើបើជាមិត្តសម្លាញ់ ហេតុអីបានជាជ្រើសរើសឲ្យដោះបំណុល ដោយការរៀបការបែបនេះ ឬថា...វាមានអ្វីលាក់បង្កប់?

"ម៉ាក់...ម៉ាក់ជំពាក់បំណុលមីង ធីហ្វានី មែនឬអត់ មិនមែនជាផែនការចោកឲ្យរៀបការបែបចាប់ផ្តើម បែបបោកដាក់ផែនការឲ្យកូនចាប់គូគ្នាស្អីបែបនេះទេដឹង បើមីង ធីហ្វានី ជាមិត្តភក្តិរបស់ម៉ាក់មែន ហេតុអីខ្ញុំមិនធ្លាប់ជួបមុខគាត់"

ម៉ាក់ជ្រួញចិញ្ចើម ហើយក៏ផ្ទាត់ថ្ពាសរបស់ខ្ញុំលាន់ផាច់ ។

"អូយ! ឈឺណាស់ម៉ាក់"

ទឹកភ្នែកខ្ញុំហូរ និងលើកដៃអង្អែលថ្ពាសដូចកូនក្មេង ។

"ផ្តេសផ្តាស ម៉ាក់ទៅពីបាកដាក់ផែនការធ្វើស្អី ម៉ាក់ជំពាក់ប្រាក់ ធីហ្វានី មែន គឺដូចដែលថា ម៉ាក់លេងហ៊ុន បងស្រីឯងក៏មានបញ្ហារឿងជំនួញនៅបរទេស ម៉ាក់ខ្ចីគេ ហើយពេលដែលដោះវាគ្មានស្អីដោះមែន ហើយយើងទាំងពីរស្គាល់គ្នាយូរហើយ តែថាបេះពៃឆ្ងាយគ្នា ជួបគ្នាម្តងទៀតបន្ទាប់ពីប៉ារបស់ឯងចែកឋានថ្មីៗ ដោយចៃដន្យ ហើយយើងក៏សប្បាយចិត្ត ទាក់ទងគ្នាដូចមុនវិញ តែឯងមកផ្ទះញឹកញាប់ពីអង្គាល់ ទើបមិនសូវបានជួបមុខមីង សួរតាមត្រង់ មើលល្ខោនច្រើនពេកឬអត់"

អ្នកណាទៅដឹង គ្រាន់តែរៀបការដោះបំណុលក៏យ៉ាប់ណាស់ទៅហើយ ប្រាប់អ្នកដទៃ តើមានអ្នកណាជឿដែរទេ?

"ឈប់ទុក្ខសោកឈប់ល្ងើល្ងើទៅ ទៅងូតទឹកផ្លាស់ខោអាវ និងអាលេចុះទៅខាងក្រោមនិយាយរឿងមង្គលការ"

ខ្ញុំចង់ផ្តួលខ្លួនដេកលើកម្រាល ហើយទាត់ជើង តែហេតុអីធ្វើបានត្រឹមតែធ្វើមុខជូរ ហើយដើរចូលបន្ទប់ទឹក ។

ខ្ញុំមើល ស្លឹកតើយ ដែលដើរចុះមកខាងក្រោម... ពណ៌ផ្ទៃមេឃ ហើយក៏ញញឹមដាក់ តែស្រីដើងល្អមើលមិន... ឃើញ នាងដើរទៅអង្គុយក្បែរម៉ាក់របស់នាង ដែលពេលនេះ... ជាម៉ាក់ក្មេករបស់ខ្ញុំហើយ ។

ងូតទឹកផ្លាស់ខោអាវហើយ មុខមាត់នេះស្រស់ស្រាយ...

"ពេលនេះយើងនិយាយគ្នារឿងមង្គលការ យើងរៀបចំ... សណ្ឋាគារល្អទេ ណើរី?"

"អឺម នាងរើសសណ្ឋាគារទៅ"

"ចាំខ្ញុំជាអ្នករកវេទិកា ហើយឲ្យពួកគេរៀបចំផែនការឲ្យ"

"ឈប់សិនម៉ាក់ គឺថាខ្ញុំ..."

ស្លឹកតើយ ចង់តវ៉ា នៅវិញស្ដីទៀត នាងមិនដឹងឬថាពេល... ដែលចុះឈ្មោះក្នុងសំបុត្រអាពាហ៍ពិពាហ៍ ខ្ញុំផ្អើលសឹងតែដាច់... ខ្យល់ ខ្លាចថានាងមិនព្រម សំណាងដែលនាងមិនបានតវ៉ាអី ។

"ស្លឹកតើយ កុំពន្យារពេល តិចពោះធំពាក់ឈុតមិនស្អាត ទៅ"

"!!!"

វាជារូបភាពដែលកំប្លែង មនុស្សស្រីបីនាក់ដែលអង្គុយនៅក្នុង បន្ទប់នេះ ងាកមកមើលមុខខ្ញុំដំណាលគ្នាដោយទឹកមុខមិនដូចគ្នា ប៉ុន្មាន ម៉ាក់ទាំងពីរធ្វើមុខភ្ញាក់ផ្អើល មុននឹងចំហមាត់ធ្លុង តែក៏មាន ទឹកមុខពេញចិត្ត ប្រហែលព្រោះពាក្យថា **ផ្ទៃពោះ** វាមានន័យថាពៅ បំផុតងាកមកមើលមុខខ្ញុំដោយការភ្ញាក់ផ្អើល ហើយក៏ប្ដូរទៅជាខឹង សម្បា ។



"បង អ៊ីនថាច់!" នាងហៅឈ្មោះខ្ញុំខ្លាំងៗ "ខ្ញុំមានផ្ទៃពោះបាន យ៉ាងម៉េចទៅ!"

"បានតើ អូនមិនដឹងទេឬថាបងមិនការពារ ហើយយើងទាំង ពីរក៏រឹងមាំ តែសំណាងដែលចុះសំបុត្រអាពាហ៍ពិពាហ៍ហើយ យ៉ាង ណាក៏កូនរបស់យើងមិនមែនជាកូនឥតខាន់ស្លា" ខ្ញុំញញឹម ។

"យ៉ាងណាខាងអ្នកម៉ាក់ផង រឿងមង្គលការ រឿងអញ្ជើញភ្ញៀវ ប្រហែលជារវល់ហើយ យ៉ាងណាសុំឲ្យឆាប់បំផុត កូនក្រមុំនឹងបាន ពាក់ឈុតស្អាតៗ"

"អត់ទេៗ ម៉ាក់មិនហត់នឿយទេ ណើ្ហយ អូខេ ធីហ្វានី ពោះ យើង ទៅដោយខ្លួនឯងទៅ មិនចាំបាច់ឲ្យគេមកទេ យើងទៅរក ក្រុមហ៊ុនវេទិកាឥឡូវនេះល្អជាង"

អ្នកស្រី ណើរី ម៉ាក់ក្មេកដ៏គួរឲ្យស្រឡាញ់ដឹកដៃម៉ាក់របស់ខ្ញុំ ដើរចេញទៅយ៉ាងលឿន ចំណែក ស្លឹកតើយ នៅតែស្ងួត នាងមើល មុខខ្ញុំដោយការភ្ញាក់ផ្អើលនិងខឹងសម្បា ។

ពេលផុតពីខ្សែភ្នែករបស់ចាស់ទុំ ស្រីតូចរបស់ខ្ញុំក៏សឹងតែស្ទុះ មកច្របាច់ករបស់ខ្ញុំ ខ្សែភ្នែករបស់នាងប្រាប់ថាអីចឹង ។

"បង អ៊ីនថាច់ និយាយរឿងអី យើងសុទ្ធតែដឹងច្បាស់ហើយ ថាខ្ញុំគ្មានថ្ងៃមានផ្ទៃពោះបាន ក្នុងពេលដែលយើងមិនបានធ្វើអី លើសលស់"

"ស្ដីដែលថាមិនលើសលស់ ខ្លួនរបស់អូន បងលិឍសព្វសាច់ គ្រប់ច្រកល្ហកអស់ទៅហើយ"

ហើយក៏បានផល មុខនាងក្រហម ចំហមាត់មួបៗដូចត្រីដំរី ពេលដែលត្រូវខ្ញុំវាយលុកចំចំណុចខ្សោយ តែថានេះគ្រាន់តែជា កណ្ដាប់ដៃស្រាលៗប៉ុណ្ណោះ ។

ខ្ញុំអើបឈរ ហើយក៏លោមុខទៅរកនាង...ក្លិនខ្លួនរបស់នាង ក្រអូបប្រហើរមិនធ្លាប់សោយ ។

"អាចពិតដូចដែលអូនប្រាប់ថាគ្មានផ្ទៃពោះ ព្រោះ
ជាអណ្ដាត តែបើអូននៅតែរឹងទទឹង របស់ដែលចូល
លើកក្រោយ វានឹងធ្វើឲ្យអូនមានផ្ទៃពោះមិនខាន បងធានា"

ស្លឹកតើយ មានទឹកមុខម្ដងស្លេកស្លាំងម្ដងក្រហម
ជាភ្នែកនាងដូចជាញ័រ...ញ័រមិនមែនខ្លាច ប៉ុន្តែខ្ញុំកំពុង
ហើយ ។

"ហើយដែលបងឲ្យចុះសំបុត្រអាពាហ៍ពិពាហ៍ភ្លាមៗ ព្រោះ
យើងទៅជាមួយគ្នាតិចបីថ្ងៃ បងមិនចង់ឲ្យម៉ាក់អូនមានអារម្មណ៍មិន
ល្អ និងមិនឲ្យអូនខូចឈ្មោះ យល់ទេ ?"

"..."

នាងនៅស្ងៀម ហើយក៏ងាកមុខចេញ តែខ្ញុំដឹងថានោះមានន័យ
នាងអៀន មែន ស្លឹកតើយ អៀនខ្ញុំ!

"តែ...យើងមិនទាន់បានរៀបចំពិធី អ្នកណាៗក៏គេមិនដឹងដែរ
ថាយើងជា...ជាប្ដីនឹងគ្នា"

នាងនិយាយដោយសំឡេងរដាក់រដុប នោះមកពីខ្ញុំលូកដៃទៅ
ស្រសក់ដៃរបស់នាងលេង ហើយលើកមកហិត ។

"ខ្ញុំ..."

"ហៅខ្លួនឯងថាអូន" ខ្ញុំបញ្ជា ។

"អូនក៏ខូចឈ្មោះដែរ បើ...បើយើង...រស់នៅ...រស់នៅជាមួយ
គ្នា"

"..."

ខ្ញុំលែងសក់របស់នាង ហើយងើបឈរពេញកម្ពស់ អ្នកម៉ាក់
ទាំងពីរចេញពីផ្ទះទៅហើយ ព្រោះថាខ្ញុំបានឮសំឡេងឡាន ។

"ខ្លាចខូចឈ្មោះ ?"

"ខ្លាច យ៉ាងណាក៏អូនជាមនុស្សស្រី"



អឹម...ខ្ញុំមើលចំហៀងមុខរបស់អ្នកដែលមិនហ៊ានប្រសព្វភ្នែក
ជាមួយ ដឹងថា ស្លឹកតើយ គ្រាន់តែរកលេសយកខ្លួនពីក្រញាំដៃ
របស់ខ្ញុំប៉ុណ្ណោះ ទាំងដែលដេញដើងទាន់ តែណ្ដើយចុះ...ខ្ញុំមើល
ថ្ពាល់ប៉ោងពណ៌ផ្កាឈូករបស់ ស្លឹកតើយ...យ៉ាងណាក៏ស្រីម្នាក់
នេះជារបស់ខ្ញុំទៅហើយ ។

"ក៏បាន"

ខ្ញុំប្រាប់ងាយៗ លូកដៃចូលហោប៉ៅខោ និងមើលអ្នកដែល
ងើយមុខមើលខ្ញុំដោយភ្នែកមូលក្លំរបស់នាង ។

"មានន័យថាម៉េច ?"

"អូនមិនទាន់ទៅនៅជាមួយបងទាល់តែយើងរៀបការតាម
ប្រពៃណីក៏បាន" ខ្ញុំងក់ក្បាលម្ដងទៀត ។

"មែនក៏អី បងនិយាយមែនក៏អី ?"

"តែមានលក្ខខណ្ឌ អូនត្រូវទៅធ្វើការនៅក្រុមហ៊ុនរបស់បង
យល់ព្រមទេ ?"

ខ្ញុំឃើញភ្នែករបស់ ស្លឹកតើយ ធ្វើឡេមឡាមយ៉ាងរហ័ស ស្រី
តូចរបស់ខ្ញុំកំពុងតែបូកដកគុណចែកការមានប្រៀបនិងចាញ់ប្រៀប
មិនខាន ។

"យល់ព្រម"

"ល្អ...អីចឹងឲ្យថ្លៃតបស្នងម៉ោ"

"ថ្លៃតបស្នង ? បងប្រហែលមិនចង់មានន័យថាធ្វើបែបនោះ
ទៀតទេដឹង ?"

ស្លឹកតើយ ភ្ញាក់ផ្អើល ថ្ពាល់កាន់តែក្រហម និងមើលខ្ញុំដោយ
ភាពញាប់ញ័រ ។

អីយ៉ា...ប្រពន្ធសម្លាញ់ ចង់ធ្វើដូចដែលអូនគិតសឹងតែដាច់
ខ្យល់ តែទុកសិនទៅចុះ ។

"មិនមែនទេ តែអូនត្រូវថើបបងមុន"

"ថើបនៅក្នុងផ្ទះនេះនេះ នេះជាបន្ទប់ទទួលភ្ញៀវ"

ខ្ញុំញាក់ស្មា ហើយដើរទៅអង្គុយលើសាឡុងដែល ហើយ... ទាំងពីរដាក់លើភ្នាក់សាឡុង ហើយមើលអ្នកដែលអង្គុយទល់... មុខដោយការរង់ចាំ ។

"ឬអូនចង់ទៅបន្ទប់ដេក ?"

ស្រីស្អាតជ្រួញចិញ្ចើមរិះគិតយ៉ាងខ្លាំង នាងចង់បានការ... ព្រៀងរឿងប្តូរទីតាំងជាមួយខ្ញុំសឹងតែដាច់ខ្យល់ ខ្ញុំដឹង នោះហើយ ដែលធ្វើឲ្យខ្ញុំកាន់សន្លឹកបៀធំជាងនាង ។

ស្លឹកតើយ ធ្វើមុខរាំងរែក ហើយក៏ដើរមករកខ្ញុំ ។

"អង្គុយចុះ" ខ្ញុំប្រាប់ ហើយនាងក៏ស្តាប់បង្គាប់ ព្រមអង្គុយចុះ និងខិតយឺតៗមករកខ្ញុំ ដាក់ដៃទាំងពីរលើផ្គួងទាំងពីររបស់ខ្ញុំ ហើយក៏លោមុខមករក ។

សំឡេងបេះដូងរបស់នាងលោតញាប់ ខ្យល់ដង្ហើមរបស់នាង ក៏ក្តៅ វាស្រោចនៅលើមុខខ្ញុំពេលដែលនាងលោមុខមកជិត ។

ក្មេងល្អ...ខ្ញុំសរសើរនៅក្នុងចិត្ត ពេលមុខនាងលោមកជិតជា រឿយៗ ។

"បិទភ្នែកទៅ"

"មិនបិទ" ខ្ញុំនឹងមើលគ្រប់វិនាទី ។

"..." ស្លឹកតើយ ខ្ទឹបបបូរមាត់ មុននឹងលោមាត់មកប៉ះបបូរ មាត់របស់ខ្ញុំ ហើយក៏ដកថយ ។

"មិនមែនអីចឹងទេ...សង្កត់ឲ្យខ្លាំងជាងនេះទៅ"

ស្លឹកតើយ ធ្វើតាម ដៃនាងដែលដាក់លើផ្គួងរបស់ខ្ញុំក៏ ច្របាច់ ប្រហែលជាញាប់ញ័រមិនតិចនោះទេ ខ្ញុំក៏ញាប់ញ័រដែរ ទាំង ញាប់ទាំងញ័រឲ្យទទ្រើតសព្វសាច់ ។



បបូរមាត់ទន់ល្មើយរបស់ ស្លឹកតើយ ទម្លាក់ចុះមក ហើយក៏ សង្កត់ខ្លាំងៗមួយភ្លែត មុននឹងដកថយ ។

"ប្រើអណ្តាតទៅ"

ខ្ញុំបញ្ជាម្តងទៀត ខ្យល់ដង្ហើមរបស់ខ្ញុំនៅតែធម្មតា ទាំងដែល ដៃដែលដាក់លើភ្នាក់សាឡុងនោះច្របាច់សាឡុងខ្លាំងៗ ដោយមិន ឲ្យនាងសង្កេតឃើញ ។

"..."

ស្លឹកតើយ ដកដង្ហើមធំ ហើយនាងក៏លៀនអណ្តាតលិឍបបូរ មាត់ពណ៌ស្រស់របស់នាងយឺតៗទាំងញញើតញញើម ។

ប្រពន្ធអើយ! ធ្លាប់មានអ្នកណាប្រាប់ទេថានោះគឺជាការទាក់ ទាញច្បាស់ណាស់!

"អុំប!"

នាងឧទាន ពេលដែលខ្ញុំលូកដៃទៅឱបករបស់នាងទាញមក ថើប ញែកបបូរមាត់របស់នាងចេញ ហើយជ្រែកអណ្តាតចូលទៅ ក្នុងប្រអប់មាត់ ហើយក៏ថើបជញ្ជក់យ៉ាងពុះកញ្ជ្រោលនិងយឺតៗ មុននឹងដកថយ ។

បបូរមាត់របស់នាងផ្អែម ខ្យល់ដង្ហើមរបស់យើងក៏ដង្ហក់ ។

"ថើបមិនទាន់បានល្អ តែមិនអីទេ ចាំយើងរៀនជាមួយគ្នា ពេលក្រោយ"

ខ្ញុំមិចភ្នែកដាក់ ហើយក៏រុញនាងចេញ មុននឹងងើបឈរលើក ដៃគ្រងសក់ដែលសើងម៉ើង ដោយមិនដឹងថាធ្វើបែបណាល្អជាង នេះ ។ ស្លឹកតើយ ដូចជាទន់ជង្គង់ ព្រោះថានាងទម្លាក់ខ្លួនអង្គុយ លើកម្រាល សក់របស់នាងក៏សើងម៉ើងដោយសារដៃរបស់ខ្ញុំដែល ជ្រែកចូលទៅអម្បាញ់មិញ ភ្នែកក៏ភ្លឺផ្លេកៗនិងរំភើរាយ ចំណែកមាត់ ឬ? ជាផ្នែកដែលខ្ញុំដកខ្សែភ្នែកចេញបានពិបាកបំផុត ។

"បងទៅវិញសិនហើយ ហើយអូនត្រៀមខ្លួនរឿងការង
ពេលណា ចាំតែទៅប្រាប់បង"

"..."

ខ្ញុំមើលអ្នកដែលអង្គុយដូចមនុស្សមិនទាន់ដឹងខ្លួនស្រួលបួល ហើយញញឹម ចូលចិត្តខ្លាំងណាស់អាអាកប្បកិរិយាមិនដឹងខ្លួន ដូចមិនបានធ្វើពុតរបស់ ស្លឹកតើយ ទើបអត់មិនបាននឹងឱនទៅ ថើបថ្ពាល់របស់នាងមួយខ្សឺតយ៉ាងលឿន ព្រោះបើអែនអន មាន សង្ឃឹមថាខាតពេលទៅលើនាងយូរទៀតមិនបាន ហើយ ស្លឹក តើយ នឹងហើមមាត់យូរទៀត ។

បន្ទាប់ពីនោះខ្ញុំក៏ដើរហួចចេញពីបន្ទប់ទទួលភ្ញៀវ ។



# ៨
# ស្រីរបស់ អ៊ុនថាច់

ពីសប្តាហ៍បន្ទាប់មក ខ្ញុំប្តូរលេខទូរសព្ទថ្មី ព្រោះថាដើម្បីបញ្ចប់ការធុញទ្រាន់ពីពួកស្រីៗដែលធ្លាប់ទាក់ទងគ្នា ។

ពួកនាងតែមកសួរនាំតែរឿងព័ត៌មានការត្រៀមមង្គលការរបស់ខ្ញុំ ដែលប្រាប់ថាជារឿងផ្ទៃក្នុងក្រុមគ្រួសារក៏មិនមែន ព្រោះថាពេលនេះវាល្បីសុសសាយពេញប្រទេសទៅហើយ មិនចេញព័ត៌មានមង្គលការរបស់តារាល្បីៗ ដោយសារសង្គមសុទ្ធតែដឹងថាខ្ញុំមិនធ្លាប់ទាក់ទងស្រីណាឲ្យប្រាកដប្រជា ផ្កាក់ គីតេ នៅមិនចង់ជឿផងថាខ្ញុំបញ្ឈប់គ្រប់យ៉ាង ។

ប៉ក់ៗ!

សំឡេងចុចឃីយ៍បដកុំព្យូទ័រ ធ្វើឲ្យខ្ញុំងើយមុខចេញពីការងារទៅមើលអ្នកដែលអង្គុយនៅតុធ្វើការតូចកៀនជញ្ជាំងក្នុងបន្ទប់របស់ខ្ញុំ នោះអី...មនុស្សស្រីដែល គីតេ ប្រាប់ថាធ្វើឲ្យខ្លាដូចជាខ្ញុំក្លាយជាកូនឆ្មា ។

ស្លឹកតើយ...នាងស្លៀកឯកសណ្ឋានអហ្វហ្វីសគួរឲ្យស្រឡាញ់ខ្លាំងណាស់ តែក៏អត់ឃ្លើសចិត្តមិនបាននឹងសម្រុងរបស់សំពត់ពេលដែលងើបឈរវាលុបផង្គង់ល្មម ប៉ុន្តែពេលអង្គុយចុះវាក៏ខើចដល់ភ្លៅ ដែលធ្វើឲ្យសមាធិធ្វើការរបស់ខ្ញុំវាប្រាស់ប្រាល់មិនតិចនោះទេ ។

"ស្លឹកតើយ បងសុំកាហ្វេ"

"ចាំ"

ស្រីតូចរបស់ខ្ញុំនៅតែទប់ទល់នឹងខ្ញុំហាក់ដូចជាលេខាអាជីព

ហើយក៏ផ្ទឹមម្នាទៅតុបារដែលនៅក្នុងបន្ទប់ធ្វើការនេះឯង ។ [illegible]
នាងឆុងកាហ្វេ វាធ្វើឲ្យអារម្មណ៍របស់ខ្ញុំល្អ តាំងពីអាទិត្យមុន [illegible]
ស្លឹកតើយ មកធ្វើការនៅទីនេះក្នុងក្រុមហ៊ុនរបស់ខ្ញុំតាមកិច្ច [illegible]
ព្រៀងដែលថាបើមិនទៅរស់នៅជាមួយគ្នា គឺត្រូវតែមកធ្វើការ [illegible]
ជាមួយខ្ញុំ ចំណែករឿងពិធីមង្គលការ គឺកំណត់ឡើងនៅថ្ងៃ [illegible]
ប៉ុណ្ណោះ...៥ថ្ងៃទៀតខ្ញុំបានធ្វើជាម្ចាស់របស់ ស្លឹកតើយ [illegible]
លេញហើយ ។

"មិនយកផ្អែម"

"បាទ"

លេខាកិត្តិយសដើរមករក ដោយដាក់ពែងកាហ្វេលើតុ មុន
នឹងដើរទៅអង្គុយចុចយីយ៉បន្ត ។

តាមពិតវាមិនមែនជាការងារសំខាន់អីទេ គ្រាន់តែសរុបអង្គ
ប្រជុំគឺឲ្យអ្នកដទៃធ្វើក៏បាន តែជាកាលពីច្រើនថ្ងៃមុន ស្លឹកតើយ
ងរង់ចាំនាងមកអង្គុយដកដង្ហើមចោល មិនបានធ្វើការ ទើបខ្ញុំរក
ការងារឲ្យធ្វើ ។

"ស្លឹកតើយ..."

"បាទ"

"កាហ្វេផ្អែម"

"ផ្អែមឬ អូនមិនបានឆុងផ្អែមទេ"

នាងធ្វើមុខមិនមាំង ហើយក៏ដើរដើរមកតុរបស់ខ្ញុំ មើលពែង
កាហ្វេដែលវាអស់ទៅហើយ និងដាក់លើចានទ្រ ធ្វើមុខដូចចង់
ប្រាប់ថាផឹកអស់ទៅហើយតើ ។

"ផ្អែមដល់ថ្នាក់ផ្សារពោះវៀន"

ខ្ញុំប្រាប់ដោយសំឡេងហត់នឿយ ។

"ផ្អែមឬ..."



នាងធ្វើមុខសង្ស័យ ប្រាកដណាស់ថាមិនសង្ស័យបានយ៉ាង
ម៉េច ក្នុងពេលកាហ្វេដែលនាងឆុងមកជាកាហ្វេខ្មៅ ។

"មិនជឿ ?"

"គឺវាជាកាហ្វេខ្មៅ"

"អីចឹងភ្លក្ស" ខ្ញុំប្រាប់ មុននឹងងើបឈរ ហើយលូកដៃចាប់
កញ្ចឹងករបស់ ស្លឹកតើយ ឲ្យលោមករក មុននឹងថើបបបូរមាត់របស់
នាងមួយខ្សឹតយ៉ាងលឿន ។

"យ៉ាងម៉េចដែរ ផ្អែមមែនទេ ?"

"!!!" ស្លឹកតើយ នៅតែមិនតប នាងធ្វើមុខភ្ញាក់ផ្អើល ហើយ
ដូចមិនស្មានថាខ្ញុំថើប ព្រោះអីចឹងហើយ...

"មានន័យថាមិនទាន់ដឹង អីចឹងភ្លក្សទេ"

លើកនេះខ្ញុំថើបម្តងទៀត និងប្រើពេលយូរទម្រាំតែខ្ញុំដកបបូរ
មាត់ចេញពីនាង ហើយពេលដកបបូរមាត់ចេញ បបូរមាត់ស្រស់
របស់នាងក៏ហើមតិចៗ ព្រោះត្រូវខ្ញុំជញ្ជក់ខ្លាំងៗ ។

"វាផ្អែម...មែនទេ ?"

"ផ្អែមក៏ផ្អែម"

មនុស្សឆ្លាតដែលពត្រឹងជំហរបានរហ័សប្រាប់ ហើយងាកខ្លួន
គេច ធ្វើឲ្យខ្ញុំសោកស្តាយតិចតួច គឺពីរអាទិត្យមកនេះចាប់តាំងពី
ថើបគ្នានៅក្នុងបន្ទប់ទទួលភ្ញៀវហើយ ខ្ញុំក៏មិនបានប៉ះពាល់ ស្លឹក
តើយ ទៀត ទ្រូងសឹងតែបែកព្រោះបានតែមើល ។

"ឆុងថ្មី យកទេ ?"

"មិនយកទេ ពេលនេះញ៉ាំអីក៏ផ្អែមដែរ"

ខ្ញុំប្រាប់ហើយក៏យកមេដៃជូតមាត់ខ្លួនឯង និងសើចញឹមៗ ធ្វើ
ឲ្យមុខរបស់ ស្លឹកតើយ ក្រហម នាងរអ៊ូរទាំ ធ្វើមាត់រអេចរអូច មុន
នឹងលើកពែងកាហ្វេទៅដាក់នៅតុបារ ល្ងាចពេលចេញពីធ្វើការ

មានមេផ្ទះមកចាត់ការបន្ត ។

គ្រឹត! គ្រឹត!

សំឡេងទូរសព្ទដៃរបស់ខ្ញុំដែលញ័រ ធ្វើឲ្យខ្ញុំលើកចិត្តើល ក្នុងម៉ោងធ្វើការមិត្តភក្តិមិនធ្លាប់តេមក ( បើចាទៅតិកប់អាតដែល ប៉ុណ្ណោះ គឺ គីតេ ) ។

"មានការអី ម៉េចក៏តេម៉ោក្នុងម៉ោងធ្វើការ ?" ខ្ញុំសួរ ។

( រឿងសំខាន់ មកជួយបន្តិចម៉ោ ជិតងាប់ទៅហើយ )

"នៅឯណា ?"

( សណ្ឋាគារ... )

"ហើយទៅធ្វើស្អីនៅទីនោះ" ខ្ញុំសួរបន្ត ។

សំឡេងគោះទ្វារខ្លាំងៗរត់មកចូលក្នុងទូរសព្ទ ហើយសំឡេងមនុស្សស្រីស្រែកក៏ធ្វើឲ្យខ្ញុំអាចដៅស្ថានការណ៍បាន ។ អាម្សៀនោះ...រទេះភ្លើងបុកគ្នាទៀតហើយ ។

"វាជាផ្ទះដៃរទេះនេះ ?" ខ្ញុំសួរបន្ត ដូចមិនក្តៅមិនក្រហាយអី ។

( ឈី អីនចាច់ អ្នកណាធ្វើជាអ្នកកំដរកូនកំលោះហាំស! បើខ្ញុំជួបមនុស្សស្រីយកស្បែកជើងគោះខ្លាឲ្យងាប់ពេលនេះ ) សាំមែន...តែវានិយាយក៏ជាការពិត ខ្ញុំដកដង្ហើមធំ តាមរយៈឈ្មោះសណ្ឋាគារនោះ វានៅមិនឆ្ងាយពីក្រុមហ៊ុនប៉ុន្មាន ខ្ញុំងើបឈរហើយទាញកូនសោចេញពីថតតុ ។

"ចេញទៅក្រៅឬ ?" ស្លឹកតើយ ងើយមុខចេញពីការងារមកសួរខ្ញុំ តាមពិតប្រហែលសួរនាំតាមមារយាទប៉ុណ្ណោះ បែបដែលលេខា( ប្អូនគំក៏មិនដឹង ) គួរដឹង តែវាធ្វើឲ្យខ្ញុំមានអារម្មណ៍ចាប្លែកៗ គឺតាមធម្មតាមិនចាំបាច់ប្រាប់អ្នកណាមុនពេលដែលទៅណាមកណា អឺម...ចាប់ផ្តើមមានអារម្មណ៍ដូចមានប្រពន្ធបន្តិចម្តងៗហើយ ។

"មែន ទៅជាមួយគ្នាទេ ?"

"..." នាងពិចារណា ប្រហែលខ្លាចថាខ្ញុំនាំទៅរំលោភ តាមពិតល្អដែរ តែ ស្លឹកតើយ មិនស្គាល់ចរិតខ្ញុំ **របស់** ចូលចិត្តត្រូវតែទុកស៊ីពេលក្រោយ ។

"ទៅជាមួយគ្នាទៅ ជិតថ្ងៃត្រង់ហើយ នឹងបានទៅរកអីញ៉ាំដែរ"

"មិនទៅទេ អូនបបួលមិត្តភក្តិមកញ៉ាំអាហារថ្ងៃត្រង់ជាមួយគ្នានៅហាងផ្ទុំនេះល្អជាង អូនខានជួបមិត្តភក្តិយូរហើយ"

"អីចឹងតាមចិត្ត ល្អដែលស្រីៗបាននិយាយគ្នារឿងឈុតអ្នកកំដរកូនក្រមុំ"

"..."

បានឃើញផ្ទាល់នាងក្រហមច្រៀងៗ ធ្វើឲ្យខ្ញុំមានអារម្មណ៍ល្អបន្តិចទៀត បាត់មួម៉ោដែលត្រូវទៅជួយរឿងគ្មានបានការរបស់ គីតេភ្លាម ។

"បងទៅហើយ រសៀលនឹងប្រញាប់មកវិញ ល្ងាចនេះបងនាំទៅញ៉ាំបាយនៅផ្ទះម៉ាក់ ណេីរី"

"ចាំ"

ខ្ញុំដើរចេញទៅ ដោយមិនដឹងទេថាការដើរចេញពីបន្ទប់ធ្វើការនៅពេលនេះ វានឹងនាំបញ្ហាឲ្យនៅពេលក្រោយ ដល់ថ្នាក់អ្នកអង្គុយនៅមុខកុំព្យូទ័រយំ...បើដឹងខ្ញុំនឹងទុកឲ្យ គីតេ ងាប់នៅក្នុងសណ្ឋាគារនោះបាត់ទៅហើយ ។

[End Intouch's Talk]

"នែ៎ សរុបទៅកម្មវិធីរបស់មិត្តភក្តិនេះ ឈុតគេកាត់ឲ្យហ្វ្រីមែនទេ ?" ភ្លាមឡេរ ជាអ្នកសួរដោយសំឡេងបន្ទីបន្ទា ចំណែកខ្ញុំក៏យកសមត្ថិះស្មោកក្នុងចានដែលហាន់រួចរាល់ មុននឹងងក់ក្បាល "វារ...

ឡូយមែន របស់ក្រើមាននៅក្នុងលោក"

"ឲ្យល្មមៗទៅ ក្លាមខ្មៅ ឯងនេះ...តែជាអ្នកក

សង្ហាទេ?" គ្រាប់ត្នោត សួរម្តង ខ្ញុំក៏ជ្រួញចិញ្ចើម ។

"មិនដឹងទេ មិនធ្លាប់ឃើញ ហើយក៏មិនធ្លាប់ដឹងដែល

មិត្តភក្តិឬអត់"

"ខ្ញុំសួរតាមត្រង់"

"ខ្ញុំក៏ឆ្លើយតាមត្រង់ហើយតើ"

ខ្ញុំចាក់សាច់ដាក់ចូលមាត់ទំពាយឺតៗ អាហារថ្ងៃត្រង់ដែល ជាប់ត្រូវខ្សែភ្នែករបស់ អ៊ីនជាច់ មើលនេះ វាធ្វើឲ្យស្រួលខ្លួនជុំ ទោះមានអារម្មណ៍ប្លែកៗដូចខ្វះអ្វីម្យ៉ាង តែ...ខ្ញុំបោសវាសអារម្មណ៍ នោះចោល ខ្ញុំប្រហែលជាប្រើពេលវេលានៅជាមួយគេហួសពេក មួយថ្ងៃទេដឹង ទើបធ្វើឲ្យស៊ាំ...ហ៊ុំ!

"អ៎! ម៉េចនឹងអាចទៅ ស្លឹកតើយ ឯងជិតរៀបការជាមួយគេ ហើយ មិត្តភក្តិរបស់គេឯងមិនស្គាល់ទៀតឬ?"

"អឺម"

"ងាប់ហើយ នេះជាបញ្ហាធំលំដាប់ប្រទេសជាតិ"

"ត្រង់ណា?"

ខ្ញុំមិងម៉ាំង អាគ្រាន់តែមិនស្គាល់មិត្តភក្តិរបស់គេនេះ វាត្រូវ ធ្លាក់ផ្អើលស្អីដល់ថ្នាក់នេះដែរឬ មិនពិតទេដឹង?

"កម្ម...កម្មរបស់ញៀរ បើស្វាមីឯងមានស្រីនោះ ស្លឹកតើយ បើ គេយកលេសថាទៅរកមិត្តភក្តិតែលួចទៅរកស្រី បើយើងស្គាល់មិត្ត ភក្តិរបស់គេ នឹងតាមទៅឆែកបាននោះអី" ក្លាមខ្មៅ ប្រាប់ដោយទឹក មុខប្រាកដប្រជាខ្លាំង ខ្លាំងដល់ថ្នាក់ខ្ញុំអស់សំណើច ។

"ដល់ថ្នាក់ហ្នឹងផងឬ"

"មែន បង អ៊ីនជាច់ របស់ឯងជាកំលោះសាច់ក្រអូប

សេរីល ស្រីៗទាំងតារាទាំងពួកហៃសូនាំគ្នាត្របាក់សាច់ដុំរបស់គេ សឹងស្លាប់ទៅហើយ"

គ្រាប់ត្នោត បន្ថែម ខ្ញុំក៏នឹករូបភាពតាម...ឃើញ អ៊ីនជាច់ មាន ស្រីៗមើលគេដោយទឹកមាត់ហូរកញ្ចាក់ហើយ ក៏អត់អស់សំណើច មិនបាន ។

"ទៅសើចទៀត ចាំឲ្យប្តីសង្ហាត្រូវអូសទៅស៊ីសិន ទើបនាងត្រូវ ស្រក់ទឹកភ្នែករហាមឬយ៉ាងម៉េច"

"អឺម ចាំឲ្យដល់ថ្ងៃនោះសិនទៅ"

ខ្ញុំប្រាប់ញឹមៗហើយញ៉ាំបន្ត មិនដឹងទេ...ខ្ញុំអាចសប្បាយចិត្ត ក៏ជាបាន ដែលមានមនុស្សមកយកមនុស្សប្រុសផ្តាច់ការម្នាក់នេះ ចេញពីជីវិត ។

ខ្ញុំលាមិត្តភក្តិ ហើយត្រឡប់ទៅធ្វើការវិញដោយជិះតាក់ស៊ី ការងារដែល អ៊ីនជាច់ ឲ្យវាយឯកសារនោះវាគួរឲ្យធុញ តែក៏ល្អ ជាងត្រូវបើទៅនៅជាមួយនឹងគេតាំងពីយប់ដំបូងដែលចុះសំបុត្រ អាពាហ៍ពិពាហ៍ ។

មង្គលការរបស់យើង...អៀនតិចៗពេលគិតបែបនេះ ខ្ញុំក៏បាន រើសឈុតទុករួចហើយដែរ វាស្អាតណាស់ តែឈុតមកដល់ប្រទេស កូរ៉េនៅបីថ្ងៃទៀត (អានេះ អ៊ីនជាច់ ជាអ្នកណែនាំណាយបង្គាប់បញ្ជា ឲ្យក្រុមហ៊ុនពីអ្នកឌីហ្សាញបរទេស) ។

អ្នកជាចៅហ្វាយមិនទាន់មកវិញ...ខ្ញុំមើលតុធ្វើការរបស់គេ ដោយការងឿងឆ្ងល់ តែតាមតែគេទៅ អ្នកណាទៅចាប់អារម្មណ៍ ។

ម៉ោង១កន្លះគេមិនទាន់មកវិញ...

ម៉ោង២គេក៏មិនទាន់មកវិញ...

អ៎...ត្រូវឡានបុកឬអត់ ឬថាទៅមាត់ថ្លៃនៅឯណា ហើយត្រូវ គេអូសយកទៅសម្លាប់ទៅហើយ? មិនមែនទេដឹង មានដូចយក្ស

ថែមទាំងកំណាចដល់ថ្នាក់នោះ ត្រូវនិយាយថាអ្នកសម្លាប់ច្រើនជាង ។

ខ្ញុំធ្វើការបន្ត ហើយពេលមើលម៉ោងម្តងទៀត ក៏ឃើញថាល្ងាចទៅហើយ វាជាពេលវេលាចេញពីធ្វើការហើយ អ៊ីនថាច់មិនទាន់ត្រឡប់មកវិញ...គេទៅណា ?

ខ្ញុំត្រឡប់មកដល់ផ្ទះដោយខ្លួនឯងជាលើកដំបូង នៅក្នុងពេលកន្លះខែមកនេះ តាមធម្មតា អ៊ីនថាច់ ជាអ្នកមកយកខ្ញុំពីការ ហើយក៏ជូនខ្ញុំមកផ្ទះវិញរហូតដែរ ។

"អាំ...មកហើយឬ មិនឮសំឡេងឡាន"

អ្នកស្រី គេហ៊ី ដែលជាម៉ាក់របស់ខ្ញុំសួរ មុននឹងដើរមកអង្គុយនៅបន្ទប់អង្គុយលេង អ្នកបម្រើក៏លើកចានគ្រាប់ផ្លែឈើមកឲ្យ ហើយតើថាជារឿងសម្រស់រឿងស្អាតនេះ ម៉ាក់ខ្ញុំឈ្មោះដាច់ហ្គូង ។

"ឯណា អ៊ីនថាច់ ?"

"មិនទាន់មកទេ ខ្ញុំមកម្នាក់ឯង"

"អាំ...ឯងទៅធ្វើស្អីឲ្យគេខឹងឬអត់ ?"

ខ្ញុំជ្រួញចិញ្ចើម ។

"ម៉ាក់...នោះជាអ្នកដទៃ ខ្ញុំជាកូនម៉ាក់ និយាយមិនកាន់ជើងគ្នាសោះ"

"អ្នកដទៃឯណា កូនប្រសាររបស់ម៉ាក់ណាំ"

ម៉ាក់ខ្ញុំញញឹមញញែម ខ្ញុំក៏ដកដង្ហើមធំ មើលមុខម៉ាក់ដែលឲ្យអ្នកបម្រើចិទក្រសក់ហើមុខ ។

"អ៊ឺម បងស្រីឯងមកមុនថ្ងៃមង្គលការពីរថ្ងៃ"

បង ផ្កាឈូក ដើមហេតុមួយនៃបំណុល...ពេលជួបមុខនឹងលេងឲ្យណាណី !

"ចាំ ម៉ាក់ ខ្ញុំហត់ ទៅបន្ទប់សិនហើយ"

ខ្ញុំប្រាប់ ម៉ាក់ក៏ត្រវៃដៃដាក់ ទើបខ្ញុំដើរអូសជើងទៅបន្ទប់ដេករបស់ខ្លួនឯង កំពុងតែដាក់កាបូបចុះទូរសព្ទក៏រោទ៍ ពេលយកមកមើលក៏ឃើញមុខការបស់ អ៊ីនថាច់ ពេញអេក្រង់ គេសេវលេខខ្លួនឯងដោយដាក់រូបភាពតាំងពីពេលណានេះ ?

"ចាំ" ខ្ញុំចុចទទួល ។

(អូនដល់ផ្ទះហើយឬ ? )

សំឡេងរបស់គេបន្លឺឡើង ដូចកំពុងមានអារម្មណ៍មិនល្អដែរ ឬប្រហែលមានអារម្មណ៍ដឹងខុសដែលបណ្តោយឲ្យខ្ញុំជិះតាក់ស៊ីមកផ្ទះ ។

"ដល់ហើយ កំពុងតែងូតទឹក ចុះទៅញ៉ាំអាហារពេលល្ងាច"

(អឺម បងកំពុងតែទៅផ្ទះអូន)

"មកធ្វើអី ?"

អ្នកគេមកស្ងាត់មាត់ មុននឹងតបដោយសំឡេងរឹង ៖

(ទៅញ៉ាំបាយជាមួយ បានទេ ប្របដែលប្តីចង់ញ៉ាំបាយជាមួយ បានទេ ? )

អាម្សៀនេះកើតស្អីទៀតហើយ រដូវមិនមកឬយ៉ាងម៉េច ងាយមួម៉ៅម្ល៉េះ...ខ្ញុំរអ៊ូក្នុងចិត្ត ។

"ម៉ោក៏ម៉ោៗ ខឹងធ្វើស្អី ប្លែកមែន"

សំឡេងដកដង្ហើមធំយ៉ាងវែងបន្លឺឡើង ហើយសំឡេងគេដែលតបមកនោះក៏រាងអន់តិចតួច ។

(តិចទៀតជួបគ្នា)

ខ្ញុំជ្រួញចិញ្ចើមដាក់ទូរសព្ទ មុននឹងដាក់វាចុះ ហើយដើរទៅរកខោអាវងូតទឹក មិនយល់ពីមនុស្សប្រុសម្នាក់នេះមែន ។

ពេលងូតទឹករួចរាល់ក៏ចុះមកជាន់ក្រោម ខ្ញុំឃើញ អ៊ីនថាច់ ... ក្នុងបន្ទប់ទទួលភ្ញៀវ ចំណែកម៉ាក់ខ្ញុំប្រហែល

ជាបញ្ហាអ្នកបម្រើរឿងម្ហូបអាហារល្ងាចនេះ ព្រោះជា ...
មក ។

"ស្លឹកតើយ..."

អ៊ីនជាច់ ហៅពេលដែលខ្ញុំចុះដើរចូលទៅ ...
ថ្មី មិនមែនឈុតកាលពីព្រឹក ត្រឡប់ទៅផ្ទះផ្លាស់ខោអាវ...

"ឃ្លានដល់ហើយ មានអីឲ្យញ៉ាំខ្លះ"

"ចាំទៅសួរនៅផ្ទះបាយឲ្យ"

យ៉ាងណាក៏មានឈ្មោះជាស្វាមី រឿងអាហារការហូប...
តែយកចិត្តទុកដាក់ខ្លះ ។

"កុំធ្វើខ្លួនឯង ឲ្យអ្នកដទៃធ្វើទៅ ចង់ញ៉ាំម្ហូបឆ្ងាញ់ៗ"

លាយថ្នាំពុលក្នុងបាយឲ្យញ៉ាំល្អទេ ?

ខ្ញុំងាកទៅមើលគេ និងខាំធ្មេញញញឹមដាក់ ។

អ៊ីនជាច់ ក៏អស់សំណើចពេលឃើញថាខ្ញុំធ្វើបែបនេះ មុននឹង
បក់ដៃហៅ ហើយទះសាឡុងក្បែរ ។

"លេងសើចទេ ធ្វើមុខដូចឆ្មាហើមពោះ មកនេះ មកអង្គុយ
ជិតម៉ោ"

"..."

ខ្ញុំក្រឹមភ្នែកមើលគេ ហើយដើរទៅអង្គុយក្បែរយ៉ាងងាយ ...
ដូងលោតញាប់តិចតួច ហើយក៏អឹមអៀនតិចតួចដូចគ្នា ។

"ថ្ងៃនេះមកវិញម្នាក់ឯងហត់ទេ ជិះឡានអីម៉ោ ?"

សំឡេងនេះស្រទន់ដល់ហើយ ។

"តាក់ស៊ី មិនហត់ទេ ឡានក៏មិនស្ទះដែរ"

"សូមទោសដែលឲ្យមកវិញម្នាក់ឯង"

"មិនអីទេ"

ភមិនមែនជារឿងធំហ្នឹងណា...



គុប...

អ៊ីនជាច់ ផ្តួលខ្លួនដេកកើយភ្លៅរបស់ខ្ញុំ គេចូលចិត្តធ្វើបែបនេះ
ណាស់ៗ ខ្ញុំហាមាត់ប្រុងប្រាប់ឲ្យគេងើប តែកែវភ្នែកមុតស្រួច
ដែលមើលមកនោះធ្វើឲ្យបេះដូងរបស់ខ្ញុំទន់អស់ ហេតុអីភ្នែករបស់
គេស្អាតបែបនេះ អី...ឲ្យដេកមួយភ្លែតក៏បាន ។

"កើតអីឬអត់ នឿយឬ ?"

ខ្ញុំសួរហើយក៏ក្ដាប់ដៃណែន ព្រោះថាពេលនេះខ្ញុំសឹងតែហាម
ខ្លួនឯងមិនឲ្យស្ទាបសក់ទន់ល្មើយរបស់គេលេងមិនបាន ។

គេសង្ហាដល់ហើយ កាន់តែមើលជិតបែបនេះក៏កាន់តែសង្ហា
អីចឹងតើបានជា គ្រាប់ត្នោត និង ក្ដាមខ្មៅ ប្រាប់ថាមានតែស្រីៗ
ពាមញ៉ែគេឲ្យប្រាក់ ។

"អត់ទេ...មិនបាននឿយទេ គ្រាន់តែចង់ម៉ូកម៉ូក់ដាក់ប្រពន្ធ"

ហាំស...ខ្ញុំជ្រួញចិញ្ចើម ។

"ធ្វើអី ស្លឹកតើយ ?"

អ៊ីនជាច់ សួរពេលឃើញខ្ញុំដាក់ដៃលើថ្ពាសរបស់គេ ចំណែក
ដៃម្ខាងទៀតក៏ដាក់លើថ្ពាសខ្លួនឯង ខ្លួនគេមិនក្ដៅឯណា ចេះ
រើរកាយទៅកើត !

"គឺចង់ដឹងថាបងមិនស្រួលខ្លួនឬអត់ ក្រែងលោកាលពីថ្ងៃញ៉ាំ
អីខុស"

"..." គេនៅស្ងៀម មុននឹងលូកដៃមកផ្ទាត់ថ្ពាសខ្ញុំលាន់ផាច់
ហើយស្ដីឲ្យ "ច្រឡឹម"

អ៊ីនជាច់ ញញឹមដាក់ខ្ញុំ...ទៀតហើយ...នេះខ្ញុំកំពុងតែលង់
ស្នេហ៍ស្វាមីខ្លួនឯងមែនទេ ?

[Intouch's Talk]

ខ្ញុំដើរមករកឡាន ព្រមទាំងមើលនាឡិកាដៃ ព្រោះបានដល់ពេលទៅទទួលស្រីតូចភរិយាក្បាលរឹងនៅផ្ទះម៉ាក់ហ្គ្រេហ្វ ថ្ងៃនេះជាថ្ងៃថតរូបព្រីវេឌីងរបស់យើងទាំងពីរ...ថ្ងៃមង្គលការរបស់យើងជិតមកដល់ហើយ ។

"លោក អ៊ីនថាច់" សំឡេងមនុស្សស្រីដែលមិនធ្លាប់ស្គាល់បន្លឺឡើង ខ្ញុំងាកទៅមើល ហើយក៏ត្រូវលើកចិញ្ចើម...អ្នកណាគេ?

"ស្មានថាមិនបានជួបលោក ហើយត្រូវមកខាតជើង សប្បាយចិត្តមែនទែន មានន័យថាទិន្នន័យដែលខ្ញុំបានមកមិនខុស"

"..."

ខ្ញុំមើលស្រីស្អាតសម្បុរសម្រាំងក្នុងឈុតរ៉ូបរាងពណ៌ផ្កាឈូកដែលដើរមករកខ្ញុំដោយការងឿងឆ្ងល់តិចតួច ខួរក្បាលចាំមិនបានទេថាធ្លាប់ស្គាល់ម្នាក់នេះ ។

"ខ្ញុំ ណាអូមិ ហ្គីងអ៊ី ណាអូមិ មិត្តភក្តិរបស់ បែល សង្សាររបស់ គីតេ ហ្គីងអ៊ី"

ឈប់សិន ខ្ញុំ...ខ្ញុំរំឭកទៅដល់កាលពីបីថ្ងៃមុន ពេលដែលអាមិត្តចង្រៃហៅឲ្យទៅជួយនៅសណ្ឋាគារ ។

សង្សាររបស់អា គីតេ អ៊ីចឹងឬ? វាគ្មានសង្សារទេ មានតែដៃគូលើគ្រែ អំ...ចាំបានហើយ មនុស្សស្រីដែលប្រាប់ថាខ្លួនឯងឈ្មោះ ណាអូមិ ម្នាក់នេះ មកជាមួយស្រីរបស់ គីតេ ម្នាក់ទៀត ជាអ្នកតាមទៅរករឿង គីតេ ដែលនៅជាមួយស្រីដែលជាគ្រីតធីដ៏ស្រស់ស្អាតនៅក្នុងបន្ទប់ ។ កាលនោះខ្ញុំទៅដល់ គ្រីតធីនោះក៏ហៅមិត្តភក្តិរបស់នាងមកជួយ ទើបសង្គ្រាមទះតប់ដណ្ដើមប្រុសកើតឡើង ។

"ខ្ញុំអរគុណលោក បើថ្ងៃនោះលោកមិនទៅចាប់ស្រីម្នាក់នោះ ខ្ញុំច្បាស់ជាខូចសម្រស់មិនខាន"

"មិនអីទេ"

ខ្ញុំតបតាមមារយាទ ទាំងដែលការពិតទៅចង់ប្រាប់នាងថា ផ្លាស្ទិកលើមុខដែលពេទ្យធ្វើឲ្យនោះខ្ទៅមិនរបកនោះទេ ។

ដូចដែលប្រាប់ ខ្ញុំមិនមែនជាមាន់សម្ល តាមភាពស្ទាត់ជំនាញទិតនិករបស់ លី អ៊ីនថាច់ មើលតែមួយភ្លែតក៏ដឹងហើយថាមុខស្អាតដូចស្រីជប៉ុននៅចំពោះមុខ បានមកដោយសារកាំបិតរបស់ពេទ្យ ។ មនុស្សស្រីសម័យនេះកើតស្ទើរអស់ទៅហើយ ចូលចិត្តស្អាតបែបផ្លាស្ទិក ចង្កាស្រួច មាត់ស្រួច ភ្នែកធំៗខុសពីធម្មតាដូចតុក្កតា ដែលហៅថាបឹកអាយមិនឃើញថាស្អាតអីបន្តិច មិនឃើញដូច ស្ទីកគើយ របស់ខ្ញុំផង អឺម...និយាយហើយក៏នឹក ។

"សូមទោស ខ្ញុំមានការរវល់" ខ្ញុំប្រាប់ មុននឹងចាក់សោឡាន ។

តែថា...

"ខ្ញុំចង់អរគុណលោក"

សំឡេងញាប់ស្អែកនោះបន្លឺឡើង ស្របពេលដែលនាងរត់មកឱបដៃខ្ញុំ ។

ហ៊ឹម?

ខ្ញុំមើលមុខរបស់មនុស្សស្រីដែលសង្កត់ដើមទ្រូងនឹងដើមដៃរបស់ខ្ញុំ ហើយក្រដុស...ស្លុចច្បាស់ណាស់!

"ចង់អរគុណលោកជាលក្ខណៈផ្ទាល់ខ្លួនដែរ មិនដឹងថា...អាចមានពេលឲ្យខ្ញុំឬអត់"

"..."

ខ្ញុំមើលជ្រលងទ្រូងដែលបៀតនឹងអាវរីបរាងកធំ ដល់ថ្នាក់ស្ទើមិនដឹងជាស្ទើធ្លាក់ចេញមក ហើយក៏នៅស្ងៀម ។

"វា..."

ណាអូមិ លើកចិញ្ចើមខ្ពស់ មើលខ្ញុំដោយការសង្ស័យ ។

"ស្អីគេ ?"

"ភរិយា"

"!!!"

នាងធ្វើមុខដូចមិនបានឮ ឬមិនអើពើក៏មិនយល់...មនុស្ស… សម័យនេះចាប់អារម្មណ៍តែរឿងបន្ថែមទំហំដើមទ្រូង តែមិន… អារម្មណ៍បន្ថែមតម្លៃខ្លួនឯង ។ ជាការពិត ខ្ញុំអាចធ្លាប់ចូលចិត្ត… ច្រើន តែគ្មានចំណង គ្រាន់តែទាក់ទងគ្នាហើយក៏ចប់ទៅលើគ្រែ ។

តែថា...នោះជាពេលវេលាមុនពេលដែលម៉ាក់ប្រាប់ឲ្យ… មើលគូជាមួយ ស្អីកតើយ កូនបំណុលដែលគួរឲ្យស្រឡាញ់បំផុត… នៅក្នុងលោក ។

"ស៊ីលីខុនយារពេកហើយ សូមទោស អូម៉ាមិ...អី អ្នកចង់… ឈ្មោះអី ណ្ហើយចុះ ខ្ញុំមិនចូលចិត្តស៊ីរបស់ក្លែងក្លាយ ខ្ញុំមានការ… រស់ លាហើយ" ខ្ញុំញញឹម ហើយបេះដៃនាងចេញ ។

រឹងមូលបែបនោះ គឺស៊ីលីខុនច្បាស់ណាស់ ហើយទោះភព… របស់ពិត ក៏មនុស្សស្រីតែម្នាក់គត់ដែលខ្ញុំចង់លោតសង្គ្រាម ស្អីក តើយ ក្រៅពីនោះមិនយក ។

ខ្ញុំបើកឡានចេញពីចំណតឡានរបស់ខុនដូ ទុកឲ្យនាងនៅ ត្រង់នោះ ដៃក៏ចុចទូរសព្ទទៅរកអាមេបញ្ហានៃរឿងទាំងអស់ ។

(ហាឡូ)

សំឡេងអាមិត្តចង្រៃស្តាប់ទៅដូចទើបតែភ្ញាក់ពីដេក ។

"គីតេ មិត្តរបស់ស្រីឯងម្នាក់មករកខ្ញុំនៅខុនដូ"

(អ្នកណាគេ ?)

គីតេ សួរដោយសំឡេងគួរដូចនៅងងុយ ។

"ឈ្មោះ អូម៉ូហ្គិ អូកាតិ ស្អីគេនោះ ចាំមិនបានទេ"

(ណាអូមិ ?)



"អឺ...ហ្អើងហើយ ណាអូមិ មករកខ្ញុំនៅខុនដូ ឲ្យស្រីរបស់ឯង ប្រាប់មិត្តភក្តិផងថាកុំម៉ោរវីរល់នឹងខ្ញុំ យល់ទេ ?"

(ចាំខ្ញុំប្រាប់ឲ្យ សូមទោសផងសម្លាញ់)

"អឺម"

ខ្ញុំដាក់ទូរសព្ទចុះ វាក្លាយជាច្បាប់តាំងពីពេលណា ខ្ញុំនិង គីតេ តាំងពីកាលនៅជាព្រាននារី មានស្រីៗចាំដេកជាមួយ គ្រប់គ្នាមិនធ្លាប់មករកដល់ខុនដូឬផ្ទះទាល់តែសោះ ដូច្នេះហើយទោះខ្ញុំដកខ្លួនចេញពីវិស័យនោះ តែការដែល ណាអូមិ មករកដល់ទីនេះត្រូវតែឲ្យ គីតេ ចាត់ការ ប្រាប់ស្រីរបស់វាឲ្យដាស់តឿននាងម្តងទៀត ។

ខ្ញុំបើកឡានចេញទៅ គោលដៅគឺផ្ទះរបស់ ស្អីកតើយ ទោះមួម៉ៅនឹងរឿងដែលមិនបានអញ្ជើញដូចជា ណាអូមិ តែក៏មានអារម្មណ៍ល្អដែលបានទៅរកប្រពន្ធ ។

ហើយ១០នាទីក្រោយមក ខ្ញុំក៏ភ្លេចរឿងស្រីដើមទ្រូងស៊ីលីខុនម្នាក់នោះឲ្យឈឹង ។

[End Intouch's Talk]

# ៩

# ភាពស្មុគស្មាញដោយសារស្រីខ្ទុចស៊ីលីខុះ

Mission Complete

រាងកាយរបស់ខ្ញុំស៊ឹងតែរលាយ ច្រើនថ្ងៃមកនេះហត់ហ្មើ... ខ្លាំងណាស់ អ៊ីនជាប់ មកយកទៅថតរូបក្រិវេននឹង ហើយយើង... ត្រូវឱបគ្នា នៃបនិត្យគ្នា ថើបថ្ពាល់គ្នាគ្រប់សារពើ ទាល់តែជាងបេ... ពេញចិត្ត ។

ចំណែកឈុតកូនក្រមុំដែលកុម្ម៉ង់កាត់ក៏ត្រូវបញ្ជូនមកដល់ ហើយ ខ្ញុំក៏បានទៅល្បងរួចរាល់ហើយដែរជាមួយ គ្រប់គ្នា និង ក្លាមខ្មេរ ដែលជាអ្នកកំដរកូនក្រមុំ ។ តាមពិត អ៊ីនជាន់ ត្រូវមក... ជាមួយដែរ តែម៉ាក់របស់គេនឹងម៉ាក់របស់ខ្ញុំហាម ព្រោះចង់ឲ្យគេ... ភ្ញាក់ផ្អើលនៅថ្ងៃពិធីដែលជិតមកដល់ ។

"ស្លឹកតើយ...កំពុងធ្វើអី មកមើលម៉ូដខេកទៅ"

សំឡេងនោះធ្វើឲ្យខ្ញុំចង់យំ...ខ្ញុំហត់ហើយ ។

"ស្លឹកតើយ"

ទ្វារបន្ទប់ត្រូវបើក មនុស្សស្រីដែលពាក់អាវពណ៌ស្រស់នោះ មិនមែនអ្នកឯណាទេ គឺបងស្រីខ្ញុំហ្នឹងឯង ។

ផ្កាឈូក...បងស្រីខ្ញុំមកពីបរទេសបានពីរថ្ងៃហើយ ដំបូងថា មកមុនមង្គលការពីរថ្ងៃ តែម៉ាក់របស់ខ្ញុំហៅមកមុនដើម្បីជួយកម្មវិធី ដែលរវល់ខ្វែងដៃខ្វែងជើង ។

"បងស្រី"

"មកឲ្យឆាប់ឡើង និងបានឲ្យចម្លើយគេ"

"ឲ្យវេននឹងរើសទៅ"

ខ្ញុំមាននាយដល់ក្រុមហ៊ុនរៀបចំ...

ទាល់លុយផ្ទួលឡើងតរតោក នៅមកទម្លាក់ការងារឲ្យខ្ញុំធ្វើទៀត ។

"តែយកមកឲ្យយើងមើលហើយ នេះអី ឆាប់ៗឡើង សុទ្ធតែ ស្អាត...កើតអី?"

បងស្រីដែលបែកពីខ្ញុំច្រើនឆ្នាំព្រោះរៀបការទៅនៅជាមួយ ស្វាមីសួរ ព្រមទាំងដើរមកអង្គុយលើគ្រែ ។

"ហត់" ខ្ញុំតបខ្លីៗ ។

"..."

យើងមើលមុខគ្នា មុននឹងបងស្រីលូកដៃមកអង្អែលដៃរបស់ខ្ញុំ តិចៗ ហើយក៏...

"អូយ!"

ខ្ញុំស្រែកពេលត្រូវបងស្រីក្តិចដើមដៃខ្លាំងៗ សូមបញ្ជាក់... ថាខ្លាំងៗ ខ្លាំងណាស់!

ខ្ញុំលើកដៃអង្អែលដៃខ្លួនឯង និងមើលមុខបងស្រីដោយខ្សែ ភ្នែកខឹងសម្បា ។

"ឈឺ ក្តិចធ្វើអី"

"ព្រេញ បានប្តីសង្ហា ប្តីអ្នកមាន ប្តីឡូយប្លែកនេះហើយ នៅ មកធ្វើមុខដូចងាប់ទៀត"

"បងរៀបការជំនួសទេ រៀបការដោះបំណុល អញ្ចឹង"

ខ្ញុំឡូឡានេះ តែក៏ត្រូវក្តិចម្តងទៀត ធ្វើឲ្យបាក់ព្រញាង ស្អីនេះ!

"បើគេយក ខ្ញុំក៏ព្រម" បងស្រីធ្វើភ្នែកធំៗ ហើយដកដង្ហើមធំ

"និយាយលេងទេ...ស្លឹកតើយ ខ្ញុំមិនដឹងថាឯងលះបង់ប៉ុណ្ណា ដំបូង ពេលដឹងពីម៉ាក់ថាឯងរៀបការដោះបំណុល១០០លាន ខ្ញុំភ្ញាក់ ផ្អើល ហើយក៏អន្ទះអន្ទែងដែរ ខ្ញុំចង់មកជួយ តែម៉ាក់ប្រាប់ថាមិន ...ដែរថាហេតុអីបានជាម៉ាក់មិនទុក្ខសោក តែ ... ខ្ញុំទៅជាលេងអាណិតឯង មានតែ...

ប្រណែនទៅវិញ"

អាំ...ទៅជាអីចឹងទៅ!

"ប្រណែនរឿងអី?"

"ហ៊ានសួរផង គេទាំងសង្ហា ទាំងល្អ និងស្រឡាញ់ឯងរហូតដល់ថ្នាក់នេះ មើលម្តងៗសឹងតែលេបត្របាក់ហើយ មិនឃើញទេឬ"

ដែលថាសង្ហានោះព្រមទទួលស្គាល់ រឿងល្អនេះវាមិនប្រាកដចិត្ត តែរឿងដែលថាស្រឡាញ់ខ្ញុំ...

"គេមិនបានស្រឡាញ់ខ្ញុំទេ"

"..." បងស្រីមើលខ្ញុំដោយខ្សែភ្នែកជិនឆ្អន់យ៉ាងខ្លាំង ខ្ញុំក៏រហ័សគេចទៅឲ្យឆ្ងាយពីដៃរបស់នាង ។

"តាមធម្មតាប្អូនខ្ញុំឆ្លាត តែពេលល្ងង់ ល្ងង់រកលេខដាក់គ្មាន"

"បងស្រី!" ខ្ញុំស្រែក "ជ្រុលពេកហើយ"

"ឈប់ទុក្ខសោកបានហើយ ចុះទៅបើសខេក គេចាំបម្រើយាំកូនក្រមុំ" និយាយចប់នាងក៏រុញក្បាលខ្ញុំមួយទំហឹង ។

ល្អិនេះ នេះខ្ញុំជាអ្នកលះបង់ដើម្បីក្រុមគ្រួសារមិនអីចឹង គ្រប់គ្នាគួរតែរំភើបនិងអាណិត មិនមែនព្រួតគ្នាធ្វើបាបខ្ញុំបែបនេះទេ ។

ខ្ញុំតាមមើលបងស្រីដែលចេញពីបន្ទប់ សំឡេងរបស់នាងនៅតែបន្លឺកងរំពងក្នុងខួរក្បាល ។

*"គេស្រឡាញ់ឯងដល់ថ្នាក់នេះ..."*

បេះដូងលោតញាប់ទៀតហើយ ខ្ញុំកំពុងតែកើតរោគបេះដូងឬអត់ ហើយអារម្មណ៍សប្បាយចិត្តបែបនេះ អារម្មណ៍ស្ងប់ស្ងល់បែបនេះ...វាជាអ្វី? គ្រាន់តែគិតថា អ៊ីនចាច់ ស្រឡាញ់ខ្ញុំ វាក៏ធ្វើឲ្យខ្ញុំ...កុំប្រាប់ណា ថាខ្ញុំលង់ស្នេហ៍ប្រុសម្នាក់នោះទៅហើយ លង់ស្នេហ៍ស្វាមីខ្លួនឯងឬនេះ!

"..."



ខ្ញុំក្តិចថ្ពាល់ខ្លួនឯងហៅស្មារតី ។

"មិនមែនទេ ស្តាប់គេនិយាយដល់ថ្នាក់ឆ្កួតទៅហើយ ស្លឹក តើយ"

ខ្ញុំចុះទៅបើសខេក ហើយក៏ត្រឡប់មកបន្ទប់វិញ រាប់តាំងពីត្រូវចុះសំបុត្រអាពាហ៍ពិពាហ៍ហើយ អ៊ីនចាច់ ដាក់លក្ខខណ្ឌដាច់ខាតឲ្យខ្ញុំមកស្នាក់នៅផ្ទះ ជំនួសការស្នាក់នៅខុនដូ ធ្វើឲ្យខ្ញុំទំនេរខ្លាំងណាស់ ។

តាមធម្មតាមិត្តភក្តិទាំងពីរតែងតែមកដេកជាមួយ ហើយស្អែកនេះម៉ាក់របស់ខ្ញុំឲ្យទៅខាត់ស្បែក ត្រាំទឹកដោះគោនៅមជ្ឈមណ្ឌលតែសម្ផស្ស ម៉ាក់ប្រាប់ថាខ្ញុំត្រូវតែងូតទឹកដោះគោរាល់ថ្ងៃរាល់តែដល់ថ្ងៃរៀបការ ។ ណាត់ គ្រាប់ត្នោត និង ក្តាមខ្មៅ ទៅកំដរល្អជាង ហើយពេលប្រុងតេទៅរកមិត្តភក្តិទូរសព្ទក៏រោទ៍ ពេលមើលមុខកាចរបស់អ្នកដែលតេមកហើយ បេះដូងរបស់ខ្ញុំក៏លោតញាប់ ។

"សួស្តី"

(ដេកលក់ហើយនៅ?)

"..."

បើដេកលក់ឲ្យទទួលទូរសព្ទបានយ៉ាងម៉េច?

ប្រាកដណាស់ថាខ្ញុំនិយាយនៅក្នុងចិត្តដូចទម្លាប់ ។

"នៅទេ ចុះបង?"

(បើដេកលក់ម៉េចនឹងតេទៅរកអូនកើតទៅ)

"បេះបួយ"

ខ្ញុំភ្លេចខ្លួន ភ្លេចខ្លួនពិតមែន ទើបរហ័សលើកដៃសង្គ្រុបមាត់ អ្នកចុងខ្សែក៏ស្ងាត់មួយភ្លែត មុននឹងផ្ទុះសំណើច ។

(ហាសៗ ស្រីឡប់...បងទើបតែមកពីហ្វឹតនេសទើបតេរកនឹក ខានជួបពេញមួយថ្ងៃហើយ)

ដូចគ្នា...អេ់! មិនមែនទេ មិនមែន! អាយ...ខ្ញុំហ៊ាននិ
ព្រោះបងស្រីកំណាចយកមកនិយាយ ទើបធ្វើឲ្យខ្ញុំ
ដល់ថ្នាក់នេះ ។

"ទៅហាត់ប្រាណឬ?"

ខ្ញុំសួរ ព្រមទាំងយកម្រាមដៃផ្ទិះឮកលេង...មៀនហ្នឹង
ជាមនុស្សស្រី ។

( មែន រាងកាយនឹងបានរឹងមាំ...កាន់តែរឹងពេលចូលបន្ទប់
ដំណេក! )

"!!!"

ខ្ញុំចំហមាត់ឆ្ងង ពាក្យសម្ដីដែលមិនចាំបាច់បកប្រែប្រាប់
ឲ្យខ្ញុំក្ដៅថ្ពាល់ភាយៗ ។

( នែ៎ ដឹងទេថាចង្កេះបងរឹងមាំខ្លាំង ផង្កងក៏រឹងមាំ បែមទាំង...)

"បានហើយៗ មិនបាច់រៀបរាប់ទេ អូនមិនចង់ខូចខ្លួនតាមឲ្យ
សព្ទ" ខ្ញុំរហ័សហាមពេល អ៊ីនចាន់ ប្រុងរៀបរាប់បន្ត ។

គេសើចម្ដងទៀត លើកនេះសើចយូរជាងមុន ចំណែកខ្ញុំអេះ
ញញឹមមិនបាន ហើយពេលដឹងខ្លួនក៏រហ័សបិទស្នាមញញឹមភ្លាមៗ

"បងគេមកតែរឿងប៉ុណ្ណឹងមែនទេ?"

( អឹម...ចង់ឮសំឡេងអូនមុនចូលដេក )

"..."

ខ្ញុំទប់ទល់ពេលដែលគេកំណាច បានងាយជាងពេលដែលគេ
ធ្វើខ្លួនគួរឲ្យស្រឡាញ់ ពេលនេះអង់ទឹករប្រឆាំងនឹង អ៊ីនចាន់ ដែល
ខ្ញុំមានភរិយាពេញបន្ទប់ ពេលគេធ្វើសំឡេងផ្អែមល្ហែមបែបនេះ
បេះដូងខ្ញុំក៏រលាយដូចអៃស្គ្រីមដែលដាក់នៅក្រោមពន្លឺថ្ងៃ ។

( ចូលដេកហើយនៅ? )

"អឹម"



( ស្លឹកតើយ... )

"ចាំ"

( ងូតទឹកហើយនៅ )

ស្អាតធ្វើអី...ខ្ញុំឈ្ងោកមើលខ្លួនឯងដែលនៅក្នុងឈុតដេដែល
ហើយត្រវិក្បាល អាំ...ភ្លេចទៅ គេមើលមិនឃើញនោះទេ ។

"នៅ"

អ្នកពុងខ្សែស្ងាត់មាត់ម្ដងទៀត ទើបខ្ញុំស្រែកហៅ ។

"បង អ៊ីនចាន់"

( អ៊ីចឹងបើងូតទឹកហើយពេលជូតខ្លួននឹកបងផង ពេលដែល
ដៃរបស់អូនជូត...ស្លឹកតើយតូច នឹកបងផង )

ក្ដុក!

ខ្ញុំក្រវែងទូរសព្ទដៃទៅលើគ្រែភ្លាម មុខនេះក្ដៅដូចត្រូវទឹកក្ដៅ
ស្រោច អាប្រុសឆ្កួតនេះនិយាយស្ដីពីរោះៗដូចអ្នកដៃមិនបានឬ
យ៉ាងម៉េច ខំតែមានអារម្មណ៍ល្អៗបែបមនុស្សធម្មតាទូទៅហើយ
នៅមកធ្វើឲ្យខូចអារម្មណ៍ទៀត ។

ខ្ញុំលើកដៃអង្អែលថ្ពាល់ សំឡេងទូរសព្ទរោទ៍ទៀត ខ្ញុំក៏ដើរទៅ
យកមកមើល...អ៊ីនចាន់ ហ្នឹងឯង គេប្រហែលជាចុចផ្ដាច់ ហើយក៏
តេមកម្ដងទៀត ខ្ញុំក៏ឈររារែកថាទទួលឬមិនទទួល តែចុងក្រោយក៏
ចុចទទួលឲ្យទាល់តែបាន ។

( កុំខឹង បងលេងសើចទេ ទោះចង់ឲ្យអូនធ្វើមែនក៏ដោយ )

សំឡេងរបស់គេបន្លឺឡើងដំណាលគ្នានឹងសំឡេងអស់សំណើច ស្ដី
គេ សើចឲ្យដាច់ខ្យល់ស្លាប់តែម្ដងទៅអ៊ីចឹង ខ្ញុំសុខចិត្តមេម៉ាយ ។

( យល់សប្ដិល្អប្រពន្ធសម្លាញ់ បងនឹងចូលដេក ហើយយល់
សប្តិឃើញអូនដូចគ្នា មិនប៉ុន្មានថ្ងៃទៀតទេយើងនឹងបាននៅ

អាំ...ទៀតហើយ គេធ្វើបែបនេះទៀតហើយ ធ្វើឲ្យខ្ញុំខឹង
បញ្ចប់ដោយការនិយាយស្តីធ្វើឲ្យបេះដូងខ្ញុំលោតញាប់
ប្រុសម្នាក់នេះចំជាមានឥទ្ធិពលចំពោះខ្ញុំមែន ធ្វើឲ្យសម្លេង
ឡើងខ្ពស់ដោយពាក្យសម្តីមិនប៉ុន្មានម៉ាត់ ។

"យល់សប្តិល្អ"

អ៊ីនចាច់ ដាក់ទូរសព្ទចុះទៅហើយ ខ្ញុំក៏ខ្ទប់បបូរមាត់ មុននឹង យកទូរសព្ទទៅដាក់នៅតុកញ្ចក់ ហើយពេលនោះឯងដែលខ្ញុំមើល មុខត្រូវកាំង រូបភាពក្នុងកញ្ចក់គឺស្រីមុខមាត់ស្អាត ( ? ? ) ញញឹម ដូចមនុស្សឆ្កួត ហ៎ា! ខ្ញុំហ៊ាសបិទស្នាមញញឹម ហើយលើកដៃទះ ថ្ពាល់ហៅស្មារតី មុននឹងដើរចូលបន្ទប់ទឹកយ៉ាងលឿន ។

**ព្រឹកថ្ងៃបន្ទាប់**

ដោយសារតែ អ៊ីនចាច់ ទើបធ្វើឲ្យខ្ញុំត្រូវងូតទឹកហើយងូតទៀត អាប្រុសឆ្កួតនោះ ថ្នាក់ពេលចូលដេកនៅធ្វើឲ្យខ្ញុំដេកមិនលក់ ពេល ដេកលក់ហើយក៏ឃើញតែមុខរបស់គេ...គេជាបិសាច!

ខ្ញុំដើរចុះជណ្តើរ ជួបបងស្រីដែលអង្គុយមានទឹកមុខតានតឹង មើលកាសែត ពេលឃើញមុខខ្ញុំនាងក៏បត់កាសែតហើយញញឹម ។

"ម៉េចក៏ធ្វើមុខអ៊ីចឹង នឹកបងថ្លៃឬ?"

ខ្ញុំបង្អាប់ ព្រោះជាបងថ្លៃរបស់ខ្ញុំពីរថ្ងៃទៀតទើបមកដល់ ។

"អត់ទេ ឃ្លានទេ ថ្ងៃនេះមានបបរត្រី"

"ឃ្លាន តិចទៀតត្រូវទៅធ្វើជាជ្រូកត្រាំទឹកដោះគោទៀត"

ខ្ញុំប្រាប់ ហើយក៏ដើរទៅអង្គុយកៅអី ដកដង្ហើមស្រង់យកក្លិន បបរចូលសួត អឹម...ឈ្ងុយតើ!

"ហើយបានអ្នកណាមកយក?"

"ទៅជាមួយ គ្រាប់ភ្លោត ថ្ងៃនេះ ក្លាមខ្ទេ មិនទំនេរ"

"ហើយ...មួយរយៈនេះជួប អ៊ីនចាច់ ដែរទេ"

ខ្ញុំលើកចិញ្ចើម ។

"ខានជួបគ្នាបីបួនថ្ងៃហើយទេដឹង"

បងស្រីងក់ក្បាល ខ្ញុំក៏ជូសបបរដាក់មាត់ ហើយលូកដៃទៅ
យកកាសែតមកមើល តែបងស្រីបែរជាដកចេញ ហើយវាយដៃខ្ញុំ
ទៀតផង ។

"អ្នកណាគេអានបណ្តើរញ៉ាំបណ្តើរទៅ គ្មានមារយាទ"

អេ៎...ចុះអម្បាញ់មិញអ្នកណាគេអានបណ្តើរញ៉ាំបណ្តើរ ?

ខ្ញុំធ្វើភ្លេកឡេមឡាម និងជូសបបរដាក់មាត់ញាប់ដៃស្អេក ។

"ស្រីៗ មានអីឲ្យម៉ាក់ញ៉ាំខ្លះ"

សំឡេងរបស់ម៉ាក់បន្លឺឡើង ស្របពេលដែលគាត់ដើរចូលម
ក្នុងបន្ទប់ មុខក្មេងជាងវ័យមើលអាហារពេលព្រឹកហើយញញឹម "

"ល្អដល់ហើយ ចង់ញ៉ាំបបរល្មម ផ្កាឈូក ធ្វើឆ្ងាញ់"

"ចាំខ្ញុំជូសឲ្យ"

ម៉ាក់ខ្ញុំញញឹមញញែម ហើយងាកមកមើលខ្ញុំដែលថែមបប
មួយចានទៀត មុននឹងធ្វើមុខភ្ញាក់ផ្អើលនិងលូកដៃមកវាយស្មាខ្ញុំ

"ខ្ញុំឈឺម៉ាក់" ខ្ញុំតវ៉ា ។

"ថែមធ្វើអី ញ៉ាំច្រើនដុះក្បាលពោះ ពាក់ឈុតមិនស្អាត ចា
ហើយ"

មិនយុត្តិធម៌ទេ ខ្ញុំគួរតែញ៉ាំឲ្យឆ្អែត!

បងស្រីហុចចានបបរឲ្យម៉ាក់ ពេលនោះឯងដែលខ្ញុំហ៊ាសលូ
ដៃទៅទាញយកកាសែតមកមើល ក្នុងពេលដែលមិនឲ្យញ៉ាំ អ៊ីចឹ
អានកាសែតក៏មិនខុសមារយាទអីដែរ តែបងស្រីបែរជាដណ្តើមយក
ដោយទឹកមុខភ្ញាក់ផ្អើល ។

"បងស្រី"

"អី...ញ៉ាំទៀតទៅ ចាំថែមបបរឲ្យ"

បងស្រីប្រាប់ មុននឹងទាញកាសែតទៅកាន់ មិនប្រុង...

ភព្បាស់ជាមានស្អីមិនខាន មើលទៅបងស្រីដូចហួងហែង...

ខុសពីធម្មតា ។ ដោយសារការសង្ស័យ បុក្រុមនឹងការចង់ដឹង...

ខ្ញុំងក់ក្បាល ហើយហុចចានទៅឲ្យ បងស្រីក៏ដូសបបរដាក់...ខ្ញុំ

ខ្ញុំអាស្រ័យពេលនោះទាញកាសែតពីដៃនាងបានសម្រេច ។

"ស្អីកតើយ កុំមើល"

ម៉េចក៏ហាមមិនឲ្យអាន...ភមាន...

ខ្ញុំនៅស្ងៀម សម្លឹងមើលរូបក្នុងប្រអប់តូចមួយនៅក្នុង...

កាសែតយ៉ិតៗ រូបតារាស្រីកូនកាត់ជប៉ុនម្នាក់ដែលធ្លាប់ឃើញ...

ក្នុងរឿងភាគ ជាគូបន្ទាប់បន្សំ ហើយនិង...អ៊ីនថាច់ ។

ពួកគេនៅកន្លែងហាត់ប្រាណ ខាងស្រីពាក់អាវដៃវៀលបន្តូច

ដើមទ្រូងប្រាណអាវ ចំណែកខាងប្រុសក៏ឱបចង្កេះនាង ។

*ក្រែងតាជិតរៀបការហើយ...ចុះហេតុអីក៏លោះសាច់ក្រុម*

*ល័ អ៊ីនថាច់ មកផ្ដួមផ្ដែមជាមួយនឹង ណាអូមិ ទៅកើត?*

*ចង់ដឹងដល់ហើយតាកូនក្រមុំរស់ទៅណា ដឹងឬអត់តាកូន*

*កំលោះផ្ដេសផ្ដាស ?*

*ឬតាពិធីមង្គលការគ្រាន់តែជាពាក្យចចាមអារ៉ាម...*

"..."

ខ្ញុំបត់កាសែត បន្ទាប់ពីមើលព័ត៌មាននៅក្រោមរូបនោះរួច ។

"វាគ្រាន់តែជាព័ត៌មានទេ ស្អីកតើយ កុំគិតច្រើន" បងស្រី

ប្រាប់ខ្ញុំ ។

"ព័ត៌មានអី ឯណា ម៉ាក់មើលបន្តិចមើល៍" ...

យកអាន មុននឹងឧទាន "អា៎!"

"ខ្ញុំទៅហើយ ខ្លាច គ្រាប់ឆ្លោត ចាំយូរ" ខ្ញុំប្រាប់ ហើយក៏ងើប

ដើរចេញទៅ ។

"ស្អីកតើយ...អូខេណាំ" បងស្រីនៅតែជាអ្នក ។

អូខេទេ...គឺអូខេ បើមិនរាប់អារម្មណ៍ខ្មោចៗពេលដែលឃើញ

រូបរបស់ អ៊ីនថាច់ និងស្រីផ្សេង និងអារម្មណ៍ឈឺចៀបៗដែលប្រាប់

មិនស្រួល ។

[Intouch`s Talk]

"មានការអី ?"

ខ្ញុំសួរ ព្រមទាំងងាកខ្លួនដោយការមួម៉ៅ ការត្រូវដាស់ឲ្យភ្ញាក់

នៅថ្ងៃដែលត្រូវការដេកចំតិត គឺជារឿងគួរឲ្យមួម៉ៅ ។

( ល័ អ៊ីនថាច់ មើលកាសែត...ហើយនៅ? )

សំឡេងរបស់ គីតេ បន្លឺឡើង ធ្វើឲ្យខ្ញុំជ្រួញចិញ្ចើម សំឡេង

របស់វាស្ដាប់ទៅដូចកំពុងអន្ទះអន្ទែង ធ្វើឲ្យខ្ញុំសង្ស័យ ។

"នៅ...នៅលើគ្រែនៅឡើយ មានរឿងអី ?"

( ឯងទៅមើលកាសែតឆ្លាម ព័ត៌មានរូបតូចៗនៅខាងក្រោម

បំផុត )

ព័ត៌មានអី បើមិនសំខាន់នឹងទៅទាត់វាដល់កន្លែងមិនខាន ។

"គ្មានកាសែត" ខ្ញុំប្រាប់ដោយសំឡេងរឹង ។

( ចង្រៃយក៍...ចាំមួយភ្លែត ចាំផ្ញើរូបទៅឲ្យមើល រឿងធំហើយ )

ច្បាស់ជារឿងធំមិនខាន គីតេ! បើសិនមិនមែនជារឿងមាន

ប្រយោជន៍ ឯងហ្នឹងហើយមានរឿងធំ!

ខ្ញុំលើកដៃច្រងសក់ដោយការមួម៉ៅ កាលពីយប់បន្ទាប់ពី

នាងយល់សប្តិឃើញខ្ញុំ បែរជាខ្ញុំដែលយល់សប្តិឃើញនាងទៅវិញ មួយយប់ យល់សប្តិបែប...ចង់ឲ្យវាក្លាយជាការពិតដល់ហើយ ធ្វើឲ្យខ្ញុំងាកភ្ញាក់ៗ ព្រមទាំងមានអារម្មណ៍ក្តៅពេញខ្លួន ស្រក់ទឹកហៅស្មារតីពន្លត់អារម្មណ៍ ដល់ថ្នាក់ភ្នែកបើកភ្លឺះរហូតដល់ព្រឹក ទម្រាំតែដេកលក់គឺដេកបានតែពីម៉ោងហ្នឹងឯង ។

ទីង!

សំឡេងសាររូបភាពក្នុងឡាញបន្លឺឡើង ខ្ញុំក៏ស្ទាយដៃយកទូរស័ព្ទ ហើយងើបអង្គុយលើគ្រែ មុននឹងស្រែកឧទាន ។

"រឿងធំមែន!"

ខ្ញុំនិយាយដាក់ទូរសព្ទ ធ្វើឲ្យអ្នកតេមកសើចទាំងជួចត់ ។

(អឺម រឿងធំ)

"គឺដោយសារតែឯងហ្នឹងហើយ អា..."

ខ្ញុំជេរព្រាវៗ ប្រាប់ថាពេលនេះខឹងខ្លាំងណាស់ ណារុមិ និងខ្ញុំក្នុងរូបនោះ មើលយ៉ាងណាក៏ដូចឱបគ្នាច្បាស់ណាស់ ក្នុងសភាពសាច់ប៉ះសាច់ នៅកន្លែងហាត់ប្រាណដូចគូស្នេហ៍ ។

បើកាលពីមុន ខ្ញុំមិនខ្វល់មិនចាប់អារម្មណ៍អាព័ត៌មានល្បីល្បាញគ្មានបានការបែបនេះទេ តែនេះ...

ស្លឹកតើយ!

ខ្ញុំគិតដល់ឈ្មោះរបស់នាងមុនគេ ស្លឹកតើយ ឃើញហើយនៅ?

(អឺម...មែន)

គឺតេ ព្រមទទួល ព្រោះតែជួយវាទើបខ្ញុំជួបនឹងស្រី អារ៉ូហ្គិ ស្លឹកតេនោះ នាងឈ្មោះស្លឹ...ស្លើយ តាមតែនាងទៅ ពេលនេះមនុស្សតែម្នាក់គត់ដែលខ្ញុំចាប់អារម្មណ៍គឺស្រីភ្នែកធំៗ ប្រមុះខើច ។

(ខ្ញុំភ្លេចប្រាប់ទៅថា ណារុមិ ជាមនុស្សមានចរិតបែបណា



មនុស្សជាច្រើនដែលធ្លាប់សេពគប់នាងប្រាប់ តែមិនស្មានថាវាថ្នាក់ធំធ្លាក់ទៅលើឯង ស្រីម្នាក់នោះជាតារាNo name ដែលប្រមាញ់[illegible] ហៅស្ទួដើម្បីទាញប្រានខ្លួនឯងឲ្យល្បី នាងគួរឲ្យខ្លាចខ្លាំងណាស់ ដៃ[illegible] ស្លឹកជាងគុកកែ និងពូកែរឿងប្រើអ្នកកាសែតបំផុត)

"..."

មែន! ពីម្សិលនៅកន្លែងហាត់ប្រាណ សុខៗក៏ផុសក្បាលចេញមក ថែមទាំងជ្រមិលជួលមករកខ្ញុំទៀតផង ខ្ញុំចង់ញញួរចេញតែមិនទាន់...

ខ្ញុំខាំធ្មេញក្រិតៗដោយកំហឹង ផែនការឆ្កួតៗដែលធ្វើឲ្យខ្ញុំមានបញ្ហាជាមួយនឹង ស្លឹកតើយ ។

ទីត!

ទូរសព្ទរោទ៍ ធ្វើឲ្យខ្ញុំមើលអេក្រង់...ម៉ាក់តេមក ។

"គឺតេ ពេលនេះម៉ាក់ខ្ញុំតេម៉ោ"

(រឿងកាន់តែធំហើយ ចង់ឲ្យខ្ញុំជួយអធិប្បាយទេថាឯងគ្មានស្អីជាមួយស្រីម្នាក់នោះ?)

"មិនបាច់" ខ្ញុំប្រាប់ ហើយក៏ចុចផ្តាច់ទូរសព្ទរបស់វា មុននឹងចុចទទួលទូរសព្ទរបស់ម៉ាក់ ។

"ម៉ាក់"

(អឺនថាច់! នៅឯណា?) សំឡេងរបស់ម៉ាក់ឮខ្លាំង ដល់ថ្នាក់ខ្ញុំត្រូវទាញទូរសព្ទចេញពីត្រចៀក ។

ប្រាកដណាស់ថាគាត់ច្បាស់ជាមើលព័ត៌មាននោះហើយ ។

"នៅខុនដូ ម៉ាក់"

(មើលព័ត៌មានហើយនៅអាជើងល្អ) កំហឹងកំពុងតែឆ្លាស់ប្តូរអ្នកស្រី ធីហ្សានិ ឲ្យក្លាយជាបិសាច ។

"បាទ"

(អី! តារាមុខស្លេកនោះជាអ្នកណា ដៃគូឯងឬអត់ ប្រាប់ខ្ញុំ
ជាបញ្ឈប់គ្រប់យ៉ាងត្រឹម ស្លឹកតើយ សុំឲ្យម៉ាក់...)

"ម៉ាក់" ខ្ញុំរហ័សហៅ មុនពេលដែលគាត់ខឹងខ្លាំងជាងនេះ
សំឡេងពុខ្លាំងៗនោះធ្វើឲ្យដឹងថាគាត់ខឹងមែនទែន "ខ្ញុំគ្មានស្រី
ជាមួយស្រីម្នាក់នោះទេ"

អ្នកចុងខ្សែនៅស្ងៀមមួយដង្ហើម មុននឹងសួរ៖

(ច្បាស់ហើយ?)

"ខ្ញុំធ្លាប់កុហកម៉ាក់ទេ"

គាត់ដកដង្ហើមធំ សំឡេងកាចរបស់គាត់ត្រូវបានកាត់បន្ថយ
តែក៏នៅតែកាចដដែលហ្នឹង ។

(ម៉ាក់ដឹងថាឯងមិនកុហក ឯងជាមនុស្សបែបណា តែនិងទ
ច្រើរនេះ ឈើរី និង ស្លឹកតើយ ឃើញព័ត៌មាននេះហើយនៅ មើល
ចុះ ដាក់ចំណងជើងឡប់ៗខ្លាំងណាស់)

នេះបើមិនដោយសារកំពុងតែមួម៉ៅនឹងព័ត៌មានចង្រៃយក៏នេះ
ដូចគ្នា ខ្ញុំប្រហែលជាអស់សំណើចទៅហើយ ដែលមនុស្សស្រីវ័យ
កណ្ដាលមុខមាត់ក្មេងជាងវ័យនិយាយបែបនេះ ។

"ខ្ញុំនឹងតេទៅ ស្លឹកតើយ"

(ម៉ាក់តេទៅហើយ នាងបិទទូរសព្ទ តេរក ឈើរី ក៏គិតបានថា
ត្រូវសួរឯងសិន ទើបហ៊ាននិយាយពេញមាត់ពេញសម្ដីថាព័ត៌មាន
នេះកុហក)

បិទទូរសព្ទអីចឹងឬ?

(ប្ដឹងពេងពុម្ពល្អទេ?)

"កុំអីម៉ាក់"

(តែបើ ស្លឹកតើយ ខឹង ហើយនាងមិន...
នោះ...)

"បញ្ជូនមនុស្សទៅដុតចោលល្អជាង លឿនជាង មិនចាំបាច់
រវល់ឡើងតុលាការ" ខ្ញុំប្រាប់ដោយសំឡេងរាបស្មើ ។

(នៅមានអារម្មណ៍លេងសើចទៀត)

មិនបានលេងសើច...តែណ្ដើយចុះ ពាក្យថាមិនព្រមរៀបការ
របស់ម៉ាក់ធ្វើឲ្យខ្ញុំស្រួល ទោះបុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា
ហើយក៏ដោយ តែ...គ្រប់យ៉ាងដែលពាក់ព័ន្ធនឹង ស្លឹកតើយ វាខ្លាំង
ខ្លាត់មិនបាន នាងប្រមក់នោះច្បាស់ជាហ៊ានប្ដឹងលែងលះខ្ញុំមិន
ខាន ។

"ខ្ញុំនឹងទៅរកនាង"

(ដឹងឬថានាងនៅឯណា?)

"ទោះមិនបានជួបគ្នា តែខ្ញុំដឹងរហូតថានាងនៅឯណា និងធ្វើអី
ខ្លះ"

មែន...ទោះប៉ុន្មានថ្ងៃនេះមិនបានជួបគ្នា តែខ្ញុំដឹងពីសកម្មភាព
របស់នាងទាំងអស់ ។

(ក៏ល្អ ហើយរឿងតារាចាត់ការឲ្យចរាល់ផង ម៉ាក់មិនចូល
ចិត្ត)

ម៉ាក់ដាក់ទូរសព្ទចុះទៅហើយ ខ្ញុំដកដង្ហើមធំនិងមើលរូបភាព
លើអេក្រង់ដដែល គឺតេ ផ្ញើមកឲ្យ ច្បាស់ជាចាត់ការមិនខាន...មិន
បណ្ដោយឲ្យឡូយឆាយនោះទេ តែពេលនេះអ្វីដែលសំខាន់បំផុតគឺ
ស្លឹកតើយ!

នាងគួរតែនៅទីនោះ...

ខ្ញុំដើរចូលទៅក្នុងហាងកែសម្ផស្សល្បីឈ្មោះ ហើយក៏មាន
...ព្រួសក្លិនក្រអូបនៃផ្កាឈូកដើរមកស្វាគមន៍ ។

"សុស្ដី ស្លឹកតើយ កូនក្រមុំរបស់ខ្ញុំនៅទីនេះមែនទេ?"

"សូមចាំមួយភ្លែត"

ទីនេះជាកន្លែងដែលម៉ាក់ខ្ញុំមកជាប្រចាំ ហើយ ស្លឹកតើយ ក៏ត្រូវមកចូលវគ្គនៅទីនេះដែរ ។ បុគ្គលិកស្រីម្នាក់ដើរចូលទៅខាងក្នុងដើម្បីឆែកកុំព្យូទ័រ ហើយក៏ដើរចេញមកវិញ ។

"អ្នកនាង ស្លឹកតើយ មិនទាន់ចូលមកទេ"

"..."

មិនទាន់ចូលមក តែពេលដែលគេទៅផ្ទះរបស់នាង បងស្រីនាងប្រាប់ថានាងចេញមកហើយតើ?

"អរគុណ"

"ចាំ"

ខ្ញុំដើរចេញទៅក្រៅ ហើយទាញទូរសព្ទតេទៅលេខដែលចាំបាននៅក្នុងចិត្តម្ដងទៀត ។

បិទទូរសព្ទ...

"នៅឯណា ស្លឹកតើយ"

ខ្ញុំកាន់តែបារម្ភមែនទែនហើយ ស្រីតូចរបស់ខ្ញុំទៅនៅឯណា?

[End Intouch's Talk]

# ១០

# ការដាក់ទោសដ៏ក្ដៅគគុក

ខ្ញុំដើរចូលហាងទំនិញនោះដោយជំហានលឿនជាងរាល់ដង ព្រោះថាបើកឡានទៅយក គ្រាប់ត្នោត ហើយក៏ឃើញថាមិត្តភក្តិផ្ដាសាយ ទើបខ្ញុំនាំទៅរកពេទ្យ ហើយក៏ជូនទៅផ្ទះវិញ បន្ទាប់មកក៏បើកឡានមកហាងទំនិញដ៏ប្រណីត ដើម្បីចូលវគ្គងូតទឹកដោះគោ ទើបធ្វើឲ្យយឺតយ៉ាវជាងការណាត់ដល់ទៅពីរម៉ោង ។

ពេលដែលដើរឡើងជណ្ដើរយន្តជើង សំណាងដែលភ្នែករៀស មើលឃើញប្រុសរាងខ្ពស់ស្រឡះដែលឈរនៅមុខស្ថាប័ននោះច្បាស់...គេប្រហែលមកស្ទាក់ចាំខ្ញុំ ។

"..."

ខ្ញុំខាំបបូរមាត់ដោយការមួម៉ៅ មិនដឹងថាហេតុអី ប៉ុន្តែដឹងខ្លួនម្ដងទៀតក៏ម្នីម្នាដើររាងជណ្ដើរយន្តជើងចុះទៅវិញ ។ ខ្ញុំមិនចង់ជួបគេ តាមពិតព័ត៌មានកាលពីព្រឹកធ្វើឲ្យខ្ញុំចង់ឡូឡា ចង់តែទៅលុបចោលមង្គលការ តែធ្វើមិនបាន គឺយើងមិនបានរៀបការជាមួយគ្នាព្រោះក្ដីស្រឡាញ់ហ្នឹងណា៎ យើងរៀបការព្រោះបំណុលទៅវិញទេ ហើយកូនបំណុលដូចខ្ញុំ មានសិទ្ធិសុំលុបចោលមង្គការបានដោយរបៀបណាទៅ ។

ខ្ញុំដើរទៅចំណតឡាន ហើយក៏ចុចបើកសោដែលជាសោស្វ័យប្រវត្ត ។

"ស្លឹកតើយ"

សំឡេងរបស់គេ មិនចាំបាច់ងាកទៅមើលក៏ខ្ញុំចាំបាន ។

www.srolanhkhmer.com

ប៉ុន្តែពេលនេះវាខុសគ្នា វាលោតញាប់និង...ឈឺទ្រូង ខ្ញុំ
អារម្មណ៍ដូចកាលមុន ។

ខ្ញុំដើរកាន់តែលឿន ឡានទៅត្រឹមឈោងដៃដល់ប៉ុណ្ណោះ ។

"ស្អីកតើយ"

លែងទាន់ហើយ...ខ្ញុំងាកទៅតាមកម្លាំងទាញរបស់អ្នកដែល
មកស្រវាចាប់ដៃខ្ញុំមុនពេលឡើងឡាន ។

គេនៅចំពោះមុខ ហើយនៅតែសង្ហានិងកាចដូចដើម ភ្នែក
របស់គេមើលមកខ្ញុំមិនដាក់ ។

"គេចពីបងធ្វើអី"

មានន័យថាគេឃើញតាំងពីនៅខាងក្នុងម្លេះ អីចឹងហើយបាន
ជាតាមមកទាន់ ។

"មិនបានគេច"

ខ្ញុំកុហក កាលមុនខ្ញុំស្អប់មនុស្សកុហកបំផុត តែចាប់តាំងពី
នៅជិតគេ ខ្ញុំបែរជាត្រូវកុហកដោយខ្លួនឯង ។

"បងឃើញអូនរត់ចុះមក ម៉េចក៏មិនចូលទៅ ហើយម៉េចក៏មក
យឺត បាត់ទៅណា?"

ដេញដោលធ្វើអី?

"ជារឿងរបស់ខ្ញុំ ខ្ញុំគ្រាន់តែមិនចង់ចូលទៅប៉ុណ្ណោះ"

"..."

"លែង ខ្ញុំទៅផ្ទះ"

ខ្ញុំរលាស់ដៃ តែបែរជាត្រូវគេដណ្ដើមយកកូនសោឡានធ្វើ
ព្រងើយ ហើយប្រាប់ ៖

"ឡើងឡាន បងមានរឿងចង់និយាយជាមួយ"

"តែខ្ញុំ..."

"ឡើងឡាន"

ខ្ញុំខ្ទឹបបបូរមាត់ មិនពេញចិត្ត តែក៏មិនចង់ខាតពេលប្រកែក
ប្រណាំងជាមួយគេ ។

សន្តិសុខហាងដើរមកមើល ដូចគិតថាយើងទាំងពីរឈ្លោះគ្នា
ធ្វើឲ្យខ្ញុំញញឹមដាក់ជាការប្រាប់ថាគ្មានរឿងអីទេ ហើយក៏មើលមុខ
ប្រុសមេផ្ដាច់ការ គេនៅតែដូចពីដំបូង ពិបាកលខ្ញុំមិនគួរណាលង់ទន់
ចិត្តទៅលើគេ ។

"ចុះឡានរបស់បង"

"តាមតែវាទៅ ចាំឲ្យគេបើកយកទៅឲ្យ"

"អ៎...អ្នកមានហ្នឹងណាំ សូមទោស ភ្លេច"

ចិញ្ចើមក្រាស់របស់ អ៊ីនជាច់ ជ្រួញជាប់គ្នា ភ្នែកមុតស្រួច
របស់គេក៏មើលមកខ្ញុំដោយការមិនពេញចិត្តតិចតួចដែលត្រូវខ្ញុំ
ដៀមដាម ។ តែអ្នកណាចាប់អារម្មណ៍ទៅ ត្រង់គេមិនយកចិត្ត
ទុកដាក់ទេថាខ្ញុំមានអារម្មណ៍បែបណាខ្លះពេលដែលត្រូវបង្ខាប់ ឬ
ឃើញព័ត៌មាននោះ...ខ្ញុំ...មួម៉ៅធ្វើអីដល់ថ្នាក់នេះ ។

"ឡើងឡាន យើងមានរឿងត្រូវនិយាយគ្នាច្រើនទៀត"

ខ្ញុំខ្ទឹបបបូរមាត់ ហើយក៏ចូលមកអង្គុយក្បែរអ្នកបើក ចង់បិទ
ទ្វារឲ្យខ្លាំងៗ តែទាស់ត្រង់ថាវាជាឡានរបស់ខ្លួនឯង ។

អ៊ីនជាច់ ក៏ចូលមកអង្គុយខាងអ្នកបើក ហើយយើងទាំងពីរក៏
ចេញពីចំណតឡាននោះ ។

"អូនខឹងបងឬអត់?" គេសួរ ។

"មិនខឹង"

"ច្បាស់ហើយ? អូនឃើញព័ត៌មាននោះហើយមែនទេ?"

"..." ខ្ញុំនៅស្ងៀមមិនតប ។

"បងមិនបាន..."

"ខ្ញុំមិនខ្វល់ទេថាវាយ៉ាងម៉េច បងចង់មានស្នេហ៍ជាមួយស្រីណាឬ

អត់ យ៉ាងណាក៏ខ្ញុំរៀបការដោះបំណុលស្រាប់ទៅហើយ មិនបាន
រៀបការព្រោះស្រឡាញ់បង ដូច្នេះហើយខ្ញុំមិនឃៃរ៍"

ខ្ញុំស្អប់ខ្លួនឯងខ្លាំងណាស់ដែលនិយាយបែបនេះ ទាំងដែល
ដឹងថាខ្លួនឯងមានអារម្មណ៍ខុសពីនោះ ។

ខ្ញុំស្អប់ អ៊ីនថាច់ ដែរ ព្រោះថាគេធ្វើឲ្យខ្ញុំក្លាយជាមនុស្សកុំ
កុហក ខ្ញុំស្អប់គេដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ដូចមនុស្សល្ងីល្ងើគ្មាន
ហេតុផលបែបនេះ ។

"..." អ៊ីនថាច់ មិនតប គេក្ដាប់ដៃដែលចាប់ចង្កូតឡានណែន
"មិនឃៃរ៍...ហ៊ឹម ?"

"មែន មិនឃៃរ៍ ខ្ញុំរៀបការដោះបំណុល មិនបានស្រឡាញ់បង
ទៅមានបញ្ហាធ្វើស្អីបើបងមានអ្នកផ្សេង"

"យុត្តិធម៌"

សំឡេងរបស់គេត្រជាក់ ប៉ុន្តែខ្ញុំនៅតែមិនខ្វល់ ទាំងដែលតាម
ពិតទៅចង់ស្រែកប្រាប់ថាខ្ញុំឃៃរ៍ខ្លាំងណាស់ ហើយក៏ខឹងណាស់
ដែរដែលឃើញព័ត៌មានបែបនោះ ។

បើគេមានតារាមុខស្រស់នោះទៅហើយ មករញ៉េរញ៉ៃនឹងខ្ញុំធ្វើ
អីទៀត ។

"ចង់ទៅណា ?" ខ្ញុំសួរ ពេលឃើញថាគេបត់ឡានចេញពីផ្លូវធំ
សំដៅទៅជាយក្រុង ។

"..." អ៊ីនថាច់ មិនតប ទើបខ្ញុំបានតែដកដង្ហើមចូលឲ្យជ្រៅ
ស្ងប់ស្ងាត់ក៏ល្អ ខ្ញុំក៏មិនចង់និយាយរកគេដែរ និងមិនចង់ឮសំឡេង
របស់គេដូចគ្នា ហ្គឹង...ប៉ុន្តែ...

"បត់ចូលទីនេះធ្វើស្អី ?"

ខ្ញុំងាកទៅសួរគេម្ដងទៀតដោយការភ្ញាក់ផ្អើល

របស់យើងបត់ចូលសណ្ឋាគារ មិន...

ដែលយើងយកធ្វើជាកន្លែងរៀបការនៅមិនប៉ុន្មានថ្ងៃខាងមុខ តែជា
សណ្ឋាគារដែលគេហៅថាភ័ងននរូត ។

"..."

គេមិនឆ្លើយ មិនងាកមករក គិតតែបើកចូលបន្ទប់ដែលមា...
ភ័ងននពណ៌ខ្មៅបើកចាំ ហើយពេលដែលឡានចូលផុត ភ័ងនន...
ត្រូវគេបិទ ។

"អ៊ីនថាច់" ខ្ញុំហៅគេដោយការភ្ញាក់ផ្អើល ។

អ៊ីនថាច់ ចុចកញ្ចក់ចុះ ហើយហុចលុយឲ្យអ្នកដែលរត់មករ...
មុខនឹងរត់ចេញទៅវិញយ៉ាងលឿន ។

"ឈប់សិន ឈប់!"

ខ្ញុំហើសហៅបុគ្គលិកសណ្ឋាគារនោះ តែ អ៊ីនថាច់ មិនបា...
និយាយអី គេចុះពីឡានហើយដើរមកបើកទ្វារឲ្យខ្ញុំ ។

"ចុះម៉ោ"

"មិនចុះ"

"ឬចង់នៅក្នុងនោះ ចង់ឲ្យធ្វើនៅក្នុងឡានក៏បាន"

"!!!"

ខ្ញុំមើលមុខស្វាមីស្របច្បាប់ដោយការភ្ញាក់ផ្អើល គេនិយាយ
ស្អីបែបនេះ ? អ៊ីនថាច់ មានទឹកមុខសោះកព្រោះ គេកើតឆ្កួតស្អីទៅ
ហើយ ?

"នាំខ្ញុំមកទីនេះធ្វើអី ?"

"អូនចុះមកតាមសម្រួលទេ ឬចង់ឲ្យបងបី ?"

ជំនួសការឆ្លើយ គេបែរជាឲ្យកសួរទៅវិញ ។

"ខ្ញុំនឹងស្រែកឲ្យគេជួយ"

"ខ្ញុំនឹងស្រែកឲ្យគេជួយ" ... តែក៏ត្រូវត្រជាក់ខ្លួនពេលបានឮសំឡេងសើចរបស់...

"ភ្លេចអីបាត់ បងជាប្ដីអូន អ្នកណាគេមកជួយប្រពន្ធដែលខ្លួន ចង់ដេកជាមួយទៅ ហ៊ឹម?"

ខ្ញុំបើកភ្នែកធំៗមើលគេ ។

អ៊ីនជាច់ ចូលមកស្រវាទាញខ្ញុំចុះពីឡាន ខ្ញុំប្រុងហាមាត់ ស្រែក តែដៃរបស់គេក៏សង្គ្រុបបិទមាត់ខ្ញុំ មុននឹងបីចុះពីឡាន ។

ខ្ញុំរើបម្រះតែមិនបានផល ព្រោះ អ៊ីនជាច់ នាំខ្ញុំចូលបន្ទប់បាន សម្រេច ។ ខ្ញុំចង់រត់គេ តែគេលឿនខ្លាំងណាស់ ដៃរបស់គេរឹតចង្កេះ របស់ខ្ញុំ ហើយគ្រវែងឲ្យទៅដេកលើគ្រែមូល ហើយនៅជុំវិញបន្ទប់ មានសុទ្ធតែកញ្ចក់ ។

"អ៊ីនជាច់...កុំធ្វើបែបនេះ"

"យ៉ាងម៉េច?" បបូរមាត់ស្អាតរបស់គេមានស្នាមញញឹម ជា ស្នាមញញឹមដែលមិនដូចរាល់ដង ។

អ៊ីនជាច់ ប្រឡេះឡេវអាវខ្លួនឯង ហើយក៏ឡើងមកលើគ្រែ ធ្វើ ឲ្យខ្ញុំថយគេច ។

នេះអាចមិនមែនជាលើកដំបូងដែលគេដាក់សម្ពាធបែបនេះ ឬយកប្រៀបខ្ញុំ តែហេតុអី...ខ្ញុំមានអារម្មណ៍ថាលើកនេះវាមិន បញ្ចប់ដូចរាល់ដង គេនឹងមិនបញ្ឈប់កណ្ដាលទីនោះទេ ។

"យើងជិតរៀបការហើយ ចាំ...ចាំរៀបការសិន"

"តែអូនជាប្រពន្ធបងហើយ យើងចុះសំបុត្ររួចហើយ អូនធ្វើឲ្យ នាទីមុនក៏បានទេដឹង"

"ខ្ញុំ...ខ្ញុំមិនទាន់ត្រៀមខ្លួន"

"ត្រៀមធ្វើស្អី មាត់ក៏ប្រកាសហើយតើ អម្បាញ់មិញថារៀបការ ដោះបំណុល មិនបានរៀបការព្រោះអ្វីផ្សេង ពេលនេះធ្វើតួនាទីទៅ ...បងទារបំណុលហើយ" អ៊ីជាន់ ប្រាប់ដោយសំឡេងត្រជាក់ គេ ញញឹម...ជាស្នាមញញឹមចំអក តែភ្នែករបស់គេម៉េច...

ព្រឺឈើញចំណើ ធ្វើឲ្យខ្ញុំត្រជាក់ខ្លួនអស់ ។

"ក្នុងពេលដែលវាមិនបានកើតឡើងដោយក្ដីស្រឡាញ់ បើ ខ្លាំងក្លា វាឈឺចាប់ក្រៅបន្តិច កុំស្រែកឲ្យសោះ!"

"អាំ!"

ខ្ញុំស្រែកខ្លាំងៗពេលដែលគេហក់មករក ។

ខ្ញុំស្រែកខ្លាំងៗពេលដែលគេហក់មករក ខ្ញុំក្រឡាស់ខ្លួនគេចពី អ៊ីនជាច់ ថ្ងៃនេះគួរឲ្យខ្លាចខ្លាំងណាស់ ខ្ញុំក្រឡាស់ខ្លួនគេចពី ការលោតសង្គ្រុប ហើយប្រវេប្រវាចុះពីគ្រែនៅជ្រុងម្ខាងទៀតឲ្យបាន ប៉ុន្តែក៏ត្រូវគេចាប់កជើងជាប់ ហើយអូសត្រឹមតែម្ដងប៉ុណ្ណោះ ខ្ញុំក៏ ទៅនៅក្រោមរាងកាយរបស់គេបានយ៉ាងងាយ ។

បើជាពេលវេលាផ្សេង ខ្ញុំប្រហែលជាមានមោទនភាពចំពោះ រាងរៅចង្កេះមួយក្ដាប់តូចរបស់ខ្លួនឯង តែពេលនេះខ្ញុំបែរជាចង់ឲ្យ ខ្លួនឯងមានមាឌធំ និងមានទម្ងន់ធ្ងន់ជាងនេះ១០០ដង ។

"កុំ!"

ខ្ញុំហាម ទឹកភ្នែកទឹកសម្បោរក៏ហូរសស្រាក់ពេលត្រូវ អ៊ីនជាច់ ចាប់កដៃសង្កត់នឹងក្បាលគ្រែ ។ គេវាយលុកខ្លាំងជាងរាល់ដង និង មើលទៅប្រាកដប្រជាជាងរាល់ដងដែរ មិនថាគេចទៅខាងណាក៏ ច្រមុះនិងមាត់របស់គេតាមមកត្រដុសទាល់តែស្បែករបស់ខ្ញុំឡើង ។

ខ្ទាប់!

"អ៊ីនជាច់ កុំ!"

ខ្ញុំស្រែកហាមពេលដែលគេហែកសម្លៀកបំពាក់របស់ខ្ញុំ ។

"កុំស្អី កុំឃើញយ៉ាងម្ដេចកុំឈប់?" សំឡេងរបស់គេឮរំខាន

"កុំស្អី កុំឃើតយ៉ាវមួយតាកុំឈប់?" ពេលដែលអូសបបូរមាត់មករករបស់ខ្ញុំ ។

អត់...អត់ទេ ខ្ញុំមិនត្រូវការបែបនេះ ។

"កុំ មិនអីចឹងខ្ញុំនឹងឈប់បងមួយជីវិត"

...របស់គេទប់ដក់ ដៃដែលកំពុងទាញសម្លៀកបំពាក់

របស់ខ្ញុំក៏នៅស្ងៀម ធ្វើឲ្យខ្ញុំសប្បាយចិត្តភ្លាម និងដកដង្ហើម...
ពេលគិតថាគេបញ្ឈប់ទៅហើយ ប៉ុន្តែ...

"អឹនចាច់" ខ្ញុំស្រែកពេលដែលគេឱនមុខមករក ស្រែកខ្ញុំ...
មកត្រង់ប្រឡោះជើងរបស់ខ្ញុំដែលព្យាយាមបិទបង្រុះ ។

ហឿក!

ខ្ញុំភ្ញាក់ព្រើត ពេលដឹងថាមានអ្វីម្យ៉ាងដែលរឹងនិងធំបៀតនឹង...
ពោះ ។

"ស្លឹកតើយ"

គេហៅខ្ញុំ មុននឹងងើយមុខមើល ភ្នែករបស់គេមើល...មិនដឹង...
ទេ ខ្ញុំមិនដឹង...គេថើប ហើយពេលដែលខ្ញុំព្យាយាមងាកមុខចេញ
គេក៏សង្កត់បបូរមាត់កាន់តែខ្លាំងធ្វើឲ្យឈឺ ។

មាត់របស់គេក្តៅ និងបឺតជញ្ជក់ខ្លាំងៗ អណ្តាតក៏ព្យាយាម
ជ្រែកចូលមកក្នុងប្រអប់មាត់របស់ខ្ញុំ តែខ្ញុំមិនព្រម ។

សំឡេងសើចរបស់គេបន្លឺឡើងនៅដើម.ក មុននឹងគេព្រម
ឈប់ព្រមចាញ់ មនុស្សដូច អឹនចាច់ ព្រមសុខចិត្តចាញ់ដែរឬ?

"អ្ហឹម! កុំ"

ខ្ញុំភ្ញាក់ព្រើត ពេលដឹងថាគេមិនបានព្រមចាញ់ គេគ្រាន់តែប្តូរ
មកថើបដើមទ្រូងរបស់ខ្ញុំ ដែលពេលនេះសម្លៀកបំពាក់ភាររហែក
អស់ទៅហើយ ធ្វើឲ្យដើមទ្រូងរបស់ខ្ញុំបង្ហាញខ្លួនឲ្យគេធ្វើបាបបាន
ពេញទំហឹង ។

ដៃរបស់គេច្របាច់ភដល់ថ្នាក់ធ្វើឲ្យខ្ញុំឈឺ មាត់គេក៏...

អឹម វា...ឈឺ តែភាពស្រៀវស្រើបដែលវាយលុកត្រង់កន្លែង
ដែលគេប៉ះពាល់ ធ្វើឲ្យខ្ញុំដកដង្ហើមមិនចេញ និងដកដង្ហើមកាន់តែ
ញាប់ រមួលខ្លួនគេចយ៉ាងណាក៏មាត់របស់គេតាមមកគ្រប់ពេល
ចំណែកដៃក៏មមាញឹកនឹងការចាប់ទាញសំណល់សម្លៀកបំពាក់

ដែលធ្លាប់ជាឈុតស្អាតៗរបស់ខ្ញុំចេញ ។

"អាំ...ស្លឹកតើយ មាត់ថាមិនព្រម មាត់ប្រាប់ថាកុំ តែនេះ...
...ហាក់មកមាត់បង" គេនិយាយ ស្របពេលដែលប្រដេញម្រាមដៃលើ
ទ្រូងរបស់ខ្ញុំ ។

អាំ...ទោះឈឺចិត្ត តែខ្ញុំបែរជាពើងទ្រូងឲ្យគេធ្វើបែបនោះ ។
ខ្ញុំនេះចំជា...ងាយពិតមែន មិនមែនទេ ព្រោះថាជា អឹនចាច់
...ព្រោះថាជាគេទៅវិញទេទើបខ្ញុំងាយដល់ថ្នាក់នេះ ។

"..."

គេថើបខ្ញុំ និងដោះសម្លៀកបំពាក់ខ្លួនឯងដែរ ។
ខ្ញុំអស់កម្លាំងកំហែងគេចហើយ ខ្លួនគេដែលសង្កត់លើខ្លួនខ្ញុំ
នេះធ្ងន់ណាស់ ពេលនេះគេលែងដៃរបស់ខ្ញុំឲ្យមានសេរីភាពហើយ
ខ្ញុំបានត្រឹមតែព្យាយាមរុញច្រានគេចេញ ប៉ុន្តែគ្មានសញ្ញាថាគេព្រម
ងើបចេញ ។

អឹនចាច់ ជ្រែកអណ្តាតចូលមកឲ្យទាល់តែបាន ហើយក៏ថើប
ខ្ញុំយ៉ាងជ្រាលជ្រៅ ដៃក៏នៅតែស្ទាបអង្អែល ធ្វើឲ្យខ្ញុំភ្ញាក់ព្រញាង ។

ខ្ញាក!

សំឡេងសំពត់រហែកស្របពេលនឹងកម្លាំងទាញឈុតក្នុង
ហើយដៃរបស់គេក៏ទម្លាក់ចុះមក ។

"អ្ហឹម...អ្ហាំ កុំ...អ្ហឹម"

ខ្ញុំងាកមុខចេញដើម្បីហាម តែបានឮសំឡេងសើចក្នុងបំពង់ក
របស់គេ បន្ទាប់ពីនោះ អឹនចាច់ ក៏តាមមកថើបខ្ញុំទៀត ។

អាំ! ខ្ញុំភ្ញាក់កន្ត្រាក់ ពេលមានអារម្មណ៍ថាមានរបស់ប្លែកថ្មី
ចូលមកក្នុងរាងកាយ វាឈឺចាប់លាយឡំស្រៀវស្រើប អឹម...គេចង់
ធ្វើអី គេចង់ធ្វើអី?

"ណែនណាស់ហើយ ស្លឹកតើយ..."

សំឡេងរបស់ អឹនជាច់ បន្លឺឡើង មុននិងញញ្រាមដៃ… ខ្លួនខ្ញុំបន្តិចទៀត ហើយក៏កម្រើកដៃ ធ្វើឲ្យខ្ញុំញ័រខ្លួនទៀត ។ មុខរបស់គេក្រហម សំឡេងក៏កាន់តែស្អកទៅៗ ហើយខ្លួន… ក៏ក្ដៅដែរ ។

"ឈឺ"

ខ្ញុំប្រាប់ និងព្យាយាមបង្ខាប់ខ្លួនឯងមិនឲ្យថ្ងូចថ្ងូរ តែបា…

"ឈឺតែប៉ុណ្ណឹង? នេះត្រឹមម្រាមដៃ បើជារបស់ផ្សេងដែលធំជាង នេះ..." សំឡេងរបស់គេឮក្បែរត្រចៀក ។

របស់ផ្សេងអីចឹងឬ?

ខ្ញុំខាំមាត់ ខ្លោយថ្ងូចថ្ងូរម្ដងទៀត និងដឹងថា អឹនជាច់ កម្រើក ខ្លួន គេដកថយចេញមួយភ្លែត មុននឹងខិតចូលមកវិញម្ដងទៀត ។

អឹនជាច់ ទាញដៃចេញពីខ្លួនរបស់ខ្ញុំ ធ្វើឲ្យខ្ញុំធ្លាក់ផ្លើមក្នុង… ទាំងរីករាយនិងសោកស្ដាយនៅក្នុងពេលតែមួយ តែនាទីបន្ទាប់មក ខ្ញុំក៏ធឹតពោះ បើកភ្នែកធំៗមើលគេដោយការភ្ញាក់ផ្អើលពេលគេធ្វើ… ដាបខ្ញុំ ។

"អូយ! ឈឺ"

ខ្ញុំស្រែក ពេលអ្វីម្យ៉ាងដែលរាវរឹងនិងធំខ្លាំងកំពុងតែរុញចូល មកក្នុងខ្លួន ។

អឹម...វាហាក់ដូចខ្លួនខ្ញុំកំពុងតែត្រូវពង្រីក ឈឺចាប់និងស្ពុង… ពេលតែមួយ ត្រង់ចំណុចតែមួយ វាតានតឹងនិងណែន អាំ...

"ចេញទៅ កុំ"

ខ្ញុំបណ្ដេញ និងខាំធ្មេញមើលមុខគេកាត់តាមតំណក់ទឹកភ្នែក ដែលហូរ ។

អឹនជាច់ ក៏មានទឹកមុខជ្រីវជ្រួញ ចិញ្ចើមរបស់គេជ្រួញជាប់គ្នា ភ្នែកសម្លក់ខ្ញុំថ្មើ ហើយខ្ញុំក៏ឃើញញើសពេញថ្ងាសរបស់គេ ។

"ស្ទើកតើយ...កុំប្រឹង"

"ចេញទៅ"

"មិនបាន ចូលទៅហើយត្រូវតែចូលឲ្យអស់"

ខ្ញុំ...ទ្រាំ...ទ្រាំមិនបាន!

"អាំ!!!"

ខ្ញុំស្រែកពេល អឹនជាច់ មានះរុញខ្លួនឯងចូលមកម្ដងទាល់តែ អស់ ។ ការឈឺចាប់ធ្វើឲ្យខ្ញុំស្រក់ទឹកភ្នែកកាន់តែខ្លាំង វាឈឺនិងចុក ណែន តានតឹងដូចដកដង្ហើមមិនចេញ ហើយ...វាក៏ក្ដៅផ្សាហាក់ ដូចមានកាំបិតចាក់ ។

"ចេញទៅ មនុស្សគម្រក់!"

"ដេញប្ដី បាបណា៎"

សំឡេងញ័រហាក់ដូចឈឺចាប់របស់ អឹនជាច់ ឮក្បែរត្រចៀក ការឈឺចាប់ពីអង្គាល់ ខ្ញុំទៅវិញទេដែលឈឺដល់ថ្នាក់និយាយមិន ចេញ ។

"អូនឈឺ"

"លើកដំបូងត្រូវតែឈឺ វាជារឿងធម្មតា"

សំឡេងរបស់គេមានសេចក្ដីសុខ ហើយពេលដែលខ្ញុំសឹងតែ ដកដង្ហើមមិនចេញ គេក៏កម្រើកខ្លួនដកថយ ហើយក៏ចូលមកម្ដង ទៀត អូយ...វាហាក់ដូចខ្ញុំកំពុងតែជិតស្លាប់ ការឈឺចាប់ចាប់ផ្ដើម រសាយ...អ្វីម្យ៉ាងក៏ចូលមកជំនួស គឺអ្វីដែលធ្វើឲ្យខ្ញុំស្រែក ហើយ អឹនជាច់ ក៏ស្រែកដូចគ្នា ។

គេឱនមកថើបខ្ញុំ ហើយក៏នៅស្ងៀមដើម្បីថ្ងូចថ្ងូរ សំឡេងរបស់ គេឮនៅក្នុងខួរក្បាលរបស់ខ្ញុំ អារម្មណ៍ឈឺផ្សារនៅមាន តែត្រូវជំនួស ដោយភាពស្រៀវស្រើប ទោះប្រាប់ខ្លួនឯងថាកុំលង់នឹងបទភ្លេង ស្នេហ៍របស់គេ តែថា...

"អ្ហាំ..." ខ្ញុំគ្រវីក្បាលដោយទ្រាំលែងបាន ពេលខ្លួនឯងឡើង
ទម្រើតព្រោះកម្លាំងវាយលុករបស់ អិនថាច់ ។
ហើយខ្ញុំក៏បានឮសំឡេងរបស់គេម្តងទៀត សំឡេងរបស់គេ
ដែលហៅឈ្មោះខ្ញុំឮខ្សាវក្នុងបន្ទប់ ។
ខ្ញុំក្រឡេកមើលរូបភាពក្នុងកញ្ចក់នៅជុំវិញគ្រែ ហើយក៏[illegible]
បបូរមាត់ រូបភាពរបស់យើង វា...
"ស្លឹកតើយ..."

[Intouch`s Talk]

ខ្ញុំហៅឈ្មោះនាងពេលខ្លួនឯងត្រូវភិតភ័យយ៉ាងខ្លាំង រហូតដល់មិនអាចទ្រាំបានតទៅទៀត ។

ស្លឹកតើយ ទាំងល្អស្អាត ទាំងបរិសុទ្ធ ខ្ញុំចាំបានច្បាស់ពេលដែលនាំខ្លួនឯងចូលទៅទម្លុះសន្ទះស្តើងដែលមនុស្សស្រីសម័យនេះសឹងតែគ្មានជាប់ខ្លួន ។

តែ ស្លឹកតើយ ដែលគួរឲ្យស្រឡាញ់នៅតែរក្សាវាទុក និងប្រគល់ឲ្យខ្ញុំដែលជាស្វាមីរបស់នាង មិនមែនទេ...ប្រាប់ថាប្រគល់ក៏មិនត្រូវ នាងមិនបានពេញចិត្ត ប្រាប់ថាខ្ញុំដណ្តើមទើបល្អជាង តែយ៉ាងណាក៏ ស្លឹកតើយ ជាភរិយារបស់ខ្ញុំស្រាប់ទៅហើយ ។

ខ្ញុំវាយលុកនាងម្តងទៀត ដឹងថាលេងខ្លាំងដៃពេក តែសំឡេងស្រែកថ្ងូរថ្ងររបស់នាង ប្រាប់ឲ្យដឹងថានាងក៏មានអារម្មណ៍ដូចដែលខ្ញុំមាន ។

"..."

សេចក្តីសុខដែលបានទទួលច្រើនមហាសាល ធ្វើឲ្យខ្ញុំដល់ថ្នាក់ត្រូវទម្លាក់ខ្លួនឱបនាង ថើបនាង និងស្ទាបអង្អែល[illegible]សុទ្ធតែញើសរបស់នាង ។

"ឈឺទេ ?"

ខ្ញុំសួរ ទាំងដែលដឹងថានាងឈឺដែលត្រូវខ្ញុំគ្រប់គ្រងយ៉ាងកំណាចនិងខ្លាំងក្លា ឈាមព្រហ្មចារីដែលជាបភាពរឹងមាំរបស់ខ្ញុំប្រាប់ឲ្យដឹងថា ស្លឹកតើយ ច្បាស់ជាឈឺ ។

លើកដំបូងរបស់មនុស្សស្រីឈឺចាប់ប៉ុណ្ណាខ្ញុំមិនដឹង តែលើកដំបូងរបស់យើង...ការគ្រប់គ្រង ស្លឹកតើយ ពិសេសបំផុត ។

មែន...ខ្ញុំខឹងដែលនាងគិតតែនិយាយរឿងបំណុល រឿងមង្គលការដែលគ្មានស្នេហា និង...ព្រមទទួលស្គាល់ដោយមិនចេះខ្មាសថា ខ្ញុំស្រមើស្រមៃដល់ការធ្វើបែបនេះរាប់រយដង ចាប់តាំងពីបានជួបនៅបន្ទប់ក្នុងខុនដូរបស់នាង ។

សារភាពតាមត្រង់ នោះមិនមែនជាលើកដំបូងដែលយើងជួបគ្នា ប៉ុន្តែនោះជាលើកដំបូងដែលនាងជួបខ្ញុំតែប៉ុណ្ណោះឯង ។

"ជូន់" នេះជាពាក្យដំបូងដែលនាងនិយាយ ។

ខ្ញុំនាំភាពរឹងមាំចេញពីខ្លួនរបស់នាង ឃើញនាងភ្ញាក់ក្រញាង ថ្ពាល់ក៏ក្រហម ភ្នែកក៏មានតំណក់ទឹក ប្រឡង់ភ្នែកទោះមានតំណក់ទឹក តែខ្ញុំដឹងថានាងមានសេចក្តីសុខមិនតិចជាងខ្ញុំនោះទេ ។

"ពេញចិត្តហើយក៏ងើបទៅ ខ្ញុំទៅផ្ទះ"

"..."

ខ្ញុំមើលមុខស្រស់ស្អាតរបស់មនុស្សស្រីដែលមិនព្រមមើលមុខខ្ញុំចំៗ មុននឹងជ្រួញចិញ្ចើម ។

"ដោះបំណុលហើយ នៅចង់យកស្អីទៀត ?"

ហេតុអីចេះតែនិយាយបញ្ឈឺចិត្ត ហេតុអី ?

"បំណុលដល់ទៅ១០០លាន ឲ្យលេងតែម្តងមិនសមាមាត្រ"

ស្លាប់ខ្លួនឯងខ្លាំងណាស់ដែលនិយាយស្អីបែបនេះដាក់នាង តែ

"កុំ"

ស្លឹកតើយ ហាមខ្ញុំម្តងទៀត ពេលដែលខ្ញុំឱនទៅរកថើប
របស់នាង អ្នកណាព្រមពេញចិត្តត្រឹមម្តងទៅ ក្នុងពេលដែលខ្ញុំ
ឱបមនុស្សស្រីដែលខ្លួនឯងស្រឡាញ់បែបនេះ ។

មែន ខ្ញុំស្រឡាញ់នាង ទាំងស្រឡាញ់ទាំងលង់ដល់ថ្នាក់ល្ងង់
វង្វេងបែបនេះ ប៉ុន្តែ ស្លឹកតើយ បែរជាចេះតែច្រានបដិសេធ
និងបណ្តេញខ្ញុំ ទាំងដែលមនុស្សស្រីជាច្រើនត្រូវការខ្ញុំ ឧទាហរណ៍
ដូចជាស្រីមុខជប៉ុននោះជាដើម តែហេតុអីមនុស្សស្រីតែម្នាក់ដែល
ខ្ញុំចង់បាន បែរជាមិនត្រូវការខ្ញុំទៅវិញ ?

ប្រពន្ធ...យ៉ាងណាក៏នាងជាប្រពន្ធរបស់ខ្ញុំតែម្នាក់គត់ ។

"សុំពីរដងទៀតទើបឲ្យទៅផ្ទះ"

ខ្ញុំប្រាប់និងញញឹមយ៉ាងកំណាចដាក់ ហើយក៏លូកដៃចូល
ក្រោមជើងស្រឡូន មុននឹងនាំខ្លួនឯងចូលទៅរកនាងម្តងទៀត ។

ស្លឹកតើយ ភ្ញាក់ព្រើត បបូរមាត់ស្រស់នោះថ្ងូរម្តងទៀត តែ
នាងមិនឈឺចាប់ដូចលើកដំបូង...ខ្ញុំប្រគល់បទពិសោធដ៏ក្តៅគគុក
ឲ្យនាងម្តងទៀត នាងតឹងណែននិងក្តៅគគុក មិនថាខ្ញុំជ្រែកចូល
ទៅប៉ុន្មានដង ក៏ត្រូវខាំធ្មេញទប់ភាពស្រៀវស្រើបដែលទទួលបាន
ដល់ថ្នាក់ឈឺចាប់សព្វសាច់ ។

ខ្ញុំនាំខ្លួនឯងចូលទៅរកនាងម្តងហើយម្តងទៀត សំឡេងគ្រាំ
ញ៉ាំគួរឲ្យខ្លាច ខ្ញុំមិនសោកស្តាយដែលធ្វើបែបនេះ ទាស់ត្រង់ម្យ៉ាង
ដែលវាជាភ័ងននរុត តែយ៉ាងណាក៏តាមតែវាទៅ សុំត្រឹមតែមាន
នាងមានខ្ញុំ ប៉ុណ្ណឹងក៏គ្រប់គ្រាន់ទៅហើយ ។

ខ្ញុំមានសេចក្តីសុខណាស់...ដែលបានឱបនាងបែបនេះ ។

សំឡេងដកដង្ហើមរបស់នាងថេរ...ស្លឹកតើយ លង់លក់ទៅ
ហើយ បន្ទប់ពីត្រូវខ្ញុំធ្វើបាបច្រើនដង មិនមែនពីរដងដូចដែលគាត់

ប្រាប់ ។

"..."

ខ្ញុំឱនទៅថើបថ្ពាល់របស់នាង និងខ្សឹបប្រាប់ ៖

"បងស្រឡាញ់អូន"

ហើយបន្ទាប់ពីនោះក៏លូកដៃឱបចង្កេះតូចស្តើងដោយការ
ហួងហែង ។

តែខ្ញុំក៏ភ្ញាក់ម្តងទៀត ពេលអ្នកនៅក្នុងរង្វង់ដៃកម្រើក...
ស្លឹកតើយ កំពុងតែចង់ងើបគេច ។

"ចង់ទៅណា ?"

"ងូតទឹក"

នាងតបដោយសំឡេងរឹងកំព្រឹស នោះហើយដែលធ្វើឲ្យខ្ញុំ
ជ្រួញចិញ្ចើម ។

"ងូតទឹកធ្វើអី ?"

"ស្មោកគ្រោក"

នាងតបខ្លីៗ ធ្វើឲ្យខ្ញុំអួលដើម.ក ។

ខ្ញុំមើលមុខស្លេកស្លាំងរបស់នាង ភាពទន់ភ្លន់ដែលបានទទួល
កាលពីមួយសន្ទុះធំនោះ នៅតែធ្វើឲ្យមានអារម្មណ៍ល្អ អាចលេង
មួយទឹកពីរទៀតបាន ។

"មិនឃើញស្មោកគ្រោកត្រង់ណាផង អូនក្រអូបគ្រប់កន្លុក
កន្លៀត"

"ស្មោកគ្រោកព្រោះត្រូវមនុស្សគម្រក់ធ្វើបាប"

"បើដេកជាមួយប្រពន្ធខ្លួនឯងហើយគម្រក់ មនុស្សប្រហែល
ជាគម្រក់ទូទាំងពិភពលោកហើយ"

ខ្ញុំងើបអង្គុយ ដោយប្រត់ដៃបើកភួយដែលនាងទាញទៅបិទ
បាំងសើមខ្លួន ធ្វើហាក់ដូចខ្លាចបិទបាំងជិតយ៉ាងអីចឹង ហើយព្រោះជា

ខ្ញុំច្របាច់ដៃលើពូក ទើបនាងងើបមិនរួច ក្រៅពីក្រមុនខ្លួនតោ ។

"ចូលចិត្តទេអ្វីដែលបងធ្វើ?"

"..."

កូនក្រមុំពីស្រស់ស្អាតរបស់ខ្ញុំងាកមុខចេញមិនឆ្លើយ ។

"ចូលចិត្តទេ ស្រៀវឬអត់?"

"ឆ្កួត! មិនចូលចិត្ត!"

ខ្ញុំសើចពេល ស្លឹកតើយ ងាកមកស្រែកច្រួតដាក់ មុខរបស់នាងមានពណ៌ផ្កាឈូក តាមពិតគឺផ្កាឈូកសព្វសាច់ហ្នឹងឯង ស្លឹកតើយ របស់ខ្ញុំស្អាតសព្វសាច់ ។

"មិនចូលចិត្ត តែពើងទទួល"

"មិនពិត កុំមកនិយាយស្តីបែបនេះ"

"អីចឹងពិសោធម្តងទៀតទេ?"

ខ្ញុំនិយាយដោយសំឡេងប្រាកដប្រជា ហើយខ្ញុំក៏ប្រហែលជាធ្វើមុខគ្រោកកាមដែរ ព្រោះថាពេលងាកមកមើល ស្លឹកតើយ ក៏ធ្វើមុខដូចឃើញខ្មោចទាំងកណ្តាលថ្ងៃចែស ហើយម្នីម្នាចុះពីគ្រែ ប្រុងរត់ទៅបន្ទប់ទឹក ។

"ឈប់សិន"

ខ្ញុំស្រែកហៅ ហើយចាប់ស្មារបស់នាងជាប់ និងទាញឲ្យដួលមកដេកលើគ្រែម្តងទៀត លើកជើងគងភ្លៅរបស់នាង ទើបអាពស់ភ្ជាន់ពិតនឹងខ្លួនរបស់នាងដោយជួយមិនបាន ។

"ឈប់ ឈប់ទៅ!"

"បើចង់ឲ្យឈប់" ខ្ញុំនិយាយញឹមៗ និងអូសស្រាមដៃតាមករហូតមកឈប់ត្រង់ដើមទ្រូងស្អាតរបស់នាង "អីចឹងនិយាយឲ្យពីរោះ ម៉េចចាំបាច់ធ្វើឫកដូចស្អប់ខឹងបងដល់ថ្នាក់នោះ កាលនៅហាង"

"..."

"មិនឆ្លើយ អីចឹងធ្វើទៀត"

ខ្ញុំប្រាប់ មុននឹងឱនទៅរកផ្លែឈើស្រស់ម្តងទៀត លើកនេះនាងក៏ស្រែកហាមភ្លាម ។

"កុំ អូននៅឈឺ"

ខ្ញុំទប់ចិត្ត មើលស្នាមរបស់ស្រាមដៃនិងកន្ទួលក្រហមជាប់សាច់របស់ ស្លឹកតើយ។ មួយសន្ទុះធំមុនតម្រូវការ បុរុសមនឹងកំហឹងដែលនាងនិយាយស្តីមិនស្រណោះស្រណោក វាយតម្លៃរឿងដែលខ្ញុំធ្វើត្រឹមតែជាការរៀបការព្រោះប្រាក់ ទើបធ្វើឲ្យខ្ញុំប្រើកម្លាំងដាក់នាង...ខ្លាំងតែម្តង ។

"ឈឺឬ?"

"សាកត្រូវម្តងមើល៍"

"ក៏ចង់ឲ្យអូនជាអ្នកធ្វើខ្លះដែរ" ខ្ញុំនិយាយព្រមទាំងញញឹម ហើយក៏យកច្រមុះត្រដុសនឹងច្រមុះរបស់នាង ។

ពន្លឺភ្នែករបស់ ស្លឹកតើយ ហាក់ដូចរសាយកំហឹងខ្លះហើយ មុខស្លេកស្លាំងក៏ឡើងក្រហមព្រោះអឹមអៀន ទើបខ្ញុំថើបច្រមុះនាងថ្នមៗ ។

"បងសូមទោស"

កែវភ្នែករបស់ ស្លឹកតើយ មើលមកខ្ញុំដោយការងឿងឆ្ងល់ ដូចមិនស្មានថាបានឮពាក្យសូមទោសចេញពីមាត់របស់ខ្ញុំ "តាមពិតបងទៅតាមរកអូនព្រោះរឿងពីសមានកាលពីព្រឹក តែយើងបែរជាឈ្លោះគ្នាមុនពេលបាននិយាយគ្នា ទើប...លទ្ធផលវាចេញមកបែបនេះទៅ"

"ក្នុងសណ្ឋាគារហ៊ាំងខនស៊ីត"

តាមពិតរឿងក៏មានអារម្មណ៍ខឹងខុសដែលធ្វើឲ្យលើកដំបូងរបស់

យើងកើតនៅទីនេះ តែពេលនោះតម្រូវការចង់ធ្វើជាម្ចាស់លើ
ស្លឹកតើយ វាខ្លាំងដល់ថ្នាក់មិនអាចរម្ងាប់បានពិតមែន ។

"ឡូយសឹងអី ផ្សំដំណេកក្នុងវាំងននរូត"

"..." ស្លឹកតើយ មើលខ្ញុំដូចចង់ច្របាច់ក ខ្ញុំក៏ញញឹមដាក់នាង ហើយក៏ដើបថ្ពាល់ពណ៌ផ្កាឈូកមួយខ្សឹតទៀត ។

"សរុបទៅបងសូមទោស ទាំងរឿងព័ត៌មាន ទាំងរឿងវាំងនន រូតនេះ អូខេទេ ?"

"មិនអូខេ"

"ហើយចង់ឲ្យធ្វើយ៉ាងម៉េច ក្នុងពេលដែលអូនធ្លាប់ធ្លាលបង មុន"

"អូនជាអ្នកខុស ?"

"បងជាអ្នកខុស"

ប្រផ្នូលខ្លាចប្រពន្ធបង្ហាញឲ្យឃើញច្បាស់ដែរទេ លី អ៊ីនចាប់ ...ខ្ញុំញញឹមដាក់មនុស្សស្រីដែលធ្វើភ្នែកកាចដាក់ សូម្បីតែខឹងដល់ថ្នាក់នេះក៏នាងនៅតែគួរឲ្យស្រឡាញ់ កាន់តែក្លាយជារបស់ខ្ញុំហើយក៏កាន់តែគួរឲ្យប្លែក ជំនួសដែលតម្រូវការ ការប្រាថ្នា ការស្រឡាញ់ ភចមចយ បែរជាកើនឡើងយ៉ាងខ្លាំងក្លា ។

ស្រីមេមត់មានល្បិចនេះវាយម្តងស្នេហ៍អីដាក់ខ្ញុំ ទើបបានជាខ្ញុំលង់ងើបមុខមិនរួចបែបនេះ តាំងពីថ្ងៃដំបូងដែលយើងជួបគ្នា ។

"ចុះស្រីតារានោះត្រូវជាស្អីនឹងបង បើបងមិនគិតចង់មានអ្នកដទៃ ទាំងដែលមានអូនជាភរិយាតាមនីតិន័យនិងព្រឹត្តិន័យបែបនេះ ត្រូវតែគ្មានស្រីម្នាក់នោះ អូនមិនប្រើរបស់រួមជាមួយអ្នកណា"

ហ៊ឹម...ខ្ញុំបានខ្លួនឯងឃើញការប្រចណ្ឌហួងហែងក្នុងកែវភ្នែករបស់ ស្លឹកតើយ បើសិនមានការប្រចណ្ឌហួងហែងគឺត្រូវតែមាន...ក្តីស្រឡាញ់ដែរ ។

"អូនប្រចណ្ឌឬ ?"

"ប្រចណ្ឌ...អឺ...អត់ទេ មិនបានប្រចណ្ឌ អូនប្រចណ្ឌបងធ្វើអី"

"ប្រចណ្ឌបងទៅ ព្រោះថាបងក៏ប្រចណ្ឌអូន"

ស្លឹកតើយ ធ្វើមុខគួរឲ្យស្រឡាញ់ទៀតហើយ នាងមើលមុខខ្ញុំដោយការងឿងឆ្ងល់ ខ្ញុំក៏ញញឹមដាក់នាងដូចគ្នា ។

ពេលបានធ្វើជាម្ចាស់រាងកាយមួយនេះហើយ ខ្ញុំក៏ចង់គ្រប់គ្រងធ្វើជាម្ចាស់បេះដូងដែរ ។

"បងស្រឡាញ់អូន"

"..."

"ម៉េចក៏ធ្វើមុខអីចឹង មិនជឿឬ ?" ខ្ញុំសួរ ។

"មិនជឿ គ្មានត្រង់ណាគួរឲ្យជឿអីបន្តិច"

ខ្ញុំព្រិមភ្នែកមើលអ្នកដែលធ្វើមុខមិនជឿ ។

មាត់ផ្ទៀងចិត្តផ្សេង គណ្ហាអើយ! ភ្នែកនេះផ្លេកៗតែម្តង មុខក៏ក្រហម ថែមទាំងសំឡេងលោតរបស់បេះដូងក៏ឮខ្លាំងៗចេញមកក្រៅដែរ នៅមកប្រាប់ថាមិនជឿទៀត អឹម...

"បងស្រឡាញ់អូនតាំងពីឃើញលើកដំបូងម្ល៉េះ"

"ក្នុងខុនដូអូន ?" នាងសួរ ។

"មិនមែន តាំងពីមុននោះម្ល៉េះ ពេលម៉ាក់ប្រាប់ថាមានកូនស្រីរបស់មិត្តជិតស្និទ្ធចង់ឲ្យស្គាល់ និងសាកល្បងរស់នៅជាមួយគ្នា ទើបបងទៅលួចមើលអូននៅមហាវិទ្យាល័យ កុំធ្វើមុខអីចឹង ស្តាប់បងសិន បងនិយាយតែម្តងទៀតទេ"

ខ្ញុំប្រាប់ពេលដែលនាងចង់ដឹង ។

"បងទៅលួចមើលអូន ហើយក៏ត្រឡប់មកវិញប្រាប់ម៉ាក់ថា បងលង់ស្នេហ៍ស្រីតូចម្នាក់នោះហើយ...និងចង់រៀបការជាមួយ តែម៉ាក់ឲ្យបងរៀនឲ្យចប់សិន ហើយបងក៏ទៅរកម៉ាក់របស់អូន

ប្រាប់ថាបងស្រឡាញ់កូនស្រីរបស់គាត់ខ្លាំងណាស់ ចង់រៀបការ
ជាមួយភ្លាមពេលដែលអូនរៀនចប់ តែម៉ាក់របស់អូនប្រាប់ថាអូន
ក្បាលរឹង គ្មានផ្លូវព្រមរៀបការជាមួយអ្នកដែលមិនធ្លាប់ស្គាល់មុខ
ជាបងនោះទេ ទើបបងដាក់សំណើបំណុលលោកប្រាស់ ហើយរឿង
យ៉ាងគឺដូចដែលអូនបានដឹង"

ស្លឹកតើយ ធ្វើមុខស្រឡាំងកាំង ចំហមាត់ធ្លុង មុននឹងស្រែក
បាច ។

"ថាម៉េច!"

"កុំប្រាប់ណាំថាជឿរឿងយើងរៀបការព្រោះបំណុល ១០០ លាននៅសម័យនេះ?"

"ជឿ...នេះមានន័យថាគ្រប់គ្នារួមគ្នាបោកអូន?"

"អឺម តែគ្រប់គ្នាមានបំណងល្អចំពោះអូន ចង់ឲ្យអូនបានស្វាមីសង្ហា អ្នកមាន ចិត្តស្មោះ"

ខ្ញុំញញឹមប្រាប់ មុននឹងស្រែកពេលដែលត្រូវអ្នកនៅក្រោមរាងកាយវាយតប់ញាប់ដៃស្អេក មើលទៅកំពុងខឹងខ្លាំងតែម្តង ។

"ចុះអាដែលធ្វើបាបគ្នាមករហូតនោះ លី អ៊ីនថាច់! អាមនុស្សបោកប្រាស់"

"គឺស្រឡាញ់ហ្នឹងណាំ ធ្វើយ៉ាងម៉េចទៅ ដែលទៅស្រាតចាំនៅខុនដូ ព្រោះចង់សាកភាពជាប់ចិត្តលើកដំបូងហ្នឹងអី" ខ្ញុំប្រាប់ ។

"អាក្រក់ណាស់!"

"ឈប់សិនៗ កុំទាន់អាលខឹង...ប្រពន្ធសម្លាញ់ និយាយគ្នាសិន យ៉ាងម៉េចដែរ ដឹងបែបនេះហើយអូននៅតែគិតថាយើងរៀបការដោះបំណុល ដោយមិនបានស្រឡាញ់គ្នាទៀតដែរទេ ដឹងហើយនៅថាបងស្រឡាញ់អូនមែន"

"..." ស្លឹកតើយ នៅស្ងៀម មុននឹងដកដង្ហើមធំធ្វើមុខផង

ទទួលយកបានហើយ "តាមពិត...បងជាស្វាមីអូន"

"អាំ...ហើយយ៉ាងម៉េច ប៉ុណ្ណឹងទេឬ ដែលស្តេចដែលភយមន្តស្នេហ៍ឡើងគរគោក មិនស្រឡាញ់ទេឬយ៉ាងម៉េច?"

"ព្រមទទួលស្គាល់ថាញាប់ញ័រខ្លះ"

"ចុះពេលណាទើបស្រឡាញ់ ?" ខ្ញុំសួរ ត្រជាក់ចិត្តខ្លាំងណាស់ មើលភ្នែកថ្លាយុងរបស់ ស្លឹកតើយ ហើយក៏មានអារម្មណ៍ថាបេះដូងភរ័កណែនដើមទ្រូងតែម្តង ។

"មិនដឹងទេ...ប្រាប់មិនបាន តែក៏មិនបានស្អប់ អម្បាញ់មិញ...តាមពិតក៏មិនបានខ្ពើមរអើម"

ស្លឹកតើយ និយាយទាំងអឹមអៀន ចំណែកមុខក៏ក្រហមងាំង។

ឃើញទេ! គួរឲ្យស្រឡាញ់បែបនេះ មិនស្រឡាញ់មិនលង់បានយ៉ាងម៉េច!

"មែនក៏អី អីចឹងប្តីសុំត្រជាក់ចិត្តម្តងទៀត"

"អត់ទេ អូនឈឺ"

"ណាំ...ធានាថាមិនឈឺទេ ណាំៗ"

ខ្ញុំប្តូរស្ទីលកាចទៅជាស្ទីលម្ទិកម៉្លក់ភ្លាម ។

"លី អ៊ីនថាច់!"

"បាទ" ខ្ញុំបង្អួសសំឡេងយ៉ាងស្រទន់ ដឹងថានាងនៅអឹមអៀន និងជើងថ្មីសម្រាប់រឿងនេះ ។

អម្បាញ់មិញព្រោះខ្ញុំល្ងីល្ងើ ទើបបានជាប្រើកម្លាំងខ្លាំងបន្តិច តែជាលើកនេះខ្ញុំនឹងកែខ្លួនជាថ្មី ។

ខ្ញុំថើបបបូរមាត់ស្រស់នោះម្តងទៀត ស្លឹកតើយ ក៏ភរែកនិងស្ទាក់ស្ទើរ តែចុងក្រោយនាងក៏ឱបករបស់ខ្ញុំ ធ្វើឲ្យបេះដូងរបស់ខ្ញុំលោតញាប់ស្អេក ឈាមនៅក្នុងខ្លួនក្តៅ ចំណែក អ៊ីនថាច់តូច ក៏ញាក់ដឹងខ្លួនសឹងតែរម្ងាប់មិនបាន ដែលដឹងថាបានស្រឡាញ់ ស្លឹក

តើយ ម្តងទៀត ។

ខ្ញុំអង្អែលនាងថ្នមៗ ដូចចង់លុបលាងកំហុសដែលធ្វើឲ្យនាងមានស្លាកស្នាមពេញខ្លួន ព្រមទាំងថើបបបូរមាត់និងប្រអប់ទ្រូងរបស់នាងដែរ ។

ក្លិនខ្លួនមនុស្សស្រីធ្វើឲ្យខ្ញុំរំភើបញាប់ញ័រ ទាំងដែលវាមិនមែនលើកដំបូង និងទើបតែឆ្លងកាត់សេចក្តីសុខជាច្រើនដងកាលពីមួយម៉ោងមុនសោះ ។

ស្លឹកតើយ បិទភ្នែក ខ្យល់ដង្ហើមរបស់នាងដកញាប់ដូចខ្ញុំ ពេលខ្ញុំអូសបបូរមាត់ចុះក្រោមជាបៀយៗមករកដើមទ្រូងស្អាតធ្វើឲ្យនាងថ្ងូចថ្ងូរនិងពុតពេនខ្លួនឡើងរមួល ។

ស្រឡាញ់...ស្រឡាញ់ខ្លាំងណាស់ ស្រឡាញ់ដល់ថ្នាក់មិនគួរឲ្យជឿថាស្រឡាញ់អ្នកណាបានដល់ថ្នាក់នេះ ។

ថើបនាងសព្វសាច់ ហើយក៏ទ្រាំលែងបាន...លើកនេះខ្ញុំចូលទៅរកនាងយ៉ាងទន់ភ្លន់ តែវានៅតែលំបាកដូចលើកដំបូងរះបិទ រាងកាយរបស់នាងតន្ត្រាក់ អាចឈឺចាប់ខ្លះ តែខ្ញុំជឿជាក់ថាវាតិចតួចខ្លាំងណាស់បើធៀបនឹងសេចក្តីសុខដែលខ្ញុំបង្កើតឡើង...

ហើយវាជាការពិត ស្លឹកតើយ បញ្ចេញសំឡេងគួរឲ្យស្រឡាញ់ចេញមក សំឡេងដូចកូនឆ្មាម៉ិកម៉ូក់សុំមេបៅដោះ ។

ចំណែកខ្ញុំវិញសឹងតែស្លាប់ឲ្យបាន នាងទន់ល្មៀយ ម៉ង្គៃ និងក្តៅគគុក ថែមទាំងតឹងណែនដល់ថ្នាក់ខ្ញុំសឹងតែថប់ដង្ហើមស្លាប់ពេលដែលឆ្លងកាត់ ។

"អ៊ិនថាច់"

នាងហៅពេលដែលលើកដៃឱបខ្ញុំ ខ្លួនប្រាណយើងធ្វើចលនាព្រមគ្នា វាធ្វើឲ្យខ្ញុំដឹងថាការមានសម្ព័ន្ធភាពជាមួយនឹងមនុស្សដែលយើងស្រឡាញ់ និងជាមួយអ្នកដែលយើងគិតថាជាគូ...

អារម្មណ៍ វាខុសគ្នាបែបណា ។

"បងស្រឡាញ់អូន"

ខ្ញុំខ្សឹបប្រាប់មនុស្សស្រីដែលខ្លួនឯងព្រមដាក់ផែនការ ព្រមធ្វើគ្រប់យ៉ាងឲ្យនាងក្លាយជារបស់ខ្ញុំ មុននឹងថើបនាងម្តងទៀត ។

[End Intouch`s Talk]

# ១១
# ស្នេហ៍ក្រោយសង្គ្រាម

ខ្ញុំចង់គក់អ្នកដែលអង្គុយធ្វើមុខមាំនៅក្បែរម្ខាងដៃ មើលចុះ គេធ្វើឫកបែបនោះបានយ៉ាងម៉េច បន្ទាប់ពីនាំខ្ញុំមកផ្ទះហើយក៏ធ្វើឫកងរង៉ក់ដូចកូនក្មេង ចង់ឲ្យខ្ញុំទៅនៅខុនដូជាមួយគេយប់នេះ ទាំងដែលពីរថ្ងៃទៀតយើងរៀបការសោះ ។

"មិនបានទេ អូនមិនទៅ ធ្វើដូចមុនល្អហើយ បងទៅខុនដូទៅ អូននៅផ្ទះម៉ាក់"

"មិនល្អ បងដេកឱបអ្នកណា ?"

"ចុះរាល់យប់កន្លងមកដេកឱបអ្នកណា ?"

អ៊ីនចាច់ ធ្វើមុខក្រញូវ ហេតុអីពេលនេះគេមើលទៅដូច...មិនដឹងទេ គួរឲ្យស្រឡាញ់ជាងមុន ប្រុសមាឌធំមុខសង្ហាធ្វើឫកងរង៉ក់...គួរឲ្យស្រឡាញ់ដែរ ។

"មិនព្រម"

"..."

ខ្ញុំដកដង្ហើមធំ មើលនាឡិកាដៃម៉ោងជិត៩ទៅហើយ ខ្ញុំចេញពីផ្ទះតាំងពីព្រឹក និង...ត្រូវអាមៀនេះអូសទៅញ៉ាំញីក្នុងសណ្ឋាគាររហូតដល់ពេលនេះទើបតែត្រឡប់មកផ្ទះ សុំប្រាប់ថាឈរមិនទាំងចង់រួចផង ឲ្យមកឈរប្រកែកជាមួយប្រុសឆ្កួតម្នាក់នេះនៅមាត់ទ្វារផ្ទះទៀតឬ ខ្ញុំចង់ដេកពេញបន្ទុកហើយ ។

"អូននឹងខឹងខ្លាំង បើបងនៅតែរឹងទទឹង"

អ៊ីនចាច់ ធ្វើមុខធុញថប់ ហ៊ឺ...ព្រមទទួលស្គាល់ថាពេលដឹងថាគេស្រឡាញ់ហើយ ខ្ញុំដូចកាន់សន្លឹកបៀធំជាងភ្លាម រឿងស្អីព្រមឲ្យគេធ្វើបាបទៀតទៅ បំណុលក៏គ្មានដែរ ធីះ!

"បានឱកាសក៏តើងថ្លៃហ្នឹ"

"បើអ្នកណាគឺអ្នកហ្នឹង ទទួលបានក៏ទទួល ទទួលមិនបាន លុបចោលមង្គលការ"

"ម៉េចកើត ទម្រាំតែបានមកពិបាកសឹងស្លាប់" អ៊ីនចាច់ ប្រាប់ដោយទឹកមុខមាំ "តែបើដឹងថាលោកហើយគួរឲ្យស្រឡាញ់បែបនេះ បងលោកតាំងពីយូរម្ល៉េះ"

"លី អ៊ីនចាច់...ត្រឡប់ទៅផ្ទះទៅ"

ខ្ញុំបណ្តេញ គេញញឹមញញែម មុននឹងដើរមកថើបក្បាលខ្ញុំហើយក៏មិចភ្នែកដាក់ ។

"ស្អែកបងមកទទួល...ចង់ទៅសរសើរបន្តិចថាវត្តកូនព្រំអស្ចារ្យណាស់"

"មិនបាច់ទេ ទៅវិញទៅ មិនអីចឹងនឹង..."

"នឹងយ៉ាងម៉េច ?"

អ៊ីនចាច់ មើលមុខខ្ញុំដោយការផ្ចាញ់ផ្ចាល ។

មែនហើយ ចង់យ៉ាងម៉េចទៅ...ខ្ញុំគិតហើយក៏ញញឹមពេលនឹកឃើញ ។

"នឹងមិនស្រឡាញ់"

ហើយក៏បានផល...អ្នកនៅចំពោះមុខបើកភ្នែកធំៗ មុននឹងរអ៊ូទាំថា ខ្ញុំបានឱកាសជិះជៀមជេញ បើគេបានឱកាសវិញនឹងជិះខ្ញុំ វ៉ាយ...

"ទៅវិញទៅ មិនយូរទេយើងបានរស់នៅជាមួយគ្នារហូតហើយ"

អ៊ីនចាច់ ញញឹម មុននឹងហួចដើរទៅហៅតាក់ស៊ី ។

ខ្ញុំឈរមើលទាល់តែគេឡើងតាក់ស៊ី ទើបឡើងឡានបើកចូល ... ហើយពេលដែលដើរចូលទ្វារធំ ម៉ាក់និងបងស្រី ផ្កាឈូក ក៏

ឈរតោងទ្វារ ប្រាប់ឲ្យដឹងទៅថាលួចមើលខ្ញុំ និង អ៊ីនចាប់ ប្អូន
រយៈហើយ...ស្រីៗពីរនាក់នេះចំមែន!

"ម៉ាក់លួចមើលឬ?" ខ្ញុំសួរភ្លាម ។

អ្នកស្រី ឈើរី និងខ្ញុំមានរឿងត្រូវជម្រះបញ្ជី មានទាំងបំណុល ១០០លាន ហើយនៅមានរឿងគេប្តឹងទៀត ។

"គ្មានទេ"

ម៉ាក់ខ្ញុំញាក់ស្មា ហើយដើរទៅអង្គុយនៅមុខទូរទស្សន៍ ដែលមានត្រឹមបំពោកមុខដាក់នៅត្រង់នោះ ។

"ហើយម៉េចក៏មកវិញយប់ម្លេះ នេះម៉ោង៩ហើយ" បងស្រីសួរ

"ហើយ អ៊ីនចាប់ គេបើកឡានមកឲ្យឬ?"

"អឺម"

"ហើយ...ទៅជួបគ្នានៅឯណា?"

"បងមិនបាច់មកដេញដោលទេ ម៉ាក់ក៏ម្នាក់ទៀតដែរ ខ្ញុំដឹងការពិតហើយ"

ត្រឹមក្ដុងដៃរបស់អ្នកស្រី ឈើរី ធ្លាក់ក្ទុក មុននឹងដាកមកសើចហេះៗដាក់ខ្ញុំ ។

"អុំយ"

"មិនបាច់មកអុំយទេ បងស្រីក៏ដូចគ្នា ប្រាប់មកថាដឹងរឿងដែរឬអត់"

ខ្ញុំដើរទៅចាប់ដៃបងស្រីមកអង្គុលើសាឡុងមុខទូរទស្សន៍ យ៉ាងណាបានជានិយាយទៅហើយ គាត់កកាយឲ្យអស់ទៅចុះ ។

"ខ្ញុំមិនដឹងទេ ទើបតែដឹងពេលដែលម៉ាក់គេប្រាប់ថាឯងរៀបការ ឲ្យខ្ញុំមក ពេលនោះទើបម៉ាក់ប្រាប់ ខ្លាចខ្ញុំប្រាប់ឯងថាមិនធ្លាប់យកប្រាក់ពីខាងនោះទៅបន្ទិល ជំនួញប្តីខ្ញុំរលូនសឹងអី ខ្ញុំជាអ្នកមានណាំ"

ខ្ញុំមើលមុខម៉ាក់ភ្លាម ពេលនេះឈ្លើយទឹកតែរួចផុតពីការចោទប្រកាន់ហើយ ។

"អី...អុំយ...យប់ជ្រៅហើយ តិចក្របកភ្នែកខ្មៅ ទៅដេកហ៊ុំ គឺថ្ងៃមង្គលការរបស់ឯង ម៉ាក់មិនស្អាតទៅ"

ខ្ញុំស្រវាយកកំប៉ុងត្រឹមរបស់ម៉ាក់លើកឡើងខ្ពស់ធ្វើជាថ្នូរ ។

"វ៉ាយ ស្អីកតើយ នោះកំប៉ុងសុកពពៃក្នុងកក់ដែលលាយនឹងទឹកបរិសុទ្ធណាំ!" ម៉ាក់ស្រែកប្រាប់ មើលទៅគាត់កំពុងភ័យ ខ្ញុំក៏ញញើមកំណាចដាក់ ។

"ម៉ាក់ប្រាប់ខ្ញុំតាមសម្រួល ឬចង់ឲ្យខ្ញុំបោះវាចោល"

"កូនឆ្កួតនេះ...ក៏បាន ម៉ាក់និង ជីហ្វានី ជាមិត្តភក្តិគ្នាតាំងពីយូរមកម្លេះ យើងចូលចិត្តមើលរឿងដូចគ្នា រៀនជាមួយគ្នា ហើយក៏ស្និទ្ធស្នាលគ្នា បែកគ្នាមួយរយៈហើយក៏បានជួបគ្នាម្តងទៀត យើងសប្បាយចិត្តខ្លាំងណាស់ ហើយក៏មានគំនិតថាយើងធ្វើត្រឹមជាមិត្តភក្តិធ្វើអី ក្នុងពេលដែលយើងអាចធ្វើជាសាច់ញាតិនឹងគ្នាបាន ហើយម៉ាក់ដឹងថា អ៊ីនចាប់ កូនប្រុសរបស់គេជាមនុស្សល្អ មានសីលធម៌" ម៉ាក់ខ្ញុំរៀបរាប់យ៉ាងវែង ។

"យកតាមត្រង់"

"គេសង្ហាខ្លាំងណាស់ ហើយម៉ាក់គិតចង់បានចៅមុខមាត់សង្ហាស្អាតៗដែរ"

"ម៉ាក់!" ខ្ញុំស្រែកអស់សំឡេង ។

"និយាយលេងទេ គេជាមនុស្សល្អ ហើយ ជីហ្វានី គិតចង់ឲ្យកូនៗសេពគប់គ្នា នាងប្រាប់ឲ្យកូនប្រុសទៅមើលឯង ហើយយ៉ាងម៉េចក៏មិនដឹង អ៊ីនចាប់ ក៏មករកម៉ាក់ និងប្រាប់ថាគេលង់ស្នេហ៍ឯង...រ៉ូមែនទិកខ្លាំងណាស់"

ម៉ាក់លើកដៃក្តោបថ្ពាល់ធ្វើភ្នែកព្រិចៗ...ខ្ញុំសង្ស័យមែនទែន

ថាបាលង់ស្នេហ៍ម៉ាក់បានយ៉ាងម៉េច ។

"..."

"កុំធ្វើភ្លេកបែបហ្នឹង ម៉ាក់ក៏ដឹងថាខ្ញុំដឹងថា អឹនចាប់ ល្អប៉ុណ្ណា ផ្ទុយទៅវិញ នៅចំពោះមុខខ្ញុំ គេមិនបានល្អបំផុតដល់ម្លឹង ទាំងមាត់ដាច ចិត្តអាក្រក់ និង...

"តែគ្រប់គ្នាក៏មិនគួរណាប្រួមដៃគ្នាបោកខ្ញុំ"

"ឡូឡាធ្វើអី ដឹងការពិតហើយមិនចូលចិត្ត ទទួលមិនបាន លែងលះគ្នាទៅ" ផ្កាឈូក ប្រាប់ដោយសំឡេងរាបស្មើ ថែមទាំងធ្វើទឹកមុខសោះអង្គើយទៀតផង ។

ខ្ញុំងាកខ្ទាប់ទៅមើលបងស្រីដោយការភ្ញាក់ផ្អើល ហ៊ានស... លែងលះឬ...?

"អឹនចាប់ មិនល្អ កន្លងមកឯងមិនចូលចិត្ត មានអារម្មណ៍ដូចត្រូវគេបង្ខាប់បង្ខំ ក៏លែងលះទៅ ខ្ញុំជាប្រហែលមានស្រីស្អាតរស់នមួយប្រទេសដែលសប្បាយចិត្ត"

ខ្ញុំមើលមុខបងស្រី ដែលធ្វើមុខសោះអង្គើយណែនាំផ្លូវចេញ ហើយក៏ចំហមាត់ឆ្ងល់ មុននឹងខ្ទឹបបបូរមាត់ ហើយក៏...

"មិនលែង"

ខ្ញុំហ៊ែសដើរចេញ ហេតុអីផ្តួលចិត្តម្ល៉េះពេលដែលបានឮពាក្យថាលែងលះ..អឹម ខ្ញុំប្រហែលជាស្រីបុរាណដែលបង់ខ្លួនបង់ប្រាណឲ្យអ្នកណាហើយ ក៏ត្រូវតែព្រមធ្វើជាប្រពន្ធគេរហូតដល់ថ្ងៃស្លាប់...

ខ្ញុំដើរចេញពីបន្ទប់ ទើបមិនបានឮសំឡេងរបស់ម៉ាក់ដែលស្តីឲ្យបងស្រី ។

"ម៉េចក៏និយាយអ៊ីចឹង ផ្កាឈូក បើប្អូនសុំលែងលះមែនគិតយ៉ាងម៉េច?"

"ហ៊ុយ" ផ្កាឈូក អួសសំឡេងយ៉ាងវែង "នាងមិនលែងលះទេ នាងស្រឡាញ់គេ មើលមុខក៏ដឹងដែរ ម៉ាក់ត្រៀមចិញ្ចឹមចៅទៅ"

"ចៅ?"

"ឈឺខ្ញុំទៅ ខ្ញុំឈប់និយាយច្រើនហើយ ទៅដេក" ផ្កាឈូក ញញឹម ហើយក៏ដើរចេញពីបន្ទប់ម្នាក់ទៀត ។

ខ្ញុំអង្គុយនៅក្នុងអាងងូតទឹក កើយក្បាលនឹងគ្នាក់របស់អាង ទឹកក្តៅឧណ្ហៗ ជួយឲ្យខ្ញុំសាយការឈឺចុករួយដែលកើតឡើងដោយសារអាមៀ អឹនចាប់ នោះបាន ។

ខ្ញុំស្បង់ទឹកលាងមុខ ទើបដឹងថាខ្លួនឯងកំពុងញញឹម ខ្ញុំញញឹមធ្វើអីនេះ?

ខ្ញុំត្រូវតែខឹង ខ្ញុំត្រូវរំលោភបំពាន...អឺ ទោះត្រឹមលើកដំបូងក៏ដោយ ក្រោពីនោះគឺ...យល់ព្រម ។

ទឹតៗ!

សំឡេងទូរសព្ទដៃរបស់ខ្ញុំរោទ៍ ជាភ្លេងឡានសង្គ្រោះបន្ទាន់ ជាសំឡេងហៅចូលសម្រាប់លេខរបស់ ស្វាមី អឺ...លេខរបស់ អឹនចាប់ តែម្នាក់គត់ ។

ខ្ញុំមើលទូរសព្ទដៃដែលដាក់លើអាងលាងមុខ ហើយក៏លើបយកកន្សែងពោះគោមរុំខ្លួន ហើយដើរទៅយក ។

"ហាឡូ"

(ដេកមិនលក់ ចង់ឱបអូន)

"..." ខ្ញុំនៅស្ងៀម ព្រោះបាសម្តីរបស់គេ...

(បងនឹកអូនដល់ហើយ ស្រឡាញ់អូនដល់ហើយ)

ខ្ញុំទទួលមិនទាន់នឹងពាក្យសារភាពស្នេហ៍នោះ ពេលដែលចង់និយាយគេក៏និយាយរួចបែបនេះ បេះដូងខ្ញុំលោតញាប់ ភ្លាយខ្ទឹបបបូរមាត់ មានអារម្មណ៍ដូចគេនៅជិត កំពុងបពោសអង្អែលខ្លួន

ប្រាណរបស់ខ្ញុំយ៉ាងអីចឹង ។

(បិទភ្នែកមិនជិត ឃើញតែមុខអូន...អូនងូតទឹកហើយមែន?

"កំ...កំពុងងូត"

(អីចឹងឬ...ចង់ងូតទឹកជាមួយដល់ហើយ យើងមិនទាំងបានរៀបមង្គលការល្អទេ?)

"ហេតុ...ហេតុអី?"

ខ្ញុំដូចមនុស្សត្រជាក់ភ្លាមពេលបានឮសំឡេងខ្សាវបែបនេះរបស់គេ អឹម...ខ្ញុំក្លាយជាស្រីពុះកញ្ជ្រោលទៅហើយឬ គ្រាន់តែ... គ្រាន់តែត្រូវគេឱបនៅថ្ងៃនេះធ្វើឲ្យខ្ញុំព្រឺសម្បុរ និងមានអារម្មណ៍ប្រហោងពោះព្រោះបានឮសំឡេងរបស់គេតាមទូរសព្ទ ។

"មិនចង់ចាំ មកនៅជាមួយគ្នាម៉ោ បើខ្លាចខូចឈ្មោះ យើងយកសំបុត្រអាពាហ៍ពិពាហ៍ចុះកាសែតល្អទេ?"

"មិនធ្វើទេ"

(ធ្វើទៅ)

សម្ដីរបស់គេស្អក មុខខ្ញុំក៏ក្រហមព្រោះដឹងន័យនៅក្នុងពាក្យសម្ដីខ្ទឹវនោះ អុំ...កុំ នេះខ្ញុំកើតអី ដាក់ទូរសព្ទចុះទៅ ដាក់ចុះ!

"កុំលាមកពេក អីនចាច់ ប៉ុណ្ណឹងចុះ អូនងូតទឹកដេកហើយ"

(លាងសាប៊ូស្អាតទេ...មិនចង់ឲ្យងូតសោះ ចង់ឲ្យទុកស្នាមស្នេហ៍របស់បងជាប់នឹងខ្លួនអូនឲ្យបានយូរ"

ខ្ញុំដាក់ទូរសព្ទចុះ ហើយសឹងតែធ្វើឲ្យទូរសព្ទធ្លាក់ពីដៃ ។

មនុស្សឆ្កួត! ថ្នាក់ខ្លួនមិននៅជិត នៅធ្វើឲ្យខ្ញុំទៅជាបែបនេះ បេះដូងរបស់ខ្ញុំលោតញាប់ ហើយខ្លួនខ្ញុំក៏...ដង្ហោយរកគេដូចគ្នា ។

ខ្ញុំញញឹមដាក់កញ្ចក់ដែលនៅពីមុខខ្លួនឯង ។

បងស្រលាញ់អូន...ពាក្យបីម៉ាត់នេះមែនទេដែលធ្វើឲ្យខ្ញុំមានក្ដីសុខ ពាក្យខ្សឹបខ្សៀវម្ដងហើយម្ដងទៀតដែល អីនចាច់ ប្រាប់

...ដែលគេព្យាយាមកែខ្លួនជាថ្មី ភាពផ្អែមល្ហែមបែបដែលមិនគិត ...មាននៅក្នុងខ្លួនគេ ដៃនិងរាងកាយរឹងមាំដែលទន់ភ្លន់ខុសពី ...លើកដំបូងដាច់ស្រឡះ...

ខ្ញុំញញឹមដាក់កញ្ចក់...អឹម...ខ្ញុំថាខ្ញុំស្រឡាញ់គេ ខ្ញុំស្រឡាញ់ ...អីនចាច់ តែ...ខ្ញុំមិនប្រាប់គេនៅពេលនេះទេ ខ្លាចគេបានចិត្ត ...ចាំ...យប់ថ្ងៃរៀបការចាំប្រាប់ ។

[Intouch's Talk]

ការធ្វើជាកូនកំលោះនេះហត់នឿយខ្លាំងណាស់ គិតខុសអស់ស្មានថាដូចក្នុងទូរទស្សន៍ដែលធ្លាប់ឃើញ ។

ម៉ាក់ខ្ញុំពាក់ឈុតហាន់បុកពណ៌ផ្កាឈូក មានទឹកមុខញញឹមញញែម និងម៉ាក់ក្មេក រួមទាំងបងថ្លៃ និងបណ្ដាសាច់ញាតិចាស់ទុំទាំងសងខាងឈរញញឹមញញែមដាក់ភ្ញៀវដែលមកចូលរួមពិធីមង្គលការរបស់ខ្ញុំ និង ស្លឹកតើយ ។

មានមនុស្សតិចតួចណាស់ដែលដឹងថាខ្ញុំ និង ស្លឹកតើយ ចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នារួចហើយ ប៉ុន្តែទោះយើងជាស្វាមីភរិយាស្របច្បាប់ក៏ដោយ ក៏អ្នកកាសែតនិងមហាជនភាគច្រើនមិនទាន់ដឹង ទើបខ្ញុំត្រូវប្រឹងញញឹមដាក់កាមេរ៉ារបស់ស្ថានីយទូរទស្សន៍ដែលតាមមកយកព័ត៌មាន ថែមទាំងឲ្យទាន់នឹងសំណួរជាច្រើន តែខ្ញុំក៏ត្រូវប្រឹងញញឹមឆ្លើយតបម្ដងមួយៗ ។

ប៉ុន្តែពេលដល់វគ្គពិសេស កូនក្រមុំត្រូវបាននាំចូលមកក្នុងព្រះវិហារ ដោយមានខ្ញុំនិងលោកអាចារ្យឈរចាំនៅលើវេទិកា ។

ស្លឹកតើយ នៅក្នុងឈុតកូនក្រមុំពណ៌ស មើលពីចម្ងាយស្រស់ស្អាត នាងកំពុងតែដើរសំដៅមករកខ្ញុំដោយទឹកមុខអឹមអៀនដែលធ្វើឲ្យបេះដូងរបស់ខ្ញុំរីកមានតែម្ដង ។

ខ្ញុំប្រសព្វភ្នែកជាមួយកូនក្រមុំមិនដាក់ភ្នែក ហើយពេលដែល
នាងត្រូវបានបញ្ជូនមកដល់ដៃរបស់ខ្ញុំ លោកអាចារ្យក៏ប្រកាសបើក
កម្មវិធីឲ្យយើងស្បថស្បែ បំពាក់ចិញ្ចៀនក្លាយជាស្វាមីភរិយានឹងគ្នា
ហើយក៏មានសំឡេងទះដៃនិងគាំទ្រឲ្យយើងបន្ត ដែលខ្ញុំក៏មិនដឹង
យ៉ាង ព្រោះរង់ចាំឱកាសនេះយូរណាស់មកហើយ ។

[End Intouch's Talk]

ហត់ណាស់ ខ្ញុំទើបតែដឹងថាការធ្វើជាកូនក្រមុំវាហត់ហ្នឹង
បែបនេះ ពិធីមង្គលការអធិកអធម និងដូចពិធីមង្គលការរបស់ព្រះ
នាង ។

ខ្ញុំដឹងថាផ្កាពណ៌សនៅក្នុងកម្មវិធីរបស់យើង អ៊ីនថាច់ ជាអ្នក
កុម្ម៉ង់ឲ្យក្រុមហ៊ុនរៀបចំកម្មវិធីដាក់ដល់ទៅបីសែនទង ទើបក្លិន
ក្រអូបរបស់លីលីពណ៌សសាយភាយពេញកម្មវិធី ។

ខ្ញុំញញឹមឡើងឈឺថ្ពាល់ដើម្បីថតរូប ដោយមានអ្នកនៅក្បែរ
ក្តោបដៃរហូត ។

ហើយនៅទីបំផុតពិធីមង្គលការក៏ចប់សព្វគ្រប់ ម៉ាក់របស់ខ្ញុំក៏
ជូនពួកយើងឡើងបន្ទប់ហាន់នីមូន បន្ទប់ស្វីតនៅជាន់លើបំផុត
របស់សណ្ឋាគារ ជាមួយបងស្រីនិងម៉ាក់របស់ អ៊ីនថាច់ ។

"នឿយទេអូនសម្លាញ់" អ្នកដែលដោះត្រ័រហ្សេពាក់នឹងដៃ និង
បន្ធូរក្រវាត់កទៅមកសួរ ។

ខ្ញុំងក់ក្បាល ហើយដើរសំដៅទៅសាឡុងពណ៌ផ្កាឈូកស្រស់
កណ្ដាលបន្ទប់ ។ លើតុមានបាច់ផ្កាកុលាបក្រហមស្រស់ និងដប
ស្រាក្នុងធុងទឹកកក ប្រហែលជាចង់ឲ្យកូនក្រមុំកូនកំលោះផឹកអប
អរ តែពេលនេះខ្ញុំចង់បានភេសជ្ជៈប៉ូវកម្លាំងដូចនៅក្នុងឃោសនា
ច្រើនជាង ព្រោះល្វើយដល់ហើយ ។

"ហត់ណាស់ ពិធីមង្គលការលើកក្រោយមិនរៀបចំបែបនេះ
ទេ" ខ្ញុំរអ៊ូទាំ តែគិតទៅឃើញ នេះខ្ញុំនិយាយស្អីហ្នឹង អ្នកណាគេរៀប
ការលើកទៅពីរដង...ខ្ញុំនឿយដល់ថ្នាក់ល្ងីល្ងើហើយ ។

ហើយសុខៗក្នុងបន្ទប់ក៏មានអាកាសធាតុត្រជាក់ភ្លាម ធ្វើឲ្យខ្ញុំ
ព្រឺសម្បុរ ហើយក៏ងាកទៅមើលកូនកំលោះដែលធ្វើមុខក្រញូវ ។

"អូននិយាយខុស មិនបានមានន័យបែបនោះទេ"

ខ្ញុំសើចហេះៗ តែ អ៊ីនថាច់ បែរជាមិនសើចជាមួយ ពេលនេះ
គេកំពុងដើរមករក ។

"វ៉ាយ!"

ខ្ញុំឧទានពេលត្រូវគេលើកបីដើរសំដៅបន្ទប់ដេកនៅខាងក្នុង...
គ្រែធំទូលាយមានស្រទាប់កុលាបពាយជារូបបេះដូងធំៗ តែអាមៀ
នេះបែរជាលើកខ្ញុំដោយដៃតែម្ខាង ហើយប្រើដៃម្ខាងទៀតទាញ
ភួយចេញ ធ្វើឲ្យស្រទាប់កុលាបខ្ចាតអស់...គួរឲ្យអាណិតអ្នកធ្វើ
ដល់ហើយ ។

"..."

ខ្ញុំបិទភ្នែកទទួលយកកម្លាំងបោះរបស់ អ៊ីនថាច់ តែថា...

"..."

ស្ងាត់...ទើបខ្ញុំបើកភ្នែកម្ខាងមើល មុននឹងបើកទាំងសងខាង
ពេលឃើញថា អ៊ីនថាច់ មិនបានបោះខ្ញុំ...គេមើលខ្ញុំមិនដាក់ភ្នែក
មុខសង្ហាដូចរូបចម្លាក់នោះមិនបានក្រញូវ ឬសោកព្រោះដូចមុន
នេះ ផ្ទុយទៅវិញគេកំពុងតែមើលខ្ញុំដោយខ្សែភ្នែកកក់ក្ដៅទន់ភ្លន់ ។

"បង អ៊ីនថាច់"

"ថ្ងៃនេះអូនស្អាតខ្លាំងណាស់ ដឹងទេ"

"ដឹង"

ខ្ញុំងក់ក្បាល ព្រោះតាំងពីព្រឹកមានតែអ្នកសរសើរ ហើយខ្ញុំក៏

ស្អាតមែនហ្នឹង ។

"..."

អ៊ីនចាច់ ធ្វើមុខញញឹមក៏មិនមែន សើចក៏មិនចំ គេជ្រួញចិញ្ចើម ហើយក៏ឱនមករក ព្រមទាំងសង្កត់ច្រមុះស្រួចរបស់គេនឹងថ្ពាល់ខ្ញុំ និងមិនត្រឹមតែច្រមុះទេ នៅមានបបូរមាត់របស់គេដែរ ។

"ត្រជាក់ចិត្ត នឹកប្រពន្ធសឹងតែដាច់ខ្យល់"

"ជ្រុលពេកដែរទេ"

"មិនជ្រុលទេ ជិតដាច់ខ្យល់មែន"

"ចុះកាលមុនគ្មានប្រពន្ធរស់នៅយ៉ាងម៉េច អំ...ភ្លេចទៅស្រីឡូតរគោក"

"ប្រចណ្ឌឬ?" អ៊ីនចាច់ ញញឹម ។

"មិនប្រចណ្ឌ" ខ្ញុំកុហកទៀតហើយ ។

"ប្រចណ្ឌទៅ តែចាប់ពីពេលនេះទៅបងមានតែអូនម្នាក់ មិនយកភ្នែកមើលអ្នកណាទៀតទេ"

អឺម...សាកល្បងជឿមើលម្តងចុះ...ខ្ញុំញញឹមដាក់គេ ហើយអ៊ីនចាច់ ក៏ធ្វើមុខដូចស្រឡាំងកាំង មុននឹងដាក់ខ្ញុំលើគ្រែយ៉ាងស្រាលដៃនិងថ្នមៗ...ទន់ភ្លន់ដាក់ខ្ញុំក៏ចេះធ្វើដែរ បើធ្វើបែបនេះតាំងពីដំបូង ខ្ញុំស្រឡាញ់តាំងពីដំបូងម្លេះ ។

# ១២
# រាត្រីផ្សំដំណេក

"បង អ៊ីនចាច់ មិនងូតទឹកសិនទេឬ?"

ខ្ញុំសួរពេលឃើញគេដោះអាវ បេះដូងក៏លោតញាប់ដល់[illegible]

។

ទោះធ្លាប់នៅក្នុងរង្វង់ដៃរបស់គេ តែ...ពេលនៅក្រោមខ្សែ[illegible]
ដែលមើលមកដោយការប្រាថ្នារបស់គេ ខ្ញុំមានអារម្មណ៍ដូចខ្លួន[illegible]
រលាយតាមធាតុអាកាស ។

"អូនចង់ងូតទឹកឬ?"

"..." ក្តៅពេញមួយថ្ងៃទៅហើយ ញើសជោកខ្លួនបែបនេះ[illegible]
...មិនជឿជាក់ "ចង់"

"បើអ៊ីចឹងយើងងូតជាមួយគ្នា"

ហើយគេក៏ទាញខ្ញុំឲ្យងើប មុននឹងលូកដៃមកក្រោយខ្នង[illegible]
ខ្ញុំ ហើយទាញរូតរែងរបស់រ៉ូបពណ៌សមកដល់កំប៉េះគូទ ខ្ញុំក៏ប[illegible]
លើកដៃទប់រ៉ូបត្រង់ដើមទ្រូង ប៉ុន្តែក៏ត្រូវគេបេះដៃចេញ ។

"បកសម្បក"

គេប្រាប់ដោយសំឡេងស្រទន់ ព្រមទាំងសម្លឹងមើលភ្នែក[illegible]
ខ្ញុំ ទើបខ្ញុំដឹងខ្លួនថាចាញ់ខ្សែភ្នែកស្រទន់របស់ អ៊ីនចាច់ ហើយ ។

"អូនមិនមែនទុរេន"

"ជាតិពុលនៅជុំវិញខ្លួន[illegible]ទុរេនទៅទៀតអូនសម្លាញ់" [illegible] ។

ខ្ញុំធ្វើមុខក្រញូវ មុននឹង[illegible] ខ្ញុំក៏ខ្ទប់មាត់[illegible]

អ៊ីនចាច់ ញញឹម[illegible]ដែល[illegible]
បណ្តោយឲ្យរ៉ូប[illegible] ។
ទៅត្រាំទឹក[illegible]

អ៊ីនថាច់ ក៏មើលមកដោយខ្សែភ្នែកសរសើរ...

"ស្លឹកតើយ..."

"ចាំ" ខ្ញុំងើបមុខមើលគេ ។

"បងស្រឡាញ់អូន"

"ហើយយ៉ាងម៉េច ?"

អ៊ីនថាច់ ធ្វើមុខម្លឹកម្លក់ ។

អាំ...គេធ្វើមុខម្លឹកម្លក់បានគួរឲ្យស្រឡាញ់បំផុត អាំយយយ!

"អូនស្រឡាញ់បងដែរទេ ?"

គេសួរ ព្រមទាំងលូកដៃមកទាញស្បៃមុខពីក្បាលរបស់ខ្ញុំ ដោយថ្នមដៃខ្លាំងបំផុត ។

"ហើយបងធ្វើខ្លួនគួរឲ្យស្រឡាញ់ដែរទេ ?" ខ្ញុំសួរវិញ ។

គេញញឹម សាកជ្រុងសក់របស់ខ្ញុំ ហើយឈ្លីក្បាលតិចៗ អឹម...ស្រួលខ្លួនដល់ហើយ ម្រាមដៃគេនេះ...ល្អដល់ហើយ ប៉ះត្រង់ណាក៏គួរឲ្យភ្លើតភ្លើន អាំ...ឈប់សិនៗ!

"បើបងងូតទឹកឲ្យអូនរាល់ថ្ងៃ អូននឹងស្រឡាញ់បងទេ ?"

"អូនងូតខ្លួនឯងក៏បាន"

"តែងូតមិនស្អាតដូចបងងូតឲ្យ"

"ករគេ"

ខ្ញុំធ្វើមាត់ស្រួចបែបដែលមិនធ្លាប់ធ្វើ អេ៎...ឈប់សិន ខ្ញុំទៅយកមាយាស្រីអស់នេះមកពីណានេះ ?

"អីចឹងបងម៉ាស្សាឲ្យរាល់ថ្ងៃ"

"អឹម...គឺត្រូវចាំមើលសិន"

អ៊ីនថាច់ ញញឹម គេសង្ហាខ្លាំងណាស់ ហើយក៏រំកិលដៃទៅក្រោយ ប្រឡេះតម្លក់អាវក្នុងដ៏សែនស្អាតរបស់ខ្ញុំ...ខ្ញុំញ័រស្មា ទោះមិនមែនលើកដំបូង តែក៏នៅតែអឹមអៀន ខ្សែភ្នែកដែលគេមើលមក

ធ្វើឲ្យបេះដូងខ្ញុំញ័រ ដៃជើងក៏ត្រជាក់អស់ ។

"បើអីចឹងបងនឹងធ្វើឲ្យអស់ពីសមត្ថភាព"

ធ្វើ...ធ្វើអីទៀតហើយ ស្លឹកតើយ នាងនេះគួរឲ្យស្អប់ខ្ពើម ធ្វើជាមិនដឹងខ្យល់អី តែហេតុអីពេលនេះខ្ញុំផ្អើលសឹងស្លាប់ ។

អ៊ីនថាច់ អង្គុញជើង ព្រមទាំងទាញកំណាត់ចុងក្រោយដែលទាក់នឹងត្រគាករបស់ខ្ញុំចុះ ។

ខ្ញុំអត់ដង្ហើមពេលដែលគេងើបឈរ ហើយលើកបី...អ៊ីនថាច់ រឹងមាំខ្លាំងណាស់ គេបីខ្ញុំដើរសំដៅបន្ទប់ទឹក ខ្យល់ដង្ហើមក៏មិនដង្ហក់ដែរ ។

បន្ទប់ទឹករបស់បន្ទប់ហាន់នីមូនទាំងធំទាំងស្អាត កម្រាលក្រាលដោយការ៉ូពណ៌ផ្កាឈូក អាងងូតទឹកធំមហិមា...ខ្ញុំឱបស្មារបស់ អ៊ីនថាច់ ពេលដែលគេបន្ទន់ខ្លួន ហើយដាក់ខ្ញុំក្នុងអាងទឹកក្តៅឧណ្ហៗដែលមានស្រទាប់កុលាបអណ្តែតត្រាលើផ្ទៃទឹក ។

"..."

អ៊ីនថាច់ ឈរនៅចំពោះមុខខ្ញុំ គេដោះអាវនិងខោដោយចិត្តត្រជាក់ ខណៈដែលភ្នែកនៅតែសម្លឹងមើលខ្ញុំមិនដាក់ [illegible] ននលតកដូចគ្នា ទើបខ្ញុំដឹងថារាងកាយរបស់មនុស្សប្រុស[illegible] ពេលបានមើលអ្នកដែលមានឈ្មោះថាជាស្វាមី[illegible]ពេញភ្នែក ។

"ស្លឹកតើយ"

គេហៅឈ្មោះខ្ញុំម្តងទៀត មុននឹងចុះមកក្នុងអាង ខ្ញុំក៏ព្យាយាមមិនមើលត្រង់...តែថាភ្នែក[illegible]មើលមិនបាន មើល[illegible]របស់គេ[illegible] ខ្ញុំមិនស្គាល់បុណ្យ[illegible]ទៅហើយ ។

"ស្រីឆ្កួតកាប"

អ៊ីនថាច់ និយាយដោយសំឡេងលាយឡំសំណើច ទើបខ្ញុំ[illegible] ទាំងដែល[illegible]មកមែនហ្នឹង ។

"គ្មានទេ"

"មានមោទនភាពទេដែលបានបងជាប្តី?"

គេនៅតែមុខក្រាស់ដដែល មិនចេះខ្មាស...ខ្ញុំពេបមាត់ដាក់ ហើយក៏ភ្ញាក់ព្រើត ស្រែចខឹកៗដូចមនុស្សឆ្កួត ព្រោះត្រូវ អ៊ីនចាច់ ចាក់ចង្កេះ ។

"អ៊ូយ កុំ ហាសៗ កុំ ខឹកៗ"

ខ្ញុំប៉ើហើយប៉ើទៀត ភ្លេចភាពញាប់ញ័ររបស់លើងពេលដែលត្រូវ ចាក់ចង្កេះ ធ្វើឲ្យប៉ើបម្រះពេញអាង ។

ទឹកនៅក្នុងអាងកើតជារលក ខ្ញុំប៉ើបម្រះហើយក៏ស្រែចទាល់តែ ឈឺថ្ពាល់ ទើបចាក់ចង្កេះគេវិញ ធ្វើឲ្យ អ៊ីនចាច់ រមួលខ្លួនគេច ។

សង្គ្រាមចាក់ចង្កេះនៅក្នុងអាងទឹកជំកំដំណើរការជាច្រើននាទី រហូតដល់...

ពឹប!

ខ្ញុំបើកភ្នែកធំៗ អ៊ីនចាច់ ក៏បើកធំៗដូចគ្នា យើងមើលមុខគ្នា មុននឹងមុខរបស់គេក្រហម ហើយគេក៏លេបទឹកមាត់ក្អឹកៗ យើង ទាំងពីរក៏ឈ្ងោកមើលដៃរបស់ខ្ញុំដែលផ្ដោយស្រវាចាប់នោះ...

"អាំ"

"អឺម...តាមពិតបងក៏ចូលចិត្ត តែយកល្អកុំប្រើក្រចកបានទេ"

វ៉ាយ...ខ្ញុំភ្ញាក់ព្រើត រហ័សលែងដៃ បរិយាកាសអម្បាញ់មិញ រលាយបាត់អស់ ក្លាយជាអារម្មណ៍មួយបែបទៀត ។

អ៊ីនចាច់ ក្តោបចង្ការបស់ខ្ញុំ មិនព្រមឲ្យខ្ញុំគេចខ្សែភ្នែក ។

"ស្រឡាញ់បងខ្លះហើយនៅ ស្លឹកតើយ ?"

"..."

គេសួរម្តងទៀត ខ្ញុំក៏មើលមុខរបស់បុរសនៅចំពោះមុខ... ញញឹម ។



"ស្រឡាញ់"

"..."

អ៊ីនចាច់ ធ្វើមុខដូចមិនចង់ជឿ មានន័យថាអម្បាញ់មិញគេ មិនបានសង្ស័យថានឹងបានចម្លើយនេះពីខ្ញុំ គ្រាន់តែសួរចោល ប៉ុណ្ណោះ ។

"មែនឬអត់ ?"

"អូនធ្លាប់កុហកឬ ?"

ខ្ញុំតបដោយសំឡេងរងក់ សំឡេងដែលខ្លួនឯងទើបតែដឹង ថាធ្វើដូចមនុស្សស្រីទូទៅដែរ វាទៅកើតស្អីទៅ ខ្ញុំចង់ម៉្ងឹកម៉្ងក់ដាក់ ស្វាមី វាមិនខុសអីបន្តិចទេ ។

"អរគុណដែលស្រឡាញ់បង បងក៏ស្រឡាញ់អូន ស្រឡាញ់ ខ្លាំងបំផុត តែអូនស្រឡាញ់បងតាំងពីពេលណា មុនរំលោភឬ ក្រោយរំលោភ ?"

"មើលគេនិយាយ មិនចេះខ្មាស"

"ខ្មាសហើយបានប្រពន្ធឬ...មែនទេ ?"

អ៊ីនចាច់ ញញឹម ញញឹមទាំងភ្នែកញញឹមទាំងមាត់ ។

ខ្ញុំមិនតប ព្រោះជាពេលនេះដូចអណ្តាតភណែនពេញមាត់ ដៃ ដែលស្រវាចាប់ចំរបស់អម្បាញ់មិញក៏ក្តៅគាយៗ ។

អ៊ីនចាច់ ញញឹមដាក់ខ្ញុំម្តងទៀត មុននឹងទាញខ្ញុំទៅអង្គុយលើ ភ្លៅរបស់គេ...អាងបាគុស៊ីមានទំហំធំ អាចឲ្យយើងដេកត្រាំទឹក បាន តែ អ៊ីនចាច់ បែរជាសន្សំសំចៃផ្ទៃក្រឡាដោយការទាញខ្ញុំឲ្យ ទៅអង្គុយលើភ្លៅបកដូចកូនក្មេង...ហើយរបស់ដែលខ្ញុំស្រវាចាប់ ពេញដៃអម្បាញ់មិញ ពេលនេះវាបៀតនឹងកំប៉េះគូទ អឹម...ខ្ញុំ...ខ្ញុំ កើតអី មើលបានជាមានអារម្មណ៍ឆឹតពោះបែបនេះ ?

... ដៃរបស់គេក្តៅ តែខ្ញុំបែរជាត្រជាក់...

ត្រជាក់ ទឹកក្ដៅឧណ្ហៗប៉ុន្តែបែរជាធ្វើឲ្យព្រឺសម្បុរ ។

អឺម...វាច់ជាមិនស៊ីគ្នាអីយ៉ាងនេះ!

"អាំ...អូនទន់ល្មើយដល់ហើយ ទន់សព្វសាច់"

"អ៊ិនថាច់"

ខ្ញុំហៅឈ្មោះរបស់គេ ព្រោះមិនដឹងថានិយាយអី មាត់របស់គេបបោសអង្អែលចង្កា ថ្ពាល់ និងស្លឹកត្រចៀក...គេអូសធ្មេញលើស្បែករបស់ខ្ញុំតាំងពី.កទៅដល់ដើមទ្រូង ដោយមានដៃរបស់គេប្របាច់ខ្លាំងផងតិចផងឆ្លាស់ប្ដូរគ្នា ។

អារម្មណ៍ស្រៀវស្រើបរត់សព្វសាច់ ខ្ញុំខាំបបូរមាត់ក្រោម ងើយមុខឲ្យ អ៊ិនថាច់ ទើបរាងកាយបានយ៉ាងស្រួល ដៃក៏ខ្ទាំស្មារបស់គេខ្លាំងៗដែរ ។

"អ្ហឹម...អ៊ិនថាច់ អូន...អូន"

ខ្ញុំថ្ងូចថ្ងូរដោយការឈឺចាប់ ពេលដែលបបូរមាត់ក្ដៅគគុករបស់គេបឺតជញ្ជក់ដើមទ្រូងរបស់ខ្ញុំខ្លាំងៗ ។

"..."

គេមិនតបត តែលើកខ្លួនខ្ញុំមុននឹងសង្កត់ចុះវិញ ។

"អ្ហឹម! អ្ហាំ!"

ខ្ញុំភ្ញាក់ព្រើត ស្រវាឱបកគេ ពេលដឹងថាកំពុងតែសង្កត់ខ្លួនឯងគ្រប់គ្រងគេបន្តិចម្ដងៗ ទឹកជួយឲ្យរាងប្រសើរឡើង...ទោះធ្លាប់ឆ្លងកាត់រឿងបែបនេះជាមួយគេរួចទៅហើយ ប៉ុន្តែវាពិបាកខ្លាំងណាស់ ការឈឺចាប់កាលនោះវាមិននៅសល់ ប៉ុន្តែនៅតែថប់ដង្ហើម និង... អ៊ូយ...ខ្ញុំ ខ្ញុំ...ខ្ញុំកំពុងតែគ្រប់គ្រង អ៊ិនថាច់!

"អ្ហាំ"

សំឡេងរបស់ អ៊ិនថាច់ បន្លឺឡើងក្នុងបំពង់កដូចរាងរបួស ថ្ងូចថ្ងូរខ្លាំងផងធ្វើសំឡេងស្រៀវស្រើបផងឆ្លាស់ប្ដូរគ្នា ហើយដៃដែលគេ

ចាប់ត្រគាករបស់ខ្ញុំនោះ ក៏នាំខ្ញុំឲ្យសង្កត់រាងកាយរបស់គេទាល់តែអស់ ។

"អ្ហឹម..."

ខ្ញុំខ្ទាក់ក្រញាង ហើយក៏បញ្ចេញសំឡេងគួរឲ្យខ្មាសចេញមកពេលដែលកម្រើកខ្លួនតាមចង្វាក់នៃការដឹកនាំរបស់ អ៊ិនថាច់ ។ ភាពស្រៀវស្រើបនិងតឹងណែន ធ្វើឲ្យខ្ញុំស្ទើរតែទៅជាឆ្កួត អ៊ិនថាច់ ក៏ដកដង្ហើមដង្ហក់ ដៃរបស់គេស្ទាបអង្អែលខ្នងរបស់ខ្ញុំ បបូរមាត់ក៏បបោសអង្អែលដើមទ្រូងរបស់ខ្ញុំដែលជីតផត ហាក់ដូចវាជាម្ហូមដ៏សប្បាយ ។

សំឡេងខ្យល់ដង្ហើមរបស់យើងបន្លឺឡើងដំណាលគ្នា និងញាប់ស្លេកដូចគ្នា រហូតដល់ខ្ញុំមានអារម្មណ៍ដូចត្រូវគេគ្រវែងឡើងទៅទីដ៏ខ្ពស់ ហើយក៏ធ្លាក់ចុះមកវិញយ៉ាងលឿន...សំឡេងស្រែកតិចៗរបស់ខ្ញុំរត់ចូលបបូរមាត់របស់ អ៊ិនថាច់ ហើយស្របពេលនោះគេក៏ស្រែកគ្រហឹមខ្លាំងៗ និងឱបខ្ញុំណែនដូចគ្នា ។

[Intouch's Talk]

ខ្ញុំមើលមនុស្សស្រីក្នុងឈុតពណ៌លឿងខ្ចីដែលអង្គុយទល់មុខដោយក្ដីស្រឡាញ់ ។

មែន! ខ្ញុំទាំងស្រឡាញ់ទាំងបំពងព្រាថ្នា ។

ស្លឹកតើយ កំពុងតែរីករាយនឹងការភ្លក្សនំខេកក្នុងហាងល្បីតំបន់ហារ៉ាជុកុ នៅប្រទេសជប៉ុន ដែលខ្ញុំនាំនាងមកបន្ទាប់ពីរៀបការបានមួយខែ ។

តាមពិត ម៉ាក់ៗរបស់យើងចង់ឲ្យយើងទៅតំបន់អឺរ៉ុបតាំងពីថ្ងៃរៀបការដំបូងម្ល៉េះ ប៉ុន្តែព្រោះថាការងារវាមានច្រើនដៃ ហើយខ្ញុំក៏គ្មានពេលទំនេរច្រើនដល់ម្លឹង ទើបព្រមព្រៀងជាមួយ ស្លឹកតើយ ថា

យើងមិនទៅ ជូនអីខ្ញុំមកចរចាជំនួញនៅជប៉ុនល្មម ទើបបបួលនាងមកដែរ ។

យើងព្រមព្រៀងគ្នាថាមកដើរលេងជប៉ុនសិន ហើយបន្ទាប់ពីខ្ញុំបាត់បែងរឿងការងាររួចរាល់ ខ្ញុំនឹងនាំនាងទៅហាន់នីមូនម្តងទៀតនៅអឺរ៉ុប ។

"បងមិនញ៉ាំទេឬ?" នាងសួរ ។

"អត់ទេ មើលអូនញ៉ាំក៏ឆ្អែតឆ្អន់ទៅហើយ"

"ឆ្ងាញ់គ្រប់មុខ ភ្លក្សមើល៍"

ខ្ញុំហាមាត់ទទួលយកខេកដែលស្រីតូចរបស់ខ្ញុំបញ្ចុកហើយទំពា មុននឹងពេបមាត់ស្បែប ។

"មិនឆ្ងាញ់ឬ ម៉េចក៏បងធ្វើមុខអីចឹង?"

"មិនឆ្ងាញ់ តែអូនឆ្ងាញ់ជាងឆ្ងាយណាស់"

ប៉ុណ្ណឹង...មុខរបស់ភរិយាដ៏ស្រស់ស្អាតក៏ក្រហមនិងញញឹមអឹមអៀនទៅហើយ ។

ស្លឹកតើយ ជាមនុស្សស្រីដែលនៅជាមួយហើយមិនធុញទ្រាន់ ខ្ញុំស្រឡាញ់នាង និងស្រឡាញ់ខ្លាំងឡើងៗជារៀងរាល់ថ្ងៃ ។

"ស្អែកទៅវិញហើយ អូនចង់ទៅទិញអីវ៉ាន់ផ្ញើអ្នកផ្ទះ"

"តាមចិត្ត"

ស្លឹកតើយ ញញឹមឡើងថ្ពាល់ប៉ោងភ្នែកលិប ខ្ញុំក៏អត់មិនបាននិងខិនទៅថើបថ្ពាល់នាងមួយខ្សឺត ។

សំឡេងស្រែកគ្រិតនៅក្បែរៗ ធ្វើឲ្យយើងទាំងពីរងាកទៅមើល...ក្មេងស្រីថ្នាក់មធ្យមក្នុងឯកសណ្ឋានសិស្សសាលាជប៉ុនក៏មើលយើង ហើយសើចខឹកៗ មុខក៏ឡើងក្រហម ។

"គួរឲ្យស្រឡាញ់ហ្ន៎ស្រីជប៉ុន"

មាត់សរសើរ តែសំឡេងរបស់ ស្លឹកតើយ ស្តាប់ទៅរឹងកំពើស



ទើបខ្ញុំងាកមកមើលមនុស្សប៉ុនប្រចណ្ឌ ។

"ធ្វើសំឡេងបែបនេះទៀតហើយ ប្រចណ្ឌបងឬ?"

"គឺធ្លាប់មានព័ត៌មានជាមួយស្រីជប៉ុនហ្នឹងណា៎"

ខ្ញុំលើកចិញ្ចើម មុននឹងស្រែក អំ ក្នុងចិត្ត ។

"ណាអូមិ ឬ?"

"មានអ្នកដទៃទៀតឬអត់?"

ស្លឹកតើយ ត្បូកសួរខ្ញុំទៀត ខ្ញុំក៏អស់សំណើច ហើយបានឮសំឡេងដកដង្ហើមធំពីយុវតីនៅក្បែរម្តងទៀត ។

"គ្មានទេ ជាមួយ ណាអូមិ បងមិនធ្លាប់មានស្អីៗជាមួយ ឬគិតចង់មានស្អីៗជាមួយស្រីម្នាក់នោះ នាងគ្រាន់តែចង់ព្យាយាមបង្កើតព័ត៌មាន ដើម្បីតោងឈ្មោះបងល្បីតែប៉ុណ្ណោះ"

ស្លឹកតើយ ជ្រិមភ្នែកមើលខ្ញុំ និងលើកស្លាបព្រាចង្អុលមុខ ។

"ប្រាកដហើយ?"

"ប្រាកដ១០០ភាគរយ បញ្ចប់ត្រឹមប្រពន្ធតែម្នាក់"

បបូរមាត់ស្រស់របស់នាងមានស្នាមញញឹម ។

"អំ...ហើយម្យ៉ាងទៀត អ្វីដែលបងចង់ប្រាប់អូន"

"ស្អីគេ?"

"ណាអូមិ ឈ្មោះដើម យូរិ ជាស្រីកូរ៉េ មិនមែនជាស្រីជប៉ុន តែទៅធ្វើមុខ ហើយប្តូរឈ្មោះប៉ុណ្ណោះដែរ"

"មែនក៏អី?" ស្លឹកតើយ ដំឡើងសំឡេង ។

"មែន" ខ្ញុំងក់ក្បាល ។

"ឃើញថាពេលនេះរបស់ហើយ មិនបានបាត់កូនចិតខាងកូរ៉េ តែទៅធ្វើជាក្រិតគិ"

"..." ភរិយារបស់ខ្ញុំងក់ក្បាល ។

ខ្ញុំប្រាប់ការពិតនាងមិនអស់ថាមូលហេតុដែល ណាអូមិ ឬ

កញ្ញា យូរី នោះក្លាយជាតារាអាប់រស្មី ព្រោះខ្ញុំមានចេតនាសុំឲ្យមិត្តភក្តិដែល ធំ នៅក្នុងវិស័យនោះជួយ ។

តាមពិតខ្ញុំគ្មានចេតនាលេងខ្លាំងដល់ថ្នាក់នោះទេ តែបើមិនដោយសារស្រីម្នាក់នោះ ស្លឹកតើយ របស់ខ្ញុំក៏មិនខឹងនិងឈឺចាប់ដែរ ។

"មិនគួរឲ្យជឿហ្ន៎"

ស្លឹកតើយ ប្រាប់ហើយក៏ជួសខេកញ៉ាំបន្ត ។

សំឡេងទូរសព្ទដៃរបស់នាងរោទ៍ ទើបនាងទាញមើល ហើយជ្រួញចិញ្ចើម ។

"ក្លាមខ្មែរ" នាងចុចទទួល "យ៉ាងម៉េចដែរ ក្លាមខ្មែរ"

ខ្ញុំមើល ស្លឹកតើយ និយាយទូរសព្ទ ព្រមទាំងលើកពែងកាហ្វេផឹក ។

"មែនក៏អី ហើយខ្ញុំទៅជួយស្អីបាន...អ់...អឹមៗ ចាំសាកល្បងមើល ប៉ុណ្ណឹងចុះ ចាំយៗ"

"មានបញ្ហាអីឬអត់ មិត្តភក្តិអូនសុំជំនួយអី ?"

ខ្ញុំសួរពេលនាងដាក់ទូរសព្ទចុះ ស្លឹកតើយ ក៏ធ្វើមុខលំបាកចិត្ត នាងខាំបបូរមាត់បន្តិចដូចកំពុងពិចារណា តែដឹងទេថាវាគឺជាកាយវិការសិចស៊ីទាក់ប្តី ។

"លោកប្តី ក្លាមខ្មែរ គេមកប្រាប់ថា មិត្តភក្តិបងឈ្មោះ គីតេ ពេលនេះមករញ៉េរញ៉ៃនៅក្រុមហ៊ុនរបស់នាង ទាំងព្រឹកទាំងល្ងាច ថែមទាំងផ្ញើបាច់ផ្កាឲ្យរាល់ថ្ងៃ តាំងពីថ្ងៃរៀបការរបស់យើងរហូតមកដល់ពេលនេះ"

ឃើញទេ...ខ្ញុំគិតអីចេះខុស ឃើញខ្សែភ្នែករបស់វាពេលដែលមើលមិត្តភក្តិរបស់ ស្លឹកតើយ ខ្ញុំក៏មានប្រផ្នូលទៅហើយ មិនស្មានថា គីតេ វាយលុកបែបនេះសោះ ។ មួយរយៈក្រោយនេះខ្ញុំមិនបាន

ទៅផឹកលេងពេលយប់ជាមួយវា ព្រោះចាំដោះចង្កូមដោះក្រញាំជាមិត្តស្និទ្ធហើយ ធ្វើជាឆ្មាសាំងក្នុងរង្វង់ដៃរបស់ ស្លឹកតើយ ។

តែមិនមែនថាខ្ញុំមិនដឹងសកម្មភាពរបស់ គីតេ នោះទេ អាមៀនោះក៏យប់ដើរលេងដែរ ថែមទាំងឈប់រវីរវល់នឹងស្រីៗក្នុងស្តុករបស់វាទៀតផង ។ មើលទៅ ក្លាមខ្មែរ ប្រហែលជាគេចពីវាមិនផុតនោះទេ បើសិន គីតេ ធ្វើដល់ថ្នាក់នេះទៅហើយ ធានាបានថាមិត្តភក្តិកំលោះព្រានរបស់ខ្ញុំកំពុងតែដោះចង្កូមព្រោះស្រីតូចថ្លាល់ចោង ម្នាក់នោះ ។

"បងជួយអីមិនបានទេ ប្រាប់ឲ្យមិត្តភក្តិអូនគេហៅប៉ូលិសទៅ"

"បានឬ ចេះនិយាយលេងទៅកើត ប្តឹងប៉ូលិសតីបទអី ?"

"តាមតែគេទៅ អូនឆ្អែតហើយនៅ ?"

"ចាំ"

"អីចឹងតោះ"

ខ្ញុំដាក់លុយលើតុ ហើយក៏ដឹកដៃ ស្លឹកតើយ ដើរចេញពីហាង តូចនោះភ្លាម ។

យើងស្នាក់នៅសណ្ឋាគារប្រណីតនៅក្នុងក្រុង បន្ទាប់ពីចប ជំនួញរួចរាល់ ខ្ញុំក៏បដិសេធឡានរបស់ដៃគូជំនួញដែលទុកជូន យើងដើរលេង និងមិនប្រើប្រាស់សេវាកម្មឡានទំនើបដែល ចំណាយលុយច្រើនដើម្បីនាំទៅណាមកណា នោះមកពីខ្ញុំចង់ដឹក ដៃ ស្លឹកតើយ ដើរលេងច្រើនជាង នាងក៏ចូលចិត្តបែបនេះដែរ ។

ខ្ញុំមើលស្លាកនៅនឹងថ្នល់ ហើយក៏ញញឹមដាក់យកមកបបួល ។

"អូនសម្លាញ់ ចូលទៅ"

"អ៎...ស្អីគេ ?"

"តោះ"

ខ្ញុំញញឹម ហើយក៏ដឹកដៃនាងចូលអគារដែលសាងសង់ដូច

ប្រាសាទព្រះនាង ដែលមានស្លាកជាភាសាជប៉ុននៅខាងក្រោម ជាអក្សរប្រាប់ថាជាសណ្ឋាគារ ។

[End Intouch's Talk]

# ១៣
# អ៊ីនថាច់ ឈឺរោគអី?

អ៊ីនថាច់ នាំខ្ញុំដើរចូលប្រាសាទពណ៌ផ្កាឈូក ។

ខ្ញុំក៏គ្មានចំណេះដឹងភ្នែកភាសាជប៉ុនដែរ ពេលឃើញរូបភា... ដែលស្រីស្អាតគួរឲ្យស្រឡាញ់យកមកឲ្យរើស ខ្ញុំក៏ដឹងភ្លាមថាស្វា... ព្រែកកាមលេងទៀតហើយ ។

នេះជាសណ្ឋាគារប្រភេទដែលហៅថា Love Hotel ហើយ... ព្រោះថាខ្ញុំរវល់តែមើលរូបអស់នោះ និងការតុបតែងដែលគួរឲ្... ស្រឡាញ់ ដឹងខ្លួនម្តងទៀតក៏ត្រូវស្វាមីដឹកដៃចូលបន្ទប់ដែលគេ... ជ្រើសរើសទៅហើយ ។

"ស្អាតទេ គួរឲ្យស្រឡាញ់ហ្ន៎"

"បងនាំអូនចូលមកធ្វើអី?" ខ្ញុំសួរទាំងដែលដឹងចម្លើយ ។

អ្នកដែលដើរពិនិត្យនេះពិនិត្យនោះក៏ងាកមកញញឹម ។

"នាំមកសម្រាក"

"ប្លាស់ហើយ មិនចាំបាច់សម្រាកទេ អូនមិនហត់អីបន្តិចទេ"

"មិនដឹងទេ"

អ្នកដែលមានមាឌធំជាងធ្វើសំឡេងមានគួរឲ្យគួរញ ព្រម ទាំងលើកខ្នោះដែលពណ៌ផ្កាឈូកបង្ហាញ ហើយញញឹម ។

ឃើញទេ...កម្រិតនៃភាពព្រែកកាយនៅតែមានដូចដើម ស្វាមី របស់ខ្ញុំជាមនុស្សស្មើគ្រប់ស្មើដើម ព្រែកកាយប៉ុណ្ណឹងតាំងពីមុនរៀប ការ រហូតដល់សព្វថ្ងៃនេះនៅតែព្រែកកាយបែបនោះមិនថយចុះ ។

"នេះកណ្តាលថ្ងៃប្លែកអត់ទេ អូនខ្លាស"

"កណ្តាលថ្ងៃមិនធ្លាប់?" ស្វាមីខ្ញុំដំឡើងសំឡេងបង្អាប់ ។

"កណ្តាលថ្ងៃក៏ធ្លាប់...ខ្ញុំលើកដៃអង្អែលថ្ពាល់អឹមអៀន ។

... ក៏ធ្លាប់ញឹកញាប់...

"ទីនេះគេធ្វើបន្ទប់គួរឲ្យស្រឡាញ់សិនអី មកហើយមិនសាកមើលបន្តិចទេឬ"

អ៊ីនថាច់ សួរ ព្រមទាំងដោះអាវ ហើយដើរទៅអង្គុយលើគ្រែពណ៌ស្រស់ មុននឹងលោតអុកគូទនឹងពូកលេងដោយទឹកមុខដែលប្រាប់ឲ្យដឹងថាកំពុងគិតអី ។

"ម៉ោ ឲ្យឆាប់ឡើង" ដៃរបស់គេទះពូកផាច់ៗ ខ្ញុំក៏ធ្វើភ្នែកឡេងឡាម តែក៏ដើរទៅរក ។

អ៊ីនថាច់ ទាញខ្ញុំឲ្យអង្គុយលើភ្លៅ មុននឹងឱបចង្កេះជាប់ ង៉ិបមុខនឹងខ្នងរបស់ខ្ញុំ ហើយធ្វើសំឡេងម្ញីកម្ញ៉ក់ ។

"ចង់ឱបរហូត បើមិនទាស់ត្រង់ថាអូនចង់ទៅទិញរបស់នៅថ្ងៃនេះ បងដេកឱបអូននៅក្នុងបន្ទប់នេះពេញមួយថ្ងៃមិនខាន ហត់ដល់ហើយ"

គេហត់នឿយមែនហ្នឹង តាំងពីមកដល់ជប៉ុន ខ្ញុំឃើញគេមើលឯកសារ ធ្វើការ ទឹកមុខស្រ្តេស ហើយក៏ត្រូវទៅចរចាជាមួយដៃគូជំនួញ ថែមទាំងត្រូវទៅមើលការងារនៅកន្លែងនេះកន្លែងនោះបន្តមានតែថ្ងៃនេះប៉ុណ្ណោះដែលគេបានសម្រាក តែក៏នាំខ្ញុំមកដើរលេងញ៉ាំនៅតំបន់សបភីងទៀត ។

"ឧស្សាហ៍ធ្វើការទៅ ទើបមាន"

"មានស្រាប់ហើយ" អ៊ីនថាច់ ប្រាប់ដោយសំឡេងហត់នឿយ

"សុំរង្វាន់បន្តិចម៉ោ"

"យករង្វាន់អី ?"

ខ្ញុំសួរ ហើយក៏លើកចិញ្ចើមពេលឃើញ អ៊ីនថាច់ លើកខ្នោះដៃពណ៌ស្រស់បង្ហាញ អឹម...លេងមែនទែនក៏អី ?

"ណាំ...ស្លឹកតើយ ណាំ" ខ្ញុំធ្វើព្រងើយ មុននឹងញញឹម ។

[Intouch's Talk]

ប្រាប់ហើយថាភរិយាស្រស់ស្អាតរបស់ខ្ញុំគួរឲ្យស្រឡាញ់បំផុតនៅក្នុងលោក ។

ខ្ញុំមើលរាងតូចច្រឡឹងរបស់នាង ដែលពត់ពេននៅក្រោមរាងកាយ ដៃទាំងពីរក៏ត្រូវដាក់ខ្នោះពណ៌ផ្កាឈូកពេមសត្វរបស់សណ្ឋាគារ ។

ស្លឹកតើយ ដេកលើគ្រែធំពណ៌ផ្កាឈូក ពាក់ឈុតខោស្លេយ៍ដែលមានស្រាប់នៅក្នុងបន្ទប់ ។

ខ្ញុំទាំងអស់សំណើចទាំងញាប់ញ័រ ប៉ុន្តែក៏ចូលចិត្ត ភាពស់អារម្មណ៍បានមួយបែបទៀត ។

"បង អ៊ីនថាច់..."

នាងហៅខ្ញុំ ព្រោះឃើញខ្ញុំរវល់តែមើល អឺយ៉ា ចង់មានកាមេរ៉ា ថតរូបនេះទុកដល់ហើយ តែស្លឹកតើយ ប្រហែលជាមិនព្រម ។

"បាទ" ខ្ញុំតប ។

"ច្បាស់ហើយថាមានកូនសោដោះ ?"

អ្នកដែលត្រូវដាក់ខ្នោះដៃជាប់នឹងគ្រែសួរដោយទឹកមុខមិនជឿជាក់ ។

"មាន..."

ខ្ញុំញញឹម មុននឹងឱបថើបនាង ។

ស្លឹកតើយ ធ្វើសំឡេងក្នុងបំពង់កដោយគួរឲ្យស្រឡាញ់ និងថើបតបខ្ញុំ ។

ប្រាប់ហើយតើ...ភរិយារបស់ខ្ញុំគួរឲ្យស្រឡាញ់ ។

"អឹម...បង អ៊ីនថាច់"

ពេលដែលដៃរបស់នាងមិនទំនេរ និងមិនអាចការពារខ្លួនឯងបាន ទើបខ្ញុំអាចធ្វើអ្វីមិនដឹងជាអ្វីបានយ៉ាងងាយស្រួល ដោយ

ស្លឹកតើយ បានតែពើងខ្លួនមករក និងពត់ពេនខ្លួនតេចទៅពេលខ្លះ
ប៉ុណ្ណោះ ហើយមិនថាខ្ញុំធ្វើអ្វីក៏នាងបានតែដកដង្ហើមញាប់ស្អេក រង់
ចាំដោយចិត្តរំភើបប៉ុណ្ណោះ ។

"អ៊ុយ!"

នាងខមានពេលខ្ញុំប្រឡេះឡេវអាវខសផ្ដេយ៍ចេញ ហើយកំ
ប្រើបបូរមាត់បពោសអង្អែលស្បែកទន់ល្មៀយរបស់នាងត្រង់គល់
ទ្រូង និងអូសចុះមកក្រោម ។

សាច់របស់ ស្លឹកតើយ នៅតែទន់ល្មៀយ និងធ្វើឲ្យខ្ញុំឈ្លក់
វង្វេងបានគ្រប់ពេល ។

"បង អ៊ីនថាច់ កុំលេងសើច"

នាងស្ទើឲ្យពេលខ្ញុំអូសម្រាមដៃទៅរកឆ្អឹងជំនីរ ទៅរកជាយ
សំពត់ និងទៅរកក្បៀកដែលនាងរសើប ។

ពេលដែលត្រូវហាម ទើបខ្ញុំដែលជាមនុស្សស្ដាប់បង្គាប់ព្រម
ធ្វើតាម ប្ដូរទីតាំងទៅស្ទាបអង្អែលទាបជាងនោះ ។

សំពត់ជីបភ្លឺខ្ចីដែល ស្លឹកតើយ ស្លៀក រាខើចឡើងដល់ភ្លៅ...
ខ្ញុំស្ទាបអង្អែលភ្លៅរបស់នាង មុននឹងលូកចូលទៅខាងក្នុង ប៉ះភាព
ទន់ជ្រាយ ហើយក៏ជ្រែកម្រាមដៃចូលទៅក្រោមសាច់កំណាត់តូច
ដើម្បីរកកន្លែងដែលខ្ញុំប្រាថ្នាបំផុត អាំ...

មិនថាធ្វើបែបនេះប៉ុន្មានដងទៀតក៏ ស្លឹកតើយ នៅតែដូចស្រី
ព្រហ្មចារីមិនផ្លាស់ប្ដូរ...ខ្លួនប្រាណរបស់នាងនៅតែក្ដៅគគុក និង
តឹងណែន ។

"អ្ហាំ...កុំ"

ស្លឹកតើយ ហាម ពត់ពេនខ្លួនគេចពីខ្ញុំ តែទាស់ត្រង់ខ្នោះដៃ
ចាក់ដៃរបស់នាងជាប់នឹងក្បាលគ្រែ ។

ខ្ញុំរំកិលបបូរមាត់...

តាមចង្វាក់ម្រាមដៃនិងមាត់របស់ខ្ញុំ ។

"បង អ៊ីនថាច់...អ៊ឹម"

ខ្ញុំបញ្ឈប់សំឡេងនោះដោយការដកដៃចេញ ហើយយកបបូរ
មាត់ទៅថ្នើបជំនួស ។

គ្មានសំឡេងហាមណាចេញពីមាត់របស់ ស្លឹកតើយ មានតែ
សំឡេងថ្ងូចថ្ងូរបែបដែលខ្ញុំចូលចិត្តស្ដាប់ប៉ុណ្ណោះ ។ ហើយពេល
ដែលខ្ញុំឱបនិងជ្រែកកាយចូលទៅ ស្លឹកតើយ ក៏ដកដង្ហើមដង្ហក់ ជា
ចង្វាក់ដូចគ្នានឹងការខ្ទាំរាងកាយរបស់ខ្ញុំ ។

សេចក្ដីសុខជាច្រើនធ្វើឲ្យយើងដកដង្ហើមដោយចង្វាក់ដូចគ្នា
រហូតដល់ខ្ញុំអាចធ្វើឲ្យ ស្លឹកតើយ ញាប់ញ័របានសម្រេច និងតាម
នាងជាប់ប្រកិត ។

"ស្លឹកតើយ..." ខ្ញុំហៅឈ្មោះនាង និងយកថ្ពាល់ខ្លួនឯងថ្នើប
នឹងថ្ពាល់របស់នាងដែរ ។

"ចាំ"

"មានកូន បើស្រីដាក់ឈ្មោះ ភំងនន បើប្រុសដាក់ឈ្មោះរូត"

"ហ៊ឹម...ស្អីគេ?"

"ឈ្មោះកូនហ្នឹងអី"

អ្នកដែលខ្ញុំឱបនៅតែធ្វើមុខមិនយល់មួយសន្ទុះ មុននឹងស្រែក
ខ្លាំងៗ ។

"ភំងនន...រូត ភំងនន...រូត បើ អ៊ីនថាច់!" ស្លឹកតើយ ស្រែក
ខ្លាំងៗ ហើយក៏ធ្វើមុខកាចយើកថ្ពាល់ដាក់ខ្ញុំ "កុំគួរ មិនខ្មាសគេ
វាជារឿងរបស់បង តែមួយខ្លួន"

ខ្ញុំអស់សំណើច និងចង់កាច់អស់នាងលេង ។

ណាំ ទើបខ្ញុំដើរទៅរកកូនសោមកដោះ តែថា...

វា...វានៅឯណា ?

"បង...កុំប្រាប់ណាំថារកមិនឃើញ ?"

ស្លឹកតើយ សួរពេលឃើញខ្ញុំបែកញើសកក្លាក់...ខ្ញុំមិត្រប់កន្លែង កន្លៀត ហើយងាកទៅមើល ស្លឹកតើយ ដែលដេកលើគ្រែ ដៃទាំងពីរជាប់ខ្នោះពណ៌ផ្កាឈូករោមសត្វ ហើយ...គ្មានកូនសោដោះ នាងបើកភ្នែកធំៗមើលខ្ញុំ និងស្រែកដោយសំឡេងស្រួចរំលេច ។

"លី អីនថាច់ !"

កម្មហើយ...ធ្វើយ៉ាងម៉េចទៅ !

[End Intouch's Talk]

ខ្ញុំចង់ប្រាប់អ្នកដែលអង្គុយក្បែរឲ្យស្លាប់មែនទែន ភគួរឲ្យចង់ធ្វើណាស់ !

កាលពីម្សិល ព្រោះអាប្រុសឆ្កួតនេះចង់សប្បាយ អូសខ្ញុំចូល Love Hotel ហើយប្រើអា...អាខ្នោះដៃរោមសត្វនោះចាក់ដៃរបស់ខ្ញុំ ហើយក៏មកដឹងការពិតថាគ្មានកូនសោដោះ ដូច្នេះហើយទើបខ្ញុំនិងគេឆ្កួតមួយសន្ទុះ ។

អីនថាច់ រើរកកូនសោខ្នោះដៃសព្វបន្ទប់ ចំណែកខ្ញុំគិតតែស្រែកប្រែតៗដាក់គេ និងអន្ទះអន្ទែង ។

គិតមើលចុះ ចុងក្រោយយើងក៏ត្រូវទូរសព្ទទៅសុំកូនសោពីបុគ្គលិកសណ្ឋាគារ តែចម្លើយរបស់គេដូចគ្នាថា...គ្មាន ។

"ទឹកក្រូចទេ ឬជាសុក្កូឡា ?"

អ្នកដែលដឹងថាមានកំហុសជាប់ខ្លួនងាកមកបម្រើ ព្រមទាំងហុចកញ្ចប់សុក្កូឡាម៉ាកដែលខ្ញុំចូលចិត្តឲ្យ ។

"មិនញ៉ាំ" ខ្ញុំងាកមុខចេញ ។

"នៅខឹងបងឬ ?" អីនថាច់ សួរដោយសំឡេងស្រទន់ ។

ភគួរឲ្យខឹងទេ នឹកដល់ពេលដែលតាមជាងមកដោះខ្នោះដៃនោះចេញហើយ គឺខ្ញុំនៅក្នុងឈុតខុសផ្លែយ ។

"..."

ខ្ញុំមិនតប តែប្រើខ្សែភ្នែកពិឃាតជំនួស ទើប អីនថាច់ ញញឹមហើយខាំសុក្កូឡានោះញ៉ាំដោយខ្លួនឯង ។

ពេលនេះយើងកំពុងនៅក្នុងយន្តហោះ ធ្វើដំណើរត្រឡប់ទៅកូរ៉េវិញ នៅជាន់ហ្វឺសក្លាស ។

ខ្ញុំពេបមាត់ហើយងាកមុខចេញ ខ្ញុំនឹងមិននិយាយរកគេទាល់តែទៅដល់កូរ៉េវិញ ចាំមើលទៅ !

សំឡេងរបស់កញ្ចប់នោះឮជារយៈ ចំណែកខ្ញុំវិញបើកចម្រៀងស្តាប់ ហើយចុចកៅអីឲ្យទាបដើម្បីដេក ភ្ញាក់ដឹងខ្លួនម្តងទៀតក៏ងាកទៅមើលអ្នកនៅក្បែរខ្លួន ។

"ភ្ញាក់ហើយឬ ?"

អីនថាច់ សួរ នៅពីមុខមានសុក្កូឡាមួយកញ្ចប់ធំដែលញ៉ាំអស់ពាក់កណ្តាល សុក្កូឡាម៉ាកនេះវាមានតម្លៃថ្លៃ ហើយនេះគេញ៉ាំអស់ប៉ុន្មានទៅហើយ ?

"បងឃ្លានឬ ?" ខ្ញុំសួរដោយមិនគ្រាកដចិត្ត តាំងពីរៀបការនិងស្គាល់គ្នា អីនថាច់ អាចញ៉ាំរបស់ផ្អែមខ្លះដែរ តែមិនច្រើនដល់ថ្នាក់នេះ ខុសពីខ្ញុំដែលចូលចិត្តញ៉ាំវត្ថុរបស់ទាំងនេះបំផុត ។

"អឺ...អត់ទេ មិនឃ្លាន"

"ចុះហេតុអី..."

"គ្រាន់តែចង់ញ៉ាំ ឃើញអូនទិញមកញ៉ាំហើយ គិតថាគួរតែឆ្ងាញ់" អីនថាច់ តប មុននឹងបើកចិញ្ចៀម "បាត់ងរហើយមែនទេ"

អឹម...ប្រហែល ខ្ញុំសម្លក់សម្លឹងគេ ហើយក៏តបដោយសំឡេង

កំពុតកំពុយ ។

"មិនទាន់បាត់"

ញ៉ាំឲ្យគាត់ដូចផ្អែកទៅ និងបានឈប់ត្រេកតាម...ខ្ញុំគិត ហើយក៏ងាកមុខចេញដោយការជិនឆ្អន់ ។

ប៉ុន្តែ...ពេលមែនទែនទៅ ខ្ញុំក៏ក្លាយជាមនុស្សដែលព្រួយបារម្ភពីរឿងនេះច្រើនជាងគេជាងឯង ។

បន្ទាប់ពីត្រឡប់មកពីការចរចាជំនួញនៅប្រទេសជប៉ុន និងជួបរឿងក្ដីខ្មោះដៃពោមសត្វហើយ អ៊ីនចាច់ និងខ្ញុំក៏ត្រឡប់មករៀបជីវិតតាមធម្មតា ។

ខ្ញុំមកជួយនៅក្រុមហ៊ុនរបស់គេ ទើបយើងនៅជាមួយគ្នាពេញ ២៤ម៉ោង ហើយបីថ្ងៃបន្ទាប់ពីត្រឡប់មកពីជប៉ុន អ៊ីនចាច់ ក៏គិតតែញ៉ាំសុកូឡាមិនឈប់ អង្គុយធ្វើការត្រូវតែមានប្រភេទគ្រាប់ស្រោបសណ្ដែកជាដើម នៅផ្ទះក៏អង្គុយអានព័ត៌មានទែះនំលេង ថ្នាក់ខ្ញុំដែលធ្លាប់ចូលចិត្តញ៉ាំច្រើន ពេលឃើញគេហើយក៏មានអារម្មណ៍ថ្រាន់ជំនួស គេឈឺមែនទេ កើតអី ?

"បង" ខ្ញុំហៅ អ៊ីនចាច់ នៅព្រឹកថ្ងៃថ្មីពេលដែលយើងជិះឡានទៅក្រុមហ៊ុន ។

"បាទ"

អ្នកដែលកំពុងចុចឡេបថបមើលការងារនៅក្នុងឡាន ( តាំងពីយើងរៀបការ អ៊ីនចាច់ ក៏ជួលអ្នកបើកឡាន ដោយហេតុផលថាបើដោយខ្លួនឯង ដៃគេមិនទំនេរក្ដោបដៃខ្ញុំ ដែលវាធ្វើឲ្យខ្ញុំរើបខ្លាំងរហូតមកដល់ពេលនេះ ) ងាកមកតប ។

"..."

ដៃម្ខាងចុចឡេបថបដែលដាក់លើភ្លៅដើម្បីមើលការងារ ដៃម្ខាងទៀតមានសុកូឡាបន្ទះដែលខាំអស់ពាក់កណ្ដាល ។

"បងមិនស្រួលខ្លួនឬអត់ ?"

"ម៉េចក៏សួរអីចឹង ?"

គេងាកមករក មុននឹងឱនមុខមកក្បែរត្រចៀក ។

"យប់មិញមិនល្អឬ ?"

"ឆ្កួត" ខ្ញុំខ្សឹបតវ៉ា ហើយក៏ដៀងមើលអ្នកបើកឡានដែលមិនបានឮអ្វីដែលយើងនិយាយ "អូនចង់មានន័យថាបងមិនស្រួលខ្លួនឬអត់ បីបួនថ្ងៃមកនេះ ម៉េចក៏ញ៉ាំតែសុកូឡា បាយទឹកក៏មិនសូវញ៉ាំ"

"អ៊ីចឹងឬ"

នៅមិនដឹងខ្លួនទៀត...ខ្ញុំដកដង្ហើមធំ ហើយទាញនំនៅក្នុងដៃរបស់គេបង្ហាញ ។

"នេះអី...ក៏សួតាង"

"..." អ៊ីនចាច់ ជ្រួញចិញ្ចើម និងលើកក្ដាមដៃដែលប្រឡាក់ [illegible] មកលិឍយើតៗ មុននឹងថ្ងូរដោយការពេញចិត្តនឹងរសជាតិរបស់វា

តែហេតុអ្វីក៏ខ្ញុំមានអារម្មណ៍ក្ដៅស្រៀវស្រាញ ?

ខ្ញុំទប់ភាពត្រេកតាមរបស់ខ្លួនឯង ហើយធ្វើមុខ [illegible] ។

"បងញ៉ាំច្រើនពេកហើយ [illegible] អូនបារម្ភ"

អ៊ីនចាច់ គិតតាម ហើយក៏ងក់ក្បាល ។

"ក៏បាន"

"ល្អ អ៊ីចឹងយើង [illegible] ថ្ងៃនេះ"

ខ្ញុំនិយាយដោយការពេញចិត្ត ហើយញញឹមដាក់គេ អ៊ីនចាច់ ក៏ញញឹមដាក់វិញ [illegible] ខ្ញុំមួយខ្សឹតយ៉ាងលឿន ។

(Inchach's Talk)

[illegible] ក្ដៅ ស្លឹកតើយ ប្រាប់ថាបើនៅតែញ៉ាំនំ

ច្រើនបែបនេះវាមិនល្អ ដែលត្រូវប្រថុយនោះគឺជំងឺទឹកនោមផ្អែម ។

តាមពិតខ្ញុំព្រមមកមន្ទីរពេទ្យព្រោះមិនចង់ឲ្យនាងបារម្ភ ទោះសប្បាយចិត្តដែលដឹងថានាងព្រួយបារម្ភពីខ្ញុំប៉ុណ្ណាក៏ដោយ ។

យើងចេញពីពេទ្យនៅម៉ោង២រសៀល ហើយខ្ញុំក៏បបួលនាងទៅផ្ទះរបស់ម៉ាក់នាង ។

"មានការអីឬ?" ម៉ាក់របស់ ស្លឹកតើយ សួរ គាត់នៅតែស្អាតក្មេងជាងវ័យដដែល ។

ខ្ញុំដឹងថាគាត់ចូលចិត្តតុបតែងមុខមាត់ ប៉ុន្តែគាត់ធ្វើដើម្បីស្អាតប៉ុណ្ណោះ ក្រៅពីនោះគឺធ្វើនេះធ្វើនោះ ។

គាត់ឈប់ចេញចូលស្ថាប័នកែសម្ផស្ស មានន័យថាពេទ្យប្រាប់ថាគាត់ស្អាតជាងនេះលែងបានហើយ ។

"មកញ៉ាំបាយល្ងាចជាមួយម៉ាក់"

"ល្អដល់ហើយ" ម៉ាក់របស់ ស្លឹកតើយ ជាមិត្តសម្លាញ់របស់ម៉ាក់ខ្ញុំ ចរិតដូចគ្នាដល់ថ្នាក់គួរឲ្យព្រឺសម្បុរ ។

"ប្រាប់ឲ្យមេផ្ទះរៀបចំអាហារល្អជាង"

តាំងពីយើងរៀបការ ខ្ញុំ និង ស្លឹកតើយ ក៏មកញ៉ាំអាហារពេលល្ងាចនៅផ្ទះរបស់ម៉ាក់នាងញឹកញាប់ ព្រោះតាំងពីនាងរៀបការទៅនៅជាមួយខ្ញុំ ហើយបងស្រីរបស់នាងក៏ត្រឡប់ទៅបរទេសវិញ ម៉ាក់ក្មេករបស់ខ្ញុំក៏នៅផ្ទះនេះម្នាក់ឯង តែប្រហែលមិនយូរនោះទេ ព្រោះម៉ាក់របស់ខ្ញុំកំពុងតែបបួលគាត់ទៅនៅជាមួយ ម៉ាក់ខ្ញុំនិងម៉ាក់ក្មេកនេះចុះសម្រុងគ្នាណាស់ បែបនេះប្រហែលមានមិនប៉ុន្មានគូទេនៅភូមិ ។

"ម៉ោះ"

ខ្ញុំដឹកដៃ ស្លឹកតើយ ចូលបន្ទប់អាហារខ្នាតតូច ដែលនៅលើតុមានម្ហូបបីមុខ ។

"តិចពេកទេ មិនគេមកប្រាប់មុន នឹងបានឲ្យគេធ្វើបន្ថែម ឬកុម្ម៉ង់ពីហាងមកញ៉ាំ"

ឃើញទេ ម៉ាក់ក្មេកខ្ញុំក្រៅពីមុខមាត់នៅក្មេងហើយ ចរិតពេលខ្លះក៏ដូចកូនក្មេងដែរ ។

"មិនបាច់ទេ នេះក៏ច្រើនហើយ"

ស្លឹកតើយ ប្រាប់មុននឹងអង្គុយចុះ ហើយក៏ទាញចង្កឹះចាប់សាច់ជ្រូកបីជាន់ពណ៌ត្នោតដែលចៀនឡើងក្រៀមគួរឲ្យចង់ញ៉ាំដាក់ចូលមាត់ ។

"ស្លឹកតើយ គ្មានមារយាទ" ម៉ាក់ក្មេកស្តីឲ្យកូនស្រី ។

"មិនអីទេ...គួរឲ្យស្រឡាញ់"

"អីយ៉ា...ប្តីបើកដៃបែបនេះ ទើបប្រពន្ធកាន់តែគ្មានមារយាទ អីនបាច់"

ខ្ញុំញញឹម គឺនៅក្នុងខ្សែភ្នែករបស់ខ្ញុំ ស្លឹកតើយ ធ្វើអ្វីក៏គួរឲ្យស្រឡាញ់ដែរ ។

"នេះជាមុខម្ហូបដែលបងចូលចិត្តហ្នឹងណាក់ មួយម៉ាត់ទេ"

ករិយាជំស្រស់ស្អាតចាប់សាច់ជ្រូកបីជាន់បញ្ចុក ខ្ញុំក៏ហាមាត់ទទួល តែព្រោះក្លិនរបស់វាចំជា...ស្អុយខ្លាំងណាស់ ។

"អុប!"

ពោះរបស់ខ្ញុំមួលក្ពាម ពេលក្លិនស្អុយនេះវាត់ចូលមកក្នុងច្រមុះ ។

ខ្ញុំស្ទុះស្ទើរទៅបន្ទប់ទឹកយ៉ាងលឿន ហើយក៏ចំកោងខ្លួនក្អួតដាក់ចានបង្គន់ ដោះលែងឲ្យអស់ពីពោះពីពង់ ។

"កើតអីបង"

ស្លឹកតើយ រត់មកតាមជួយរិតខ្នងឲ្យ ។

ស្លឹកតើយ ... គឺ

ចាប់ហើយ! លើកចុងក្រោយដែលមានសភាពបែបនេះ គឺ

ពេលពេញវ័យនិងស្រវឹងជាលើកដំបូង ។

ខ្ញុំមិនធ្លាប់ក្អួតដល់ថ្នាក់ឈឺពេញពោះបែបនេះទេ ។

"មិនអីទេ គ្រាន់តែស្អុយដល់ថ្នាក់ទ្រាំមិនបាន"

"ស្អុយអី ស្អុយអានេះឬ ?"

ខ្ញុំមើលដៃរបស់ ស្លឹកតើយ ប្រពន្ធរបស់ខ្ញុំកាន់ចានសាច់ជ្រូកមកជាមួយ ។

ក្អួតបន្តមួយភ្លែត!

"កើតអីបង"

ស្លឹកតើយ សួរ ព្រមទាំងជួយរឹតខ្នងឲ្យម្តងទៀត មេផ្ទះដែលប្រហែលជាម៉ាក់ក្មេកហៅឲ្យមកជួយ ក៏រត់យកទឹកក្រូចដាក់មួយកែវមកហុចឲ្យលាងមាត់ ។

ខ្ញុំចង្អុលឲ្យនាងយកចានសាច់ជ្រូកទៅដាក់លើតុ តែអនិច្ចា ស្លឹកតើយ នៅតែមិនយល់ ក្លិនរបស់វាស្អុយសែនស្អុយ ធ្វើឲ្យមូលពោះ ទឹកភ្នែកកូនប្រុសក៏ហូរតាមកន្ទុយភ្នែក ព្រោះពេលនេះវាឈឺពោះឡើងផ្សាអស់ទៅហើយ ។

"អីនចាច់ កើតអី ស្លឹកតើយ ?"

សំឡេងរបស់ម៉ាក់ក្មេកបន្លឺឡើងនៅមុខបន្ទប់ទឹក ។

"មិនដឹងទេ គិតតែក្អួត សួរក៏មិនប្រាប់ ចង្អុលនេះចង្អុលនោះ ស្លឹកក៏មិនដឹង"

"អេំ ?"

ខ្ញុំលេបទឹកមាត់ដែលល្វីងខះក មុននឹងចង្អុលចានសាច់ជ្រូកក្នុងដៃរបស់ ស្លឹកតើយ ។

"ស្អុយ...ស្អុយ"

"ស្អុយ...ស្អុយអានេះឬ ?"

កម្មរបស់ខ្ញុំដែល ស្លឹកតើយ យកវាមកដាក់ពីមុខម្តងទៀត ខ្ញុំ

ក៏អត់ដង្ហើមមិនបាន ងាកទៅរកចានបង្គន់ម្តងទៀតដូចគ្នា ។

"ស្លឹកតើយ ម៉ាក់ថាគេស្អុយអាសាច់ជ្រូកចៀនរបស់ឯងហ្នឹង"

"អាំ..."

ស្លឹកតើយ ហុចចានសាច់ជ្រូកឲ្យមេផ្ទះយកចេញទៅភ្លាម ក្លិនស្អុយដែលធ្វើឲ្យខ្ញុំទ្រាំមិនបាននោះក៏រសាយភ្លាម ។

ខ្ញុំដកដង្ហើមចូលឲ្យពេញសួត និងលុបលាងមុខមាត់ ដោយ ស្លឹកតើយ បើកភ្នែកមូលក្រឡង់របស់នាងមើលខ្ញុំ ។

"ធ្វើដូចមានផ្ទៃពោះ"

ភរិយារបស់ខ្ញុំនិយាយ ហើយក៏ត្រវីក្បាល ។

"..."

"..."

ខ្ញុំនិងម៉ាក់ក្មេកមើលមុខគ្នាតាមរយៈកញ្ចក់នៅក្នុងបន្ទប់ទឹក ហើយខ្ញុំក៏ងាកទៅមើលគាត់ចំៗ ស្អី...ស្អីគេ?

"អូននិយាយថាម៉េច ?"

"អូនប្រាប់ថាបងធ្វើម្ហូបដូចស្រីចាញ់កូន ស្អុយនេះស្អុយនោះ ទាំងដែលធ្លាប់ញ៉ាំសោះ ហើយក៏ជាអាហារដែលចូលចិត្តខ្លាំងដែរ"

បេះដូងរបស់ខ្ញុំលោតផុកផាក់ ប្រសព្វភ្នែកជាមួយម៉ាក់ក្មេក ឃើញខ្សែភ្នែកគាត់ដែលមើលមក និងមាត់របស់គាត់ដែលចំហជារូបបេះដូងហើយ បេះដូងរបស់ខ្ញុំក៏កន្ត្រាក់ ។

មែន! ខ្ញុំមិនធ្លាប់ចូលចិត្តញ៉ាំសុកូឡានោះសូម្បីតែម្តង ប៉ុន្តែខ្ញុំញ៉ាំវាជំនួសបាយអស់រយៈពេលជាច្រើនថ្ងៃហើយ ហើយក៏ស្អុយអាហារដែលធ្លាប់ចូលចិត្ត បើខ្ញុំជាមនុស្សស្រីមានស្បូន ខ្ញុំប្រហែលជាកំពុងតែមានផ្ទៃពោះមិនខាន តែខ្ញុំគ្មាន...ដូច្នេះហើយ រឿងតែមួយគត់ដែលអាចទៅរួច គឺ...

"ស្លឹកតើយ...រដូវមកលើកចុងក្រោយពេលណា ?"

"ណាមកទៀតហើយ"

ស្លឹកតើយ ប្រាប់ដោយសំឡេងគាច ហើយក៏នៅស្ងៀម ។

នាងមើលមុខខ្ញុំ ហើយក៏លើកចិញ្ចើមដូចកំពុងគិត ។

"..." ម៉ាក់ក្មេកខ្ញុំក៏ចំហមាត់ឆ្លង រង់ចាំចម្លើយដូចគ្នា ។

"វា...វាខានមកយូរហើយ មែនហើយ វាមិនមកទេ"

បេះដូងរបស់ខ្ញុំលោតផុកដាក់ម្តងទៀត ការសប្បាយចិត្តវារត់សំដៅមករកបេះដូង ឬថា...ឬថា...

"អូន...មានផ្ទៃពោះឬអត់?"

ខ្ញុំសួរដោយសំឡេងស្រាលស្ទើក ទោះដឹងច្បាស់ថាខ្លួនឯងមិនធ្លាប់ការពារ មិនថាដោយវិធីណាក៏ដោយ ។

ខ្ញុំចូលចិត្តប៉ះពាល់នាងបែបធម្មជាតិ ឲ្យយើងនៃបនិត្យជិតគ្នាបំផុត អាចផ្លាស្លឹកទាំងឡាយដែលថាស្ទើងស្លឹគេនោះក៏មិនធ្លាប់ប្រើ ហើយ ស្លឹកតើយ ក៏មិនធ្លាប់លេបថ្នាំដែរ ។

"មិនដឹងទេ" នាងធ្វើមុខដូចនៅតែមិនមាំង ។

"ម៉ាក់ថា...ពួកឯងទៅទិញប្រដាប់ពិនិត្យទឹកនោមទៅ"

[End Intouch's Talk]

ខ្ញុំខាំមាត់មើលឧបករណ៍ពិនិត្យទឹកនោមដោយចិត្តរំភើបញាប់ញ័រ ។ លុះគ្រាតែវាមានប៉ុន្មានគំនូសទើបប្រាប់ថាមានផ្ទៃពោះ ហើយក៏យកប្រអប់មកមើល មុននឹងជ្រួញចិញ្ចើម ព្រោះត្រូវរង់ចាំមួយនាទីទៀត ។

គុក! គុក!

"ស្លឹកតើយ បើកទ្វារ បងនិងម៉ាក់កំពុងចាំ"

សំឡេងរបស់ អ៊ីនថាច់ បន្លឺឡើង ព្រមទាំងគោះទ្វារតឿន ។

"នៅទេ មិនទាន់រួច"

"បើកម៉ោ"

សំឡេងនោះធ្វើឲ្យខ្ញុំដើបដើរទៅបើកទ្វារ ។

អ៊ីនថាច់ មានទឹកមុខតានតឹង ធ្វើឲ្យខ្ញុំខ្លាច ឬថាគេមិនទា
ចង់មានកូន? មែនហើយ! តាំងពីរៀបការយើងមិនធ្លាប់និយា
ដល់រឿងនេះ កូន...ក្មេង គេស្រឡាញ់ក្មេងដែរទេ?

"ឯណាប្រដាប់ពិនិត្យ?"

អ៊ីនថាច់ សួរ ចិញ្ចើមរបស់គេក៏ជ្រួញជាប់គ្នា ។

"នៅនោះ"

ខ្ញុំបួញមាត់ទៅក្រោយ អ៊ីនថាច់ ក៏ដើរទៅយកមកមើ
ហើយជ្រួញចិញ្ចើមកាន់តែខ្លាំង ។

ម៉ាក់របស់ខ្ញុំក៏ចូលមកដែរ សំណាងដែលបន្ទប់ទឹកនេះ
ទូលាយ អាចឲ្យមនុស្សបីនាក់មកនៅផ្ដុំគ្នាបានស្រួល ។

ខ្ញុំប្រឹងលេបទឹកមាត់ដោយចិត្តជ្រួលច្រាល់ អ៊ីនថាច់ ក៏ពិនិ
ប្រដាប់ពិនិត្យនោះ មុននឹងដើរទៅយកប្រអប់ដែលប្រាប់ពីវិធីប្រើ
ប្រាស់មកមើល ។

"វាមានប៉ុន្មានគំនូស អ៊ីនថាច់?"

ម៉ាក់ខ្ញុំសួរដោយចិត្តជ្រួលច្រាល់ដូចគ្នា ។

"ពីរគំនូស វាមានន័យថាម៉េចម៉ាក់?"

"!!!"

ម៉ាក់ខ្ញុំលើកដៃបិទមាត់ ហើយងាកមកមើលមុខខ្ញុំដោយស្មាន
មិនដល់ មុននឹងរហ័សរត់ចេញពីបន្ទប់ទឹក ។

ខ្ញុំក៏ស្លឹកខ្លួន មានអារម្មណ៍ប្លែកៗ ធ្វើខ្លួនមិនត្រូវផង សប្បាយ
ចិត្តផង ហើយក៏ចំហមាត់ឆ្លងនឹងបំប្រិចភ្នែកញាប់ស្លេក ចំណែក
ទឹកភ្នែកហៀរកក្រលច់ស្រក់ទៅហើយ ។

"មានន័យថាម៉េច អូនមានផ្ទៃពោះឬក៏គ្មាន?" អ្នកដែលកាន់

ប្រដាប់ពិនិត្យទឹកនោមស្នូរម្តងទៀត ខ្ញុំក៏មើលគេហើយញញឹម ។

"បង...អូនមានផ្ទៃពោះ"

ស្ងាត់...អ៊ីនចាប់ ស្ងាត់ស្ងៀម ទើបខ្ញុំញញឹមដាក់គេ ។

"សប្បាយចិត្តទេ"

ស្ងាត់...គេស្ងាត់...មិនតប ហើបមាត់មួបៗ ខ្ញុំក៏ក្រវិចនៅពីមុខគេហើយជ្រួញចិញ្ចើម ។

"ល៊ី អ៊ីនចាប់...ហេឡូ"

គេបានឮខ្ញុំហើយ និងប៉ប្រិចភ្នែកញាប់ស្លេក មុននឹងឱនមើលខ្ញុំព្រោះកម្ពស់របស់យើងខុសគ្នា ។

អ៊ីនចាប់ មើលខ្ញុំនិងធ្វើមុខមិនមាំង ចិត្តរបស់ខ្ញុំក៏ស្រពោន ស្អ...
គេ គ្រាន់តែដឹងមានកូនជាមួយខ្ញុំម៉េចចាំបាច់ធ្វើស្លីបែបនេះដែរ ?

"បើខូចចិ..."

ខ្ញុំនិយាយមិនទាន់ចប់ផង គេក៏ឱនមករក បបូរមាត់ក្តៅគគុកនោះសង្កត់បបូរមាត់របស់ខ្ញុំ ។ ការថើបដែលទទួលបានដោយមិនបានត្រៀមខ្លួន ធ្វើឲ្យខ្ញុំភ្ញាក់ថយក្រោយដោយការភ្ញាក់ផ្អើល ប៉ុន្តែ អ៊ីនចាប់ ក៏ស្រវាឱបចង្កេះរបស់ខ្ញុំ និងរឹតដៃកាន់តែណែន ដៃម្ខាងទៀតរបស់គេលើកមកចាប់កញ្ចឹងកក្រសោបក្បាលខ្ញុំ ។

ការថើបដ៏ផ្អែមល្ហែមនោះ វាធ្វើឲ្យយើងទាំងពីរមុខក្រហម ឡប់ល់ដង្ហើមក៏ដង្ហក់ពេលដែលគេដកបបូរមាត់ចេញ ។

"អ៊ីនចាប់"

"បងសប្បាយចិត្តណាស់ សប្បាយចិត្តខ្លាំងណាស់ ស្លឹកតើយ អរគុណដែលអូនប្រគល់កូនឲ្យបង"

"អូនស្មានថាបងមិនពេញចិត្ត ឃើញធ្វើមុខស្មើ"

ខ្ញុំសារភាពតាមត្រង់ ហើយក៏បានទទួលការជ្រួញចិញ្ចើមដាក់ ព្រមទាំងម្រាមដៃដែលលូកមកផ្ទាត់ថ្ងាស ។

"តិតស្លីបែបនេះ បងសប្បាយចិត្តដល់ថ្នាក់និយាយមិនចេញ...
ទៅវិញទេ"

ខ្ញុំញញឹម ភាពតានតឹងក៏រលាយបាត់អស់ ពេលនេះមានតែក្តី...
សុខនិងក្តីរំភើបចំពោះជីវិតថ្មីដែលនៅក្នុងរាងកាយខ្លួនឯង...កូន...
របស់ខ្ញុំ និង អ៊ីនចាប់ ។

"យើងចេញពីបន្ទប់ទឹកសិនល្អជាងទេ"

ស្វាមីសង្ហាររបស់ខ្ញុំនិយាយដូចខ្មាសអៀន មែនហើយ! គឺអ...
ប្រដាប់ត្រួតពិនិត្យទឹកនោមនេះវាមានពីរគំនូស លទ្ធផលប្រាប់ថាខ្ញុំ...
មានផ្ទៃពោះ គឺមានន័យថាអាការទាំងឡាយរបស់ អ៊ីនចាប់ នោះពី...
...ចាញ់កូនជំនួសខ្ញុំ ។

"ស្លឹកតើយ បងសុំអ្វីម្យ៉ាងបានទេ ?"

សុខៗគេក៏និយាយបែបនេះ ។

"ចាំ"

"កុំប្រាប់អ្នកណារឿងបងចាញ់កូន"

ថ្ពាល់របស់ អ៊ីនចាប់ ក្រហម អ៊ុំ...ស្វាមីកំណាចរបស់ខ្ញុំកំពុងតែអៀនដែលចាញ់កូនជំនួសខ្ញុំ គេគួរឲ្យស្រឡាញ់ដល់ហើយ ខ្ញុំក៏ធ្វើជារិះគិតយ៉ាងខ្លាំង ដល់ថ្នាក់គេលូកដៃមកច្របាច់ច្រមុះ ។

"ចាំ អូនមិនប្រាប់អ្នកណាទេ"

"គួរឲ្យស្រឡាញ់ខ្លាំងណាស់"

អ៊ីនចាប់ សរសើរខ្ញុំ ។

យើងទាំងពីរដើរចេញពីបន្ទប់ទឹក គេក្តោបដៃរបស់ខ្ញុំជាប់ ហើយម៉ាក់របស់ខ្ញុំក៏កាន់ខ្ទះសណ្តែកក្នុងដៃ កំពុងតែស្រែកគ្រហឹមដាក់ម៉ាក់របស់គេ ។

"មែនហើយ ជីហ្វានី គេខូចខ្លាំងណាស់ អាំ...មែនៗ ចាញ់កូនជំនួសប្រពន្ធ គួរឲ្យស្រឡាញ់ គួរឲ្យច្បាញ់បំផុត"

"..."

"..."

យើងទាំងពីរមើលមុខគ្នា មុននឹងខ្ញុំញាក់ស្មាប្រាប់គេដោយប្រយោលថា សោកស្តាយផង លែងទាន់ហើយ!

១៤

# រសជាតិផ្អែមល្ហែម និង រឿងនិទានគាត់បញ្ចប់

អាការចាញ់កូនពំនូសខ្ញុំរបស់ គីនថាច់ ធ្ងន់ធ្ងរជាងមុនឆ្ងាយណាស់ ។

ដំណឹងល្អរឿងខ្ញុំមានផ្ទៃពោះ ធ្វើឲ្យអ្នកម៉ាក់ទាំងពីរសប្បាយចិត្តយ៉ាងខ្លាំង ហើយក៏បង្គាប់ឲ្យខ្ញុំពាក់ឈុតពោះធំ ទាំងដែលទៅត្រួតពិនិត្យអាយុគភ៌ទើបតែមានផ្ទៃពោះបានបីសប្តាហ៍ ហើយលោកគ្រូពេទ្យដែលយើងទៅពិនិត្យ សួរខ្ញុំថាចាញ់ខ្លាំងដែរទេ យើងបានរៀបចំថ្នាំឲ្យ ។

ក្រោយពីថ្នាំប៉ុន្មានច្រើនដែលបានទទួលហើយ ខ្ញុំក៏ត្រូវក្បាលសើចញឹមៗ មុននឹងនឹកឃើញ សុំថ្នាំបំបាត់អាការវិលមុខពីលោកគ្រូពេទ្យ អ្នកមានផ្ទៃពោះគឺខ្ញុំ តែអ្នកលេបថ្នាំគឺ គីនថាច់ ។

"ថ្នាំលែងបានហើយ"

សំឡេងថ្ងូរថ្ងូររបស់អ្នកដែលដេកលើគ្រែ ធ្វើឲ្យខ្ញុំដែលដុតទឹកហើយថ្មីៗងាកទៅមើល ។

"វិលមុខ"

គីនថាច់ អស់សភាពជាអ្នកចំនួញដែលពោរពេញទៅដោយសមត្ថភាព ។

គេពាក់ឈុតដេកជំងឺនៅលើគ្រែ ហើយក៏ដេកស្លូកលើពូក មុខសង្ហាដែលតែងតែពេញស្នាមញញឹមប្រឡឹមនោះ ពេលនេះកំពុងតែស្លេកស្លាំង ។

មិនឲ្យស្លេកគាំងយ៉ាងម៉េច ចុងពេលដែលគេស្ទួយគ្រប់យ៉ាង អាហារអ្វីក៏សឹងតែរាងមិនចុះ ញ៉ាំបានតែផ្លែឈើ ទឹកដោះគោ និងស៊ុបខ្ចប់ប៉ុណ្ណោះ អាការរបស់គេធ្ងន់ធ្ងរណាស់ ធ្ងន់ធ្ងរដល់ថ្នាក់

ទៅធ្វើការមិនកើតពីរបីថ្ងៃហើយ ។

"លេបថ្នាំហើយនៅ?"

ខ្ញុំសួរ ដោយដៃកាន់កន្សែងជូតសក់ដែលទើបកក់ហើយថ្មីៗ ហើយដើរទៅអង្គុយនៅលើគ្រែក្បែរគេ ។

យើងទាំងពីរស្នាក់នៅខុនដូរបស់ អ៊ីនចាច់ ហើយក៏ទៅដេកនៅផ្ទះរបស់គេថ្ងៃឈប់សម្រាក អំ...ពេលនេះម៉ាក់របស់ខ្ញុំទៅរស់នៅជាមួយម៉ាក់ក្មេកខ្ញុំហើយ ។

"លេបហើយ...តែមិនធូរសោះ ចង់តែក្អួតមិនឈប់"

"អឺម...អ៊ីចឹងទ្រាំបន្តិចទៅ សំណាងដែលគ្រាន់តែចាញ់កូនជំនួស បើត្រូវកើតជំនួសទៀត ពេលនោះបងនឹងយ៉ាប់ជាងនេះ" ខ្ញុំប្រាប់និងញញឹមដាក់គេ ។

អ៊ីនចាច់ ធ្វើឫកពាព្រឺសម្បុរ ពេលគិតដល់រឿងថាត្រូវឆ្លងទន្លេជំនួសខ្ញុំ គេក៏ងើបទាំងទឹកមុខហត់នឿយ ហើយក៏ឱបខ្ញុំ ។

"ពេលមនុស្សស្រីឆ្លងទន្លេឈឺចាប់ខ្លាំង ការពិតបើបងឆ្លងទន្លេជំនួសបាន ឈឺជំនួសអូនបាន បងក៏រីករាយ"

ខ្ញុំកំពុងតែញញឹមហើយ តែវាទាស់ត្រង់ប្រយោគបន្ទាប់របស់គេដែលនិយាយដោយទឹកមុខធម្មតា ។

"ព្រោះថាបងជាអ្នកយកចូលហ្នឹងណា៎ បងគួរតែជាអ្នកយកចេញដែរ មែនទេ?"

អាប្រុសឆ្កួតនេះ...ខ្ញុំធ្វើឡេមឡាមមុននឹងងើប តែក៏ត្រូវអ្នកដែលអង្គុយឱបពីក្រោយមិនព្រមលែង ។

"អ៊ីនចាច់ អូនយកកន្សែងទៅទុក..."

ធ្លុក...

កន្សែងក្នុងដៃរបស់ខ្ញុំប៉ើងទៅធ្លាក់លើកម្រាល ព្រោះថាគេដណ្ដើមហើយបោះចោលនោះឯង ហើយគេក៏រុញខ្ញុំឲ្យដេកនៅ

ក្រោមរាងកាយរបស់គេយ៉ាងរហ័ស នេះស្បថបានថាពីមុន តែកែវភ្នែកមុតស្រួចរបស់គេមានពន្លឺផ្លេកៗ ។

"ស្លឹកតើយ គិតថានៅក្នុងពោះអូនជា រ៉ាងនន ឬ រួត?"

"គ្មានទាំង រ៉ាងនន គ្មានទាំង រួត!" ខ្ញុំញញួញញ៉ាក់ "ឈប់មានគំនិតយកឈ្មោះពីរនោះមកប្រើបានហើយ គួរឲ្យស្អប់ណាស់"

"ហ៊ឺៗ" អ៊ីនចាច់ អស់សំណើច គេយកឈ្មោះតួៗនោះមកបង្អាប់ឲ្យខ្ញុំខឹង ។

"អ៊ីចឹងចង់ឲ្យកូនមានឈ្មោះអី?"

អ៊ីនចាច់ សួរ ព្រមទាំងវាសសក់ខ្ញុំចេញពីថ្ពាល់ ទាំងដែលទើបតែងូតទឹករួចថ្មីៗ ខ្លួននៅត្រជាក់ស្រួង ប៉ុន្តែត្រង់កន្លែងដែលត្រូវម្រាមដៃរបស់គេប៉ះ វាក្តៅកាយៗដូចដែលធ្លាប់អានក្នុងសៀវភៅបេះបិទ...អ្នកដែលមានផ្ទៃពោះខ្ចីខែ ប៉ះត្រង់ណាអរម៉ូនក៏ច្រាស់ច្រាល់ត្រង់នោះ ។

"អូន...ត្រូវដឹងសិនថាជាកូនស្រីឬកូនប្រុស"

ខ្ញុំតប ព្យាយាមពង្រឹងស្មារតី [illegible] ដែលកំពុងបេះបួយ ដោយមាន[illegible]របស់ខ្ញុំ ។ ទោះវាពិបាកក៏ដោយ ព្រោះថាពេលនេះគេកំពុងតែរកិល[illegible]របស់ ម្រាមដៃមករកកលំទ្រូងរបស់ខ្ញុំ ហើយប្រឡេះឡេវ[illegible] ខ្ញុំម្តងមួយគ្រាប់ៗ...

"បងមានវិធី ដឹងទេ ដែលដឹងថាកូនរបស់យើងជាស្រីឬប្រុស"

"វិធីអី?"

"គឺឲ្យបងចូលទៅក្នុងខ្លួនអូនពេលនេះ ហើយបងនឹងសួរកូនថាគេជាអី ល្អទេ?"

អ្នកដែលកំពុងតែរកិលម្រាមដៃទៅរកខ្លួងដើម្បីប្រឡេះឡេវអាវក្នុងរបស់ខ្ញុំ ប្រាប់ដោយសំឡេងស្អក ហើយពេលដែលអាវក្នុង

របស់ខ្ញុំរបួត គេក៏ចាញ់ពន្លឺភ្នែកផ្លេកៗ មើលវាដោយភាពល្ងក់វង្វេង ហើយបង្កើតមោទនភាពចំពោះខ្លួនឯងឲ្យខ្ញុំមិនតិចនោះទេ មានអ្នកណាខ្លះមិនចង់ក្លាយជាទីត្រូវការរបស់អ្នកដែលយើងស្រឡាញ់ទៅ ។

"វាធំជាងមុន" អ៊ីនចាច់ និយាយ មុននឹងវាស់ទំហំដោយដៃរបស់គេ ។

"រឿងស្អីមកវាស់ទំហំបែបនេះ លី អ៊ីនចាច់ យកប្រៀបរហូត រករឿងលូកលាន់ជារឿយៗ"

"ប្រពន្ធខ្លួនឯង ចាប់ដើមទ្រូងហៅថាលូកលាន់...អ៊ីចឹងឲ្យវាស់ទំហំរបស់បងវិញ វាស់ទេ នឹងបានស្មើគ្នា កុំឲ្យចាញ់ប្រៀប"

ហ៊ាននិយាយផង!

"មិនវាស់"

"ច្បាស់ហើយថាមិនវាស់ ?"

ខ្ញុំធ្វើភ្នែកឡេមឡាម ទាំងដែលខ្លួនឯងរង់ចាំឲ្យគេចាប់ផ្តើម តែ អ៊ីនចាច់ ដូចមើលដឹង គេញញឹមមើលខ្ញុំដូចរង់ចាំឲ្យខ្ញុំជាអ្នកសុំអង្វរករគេ ។

"លី អ៊ីនចាច់..."

ហើយអ្នកដែលចូលចិត្តលេងសើចធ្វើឲ្យខ្ញុំខ្មាសអៀនក៏អស់សំណើច គេឱនមកថើបបបូរមាត់ខ្ញុំថ្នមៗម្តងទៀត មុននឹងបន្ថែមទម្ងន់ ហើយចុងអណ្តាតក្តៅសើមនោះក៏ជ្រែកចូលក្នុងប្រអប់មាត់ ...ការថើបដ៏ក្តៅគគុក ដូចគ្នានឹងដៃរបស់ស្វាមីកំណាចដែលអង្អែលសព្វសាច់ ទោះទម្ងន់ដៃរបស់គេខ្លាំងៗ តែវាក៏មិនធ្វើឲ្យខ្ញុំឈឺចាប់ ផ្ទុយទៅវិញវាបែរជាធ្វើឲ្យខ្ញុំមានអារម្មណ៍ស្រៀវស្រើបនិងញាប់ញ័របំផុត ។

"ចូលចិត្តទេ ?"

"អឺម...ចូល...ចូលចិត្ត"

ខ្ញុំតបដោយសំឡេងញ័រចេញពីចិត្តស្មោះ ។

តាមពិតមិនថាគេប៉ះត្រង់ណា ក៏ខ្ញុំសឹងតែលោកដោយសារមាត់និងដៃរបស់គេទៅហើយ ប៉ុន្តែពេលនេះ ពេលរាងកាយរបស់ខ្ញុំប្រែប្រួលព្រោះអរម៉ូន វាក៏កាន់តែក្តៅគគុក...ខ្ញុំពត់ពេនរាងកាយនិងតើងដើមទ្រូងឲ្យគេបឺតជញ្ជក់ពេញទី ពេល អ៊ីនចាច់ អូសបបូរមាត់មករក ។

"អ៊ឺម..."

អណ្តាតនិងធ្មេញរបស់គេដែលរុសនឹងទ្រូងរបស់ខ្ញុំ ធ្វើឲ្យខ្ញុំខាំបបូរមាត់ទប់សំឡេងថ្ងួចថ្ងូរ ប៉ុន្តែ...

"..."

ចុងម្រាមដៃវែងមាំរបស់ អ៊ីនចាច់ លើកមកអង្អែលបបូរមាត់របស់ខ្ញុំ មុននឹងជ្រែកចូល ។

ហើយ...ទោះមិនដឹងថាគេត្រូវការអ្វី និងមិនចាំបាច់ឲ្យគេប្រាប់ ខ្ញុំបែរជាដឹងថាត្រូវជញ្ជក់ម្រាមដៃនោះ ហើយក៏បានឮសំឡេងរបស់ អ៊ីនចាច់ ថ្ងូរកាន់តែខ្លាំង ធ្វើឲ្យខ្ញុំដឹងថា...ខ្លួនឯងធ្វើត្រូវហើយ ចំណែកដៃខ្ញុំក៏ស្ទាបអង្អែល[illegible] ។

អ៊ីនចាច់ ងើបចេញពី[illegible] ពេលឈប់ខ្ញុំ [illegible] ច្បាស់នៅលើទឹក ដោយពន្លឺភ្នែកផ្លេកៗ [illegible] មុខរបស់ អ៊ីនចាច់ ។

"..." [illegible] រាងកាយសម្បុរបែបតាមចរិត

គេថើប[illegible] ធ្វើឲ្យខ្ញុំស្ទើរគ្រប់ពេល ។

របស់អ្នក[illegible] ជាពូកលោកខាងលិចនៅក្នុងខ្លួនពាក់ [illegible] ដឹងជាអ្វីធំតាមដៃ ខ្ញុំមានន័យ...ខ្ញុំមានន័យ

ដល់ស្មានិងដើមដៃ ។

"ស្លឹកតើយ"

គេហៅ មុននឹងលោមករកខ្ញុំម្តងទៀត ចំណែកដៃធំក្រាស់ក៏ស្ទាបអង្អែលជើងរបស់ខ្ញុំ ហើយរុញវាចេញពីគ្នា ។

បន្ទាប់ពីថើបបបូរមាត់និងទ្រូងរួច អ៊ីនថាច់ ក៏ប្តូរមកថើបភាពទន់ជ្រាយរបស់ខ្ញុំ ។

វាហាក់ដូចយើងឈរនៅលើទីខ្ពស់ ហើយធ្លាក់មកវិញលឿនដូចព្យុះ តែមិនប៉ះទង្គិចផ្ទៃដី ព្រោះថាគេត្រវែងខ្ញុំឡើងទៅលើម្តងទៀត...តែ...បែបនេះដដែលៗ ធ្វើឲ្យខ្លួនខ្ញុំញ័រនិងពត់ពេនដោយពិបាកនឹងទ្រាំ ។

"អ្ហ៎"

ភាពស្រៀវស្រើបដែល អ៊ីនថាច់ ប្រគល់ឲ្យ ធ្វើឲ្យខ្ញុំញ័រខ្លួនទទ្រើត ។ គេស្រវាឱបខ្ញុំ មើលមុខខ្ញុំនិងញញឹម ខ្ញុំក៏ប្រឹងបើកភ្នែកមើលគេ ហើយភ្លាមនោះរាងកាយដែលក្តៅគគុកនិងរឹងមាំរបស់គេក៏ជ្រែកចូលមកយ៉ាងរហ័ស តែទន់ភ្លន់ដូចត្រូវការថ្នាក់ថ្នមខ្ញុំ ។

យើងទាំងពីរដកដង្ហើមរួមគ្នា ខ្ញុំលើកដៃឱបករបស់គេ ខណៈដែល អ៊ីនថាច់ លូកដៃមកឱបចង្កេះ និងលើករាងកាយរបស់ខ្ញុំដើម្បីឲ្យទទួលយកកម្លាំងស្នេហ៍ពីគេ...ភាពទន់ភ្លន់ដែលបន្ថែមទម្ងន់ និងសំឡេងថ្ងូចថ្ងូររបស់ អ៊ីនថាច់ ធ្វើឲ្យខ្ញុំកាន់តែវេទនា ។

[Intouch's Talk]

"ស្លឹកតើយ"

ខ្ញុំហៅឈ្មោះរបស់នាង មនុស្សស្រីតែម្នាក់គត់ដែលខ្ញុំឱបចាប់ពីពេលនេះតទៅ ហើយក៏ខាំធ្មេញ ។

ខ្លួនប្រាណរបស់ ស្លឹកតើយ នៅតែក្រអូបផ្អែម និងក្តៅគគុក

មិនធ្លាប់ផ្លាស់ប្តូរ ទោះថ្ងៃក្រោយរាងកាយរបស់នាងផ្លាស់ប្តូរព្រោះមានកូនរបស់ខ្ញុំ ក៏ខ្ញុំគ្មានថ្ងៃឈប់ប្រាថ្នាខ្លួនប្រាណរបស់នាងដែរ ។

"អ៊ីនថាច់...អូនទ្រាំងលែងបានហើយ"

នាងប្រាប់ដោយសំឡេងស្អក មុននឹងឱបករបស់ខ្ញុំ ប្រាប់ឲ្យដឹងថានាងជិតទៅដល់គោលដៅដែលខ្ញុំនាំទៅហើយ ។

*បន្តិចទៀត អត់ធ្មត់ដើម្បីបងបន្តិចទៀត*...ខ្ញុំខាំបបូរមាត់ មុននឹងអង្អែលពោះរបស់នាងដែលមិនយូរនឹងរីកធំ តែ...ស្នេហារបស់ខ្ញុំក៏រីកតាមវាដែរ ។

"អ៊ីនថាច់...អ៊ឹម អូន...អូន"

"ដល់វាអូនសម្លាញ់ ទៅឲ្យដល់វាដើម្បីបង"

ខ្ញុំខ្សឹបប្រាប់ ហើយរាងកាយរបស់ ស្លឹកតើយ ក៏ញ័រទទ្រើត មុននឹងមានសំឡេងដ៏ស្រទន់ចេញពីបបូរមាត់របស់នាង *កែវភ្នែកដ៏ស្រទន់ប្រាប់ឲ្យដឹងថាអ្វីដែលខ្ញុំអង្វរករ នាងធ្វើបានហើយ* ។

"បងស្រឡាញ់អូន"

ខ្ញុំខ្សឹបប្រាប់ មុននឹង*តាមនាងជាប់ៗកិត ហើយក៏ទម្លាក់ខ្លួន*ឱបនាង ហាក់ដូចជាបើមិន*ធ្វើបែបនោះខ្ញុំនឹងដាច់ខ្យល់ ហើយ*ពេលដែលនឹកឃើញថាខ្ញុំ*អាចរស់ត្រឹមដល់ថ្ងៃនេះ ទើបរហ័សក្រឡាស់*ខ្លួនដេកក្បែរដោយទាញ*នាងឲ្យមកដេកកើយដៃ* ។

"អូនក៏ស្រឡាញ់*បងដែរ*" *ស្លឹកតើយ* ខ្សឹបប្រាប់ខ្ញុំយ៉ាងស្រទន់...គ្របកសំឡេង*របស់*...

ភ្នែករបស់ខ្ញុំ*ក៏ពិបាក* ។

*ចំណែក*[illegible]*វេទនាដោយសារការចាញ់កូនជំនួស*

*...ដើម្បីយើង* ។

នាង*...នេះ* បើខ្ញុំទទួលជំនួស និងធ្វើឲ្យស្រី*...* អាចរស់នៅបានធម្មតា មិនចាំបាច់ក្លត

ឬងគីតមុខ ស្អុយនេះស្អុយនោះដូចខ្ញុំ...ខ្ញុំក៏រីករាយ ។

[End Intouch's Talk]

**ពីរឆ្នាំក្រោយមក**

នៅក្នុងកម្មវិធីជប់លៀងជួបជុំមិត្តភក្តិរួមជំនាន់របស់មហាវិទ្យាល័យ ។

"ស្ទីកតើយ នោះ ស្ទីកតើយ មែនទេ ?"

សំឡេងហៅឈ្មោះនោះធ្វើឲ្យខ្ញុំងាកទៅមើល មុននឹងញញឹមដាក់មិត្តរួមផ្នែកដែលដើរមករក ។

មនុស្សស្រីដែលតុបតែងខ្លួនស្អាតម្នាក់នេះជាមិត្តរួមផ្នែកចំណែក គ្រាប់ត្នោត ដែលឈរក្បែរខ្ញុំក៏ជ្រឹមភ្នែកមើលអ្នកដែលរាក់ទាក់នោះដោយមិនទុកចិត្ត ។

"មីននី...ពីរឆ្នាំទៅហើយនៅតែធ្វើឫកដូចស្រីមិនដឹងខ្យល់អីដដែល"

ខ្ញុំងាកទៅមើលមិត្តភក្តិដោយនឹកអស់សំណើច ។

"តិចគេឮទៅ"

មាត់ហាម តែចិត្តក៏យល់ស្រប...មីននី មិត្តរួមផ្នែកម្នាក់នេះខ្ញុំស្គាល់ច្បាស់ ព្រោះជាក្រៅពីជាមិត្តភក្តិហើយ មីននី ក៏ប្រគល់តំណែងមួយទៀតឲ្យខ្ញុំដែរ នោះគឺគូប្រជែង ។

មីននី ជាកូនស្រីអ្នកមាន ដំបូងយើងជាមិត្តភក្តិនៅក្នុងក្រុម តែពេលដែលខ្ញុំបានតំណែងជា Drum Mayer នាងក៏នាំខ្លួនឯងចេញពីក្រុមដែលមានខ្ញុំ គ្រាប់ត្នោត និង ក្តាមខ្មៅ ទៅសេពគប់មិត្តភក្តិដទៃទៀត ហើយបន្ទាប់ពីនោះមកក្រុមរបស់ មីននី ក៏ចេះតែតាមជៀមដាម និងរករឿងបង្កបញ្ហាជាមួយខ្ញុំរហូត ។

មីននី រៀនចប់ហើយក៏ទៅបន្តអនុបណ្ឌិតនៅបរទេស យើង



មិនធ្លាប់ជួបគ្នាទៀត ចាំទៅបើខ្ញុំមិនត្រូវ គ្រាប់ត្នោត អូសទាញឲ្យមកចូលរួមកម្មវិធីជប់លៀងនៅហាងនេះ ខ្ញុំអាចដេកមើលការប្រកួតបាល់ទាត់ឲ្យរំភើយទៅហើយ ។

"ខានជួបគ្នាយូរហើយ ស្ទីកតើយ"

"ចាំ តឺ...ពីរឆ្នាំហើយទេដឹង"

"មែន តាំងពីខ្ញុំទៅប៉ារីសរៀនបន្ត យើងក៏ខានជួបគ្នាទៀត ខ្ញុំមិនសូវបានខាំបែកកូរ៉េទេ"

ខ្ញុំញញឹមដាក់ ពេលវេលាកន្លងផុតទៅយូរហើយ អ្នកដទៃទៀតនៅក្នុងក្រុមរបស់ មីននី ក៏ខ្ញុំជួបនៅក្នុងកម្មវិធីនេះ គ្រប់គ្នាមានក្រុមគ្រួសារ មានជីវិតជាមនុស្សធំ គ្មានអ្នកណាប្រកែប្រកាន់រឿងកាលនៅរៀន ក្រៅពីចងចាំតែរឿងសប្បាយៗប៉ុណ្ណោះ ។

"ឮថានាងរៀបការភ្លាមពេលដែលរៀនចប់ឬ ?"

"ចាំ" ខ្ញុំតប ។

"មិនទាន់បានធ្វើការ មិនទាន់បានប្រើជំនាញដែលខំរៀនសូត្រផង ក៏រៀបការក្លាយជាមេផ្ទះទៅហើយ យ៉ាប់មែន"

យ៉ាប់ត្រង់ណា..ខ្ញុំលើកចិញ្ចើមមើលអ្នកញញឹមស្រស់ ហើយក៏ឧទាន អំ! នៅក្នុងចិត្ត នាងព្រមក់នេះក្រៅពីញញឹមធ្វើដូចមិនដឹងខ្យល់អី ទាំងដែលអាយុជិត៣០នៅ៥-៦ឆ្នាំខាងមុខទៅហើយ តែនាងនៅតែជា មីននី កាលពីមុនដែលចូលចិត្តរករឿងខ្ញុំ ។

"គួរតែរៀនបន្តអនុបណ្ឌិត មិនចាំបាច់រង់ចាំរៀនបន្តបណ្ឌិត ដូចខ្ញុំក៏បាន គ្រាន់តែយកអនុបណ្ឌិតឲ្យវាមើលទៅ High-Class ជាងនេះបន្តិច"

មើលមាត់នាង!

មីននី ក្នុងកម្មវិធីនេះ មិត្តភក្តិរួមក្រុមយើងជាងពាក់កណ្តាល គ្មានអ្នកណារៀនចប់អនុបណ្ឌិតនោះទេ តែក៏មានមិនប៉ុន្មាននាក់

ប៊ុណ្ណោះដែល Low-Class"

"ហើយ...ជីវិតជាមេផ្ទះយ៉ាងម៉េចដែរ ខ្ញុំខានមកក្លូបយូរ មេផ្ទះនៅតែត្រូវបោកខោអាវ ដាំបាយ ចិញ្ចឹមកូន ហើយក៏រង់ចាំប្រាក់ខែពីប្តីឬអត់ នាងបែបហ្នឹងដែរទេ ?"

"មីននី នាងនេះនៅតែដូចមុន"

គ្រាប់ត្នោត អត់មិនបាននឹងជៀមជាមខ្លះ តែ មីននី ក៏នៅតែញញឹមស្លាតដាក់ ។

"អរគុណ គឺមានតែអ្នកប្រាប់ថា ខ្ញុំមើលទៅនៅក្មេងដូចមុនជានិច្ច"

"មិនមែនទេ ខ្ញុំមានន័យដល់មាត់ដាចរបស់នាង"

មីននី ធ្វើមុខក្រញូវ ដើរចេញពីយើងសំដៅទៅក្រុមមិត្តភក្តិដែលនាងធ្លាប់ស្និទ្ធស្នាលភ្លាម ចំណែកខ្ញុំក៏គ្រវីក្បាលរអាចិត្ត ហើយក៏ញញឹមដាក់ គ្រាប់ត្នោត ។

"នាងនោះនៅតែចងអាឃាតឯងមិនផ្លាស់ប្តូរ"

ក្លាមខ្មៅ ប្រាប់ ហើយក៏លើកទឹកផ្លែឈើក្រេប ព្រមទាំងពេបមាត់ ។

"ម៉េចក៏មិនប្រាប់ទៅថាឯងមិនមែនជាមេផ្ទះដូចនាងនោះនិយាយ ស្លឹកតើយ ប្រាប់ទៅថាឯងជាប្រពន្ធរបស់អ្នកណា"

ខ្ញុំអស់សំណើចនឹងអាកប្បកិរិយារបស់មិត្តភក្តិ ហើយក៏គ្រវីក្បាលមិនលេងចូលជាមួយ ។

"ខ្ញុំមិនឆ្កួតតាមស្រីអន់ខួរនោះទេ ឈប់ពន្យុះទៅ ទៅរកអីញ៉ាំល្អជាង"

ណ្ហើយ...កម្មវិធីជប់លៀងមិត្តរួមជំនាន់នេះ តិចទៀតអាចនឹងសប្បាយជាងនេះ យ៉ាងហោចណាស់ក៏សប្បាយឲ្យសមនឹងការដែលខ្ញុំសុខចិត្តទុកហ្មិតបលព្រាមៀលិត និង **អ្នកនៅផ្ទះ** បោល ។



ខ្ញុំ គ្រាប់ត្នោត និង ក្លាមខ្មៅ ជ្រើសរើសតុដែលនៅជិតកន្លែងដាក់អាហារប៊ូហ្វេ ព្រោះ គ្រាប់ត្នោត ប្រាប់ថាវាជួយសន្សំសំចៃពេលវេលានៅក្នុងការដើរហើរ និងសន្សំសំចៃថាមពលដែរពេលដែលទទួលទានអាហារ ។

យើងទាំងបីបានជួបមិត្តជាច្រើន ខ្ញុំកំពុងតែសប្បាយសោះតែសុខៗ មីននី ក៏ដើរមករកតុរបស់ពួកយើងធ្វើព្រងើយ ( តាមពិតចង់ប្រើពាក្យថាមុខក្រាស់ ) តែលើកនេះនាងឱបដៃអ្នកណាម្នាក់មកជាមួយ ជាមនុស្សប្រុសភ្នែកលឹបដែលយើងមិនធ្លាប់ស្គាល់ ហើយជឿជាក់ថាមិនមែនជាមិត្តភក្តិរួមថ្នាក់ ។

ចង់ធ្វើស្អីទៀតហើយ...ខ្ញុំប្រសព្វភ្នែកជាមួយមិត្តសម្លាញ់ទាំងពីរ មុខរបស់ខ្ញុំប្រហែលជាប្រាប់ឲ្យដឹងថាអាក់ខ្លាំងណាស់ ។

"ស្រីៗ ខ្ញុំចង់ឲ្យពួកនាងស្គាល់ ស៊ុងជូ សង្សាររបស់ខ្ញុំ"

មានសួរអត់ថាខ្ញុំចង់ស្គាល់ដែរទេ ?

ខ្ញុំដកដង្ហើមធំ មុននឹងញញឹមដាក់កំលោះភ្នែកលឹប ដែលមើលទៅមានចរិតល្អម្នាក់នោះ ។

"គ្រាប់ត្នោត នាងធ្វើការនៅក្រុមហ៊ុនអី...សម្លាញ់អូនក្រូនិចមែនទេ សាកពិភាក្សាជាមួយ ស៊ុងជូ មើល៍ គេជាឈ្មួញ( Broker ) ក្រែងលោណែនាំឲ្យនាងបានលេងហ៊ុន មិនចាំបាច់ហត់នឿយធ្វើការស៊ីប្រាក់ខែតិចតួច"

ស្បថបានថាខ្ញុំឃើញ គ្រាប់ត្នោត ធ្វើមាត់អេចអូច តែព្រោះមារយាទ ហើយមិត្តរួមក្រុមផ្សេងទៀតក៏មានច្រើន ទើបនាងរក្សាឫកពា

ចំណែក ក្លាមខ្មៅ ក៏ឆេបមាត់ដាក់ក្លាយ ។

"ខ្ញុំមិនលេងហ៊ុនទេ តែអរគុណដែលណែនាំ" ក្លាមខ្មៅ ប្រាប់ដូច្នេះ ។

ខ្ញុំកាន់ក្រឡេចមើលពេល មីននី រៀបរាប់ពីគុណសម្បត្តិរបស់សង្សារ

ម្តងមួយចំណុចៗ ។

នាងព្រមក់នេះទៅរៀនជំនាញរំអុករំខានអ្នកដទៃនៅស្រុកក្រៅ និងជំនាញបង្កើតភាពជិនឆ្អន់និងគួរឲ្យធុញទ្រាន់មែនទេ?

គ្រាប់ត្នោត មើលខ្ញុំដោយខ្សែភ្នែកដាក់សម្លាធ ពេល មិននី រៀបរាប់ប្រវត្តិត្រកូលរបស់សង្សារ ដែលរៀបរាប់ដល់ទៅ៤០ជំនាន់ ជាមន្ត្រីប្រភេទថា...ឈប់សិន!

"..."

ង៉ែ!

ខ្ញុំមិនចង់ធ្វើហ្នឹងណា៎ ខ្ញុំដឹងថា គ្រាប់ត្នោត ចង់ឲ្យខ្ញុំធ្វើអី ។

"នាងគួរតែបបួលប្តីនាងម៉ោដែរ ស្លឹកតើយ"

មិត្តភក្តិដែលព្យាយាមតំរាមមិត្តភក្តិ ដល់ថ្នាក់មិនគួរហៅខ្លួនឯងជាមិត្តភក្តិនិយាយ ដូចបើកចន្លោះប្រហោងឲ្យ គ្រាប់ត្នោត ។

"មែន តែថា ស្លឹកតើយ ជិតទៅវិញហើយ ខ្លាចកូនយំងរង់ក់ តែហៅប្តីឲ្យមកទទួលទៅ ស្លឹកតើយ មិនតេ...អាំ អីចឹងមិនអីទេ ចាំខ្ញុំតេឲ្យ"

គ្រាប់ត្នោត ទាញទូរសព្ទដៃចេញមក ហើយញញឹមមិចភ្នែកដាក់ខ្ញុំ ធ្វើជាមិនឃើញការសម្លក់សម្លឹងរបស់ខ្ញុំ ចំណែក មីននី ក៏ញញឹមមើលមុខខ្ញុំដែរ ។

"ហាឡូ បង អ៊ីនថាច់ ឬ ខ្ញុំ គ្រាប់ត្នោត បងមកទទួល អាំ...អីមកទទួល ស្លឹកតើយ បន្តិច នាងចង់ទៅវិញហើយ មែន ចាំ...នៅហាង...ចាំ មែន អូខេ ចាយៗ"

គ្រាប់ត្នោត ដាក់ទូរសព្ទចុះ ព្រមទាំងញញឹមញញែម...អឹម សប្បាយចិត្តក៏ធ្វើទៅ...ខ្ញុំធ្វើភ្នែកឡេមឡាម ចំណែក មីននី នៅតែមិនឈប់បូរបាច់ អាម្សៀសង្សារនាងក៏ត្រូវជើងគ្នា គិតតែប្រ៉ូដល់ថ្នាក់មិនចម្លែកចិត្តទេថាហេតុអីទើបសេពគប់គ្នាបាន ។

"ប្តីនាងព្រមកដល់ហើយ ឡានក្រុងជិតអស់ជើងហើយ"

គ្រាប់ចុងក្រោយដែលបាញ់មកនោះ ធ្វើឲ្យ គ្រាប់ត្នោត និងក្លាមខ្មៅ បើកភ្នែកសឹងតែលៀន ។

ចំណែកខ្ញុំ...ចង់ប្រាប់ថាមិនខឹងៗ!

"ស្លឹកតើយ"

សំឡេងហៅឈ្មោះរបស់ខ្ញុំ ធ្វើឲ្យគ្រប់គ្នាដែលអង្គុយរួមតុងាកទៅមើល ។

នោះអី! នៅត្រង់មាត់ទ្វារហាង ទាំងដែលមានសំឡេងតន្ត្រី និងសំឡេងនិយាយគ្នាចេចចាចរបស់មិត្តភក្តិ តែសំឡេងរបស់មនុស្សប្រុសខ្ពស់ស្រឡះខុសពីមាត្រដ្ឋានកូរ៉េ និងមានមុខសង្ហាខ្លាំងដែលឈរនៅត្រង់នោះ ធ្វើឲ្យគ្រប់គ្នាងាកទៅមើល ។

"លោកប្តី ខាងនេះ" ខ្ញុំលើកដៃគ្រវីដាក់ ធ្វើឲ្យគ្រប់គ្នាងាកមកមើល ហើយខ្ញុំក៏ញញឹមដាក់គ្រប់គ្នា ធ្វើដូចគ្មានអីកើតឡើង ។

អឹម គឺដឹងថាប្តីសង្ហាខ្លាំង តែមិនស្មានថាអាចបញ្ឈប់គ្រប់គ្នាបានដល់ថ្នាក់នេះ ។

"បងមកយកអូន"

គេដើរមករកខ្ញុំ ហើយញញឹមដាក់ ស្នាមញញឹមដែលខ្ញុំដឹងពីអានុភាពរបស់វាច្បាស់...ឃើញទេ ហ្នឹងអី ខ្ញុំផៀងភ្នែកមើលស្រីៗគ្រប់គ្នាដែលមុខឡើងក្រហមភាមមើល អ៊ីនថាច់ សូម្បីតែ មីននី ក៏ចំហមាត់ផ្លូងដែរ ។

"សូមទោសផងអ្នកទាំងអស់គ្នា ខ្ញុំសុំទៅមុនហើយ ស្វាមីមកទទួល"

"ស្វា...ស្វាមី"

"ចាំ មីននី នេះស្វាមីខ្ញុំ លី អ៊ីនថាច់"

"លី អ៊ីនថាច់ ជាលោកពិតមែន លោក លី ខ្ញុំគិតអីចេះខុស"

គូស្នេហ៍របស់ មីននី មើលស្វាមីខ្ញុំដោយទឹកមុខញញឹមញញែមនិង សប្បាយចិត្ត "នេះនាមប័ណ្ណខ្ញុំ សង្ឃឹមខ្លាំងថានឹងបានបម្រើ"

"..." អ៊ីនថាច់ លើកចិញ្ចើមទទួលយក ហើយក៏ហុចឲ្យខ្ញុំទុក "បាទ"

ខ្ញុំមើល មីននី ហើយញញឹមពព្រាយ ទាំងដែលចិត្តចង់ស្រែក ប្រាប់ថា ម៉េចដែរ...វ៉ាហាហា!

"តោះទៅ ស្លឹកតើយ បងចតឡាននៅកន្លែងហាមចត តិចត្រូវ ដោះកង់"

"មែនហើយ ទៅៗ ស្លឹកតើយ Lamborghini ត្រូវដោះកង់វា មិនឡូយទេ"

ក្តាមខ្មៅ ប្រាប់ដោយសំឡេងស្រួចរលែម ចំណែក មីននី វិញ មិនចាំបាច់និយាយដល់ មុខរបស់ស្លេកទៅហើយ ធ្វើមាត់មួបៗ ត្រង់ពាក្យថា Lamborghini ។

ខ្ញុំឃើញខ្សែភ្នែករបស់ គ្រាប់ត្នោត និង ក្តាមខ្មៅ ហើយ ក៏ មើលដឹងថា...សមចិត្តខ្លាំង ហើយក៏អត់អស់សំណើចមិនបាន ។

"សុំទៅមុនសិនហើយអ្នកទាំងអស់គ្នា"

ខ្ញុំលា ហើយក៏ដើរតាមការដឹកដៃរបស់ស្វាមីសែនសង្ហាចេញ ពីហាង ។

យើងដើរមិនទាន់ដល់ឡានផង ខ្ញុំក៏អស់សំណើចខឹកៗ អស់ សំណើចនឹងទឹកមុខរបស់ មីននី ។

"សើចអី?"

"គ្មានទេលោកប្តី ចុះកូន ដេកលក់ហើយឬ?"

"លោកយាយទាំងពីរមកយកទៅបាត់ហើយ"

ខ្ញុំញញឹមពេលដែលនឹកដល់មុខស្រទន់របស់កូនស្រីវ័យមួយ ឆ្នាំជាង ។

"អីចឹងយើងឆាប់ទៅ ខ្លាចមិនទាន់បាល់"

អ៊ីនថាច់ លើកចិញ្ចើម ហើយក៏ដឹកដៃខ្ញុំដើរសំដៅឡាននៅ មុខហាង បន្ទាប់មកក៏ញញឹមលាក់កំណួចពេលដែលបើកទ្វារឡាន ឲ្យខ្ញុំចូលអង្គុយ ។

ស្នាមញញឹមនោះធ្វើឲ្យបេះដូងរបស់ខ្ញុំលោតញាប់ ទោះពេល វេលាកន្លងផុតទៅពីរឆ្នាំហើយក៏ដោយ ចាប់តាំងពីយើងរៀបការ ជាមួយគ្នា ។

"ភ្នាល់គ្នាទេ ក្រុមណាឈ្នះ"

"ភ្នាល់ដាក់អី?" ខ្ញុំសួរ ។

ស្នាមញញឹមត្រង់តែមមាត់របស់ស្វាមីកំណាចនិងប៉ិនដាក់ ផែនការ ធ្វើឲ្យដឹងថានេះមិនមែនជាការភ្នាល់ធម្មតាៗនោះទេ ។

"បើសិនក្រុមដែលបងគាំទ្រឈ្នះ យប់នេះអូនត្រូវឲ្យបងស៊ុត បញ្ចូលទីបីគ្រាប់ ម៉េចដែរ?"

ឃើញទេ...ខ្ញុំគិតអីចេះខុស!

"ចុះបើក្រុមអូនឈ្នះ?"

"បងឲ្យអូនស៊ុតបញ្ចូលទីវិញ"

ចាំ...យុត្តិធម៌ណាស់...ខ្ញុំធ្វើភ្នែកឡេមឡាម មុននឹងញញឹម ដាក់គេ ។

អ៊ីនថាច់ ដើរវាងមុខឡានទៅខាងអ្នកបើក ហើយក៏បើកឡាន ចេញទៅ ដោយដៃម្ខាងកាន់ចង្កូតឡាន ចំណែកដៃម្ខាងទៀតចាប់ ដៃរបស់ខ្ញុំដាក់លើភ្លៅរបស់គេ ដូចចង់ផ្ទេរក្តីស្រឡាញ់និងការព្រួយ បារម្ភឲ្យខ្ញុំដូចពេលកន្លងមក ។

ហើយខ្ញុំដឹងច្បាស់ថា គេនឹងស្រឡាញ់ខ្ញុំបែបនេះតាមពាក្យ សន្យា ចាប់ពីពេលនេះនិងជារៀងរហូតទៅ ។

ដូចគ្នានឹងខ្ញុំដែលផ្អែកក្បាលនឹងស្មារបស់គេ ហើយខ្សឹបប្រាប់

ជាស្រឡាញ់គេម្ដងទៀត មុននឹងបិទភ្នែកពេលស្វាមីកំណាចតបតមកវិញ ។

"បងស្រឡាញ់អូន..."

(ចប់ដោយបរិបូណ៌)

05-06-2016

Orkun Paoun Srey

www.srolanhkhmer.com